ED-2016/WS/33
Phnom Penh, November 2016
Original: English



សង្ខេបរបាយការណ៍ពិនិត្យតាមដានស្ថានភាពនៃការអប់រំទូទាំងសកលលោក

២០១៦

# ការអប់រំសម្រាប់មនុស្ស និងផែនដី៖

## បង្កើតអនាគតប្រកបដោយចីរភាព សម្រាប់ទាំងអស់គ្នា

United Nations
Educational, Scientific and
Cultural Organization

Sustainable
Development
Goals

Global
Education
Monitoring
Report

សង្ខេបរបាយការណ៍ពិនិត្យតាមដានស្ថានភាពនៃការអប់រំទូទាំងសកលលោក

២០១៦

# ការអប់រំសម្រាប់មនុស្ស និងផែនដី៖

បង្កើតអនាគតប្រកបដោយចីរភាព សម្រាប់ទាំងអស់គ្នា

របាយការណ៍នេះគឺជាឯកសារបោះពុម្ពផ្សាយឯករាជ្យ រៀបចំឡើងដោយយូណេស្កូ ក្នុងនាមតំណាងឲ្យសហគមន៍អន្តរជាតិ។ របាយការណ៍នេះគឺជាសមិទ្ធផលនៃការសហការគ្នារបស់សមាជិកក្រុមរៀបចំរបាយការណ៍ រួមជាមួយនឹងបុគ្គល ទីភ្នាក់ងារ ស្ថាប័ន និងរដ្ឋាភិបាលជាច្រើនផ្សេងទៀត។

ឈ្មោះតួនាទីដែលប្រើប្រាស់ និងការបង្ហាញពីព័ត៌មាននានាក្នុងឯកសារបោះពុម្ពផ្សាយនេះ ពុំមានន័យថាជាការបង្ហាញពីគំនិតយល់ឃើញអ្វីមួយរបស់យូណេស្កូ ជុំវិញស្ថានភាពស្របច្បាប់របស់ប្រទេស ដែនដី ទីក្រុងឬតំបន់ណាមួយ ឬរបស់សមត្ថកិច្ចរបស់ប្រទេស ដែនដី ទីក្រុងឬតំបន់នេះ ឬការកំណត់ព្រំប្រទល់ដែនរបស់ប្រទេស ដែនដី ទីក្រុងឬតំបន់នេះឡើយ។

ក្រុមរៀបចំរបាយការណ៍ពិនិត្យតាមដានស្ថានភាពនៃការអប់រំទូទាំងសកលលោក ជាអ្នកទទួលខុសត្រូវលើការជ្រើសរើសព័ត៌មាន ដើម្បីយកមកបង្ហាញក្នុងរបាយការណ៍នេះ ហើយក៏ជាអ្នកទទួលខុសត្រូវលើគំនិតយោបល់នានាដែលបង្ហាញក្នុងរបាយការណ៍នេះផងដែរ ពោលគឺគំនិតយោបល់ទាំងនេះមិនមែនជាគំនិតយោបល់របស់យូណេស្កូ ហើយក៏មិនមែនជាសន្យាធ្វើសកម្មភាពអ្វីមួយរបស់អង្គការនេះដែរ។

ការទទួលខុសត្រូវជារួមលើទស្សនៈ និងគំនិតយោបល់នានា ដែលបង្ហាញក្នុងរបាយការណ៍នេះ គឺជាការទទួលខុសត្រូវរបស់ប្រធានក្រុមរៀបចំរបាយការណ៍នេះ។

**ក្រុមរៀបចំរបាយការណ៍ពិនិត្យតាមដានស្ថានភាពនៃការអប់រំទូទាំងសកលលោក**
**ប្រធានក្រុម ៖** Aaron Benavot
Manos Antoninis, Madeleine Barry, Nicole Bella, Nihan Köseleci Blanchy, Marcos Delprato, Glen Hertelendy, Catherine Jere, Priyadarshani Joshi, Katarzyna Kubacka, Leila Loupis, Kassiani Lythrangomitis, Alasdair McWilliam, Anissa Mechtar, Branwen Millar, Claudine Mukizwa, Yuki Murakami, Taya Louise Owens, Judith Randrianatoavina, Kate Redman, Maria Rojnov, Anna Ewa Ruszkiewicz, Will Smith, Emily Subden, Rosa Vidarte និង Asma Zubairi.

របាយការណ៍ពិនិត្យតាមដានស្ថានភាពនៃការអប់រំទូទាំងសកលលោកគឺជាការបោះពុម្ពផ្សាយឯករាជ្យដែលធ្វើឡើងប្រចាំឆ្នាំ។ ការរៀបចំ និងការបោះពុម្ពផ្សាយរបាយការណ៍នេះ ធ្វើឡើង ដោយមានការឧបត្ថម្ភថវិកាពីក្រុមរដ្ឋាភិបាល ទីភ្នាក់ងារពហុភាគី និងមូលនិធិឯកជន ក្រោមការសម្របសម្រួល និងគាំទ្រពីយូណេស្កូ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖ ក្រុមរៀបចំរបាយការណ៍ពិនិត្យតាមដានស្ថានភាព នៃការអប់រំទូទាំងសកលលោក
អង្គការយូណេស្កូ អាសយដ្ឋាន 7, place de Fontenoy
75352 Paris 07 SP, France
អ៊ីមែល៖ gemreport@unesco.org
ទូរស័ព្ទ៖ +33 1 45 68 07 41
www.unesco.org/gemreport
https://gemreportunesco.wordpress.com

រាល់កំហុស ឬការខ្វះព័ត៌មាន ដែលរកឃើញក្រោយពេលបោះពុម្ពនឹងត្រូវកែតម្រូវក្នុងសំណៅអនឡាញ នៃឯកសារនេះ ដែលអាចរកបានតាមរយៈគេហទំព័រ
www.unesco.org/gemreport

© UNESCO, 2016

របាយការណ៍ពិនិត្យតាមដានស្ថានភាពនៃការអប់រំទូទាំងសកលលោក ចុងក្រោយ
២០១៦ ការអប់រំ សម្រាប់មនុស្ស និងផែនដី៖ បង្កើតអនាគតប្រកបដោយនិរន្តរភាព សម្រាប់ទាំងអស់គ្នា

របាយការណ៍ពិនិត្យតាមដានទូទាំង សកលលោកសម្រាប់ការអប់រំសម្រាប់ទាំងអស់គ្នា
២០១៥ ការអប់រំសម្រាប់ទាំងអស់គ្នា ២០០០-២០១៥៖ សមិទ្ធផលសម្រេចបាន និងបញ្ហាប្រឈម
២០១៣/៤ ការបង្រៀន និងរៀន៖ សម្រេចឲ្យបាននូវគុណភាពសម្រាប់ទាំងអស់គ្នា
២០១២ យុវជន និងជំនាញ៖ ប្រែក្លាយការអប់រំជាការបំពេញការងារ
២០១១ វិបត្តិលាក់មុខ៖ ជម្លោះប្រដាប់អាវុធ និងការអប់រំ
២០១០ ការផ្តល់សេវាដល់ក្រុមដែលពុំមានឱកាស
២០០៩ ការជំនះវិសមភាព៖ ហេតុអ្វីបានជាអភិបាលកិច្ចមានសារៈសំខាន់

រក្សាសិទ្ធិគ្រប់បែបយ៉ាង
កំណែទីមួយ
បោះពុម្ពផ្សាយក្នុងឆ្នាំ ២០១៦ ដោយអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ
7, Place de Fontenoy, 75352
Paris 07 SP, France

វាយអត្ថបទដោយយូណេស្កូ
រចនាក្រាហ្វិចដោយ FHI 360
រចនាសម្រាប់បោះពុម្ពដោយ FHI 360
គំនូរជីវចលដោយ Toby Morris

២០០៨ ការអប់រំសម្រាប់ទាំងអស់គ្នាត្រឹមឆ្នាំ២០១៥៖តើយើងអាចសម្រេចវាបានដែរឬទេ?
២០០៧ មូលដ្ឋានរឹងមាំ៖ ការគាំពារ និងអប់រំកុមារតូច
២០០៦ អក្ខរកម្ម ដើម្បីជីវិត
២០០៥ ការអប់រំសម្រាប់ទាំងអស់គ្នា៖ គុណភាពដែលចាំបាច់ត្រូវមាន
២០០៣/៤ យេនឌ័រ និងការអប់រំសម្រាប់ទាំងអស់គ្នា៖ ការបោះជំហានទៅរកសមភាព
២០០២ ការអប់រំសម្រាប់ទាំងអស់គ្នា៖ តើពិភពលោកស្ថិតតាមផែនការដែលបានគ្រោងទុកដែរឬទេ?

រូបថតគ្របមុខ និងគ្របក្រោយ៖
Fadil Aziz/Alcibbum Photography
រូបថតគ្របមុខ បង្ហាញពីសិស្សលើកោះ Palau Papan ដែលស្ថិតក្នុងប្រជុំកោះ Togean នៅស៊ូឡាវេស៊ី ឥណ្ឌូនេស៊ី។ កុមារទាំងនេះមកពីកុលសម្ព័ន្ធ Bajo រស់នៅលើផ្ទះដែលមានសសរខ្ពស់ៗ និងត្រូវឆ្លងស្ពានចំងាយ ១,៨ គីឡូម៉ែត្រ ទៅកាន់កោះ Melange ដែលនៅជិតនោះ ដើម្បីទៅសាលារៀនរាល់ថ្ងៃ។

# អារម្ភកថា

កាលពីខែ ឧសភា ឆ្នាំ ២០១៥ វេទិកាអប់រំពិភពលោក ក្នុងទីក្រុងអ៊ីនឈ័ន (សាធារណរដ្ឋកូរ៉េ) ត្រូវបានរៀបចំឡើង ដោយមានអ្នកចូលរួម ១៦០០ នាក់ មកពី ១៦០ ប្រទេស ដោយផ្តោតលើគោលដៅតែមួយគត់នោះគឺៈ ត្រូវធ្វើយ៉ាងណា ដើម្បីធានាឲ្យមានការអប់រំប្រកបដោយបរិយាប័ន្ន សមធម៌ និងគុណភាព និងការរៀនសូត្រពេញមួយជីវិត សម្រាប់ទាំងអស់គ្នា ត្រឹមឆ្នាំ ២០៣០?

សេចក្តីប្រកាសអ៊ីនឈ័នស្តីពីការអប់រំឆ្នាំ២០៣០មានតួនាទីសំខាន់ជាមូលដ្ឋានសម្រាប់ការរៀបចំគោលដៅអប់រំនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG ) ដើម្បី "ធានាឲ្យមានការអប់រំប្រកបដោយបរិយាប័ន្ន សមធម៌ និងគុណភាព និងលើកកម្ពស់ឱកាសរៀនសូត្រពេញមួយជីវិត សម្រាប់ទាំងអស់គ្នា"។

សេចក្តីប្រកាសនេះបានប្រគល់ភារកិច្ចឲ្យយូណេស្កូធ្វើការដឹកនាំ សម្របសម្រួល និងពិនិត្យតាមដានលើរបៀបវារៈអប់រំឆ្នាំ ២០៣០។ សេចក្តីប្រកាសនេះក៏បានអំពាវនាវឲ្យមានការរៀបចំរបាយការណ៍ពិនិត្យតាមដានស្ថានភាពអប់រំទូទាំងសកលលោក ដើម្បីធ្វើការពិនិត្យតាមដាននិងរាយការណ៍ដោយឯករាជ្យលើការសម្រេចគោលដៅទី៤ស្តីពីការអប់រំ(SDG4)នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក៏ដូចជាលើការងារអប់រំ ដែលត្រូវបានបញ្ចូលក្នុងគោលដៅ SDGs ផ្សេងទៀត ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខនេះ។

គោលដៅចុងក្រោយនៃរបៀបវារៈនេះ គឺមិនត្រូវទុកអ្នកណាម្នាក់ចោល។ គោលដៅនេះអំពាវនាវឲ្យមានការប្រមូលទិន្នន័យ និងពិនិត្យតាមដានឲ្យបានត្រឹមត្រូវ។ របាយការណ៍ពិនិត្យតាមដានលើស្ថានភាពអប់រំទូទាំងសកលលោកឆ្នាំ ២០១៦ នេះ ផ្តល់នូវព័ត៌មានវិភាគស៊ីជម្រៅដ៏មានតម្លៃ ដល់រដ្ឋាភិបាល និងអ្នកតាក់តែងគោលនយោបាយនានា សម្រាប់ធ្វើការពិនិត្យតាមដាន និងពន្លឿនវឌ្ឍនភាពឆ្ពោះទៅសម្រេចគោលដៅ SDG ទី ៤ ដោយប្រើប្រាស់សូចនាករ និងចំណុចដៅ ដែលយើងមាន ដោយសមធម៌ និងបរិយាប័ន្ន គឺជារង្វាស់សម្រាប់វាស់វែងជោគជ័យដែលសម្រេចបានជារួម។

**របាយការណ៍នេះបង្ហាញយ៉ាងច្បាស់នូវសារចំនួនបី។**

ទីមួយ ភាពចាំបាច់ជាបន្ទាន់នៃការប្រើប្រាស់វិធីសាស្រ្តថ្មីៗ។ បើតាមនិន្នាការបច្ចុប្បន្ននេះ ក្នុងចំណោមកុមារទាំងអស់ដែលរស់នៅក្នុងប្រទេសដែលមានចំណូលទាប មានតែ ៧០% ប៉ុណ្ណោះ ដែលនឹងរៀនចប់បឋមសិក្សា ក្នុងឆ្នាំ ២០៣០ ដែលនេះជាគោលដៅដែលគួរតែសម្រេចបាន តាំងតែពីឆ្នាំ ២០១៥ មកម្ល៉េះ។ យើងត្រូវការឆន្ទៈនយោបាយ គោលនយោបាយ គំនិតច្នៃប្រឌិតថ្មី និងធនធាន ដើម្បីកុំឲ្យនិន្នាការនេះនៅតែបន្តមានទៀត។

ទីពីរ ប្រសិនបើយើងពិតជាចាត់ទុកគោលដៅ SDG ទី ៤ នេះថាជាគោលដៅសំខាន់មែន យើងត្រូវធ្វើសកម្មភាពជាបន្ទាន់ និងត្រូវតែដាក់ចេញនូវការប្តេជ្ញាចិត្តសម្រាប់រយៈពេលវែង។ ការខកខានមិនបានធ្វើបែបនេះ មិនត្រឹមតែនាំឲ្យមានផលប៉ះពាល់ជាអវិជ្ជមានលើការអប់រំប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបន្ថយបង្អាក់ដល់វឌ្ឍនភាព ក្នុងការឈានទៅសម្រេចគ្រប់គោលដៅអភិវឌ្ឍន៍ទាំងអស់ ដូចជាគោលដៅកាត់បន្ថយភាពក្រីក្រ លុបបំបាត់គ្រោះអត់ឃ្លាន លើកកម្ពស់សុខភាព សមភាពយេនឌ័រនិងការផ្តល់ភាពអង់អាចដល់ស្រ្តី និរន្តរភាពផលិតកម្មនិងការប្រើប្រាស់ ភាពធន់នៃទីក្រុង និងសង្គមដែលកាន់តែមានសមភាពនិងបរិយាប័ន្ន។

ចុងក្រោយ យើងត្រូវតែផ្លាស់ប្តូររបៀបដែលយើងគិតពីការអប់រំនិងតួនាទីរបស់ការអប់រំក្នុងការសម្រេចនូវសុខុមាលភាពរបស់មនុស្ស និងការអភិវឌ្ឍសកល។ បច្ចុប្បន្ននេះ ជាងពេលណាៗទាំងអស់ វិស័យអប់រំជាវិស័យដែលទទួលខុសត្រូវលើការបណ្តុះជំនាញ ឥរិយាបថ និងអាកប្បកិរិយាឲ្យចំជំនាញ ឥរិយាបថ និងអាកប្បកិរិយា ដែលត្រូវមាន ដើម្បីនាំឲ្យមានកំណើនប្រកបដោយចីរភាព និងបរិយាប័ន្ន។

របៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ ២០៣០ អំពាវនាវឲ្យយើងធ្វើការឆ្លើយតបចម្រុះវិស័យ ដែលមានលក្ខណៈក្តោបរួមលើបញ្ហាប្រឈមខាងសង្គម សេដ្ឋកិច្ច និងបរិស្ថានជាច្រើន ដែលយើងកំពុងជួបប្រទះ។ នេះមានន័យថា យើងត្រូវធ្វើសកម្មភាពហួសពីព្រំដែនប្រពៃណីរបស់យើង និងត្រូវបង្កើតភាពជាដៃគូអន្តរវិស័យដែលមានប្រសិទ្ធភាព។

អនាគតប្រកបដោយចីរភាពសម្រាប់ទាំងអស់គ្នា គឺសំដៅលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស បរិយាប័ន្នសង្គម និងកិច្ចគាំពារបរិស្ថាន។ វាជាអនាគត ដែលកំណើនសេដ្ឋកិច្ចមិនបង្កឲ្យមានបញ្ហាវិសមភាព ប៉ុន្តែជាកំណើនដែលនាំមកនូវភាពរុងរឿងសម្រាប់ទាំងអស់គ្នា។ វាគឺជាអនាគត ដែលតំបន់ប្រជុំជន និងទីផ្សារការងារ ត្រូវបានរៀបចំឡើង ដើម្បីផ្ដល់ភាពអង់អាចដល់មនុស្សគ្រប់គ្នា ហើយសកម្មភាពសេដ្ឋកិច្ចនានា ក្នុងក្របខ័ណ្ឌសហគមន៍ និងក្រុមហ៊ុន សុទ្ធតែផ្ដោតលើភាពបៃតង។ ការអភិវឌ្ឍប្រកបដោយចីរភាពជឿថា ការអភិវឌ្ឍមនុស្សមិនអាចកើតឡើងបានឡើយ ប្រសិនបើផែនដីរបស់យើងពុំមានសុខភាពល្អនោះ។ នៅពេលចាប់ផ្ដើមអនុវត្តតាមរបៀបវារៈ SDG ថ្មីនេះ យើងទាំងអស់គ្នាត្រូវធ្វើឆ្លុះបញ្ចាំងលើគោលបំណងចុងក្រោយ នោះគឺការរៀនសូត្រពេញមួយជីវិត។ ព្រោះថា ប្រសិនបើធ្វើបានត្រឹមត្រូវ ការអប់រំមានអំណាចខុសពីសកម្មភាពផ្សេងទៀត ដោយវានឹងបណ្ដុះមនុស្សដែលមានភាពអង់អាច ចេះឆ្លុះបញ្ចាំង ចូលរួមបានសកម្ម និងមានជំនាញ ដែលអាចត្រួសត្រាយផ្លូវ ដើម្បីឲ្យផែនដីរបស់យើងកាន់តែមានសុវត្ថិភាព មានភាពបៃតង និងយុត្តិធម៌ សម្រាប់ទាំងអស់គ្នា។ របាយការណ៍ថ្មីនេះបង្ហាញនូវភស្តុតាងពាក់ព័ន្ធ ដែលនាំឲ្យការពិភាក្សាលើចំណុចទាំងនេះកាន់តែមានលក្ខណៈសម្បូរបែប និងសម្រាប់រៀបចំគោលនយោបាយនានា ដែលចាំបាច់ ដើម្បីឲ្យគោលដៅនេះក្លាយជាការពិត សម្រាប់ទាំងអស់គ្នា។

Irina Bokova

អគ្គនាយកយូណេស្កូ

# អារម្ភកថា

របាយការណ៍ពិនិត្យតាមដានស្ថានភាពអប់រំទូទាំងសកលលោកឆ្នាំ ២០១៦ (ដែលហៅកាត់ថារបាយការណ៍ GEM) គឺជារបាយការណ៍ដែលបង្កប់នូវអត្ថន័យដ៏សែនជ្រៅផង និងជារបាយការណ៍ ដែលទម្លាយនូវភាពស្ងប់ស្ងាត់ផង។ នេះគឺជារបាយការណ៍ធំមួយ ជារបាយការណ៍គ្រប់ជ្រុងជ្រោយ ស៊ីជម្រៅ និងមានលក្ខណៈមុតស្រួច។ វាក៏ជារបាយការណ៍ដែលនាំឲ្យយើងមានការព្រួយបារម្ភផងដែរ។ របាយការណ៍នេះបង្ហាញយ៉ាងច្បាស់ថា ការអប់រំ គឺជាបេះដូងនៃការអភិវឌ្ឍប្រកបដោយចីរភាព និងនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) លើសពីនេះ របាយការណ៍នេះក៏បង្ហាញយ៉ាងច្បាស់ផងដែរថា ដំណើរផ្លូវរបស់យើងនៅវែងឆ្ងាយណាស់ ដើម្បីឈានទៅសម្រេចគោលដៅ SDGs។ របាយការណ៍នេះគួរជាការប្រកាសអាសន្នទូទាំងពិភពលោក និងត្រួសត្រាយផ្លូវ ដើម្បីឲ្យមានការពង្រីកជាប្រវត្តិសាស្ត្រនូវសកម្មភាពនានា ដើម្បីឈានទៅសម្រេចគោលដៅ SDG ទី ៤។

របាយការណ៍ GEM នេះធ្វើការរៀបរាប់ពីទស្សនៈដែលមិនអាចប្រកែកបានថា ការអប់រំគឺជាធាតុចូលសំខាន់បំផុត សម្រាប់គ្រប់ទិដ្ឋភាពទាំងអស់នៃការអភិវឌ្ឍប្រកបដោយចីរភាព។ ការអប់រំកាន់តែប្រសើរ បង្កើនភាពរុងរឿង លើកកម្ពស់វិស័យកសិកម្ម ធ្វើឲ្យសុខភាពកាន់តែប្រសើរជាងមុន កាត់បន្ថយអំពើហិង្សា បង្កើនសមភាពយេនឌ័រ បង្កើនធនធានសង្គម និងលើកកម្ពស់បរិស្ថានធម្មជាតិ។ ការអប់រំ គឺជាកូនសោរ សម្រាប់ជួយឲ្យមនុស្សជុំវិញពិភពលោកយល់ដឹងថាហេតុអ្វីបានជាការអភិវឌ្ឍប្រកបដោយចីរភាព ជាទស្សនទានដ៏សំខាន់ ដើម្បីអនាគតរួមរបស់យើងទាំងអស់គ្នា។ ការអប់រំផ្តល់ឲ្យយើងនូវមធ្យោបាយសំខាន់ៗ ដូចជា មធ្យោបាយសេដ្ឋកិច្ចសង្គម បច្ចេកវិទ្យា និងក្រមសីលធម៌ ក្នុងការទទួលយកគោលដៅ SDGs និងសម្រេចគោលដៅទាំងនេះ។ ចំណុចទាំងនេះត្រូវបានលើកឡើងយ៉ាងលំអិត ក្នុងរបាយការណ៍នេះ។ មានព័ត៌មានដ៏សម្បូរបែបយ៉ាងច្រើន ដែលគេអាចទាញចេញពីតារាង ក្រាហ្វ និងអត្ថបទនានា។

ទោះជាយ៉ាងណាក៏ដោយ របាយការណ៍នេះក៏បានគូសបញ្ជាក់ពីគម្លាតដ៏សែនឆ្ងាយរវាងស្ថានភាពអប់រំបច្ចុប្បន្នរបស់ពិភពលោក និងអ្វីដែលការសន្យាថាត្រូវសម្រេចឲ្យបាន នៅឆ្នាំ ២០៣០។ គម្លាតនៃការទទួលបានការអប់រំរវាងអ្នកមាន និងអ្នកក្រ ក្នុងប្រទេសមួយ និងរវាងប្រទេសមួយ និងប្រទេសមួយ គឺជាគម្លាតដែលនាំឲ្យមានការព្រួយបារម្ភ។ នៅតាមប្រទេសក្រីក្រជាច្រើនកុមារដែលមានជីវភាពក្រីក្រត្រូវប្រឈមនឹងឧបសគ្គ ដែលគេស្ទើរតែមិនអាចដោះស្រាយបាន ក្រោមស្ថានភាពបច្ចុប្បន្ននេះ។ ពួកគេខ្វះសៀវភៅសិក្សានៅផ្ទះ ពុំមានឱកាសចូលរៀននៅសាលាមត្តេយ្យ និងទៅរៀននៅសាលារៀន ដែលពុំមានអគ្គិសនី ទឹក អនាម័យ គ្រូដែលមានសមត្ថភាព សៀវភៅសិក្សា និងសម្ភារបរិក្ខារចាំបាច់ផ្សេងទៀត ដែលបម្រើដល់ការអប់រំកម្រិតមូលដ្ឋាន ដែលនាំឲ្យការអប់រំរបស់ពួកគេមិនសូវមានគុណភាព។ចំណុចទាំងនេះមានភាពពាក់ព័ន្ធគួរឲ្យសម្គាល់។ខណៈពេលដែលគោលដៅSDGទី៤អំពាវនាវឲ្យមានសកលកម្មនៃការបញ្ចប់ការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិត្រឹមឆ្នាំ ២០៣០ អត្រាបញ្ចប់ការសិក្សាបច្ចុប្បន្ន នៅតាមប្រទេសដែលមានចំណូលទាប គឺត្រឹមតែ ១៤% ប៉ុណ្ណោះ (សូមមើលតារាង ១០.៣ នៃរបាយការណ៍ពិស្តារ)។

របាយការណ៍ GEM នេះ បានធ្វើការវិភាគដ៏សំខាន់មួយ ដើម្បីកំណត់ថាតើមានប្រទេសប៉ុន្មាន ដែលនឹងសម្រេចចំណុចដៅឆ្នាំ ២០៣០ តាមគន្លងផ្លូវបច្ចុប្បន្នរបស់ប្រទេសទាំងនោះ ឬសូម្បីតែតាមគន្លងផ្លូវរបស់ប្រទេសដែលមានការរីកចម្រើនឆាប់រហ័សជាងគេក្នុងតំបន់នេះ។ ចម្លើយចំពោះសំណួរនេះគឺមិនជាល្អនោះឡើយ។ យើងត្រូវការជាចាំបាច់នូវវឌ្ឍនភាព ដែលមិនធ្លាប់មានពីមុនមក ដែលវឌ្ឍនភាពនេះត្រូវតែចាប់ផ្តើមភ្លាម ដើម្បីឲ្យយើងអាចទទួលបានជោគជ័យជាមួយនឹងគោលដៅ SDG ទី ៤។

អ្នកដែលមានទុទិដ្ឋិនិយមអាចនិយាយថា “យើងបានប្រាប់អ្នកហើយថា ការសម្រេចគោលដៅ SDG ទី ៤ គឺមិនអាចទៅរួចឡើយ” ហើយពួកគេលើកឡើងថា យើងត្រូវតែទទួលយកអ្វីដែលជា “តថភាព”។ តែទោះជាយ៉ាងណាក៏ដោយ របាយការណ៍នេះឆ្លើយតបមកវិញថា ការពេញចិត្តនឹងស្ថានភាពបច្ចុប្បន្ន គឺជាការធ្វេសប្រហែស និងមិនបានគិតគូរវែងឆ្ងាយ។ ប្រសិនបើយើងបណ្តោយឲ្យក្មេងៗជំនាន់នេះ មិនបានទទួលការអប់រំគ្រប់គ្រាន់ យើងនឹងធ្វើឲ្យពួកគេជួបនឹងភ័យន្តរាយ និងធ្វើឲ្យពិភពលោករបស់យើងជួបនឹងភាពក្រីក្រ មានវិបត្តិបរិស្ថាន និងមានអំពើហិង្សា និងអស្ថិរភាពសង្គម រាប់ទសវត្សរ៍ទៅមុខទៀតជាមិនខាន។ គ្មានហេតុផលណា ដែលជាលេសនាំឲ្យយើងទទួលយកស្ថានភាពបច្ចុប្បន្ននេះឡើយ។ សារពីរបាយការណ៍នេះបញ្ជាក់យ៉ាងច្បាស់ថាយើងត្រូវតែធ្វើសកម្មភាពរួមគ្នា ដើម្បីពន្លឿនការសម្រេចលទ្ធផលនៃការអប់រំ ក្នុងល្បឿនមួយលឿន ដែលមិនធ្លាប់មានកន្លងមក។ គន្លឹះសំខាន់មួយ ក្នុងចំណោមគន្លឹះសំខាន់ៗនានា គឺការផ្តល់ថវិកា។ ដូចលើកឡើងពីខាងដើមដែរ របាយការណ៍នេះបង្ហាញពីចំណុចគួរឲ្យព្រួយបារម្ភ។ ជំនួយអភិវឌ្ឍន៍ សម្រាប់វិស័យអប់រំនាពេលបច្ចុប្បន្ននេះមានកម្រិតទាបជាងកាលពីឆ្នាំ២០០៩ (រូបភាព២០.៧នៃរបាយការណ៍ពិស្តារ)។នេះគឺជាការមើលមិនបានវែងឆ្ងាយ

របស់ប្រទេសអ្នកមាន។ តើប្រទេសផ្តល់ជំនួយទាំងនេះពិតជាជឿថា ពួកគេ “កំពុងតែសន្សំសំចៃប្រាក់” តាមរយៈការដាក់ទុនវិនិយោគតិចតួចលើការផ្តល់ជំនួយដល់វិស័យអប់រំ ក្នុងប្រទេសដែលមានចំណូលទាបក្នុងពិភពលោកមែនទេ? ក្រោយពីអានរបាយការណ៍នេះ មេដឹកនាំ និងប្រជាពលរដ្ឋក្នុងប្រទេសដែលមានចំណូលខ្ពស់នឹងដឹងស៊ីជម្រៅថា ការវិនិយោគលើវិស័យអប់រំ គឺជាការកសាងនូវមូលដ្ឋានគ្រឹះ សម្រាប់សុខុមាលភាពរបស់សកលលោកទាំងមូល ហើយការផ្តល់ជំនួយនៅកម្រិតបច្ចុប្បន្ននេះ ពោលគឺប្រមាណជា ៥ ពាន់លានដុល្លារ ក្នុងមួយឆ្នាំ សម្រាប់ការអប់រំកម្រិតបឋមសិក្សា គឺមានចំនួនត្រឹមតែ ៥ ដុល្លារ ក្នុងមួយឆ្នាំ ក្នុងប្រទេសអ្នកមានតែប៉ុណ្ណោះ! ដែលនេះគឺជាការវិនិយោគដ៏សែនតូចតាច សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងសន្តិភាពរបស់ពិភពលោកនាពេលអនាគត។

របាយការណ៍ GEM ឆ្នាំ ២០១៦ នេះ ផ្តល់នូវព័ត៌មានស៊ីជម្រៅដ៏ច្រើនអនេក ក៏ដូចជា អនុសាសន៍ និងស្តង់ដា សម្រាប់បោះជំហានទៅមុខទៀត។ របាយការណ៍នេះលើកស្នើនូវវិធីសាស្រ្ត ដ៏មានតម្លៃ ដើម្បីធ្វើការពិនិត្យតាមដាន និងវាស់វែងវឌ្ឍនភាពនៃគោលដៅ SDG ទី ៤។ របាយការណ៍នេះបង្ហាញឧទាហរណ៍ពីលទ្ធភាពកែសម្រួលការវាស់វែងធនធានដែលផ្តល់សម្រាប់វិស័យអប់រំ គុណភាពនៃការអប់រំ និងលទ្ធផលនៃការអប់រំ ជាជាងវាស់វែងត្រឹមតែការចុះឈ្មោះចូលរៀន និងការបញ្ចប់ការសិក្សា ដូចដែលយើងកំពុងធ្វើបច្ចុប្បន្ននេះ។ ដោយប្រើប្រាស់ទិន្នន័យសម្បូរបែបឧបករណ៍អង្កេតវិធីសាស្រ្តពិនិត្យតាមដាននិងបច្ចេកវិទ្យាព័ត៌មានដែលមានលក្ខណៈល្អប្រសើរជាងមុន យើងអាចធ្វើការវាស់វែងដំណើរការនៃការអប់រំ និងលទ្ធផលនៃការអប់រំ នៅគ្រប់កម្រិតទាំងអស់ កាន់តែលំអិតឆ្ងាយជាងមុន។

កាលពី ១៥ ឆ្នាំមុន ទីបំផុត ពិភពលោកបានទទួលស្គាល់ពីភាពធំសម្បើមនៃការរាតត្បាតជំងឺអេដស៍ និងភាពអាសន្នខាងសុខភាពផ្សេងទៀត ហើយបានចាត់វិធានការជាក់លាក់ ដើម្បីពង្រីកអន្តរាគមន៍ខាងសុខភាពសាធារណៈក្នុងបរិបទគោលដៅអភិវឌ្ឍន៍សហសវត្សរ៍។ដូច្នេះហើយបានជាមានការបង្កើតនូវគំនិតផ្តួចផ្តើមធំៗដូចជាមូលនិធិសកលដើម្បីប្រយុទ្ធនឹងជំងឺអេដស៍របេងនិងគ្រុនចាញ់ និងសម្ព័ន្ធភាពសកលសម្រាប់វ៉ាក់សាំង និងថ្នាំបង្ការ (ដែលបច្ចុប្បន្ននេះហៅថា Gavi សម្ព័ន្ធភាពខាងវ៉ាក់សាំង) និងមានឧទាហរណ៍ជា} ច្រើនផ្សេងទៀត។ កិច្ចខិតខំប្រឹងប្រែងទាំងនេះនាំឲ្យមានការបង្កើតអន្តរាគមន៍សុខភាពសាធារណៈ និងការផ្តល់មូលនិធិសម្រាប់អន្តរាគមន៍ទាំងនេះយ៉ាងច្រើន។ បើទោះបីជាគេមិនបានសម្រេចអ្វីដែលអាចសម្រេចបានក៏ដោយ (ដោយសារតែវិបត្តិហិរញ្ញវត្ថុឆ្នាំ ២០០៨ នាំឲ្យមានការបញ្ចប់ការបង្កើនការផ្តល់ថវិកាសម្រាប់គំនិតផ្តួចផ្តើមសុខភាពសាធារណៈ) កិច្ចខិតខំប្រឹងប្រែងទាំងនេះនាំឲ្យមានការសម្រេចជោគជ័យថ្មីៗជាច្រើន ដែលឥទ្ធិពលរបស់វានៅតែសាយភាយរហូតមកដល់បច្ចុប្បន្ននេះ។

របាយការណ៍ GEM ឆ្នាំ ២០១៦ នេះ គួរចាត់ទុកថាជាការអំពាវនាវស្រដៀងគ្នានេះ សម្រាប់ការអប់រំ ដែលជាគោលដៅស្នូលនៃគោលដៅ SDGs។ តាមទស្សនៈផ្ទាល់ខ្លួនរបស់ខ្ញុំ ដែលត្រូវបានលើកឡើងជាច្រើនដង ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ គឺភាពបន្ទាន់នៃការបង្កើតមូលនិធិសកល សម្រាប់ការអប់រំ ដោយប្រើប្រាស់មេរៀនជាវិជ្ជមាន ដែលទទួលបានពីមូលនិធិសកលសម្រាប់ជំងឺអេដស៍ របេង និងគ្រុនចាញ់។ ឧបសគ្គផ្នែកថវិកា គឺជាស្នូលនៃបញ្ហាប្រឈម សម្រាប់ការអប់រំ ដូចដែលលើកឡើងយ៉ាងច្បាស់តាមរយៈទិន្នន័យឆ្លងប្រទេស និងទិន្នន័យដែលប្រមូលពីតាមគ្រួសារ។

ឯកសារដ៏មានឥទ្ធិពលនេះអំពាវនាវឲ្យយើងទាំងអស់គ្នាធ្វើការឆ្លើយតបចំពោះកាលនុវត្តភាព ភាពបន្ទាន់ និងគោលដៅសកល ដែលត្រូវបានបង្កប់ចូលក្នុងគោលដៅ SDG ទី ៤៖ សកលកម្មនៃការអប់រំប្រកបដោយគុណភាពសម្រាប់ទាំងអស់គ្នា និងឱកាសរៀនសូត្រពេញមួយជីវិត។ ខ្ញុំសូមជម្រុញឲ្យមនុស្សគ្រប់រូបនៅគ្រប់ទិសទីធ្វើការសិក្សាស្វែងយល់ពីរបាយការណ៍នេះដោយប្រុងប្រយ័ត្ននិងចងចាំនូវសារសំខាន់ៗនៃរបាយការណ៍នេះ។ សំខាន់ជាងគេ យើងទាំងអស់គ្នាត្រូវតែនាំគ្នាធ្វើសកម្មភាព មិនថាយើងនៅកម្រិតណានោះទេ ចាប់ពីកម្រិតសហគមន៍មូលដ្ឋាន រហូតដល់សហគមន៍កម្រិតសកល។



Jeffrey D. Sachs
ទីប្រឹក្សាពិសេសរបស់អគ្គលេខាធិការសហប្រជាជាតិ
ទទួលបន្ទុកគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

# សង្ខេបរបាយការណ៍ពិនិត្យតាមដាន ស្ថានភាពនៃការអប់រំទូទាំងសកលលោក ឆ្នាំ២០៦

## សេចក្តីផ្តើម

ក្នុងសម័យប្រជុំលើកទី ៧០ នៃមហាសន្និបាទសហប្រជាជាតិ កាលពីខែ កញ្ញា ឆ្នាំ ២០១៥ រដ្ឋជាសមាជិក បានធ្វើការអនុម័តរបៀបវារៈអភិវឌ្ឍន៍សកលថ្មីមួយ ដែលមានឈ្មោះថា របៀបវារៈសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ឆ្នាំ ២០៣០៖ ធ្វើឲ្យពិភពលោករបស់យើងមានការផ្លាស់ប្តូរ។ របៀបវារៈនេះដាក់ចេញនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (ដែលហៅកាត់ថា SDGs) ចំនួន ១៧ ក្នុងនោះមានគោលដៅ SDG ទី ៤ ស្តីពីការអប់រំផងដែរ។ គោលដៅ SDGs កំណត់អាទិភាពនៃការអភិវឌ្ឍរហូតដល់ឆ្នាំ ២០៣០ និងជាគោលដៅបន្តពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ផង និងគោលដៅអប់រំសម្រាប់ទាំងអស់គ្នា (EFA) ផង ដែលគោលដៅទាំងពីរនេះសុទ្ធតែផុតកំណត់ក្នុងឆ្នាំ ២០១៥។

> “ការអប់រំនឹងមិនអាច សម្រេចសក្តានុពលរបស់ខ្លួន ក្នុងនាមជាកម្លាំងចលករុញច្រានពិភពលោកឲ្យបោះជំហានទៅមុខឡើយ លុះត្រាតែអត្រានៃការចូលរួមទទួលបានការអប់រំមានការកើនឡើងខ្លាំង ការរៀនសូត្រក្លាយជាកិច្ចការដែលគេធ្វើពេញមួយជីវិត ហើយប្រព័ន្ធអប់រំទទួលយកការអភិវឌ្ឍប្រកបដោយចីរភាពទាំងស្រុង។”

របាយការណ៍ពិនិត្យតាមដានស្ថាន ភាពនៃការអប់រំទូទាំងសកលលោក (ហៅកាត់ថារបាយការណ៍ GEM) នេះ ដែលត្រូវបានរៀបចំឡើងផ្អែកទៅតាមបទពិសោធន៍ ពីរបាយការណ៍ពិនិត្យតាមដានកម្រិតសកលលើការអប់រំសម្រាប់ទាំងអស់គ្នា កន្លងមក មានតួនាទីថ្មីមួយ គឺធ្វើការវាយតម្លៃលើវឌ្ឍនភាពនៃវិស័យអប់រំ ក្រោមរបៀបវារៈ ២០៣០។ របាយការណ៍ GEM ឆ្នាំ២០១៦ ដែលជារបាយការណ៍ដំបូងគេ ក្នុងចំណោមរបាយការណ៍ថ្មីៗដែលនឹងរៀបចំឡើងជាបន្តបន្ទាប់ក្នុងរយៈពេល ១៥ ឆ្នាំ ធ្វើការពិនិត្យលើទំនាក់ទំនងដ៏សែនស្មុគស្មាញរវាងការអប់រំ និងមុខព្រួញផ្សេងទៀតនៃការអភិវឌ្ឍប្រកបដោយចីរភាព ក៏ដូចជាធ្វើការពិនិត្យតាមដានគោលដៅ SDG ទី ៤ ផងដែរ។ របាយការណ៍នេះបង្ហាញថា ការអប់រំនឹងមិនអាចសម្រេចសក្តានុពលរបស់ខ្លួន ក្នុងនាមជាកម្លាំងចលករុញច្រានពិភពលោកឲ្យបោះជំហានទៅមុខឡើយ លុះត្រាតែអត្រានៃការចូលរួមទទួលបានការអប់រំមានការកើនឡើងខ្លាំង ការរៀនសូត្រក្លាយជាកិច្ចការដែលគេធ្វើពេញមួយជីវិត ហើយប្រព័ន្ធអប់រំទទួលយកការអភិវឌ្ឍប្រកបដោយចីរភាពទាំងស្រុង។

ផ្នែកប្រធានបទនៃរបាយការណ៍នេះរំលេចឲ្យឃើញពីភស្តុតាង ការអនុវត្ត និងគោលនយោបាយនានា ដែលបង្ហាញឲ្យឃើញពីរបៀបដែលការអប់រំអាចបំពេញនាទីជាកាតាលីករ ដើម្បីឈានទៅសម្រេចរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាពជារួម។ របាយការណ៍នេះបង្ហាញពីទល្ហីករណ៍ច្បាស់លាស់ពីប្រភេទនៃការអប់រំ ដែលមានសារៈសំខាន់ ដើម្បីសម្រេចគោលដៅកាត់បន្ថយភាពក្រីក្រ ការលុបបំបាត់គ្រោះអត់ឃ្លាន ការលើកកម្ពស់សុខភាព សមភាពយេនឌ័រនិងការផ្តល់ភាពអង់អាច កសិកម្មប្រកបដោយនិរន្តរភាព ភាពធន់នៃទីក្រុង និងសង្គមដែលកាន់តែមានសមភាព បរិយាប័ន្ន និងយុត្តិធម៌ជាងមុន។

ដោយឡែកផ្នែកស្តីពីការពិនិត្យតាមដានក្នុងរបាយការណ៍នេះវិញ ធ្វើការពិភាក្សាពីបញ្ហាប្រឈមជាច្រើន ពាក់ព័ន្ធជាមួយនឹងរបៀបធ្វើការវាយតម្លៃវឌ្ឍនភាពគោលដៅ SDG ទី ៤ ដោយមានដាក់ចេញនូវអនុសាសន៍ជាក់លាក់ ដើម្បីឲ្យមានការកែសម្រួលគោលនយោបាយ។ ចំណុចដៅនីមួយៗ ក្នុងចំណោមចំណុចដៅអប់រំទាំង ៧ និងមធ្យោបាយចំនួន ៣ សម្រាប់អនុវត្តគោលដៅ SDG ទី ៤ ត្រូវបានលើកយកមកបកស្រាយលំអិតម្តងមួយៗ។ លើសពីនេះ ក៏មានការវិភាគលើប្រព័ន្ធផ្តល់ហិរញ្ញប្បទានដល់វិស័យអប់រំ និងប្រព័ន្ធអប់រំផងដែរ ក៏ដូចជាកម្រិតដែលគេអាចធ្វើការពិនិត្យតាមដានការងារអប់រំក្នុងគោលដៅ SDG ផ្សេងទៀត។ មានការកំណត់ផងដែរនូវមូលដ្ឋានគ្រឹះ និងសក្តានុពលសម្រាប់ធ្វើការងារផ្គួបកម្លាំងគ្នា ដើម្បីឲ្យការអនុវត្តរបៀបវារៈពិនិត្យតាមដានការអប់រំទូទាំងសកលលោកកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិ ក្នុងរយៈពេល ១៥ ឆ្នាំទៅមុខទៀត នៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ។

# តារាងទី ១ :

## ជាធម្មតា តើការអប់រំមានទំនាក់ទំនងយ៉ាងដូចម្តេចជាមួយនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពផ្សេងទៀត

| | | | |
|---|---|---|---|
| **គោលដៅទី ១** | ការអប់រំមានសារៈសំខាន់ សម្រាប់រំដោះប្រជាពលរដ្ឋពីភាពក្រីក្រ | **គោលដៅទី ៩** | នៅកន្លែងដែលគេអាចទទួលបានការអប់រំប្រកបដោយសមភាព ការអប់រំនាំឲ្យមានភាពខុសប្លែកពីមុន កាលពីពេលដែលមានវិសមភាពសង្គម និងសេដ្ឋកិច្ច |
| **គោលដៅទី ២** | ការអប់រំបំពេញតួនាទីសំខាន់ក្នុងការជួយឲ្យមនុស្សផ្លាស់ទៅប្រើប្រាស់វិធីសាស្ត្របង្កបង្កើនផលដែលកាន់តែមាននិរន្តរភាព និងយល់ពីអាហារូបត្ថម្ភ | **គោលដៅទី ៩** | ការអប់រំអាចផ្តល់ឲ្យមនុស្សនូវជំនាញ ដើម្បីចូលរួមកំណត់ និងរក្សានិរន្តរភាពទីក្រុង និងធ្វើឲ្យទីក្រុងមានភាពធន់ នៅពេលដែលមានគ្រោះមហន្តរាយកើតមានឡើង |
| **គោលដៅទី ៣** | ការអប់រំអាចនាំឲ្យមានការផ្លាស់ប្តូរសំខាន់ៗពាក់ព័ន្ធនឹងបញ្ហាសុខភាព ដូចជា ការឆាប់ស្លាប់ សុខភាពបន្តពូជ ការឆ្លងរាលដាលជំងឺ របៀបផែននៃការរស់នៅដែលនាំមកនូវសុខភាពល្អ និងសុខុមាលភាព | **គោលដៅទី ១០** | ការអប់រំអាចធ្វើឲ្យមានការផ្លាស់ប្តូរសំខាន់ៗពាក់ព័ន្ធនឹងនិន្នាការផលិតកម្ម ( ឧ. ពាក់ព័ន្ធនឹងសេដ្ឋកិច្ចដែលពុំបញ្ចេញសំណល់ និងជាតិពុល ) និងធ្វើឲ្យអ្នកប្រើប្រាស់កាន់តែមានការយល់ដឹងពីទំនិញដែលផលិតប្រកបដោយចីរភាព និងការបង្ការមិនឲ្យមានសំណល់នានា |
| **គោលដៅទី ៤** | ការអប់រំសម្រាប់ស្ត្រី និងក្មេងស្រី មានសារៈសំខាន់ជាពិសេសដើម្បីឲ្យពួកគេមានចំណេះដឹងអក្ខរកម្មកម្រិតមូលដ្ឋាន បង្កើនជំនាញ និងសមត្ថភាពចូលរួម និងលើកកម្ពស់ឱកាសក្នុងជីវិតរបស់ពួកគេ | **គោលដៅទី ១១** | ការអប់រំ គឺជាគន្លឹះ ដើម្បីឲ្យមនុស្សទូទៅយល់ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ក៏ដូចជាការបន្សាំ និងការកាត់បន្ថយផលប៉ះពាល់នេះ ជាពិសេស នៅថ្នាក់មូលដ្ឋាន |
| **គោលដៅទី ៥** | ការអប់រំ និងបណ្តុះបណ្តាលបង្កើនជំនាញ និងសមត្ថភាពប្រើប្រាស់ធនធានធម្មជាតិឲ្យកាន់តែមាននិរន្តរភាព និងអាចលើកកម្ពស់ការអនុវត្តអនាម័យ | **គោលដៅទី ១២** | ការអប់រំ មានសារៈសំខាន់ សម្រាប់បង្កើនការយល់ដឹងអំពីបរិស្ថានសមុទ្ទ និងផ្តួចផ្តើមឲ្យមានការឯកភាពគ្នាជារួម ពាក់ព័ន្ធនឹងការប្រើប្រាស់ប្រកបដោយភាពឆ្លាតវៃ និងនិរន្តរភាព |
| **គោលដៅទី ៦** | កម្មវិធីអប់រំ ជាពិសេស កម្មវិធីអប់រំក្រៅប្រព័ន្ធ និងក្រៅផ្លូវការអាចលើកទឹកចិត្តឲ្យមានការសន្សំសំចៃថាមពល និងការប្រើប្រាស់ប្រភពថាមពលកកើតឡើងវិញ | **គោលដៅទី ១៣** | ការអប់រំ និងការបណ្តុះបណ្តាល បង្កើនជំនាញ និងសមត្ថភាពប្រកបមុខរបរចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព ក៏ដូចជាការពារធនធានធម្មជាតិ និងជីវចម្រុះ ជាពិសេស ក្នុងបរិស្ថានដែលទទួលរងការគំរាមកំហែង |
| **គោលដៅទី ៧** | ភាពរឹងមាំខាងសេដ្ឋកិច្ច សហគ្រិនភាព និងជំនាញទីផ្សារការងារ សុទ្ធតែមានទំនាក់ទំនងផ្ទាល់ជាមួយនឹងកម្រិតនៃការអប់រំ | **គោលដៅទី ១៤** | ការរៀនសូត្រក្នុងសង្គម មានសារៈសំខាន់ ដើម្បីបង្កលក្ខណៈងាយស្រួល និងធានាឲ្យមានការបង្កើតនូវសង្គមមួយដែលបើកចំហឲ្យមានការចូលរួមប្រកបដោយបរិយាប័ន្ន មានយុត្តិធម៌ និងមានភាពស៊ីសង្វាក់គ្នា |
| **គោលដៅទី ៨** | ការអប់រំគឺជាអ្វីដែលចាំបាច់ ដើម្បីអភិវឌ្ឍជំនាញ ដែលចាំបាច់ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធដែលកាន់តែធន់ជាងមុន និងកសាងនូវ | **គោលដៅទី ១៥** | ការរៀនសូត្រពេញមួយជីវិតកសាងសមត្ថភាពយល់ដឹង និងជម្រុញឲ្យមានការរៀបចំគោលនយោបាយស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព និងការអនុវត្តគោលនយោបាយទាំងនេះ |

ប្រភព៖ ICSU and ISSU (2015)



កុមារប្រើប្រាស់ក្ដារខៀន
ដើម្បីទប់សរសេរ ក្នុង
សាលារៀន Dan Saa
នៅប្រទេសនីហ្សេ

រូបថត: Tagaza Djibo/UNESCO

# ភពផែនដី




@GEMReport #SDG4All bitly.com/sdg4all

# ការអប់រំ និងការអភិវឌ្ឍប្រកបដោយចីរភាព៖ តើទាំងពីរនេះ មានទំនាក់ទំនងជាមួយគ្នាយ៉ាងដូចម្តេច និងហេតុអ្វីបានជា ទំនាក់ទំនងទាំងនេះមានសារៈសំខាន់ ?

## ភពផែនដី៖ និរន្តរភាពបរិស្ថាន

សកម្មភាពរបស់មនុស្ស ទោះធ្វើឡើងដោយឡែករៀងៗខ្លួនក្តី និងជាសមូហភាពក្តី បានដាក់នូវបន្ទុកយ៉ាងធំធេងមកលើភពផែនដី និងមកលើជីវិត ដែលទទួលបានការគាំទ្រពីភពផែនដី។ ដោយសារតែមនុស្សជាអ្នករួមចំណែកធ្វើឲ្យបរិស្ថានមានការរិចរឹល បង្កឲ្យមានការបាត់បង់ជីវចម្រុះយ៉ាងឆាប់រហ័ស និងការប្រែប្រួលអាកាសធាតុ មនុស្សក៏ត្រូវធ្វើសកម្មភាព ដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមទាំងនេះផងដែរ។

ការអប់រំអាចបំពេញតួនាទីយ៉ាងសំខាន់ ក្នុងការធ្វើឲ្យសង្គមរបស់យើងប្រែក្លាយជាសង្គមដែលអាចធានាបាននូវនិរន្តរភាពបរិស្ថាន ដោយមានការសហការជាមួយនឹងគំនិតផ្តួចផ្តើមនានារបស់រដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជន។ ការអប់រំជាកត្តាដែលកំណត់ពីតម្លៃ និងការយល់ឃើញរបស់មនុស្ស។ ការអប់រំក៏រួមចំណែកអភិវឌ្ឍជំនាញ ទស្សនទាន និងឧបករណ៍ផ្សេងៗ ដែលគេអាចប្រើប្រាស់ ដើម្បីកាត់បន្ថយ ឬបញ្ឈប់ការអនុវត្តទាំងឡាយ ដែលពុំមាននិរន្តរភាពផងដែរ។

តួនាទីចម្រុះរបស់ការអប់រំ ក្នុងការនាំមកនូវនិរន្តរភាព មិនមែនសុទ្ធតែវិជ្ជមានរហូតនោះទេ។ ការអប់រំ ក៏អាចរួមចំណែកនាំឲ្យមានការអនុវត្តដែលពុំមាននិរន្តរភាពផងដែរ ដូចជា ការប្រើប្រាស់ធនធានហួសកម្រិត និងការធ្វើឲ្យបាត់បង់ចំណេះដឹង និងបែបផែននៃការរស់នៅរបស់ជនជាតិដើមភាគតិច ដែលអាចជួយឲ្យមាននិរន្តរភាព ជាដើម។ គេត្រូវរៀបចំ និងកែប្រែការអប់រំ ដើម្បីធានាយ៉ាងណាឲ្យផលជះដែលបានពីការអប់រំនេះមានលក្ខណៈវិជ្ជមាន។

### ឥរិយាបថរបស់មនុស្សនាំមកនូវវិបត្តិបរិស្ថាន

មានកត្តាចំនួន ៣ ដើម្បីស្វែងយល់អំពីរបៀបដែលឥរិយាបថរបស់មនុស្សបង្កឲ្យបរិស្ថានរិចរឹល នោះគឺលក្ខណៈប្រជាសាស្ត្រ បែបផែននៃការរស់នៅតាមបែបទំនើប និងឥរិយាបថរបស់មនុស្សម្នាក់ៗ។ សម្រាប់កត្តាប្រជាសាស្ត្រ មានមនុស្សច្រើនពេក លើភពផែនដីនេះ៖ ចំនួនមនុស្សសរុបក្នុងសកលលោកទាំងមូលបានកើនឡើងបីដង ចន្លោះឆ្នាំ ១៩៥០ ដល់ ២០១៥ ហើយគេរំពឹងថា ចំនួនមនុស្សនឹងកើនឡើងមួយពាន់លាននាក់ទៀត ពោលគឺរហូតដល់ ៨,៥ ពាន់លាននាក់ ត្រឹមឆ្នាំ ២០៣០។ បែបផែននៃការរស់នៅតាមបែបទំនើប ផ្តោតលើការប្រើប្រាស់ធនធានក្នុងមនុស្សម្នាក់ ដែលមានកម្រិតខ្ពស់ នៅតាមតំបន់ប្រជុំជន និងតាមប្រទេសអ្នកមាន។ ប្រទេស ដែលជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានការកើនឡើងយ៉ាងឆាប់រហ័ស បានបង្កើនកម្រិតនៃផលប៉ះពាល់ដែលពួកគេបង្កលើបរិស្ថាន (ecological footprint) ជិតពីរដង ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ។ ក្នុងឆ្នាំ ២០១២ ប្រទេសដែលមានចំណូលខ្ពស់ភាគច្រើន បានបង្កផលប៉ះពាល់ជាច្រើនមកលើបរិស្ថាន ក្នុងនិន្នាការមួយ ដែលពុំមាននិរន្តរភាព។ សម្រាប់កត្តាឥរិយាបថរបស់មនុស្សម្នាក់ៗវិញ គេចាត់ទុកមនុស្សម្នាក់ៗថាជាប្រភពដែលនាំឲ្យមានបញ្ហាបរិស្ថានផង និងជាអ្នកដែលមានសក្តានុពលស្វែងរកដំណោះស្រាយចំពោះបញ្ហាទាំងអស់នេះផង ឧទាហរណ៍ តាមរយៈការរៀបចំនូវគោលនយោបាយ ដែលលើកទឹកចិត្តឲ្យមានការកែច្នៃសំរាម ការប្រើប្រាស់កង់ និងឡានសន្សំសំចៃប្រេងផង។

### ការរៀនសូត្រមានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីជំនះបញ្ហាប្រឈមទាំងនេះ

ការអប់រំមានតួនាទីសំខាន់ ក្នុងការឆ្លើយតបចំពោះបញ្ហាប្រឈមផ្នែកបរិស្ថាន។ ការអប់រំ ជាពិសេស ការអប់រំក្មេងស្រី និងស្ត្រី គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុត ដើម្បីទប់ស្កាត់កំណើនចំនួនប្រជាជន បង្កើនសិទ្ធិស្វ័យសម្រេចរបស់ស្ត្រីពាក់ព័ន្ធជាមួយនឹងការមានកូន និងពេលមានផ្ទៃពោះ។ ការអប់រំអាចលើកកម្ពស់ជីវភាពរស់នៅរបស់មនុស្ស តាមរយៈការបង្កើនប្រាក់ចំណូល ហើយមនុស្សដែលមានជំនាញគឺជាអ្នកដែលមានតួនាទីសំខាន់ក្នុងការកែប្រែសេដ្ឋកិច្ចនិងប្រព័ន្ធអាហារ។ ការអប់រំអាចមានឥទ្ធិពលលើឥរិយាបថជាលក្ខណៈបុគ្គល និងជាលក្ខណៈសមូហភាព ពាក់ព័ន្ធនឹងបរិស្ថាន ដោយប្រើប្រាស់វិធីសាស្ត្ររៀនសូត្រដែលកំពុងអនុវត្តបច្ចុប្បន្ន វិធីសាស្ត្ររៀនសូត្របែបប្រពៃណី និងវិធីសាស្ត្ររៀនសូត្រពេញមួយជីវិត។

“ការវិភាគលើកម្មវិធីសិក្សាជាតិក្នុងប្រទេសចំនួន ៧៨ បង្ហាញថា មាន ៥៥% ប្រើប្រាស់ពាក្យថា “អេកូឡូហ្សី” និង ៤៧% ប្រើប្រាស់ពាក្យថា “ការអប់រំបរិស្ថាន”។”

## វិធីសាស្ត្ររៀនសូត្រដែលកំពុងអនុវត្តបច្ចុប្បន្ន

សាលារៀនជួយឲ្យសិស្សយល់ពីបញ្ហាបរិស្ថានអ្វីមួយ ផលវិបាកដែលបង្កឡើងដោយបញ្ហានេះ និងប្រភេទសកម្មភាព ដែលចាំបាច់ដើម្បីដោះស្រាយបញ្ហានេះ។ ចំណេះដឹងអំពីបរិស្ថានត្រូវបានដាក់បញ្ចូលកាន់តែច្រើនឡើង ទៅក្នុងកម្មវិធីសិក្សាផ្លូវការ។ ការវិភាគលើកម្មវិធីសិក្សាជាតិក្នុងប្រទេសចំនួន ៧៨ បង្ហាញថា មាន ៥៥% ប្រើប្រាស់ពាក្យថា “អេកូឡូហ្ស៊ី” និង ៤៧% ប្រើប្រាស់ពាក្យថា “ការអប់រំបរិស្ថាន”។

**រូបភាពទី១ :**

**ការអភិវឌ្ឍមនុស្សក្នុងកម្រិតខ្ពស់កើតឡើងជាថ្នូរនឹងការបាត់បង់ធនធានបរិស្ថាន**

ផលប៉ះពាល់លើបរិស្ថាន (ecological footprint) សរុប ទៅតាមសន្ទស្សន៍នៃការអភិវឌ្ឍមនុស្ស បែងចែកតាមប្រទេស ឆ្នាំ ២០១២

ផលប៉ះពាល់លើបរិស្ថាន (ecologicalfootprint) ក្នុងកម្រិតតិចជាង ១,៧ ហិចតា ក្នុងមនុស្សម្នាក់ បើគិតតាមចំនួនប្រជាជន ផ្ទៃដីនិងសមុទ្រដែលប្រើប្រាស់សម្រាប់ ផលិតកម្ម (សមត្ថភាពរបស់ធម្មជាតិ) ត្រូវបានចាត់ទុកថាជាកម្រិតដែលមាននិរន្តរភាព។ ផែនដីអាចបំពេញឡើងវិញនូវធនធាន ដែលប្រទេសមួយប្រើអស់។
សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស (HDI ដែលកំណត់ដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ) វាស់វែងលទ្ធផល ដែលសម្រេចបានគិតជាមធ្យមរបស់ប្រទេសមួយ ខាងសុខភាព ចំណេះដឹង និងជីវភាពរស់នៅ។ ពិន្ទុ HDI កម្រិតចាប់ពី ០,៨ ឡើងទៅ បង្ហាញថា ការអភិវឌ្ឍមនុស្សមានកម្រិតខ្ពស់ខ្លាំង។
HDI ដ៏ខ្ពស់របស់ប្រទេសសឹង្ហបុរី (០,៩១) មានទំនាក់ទំនងជាមួយនឹងផលប៉ះពាល់លើបរិស្ថាន (ecological footprint) ដ៏ធំក្នុងប្រជាជនម្នាក់ (៧,៩៧)។នេះមានន័យថាបើទោះបីជាប្រជាជនក្នុងប្រទេសសឹង្ហបុរី មានជីវភាពរស់នៅខ្ពស់ក៏ដោយ ពួកគេក៏មានតម្រូវការធនធានច្រើនផងដែរ។




- តំបន់ខូខាស (ប្រទេសស្ថិតនៅចន្លោះអឺរ៉ុប និងអាស៊ី) និងអាស៊ីកណ្ដាល
- អាស៊ីខាងកើត និងអាស៊ីអាគ្នេយ៍
- អឺរ៉ុប និងអាមេរិកភាគខាងជើង
- អាមេរិចឡាទីន និងការីបៀន
- អាហ្វ្រិចខាងជើង និងអាស៊ីខាងលិច
- ប៉ាស៊ីហ្វិច
- អាស៊ីភាគខាងត្បូង
- អាហ្វ្រិចសាប់សាហារ៉ា

ប្រភព៖ ការវិភាគរបស់ក្រុមរៀបចំរបាយការណ៍ GEM ផ្អែកតាមទិន្នន័យដែលបានពីបណ្ដាញ Footprint សកល (២០១៦)

ឧទាហរណ៍ក្នុងប្រទេសឥណ្ឌាក្រោយពេលមានការចេញសេចក្ដីសម្រេចរបស់តុលាការកំពូលរួចមកក្នុងឆ្នាំ២០០៣ទីភ្នាក់ងារនានារបស់រដ្ឋាភិបាល បានចាប់ផ្ដើមរៀបចំខ្លឹមសារសម្រាប់ផ្ដល់ការអប់រំផ្នែកបរិស្ថាន ដែលនាំឲ្យមានសិស្សជាង ៣០០ លាននាក់ ក្នុងសាលារៀន ១,៣ លានកន្លែង បានទទួលការអប់រំបណ្ដុះបណ្ដាលអំពីបរិស្ថាន។

ការអប់រំអំពីបរិស្ថានលើកទឹកចិត្តឲ្យមានរបៀបផែននៃការរស់នៅប្រកបដោយចីរភាព ការកាត់បន្ថយសំណល់ ការកែលំអការប្រើប្រាស់ថាមពល ការប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈច្រើនជាងមុន ការគាំទ្រដល់គោលនយោបាយគាំទ្របរិស្ថាន និងយុទ្ធនាការគាំទ្របរិស្ថាន។ ក្នុងប្រទេសអេស្តូនៀ និងស៊ុយអែត ដែលការអភិវឌ្ឍប្រកបដោយចីរភាពត្រូវបានបញ្ចូលទៅក្នុងកម្មវិធីសិក្សា សិស្សមានសមត្ថភាពផ្តល់ចម្លើយចំពោះសំណួរក្នុងវិញ្ញាសារវិទ្យាសាស្ត្របរិស្ថាន ក្នុងកម្មវិធីវាយតម្លៃសិស្សអន្តរជាតិឆ្នាំ ២០០៦ បានត្រឹមត្រូវជាងសិស្សក្នុងប្រទេសដែលពុំបានរៀបចំកម្មវិធីសិក្សាបែបនេះ។ ការសិក្សាលើសាលារៀនបែបនេះក្នុងប្រទេសអង់គ្លេស (ចក្រភពអង់គ្លេស) បង្ហាញពីការរីកចម្រើនខាងគុណតម្លៃរបស់សាលារៀន ក៏ដូចជាខាងសុខភាព និងការរៀនសូត្ររបស់សិស្ស និងមានការកាត់បន្ថយផលប៉ះពាល់លើបរិស្ថាន (ecological footprint) របស់សាលារៀន។

## វិធីសាស្ត្ររៀនសូត្របែបប្រពៃណី

ចំណេះដឹងបែបប្រពៃណី ជាពិសេស ចំណេះដឹងរបស់ជនជាតិដើមភាគតិច ខាងកសិកម្ម ការផលិតអាហារ និងការអភិរក្សបំពេញតួនាទីយ៉ាងសំខាន់ ក្នុងការធានាឲ្យនិរន្តរភាពបរិស្ថានរាប់សតវត្សរ៍មកហើយ។ ឧទាហរណ៍ជាច្រើនអំពីរបៀបគ្រប់គ្រងដីធ្លីតាមបែបប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច កាន់តែត្រូវបានពិភពលោកទាំងមូលទទួលស្គាល់ថាជាវិធីសាស្ត្រល្អបំផុត សម្រាប់អភិរក្សជីវចម្រុះ និងរក្សាដំណើរការនៃប្រព័ន្ធបរិស្ថាន។ ក្នុងប្រទេសកូឡុំប៊ី ក្រុមប្រឹក្សាទទួលបន្ទុកការតាំងទីលំនៅប្រកបដោយនិរន្តរភាពនៅអាមេរិច (Council of Sustainable Settlements of the Americas) កំពុងដាក់ឲ្យអនុវត្តនូវទស្សនទាន “ការរស់នៅប្រកបដោយផាសុកភាព (bienvivir)”ដែលទទួលស្គាល់ការរួមចំណែករបស់សហគមន៍ជនជាតិដើមភាគតិច ដូចជាក្នុងគម្រោងបរិស្ថាននៅតំបន់ប្រជុំជនភូមិដែលមាននិរន្តរភាពបែបប្រពៃណី និងមជ្ឈមណ្ឌលអប់រំអំពីនិរន្តរភាព ជាដើម។

ចំណេះដឹងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន និងរបស់ជនជាតិដើមភាគតិច បានរួមចំណែកដល់ការបំពេញមុខងាររបស់ប្រព័ន្ធបរិស្ថាន ប្រព័ន្ធផ្តល់ព័ត៌មានជាមុនអំពីគ្រោះមហន្តរាយ និងការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ ក៏ដូចជាភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។ គំនិតផ្តួចផ្តើមប្រព័ន្ធជនបទនៅអាឡាស្កា ក្នុងសហរដ្ឋអាមេរិច ដែលផ្តល់ឱកាសឲ្យសិស្សានុសិស្សធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងចាស់ព្រឹទ្ធាចារ្យដែលជាជនជាតិដើមភាគតិច គឺជាឧទាហរណ៍មួយ ដែលបង្ហាញពីសាលារៀនទទួលចំណេះដឹងពីជនជាតិដើមភាគតិច។ ការបង្រៀន ដោយប្រើប្រាស់ភាសារបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ក៏រួមចំណែកនាំឲ្យមានការចែករំលែកចំណេះដឹងរវាងមនុស្សជំនាន់មួយ និងជំនាន់មួយទៀតផងដែរ។

## វិធីសាស្ត្ររៀនសូត្រពេញមួយជីវិត៖ ការរៀនសូត្រ តាមរយៈការងារ និងការរស់នៅប្រចាំថ្ងៃ

បន្ថែមពីលើការអប់រំក្នុងប្រព័ន្ធ ស្ថាប័ននានារបស់រដ្ឋាភិបាល អង្គការសាសនា អង្គការមិនរកប្រាក់ចំណេញ និងក្រុមសហគមន៍ អង្គការសមាគមកម្មករនិយោជិត និងវិស័យឯកជន សុទ្ធតែអាចជួយធ្វើឲ្យឥរិយាបថរបស់បុគ្គលម្នាក់ៗ និងឥរិយាបថជាសមូហភាពមានការផ្លាស់ប្តូរ។

យុទ្ធនាការ ដែលទទួលបានការគាំទ្រពីរដ្ឋាភិបាល អាចបង្កើនចំណេះដឹងអំពីបញ្ហាបរិស្ថាន រំលេចឲ្យឃើញពីមូលហេតុដែលនាំឲ្យមានបញ្ហានេះ និងបង្ហាញពីរបៀបដែលគេអាចដោះស្រាយបញ្ហានេះបាន។ ក្នុងឆ្នាំ ២០១៥ រដ្ឋាភិបាលប្រទេសអេត្យូពី និងដៃគូ បានប្រកាសចាប់ផ្តើមអនុវត្តយុទ្ធនាការបង្កើនកការយល់ដឹងជាសាធារណៈមួយ ដែលមានរយៈពេល ២ ឆ្នាំ ក្នុងគោលបំណងលើកទឹកចិត្តឲ្យមានការប្រើប្រាស់ផលិតផលភ្លើងបំភ្លឺ ដែលទទួលថាមពលពីពន្លឺព្រះអាទិត្យ។

អ្នកដឹកនាំសាសនា វប្បធម៌ និងសង្គម អាចជួយផ្សព្វផ្សាយគុណតម្លៃ និងឥរិយាបថ ដែលជួយដល់បរិស្ថាន។ ឧទាហរណ៍ មានដូចជា ការស្វែងរកមតិគាំទ្រដល់បរិស្ថានដោយសម្តេចសង្ឃគ្រីស្តសាសនា ហ្វ្រង់ស៊ីស សម្តេចសង្ឃ ដាឡៃ ឡាម៉ា និងសមាគមមូស្លីមសម្រាប់សកម្មភាពប្រែប្រួលអាកាសធាតុ ជាដើម។

កន្លែងធ្វើការ គឺជាមជ្ឈមណ្ឌលដ៏សំខាន់ សម្រាប់រៀនសូត្រពីបរិស្ថាន។ ក្រុមហ៊ុននានាបានប្រកាសចាប់ផ្តើមអនុវត្តគំនិតផ្តួចផ្តើម ដើម្បីកាត់បន្ថយផលប៉ះពាល់លើបរិស្ថាន (ecological footprint) របស់ខ្លួន ក៏ដូចជាអប់រំបុគ្គលិក និងសាធារណជនអំពីកិច្ចការពារបរិស្ថាន។ ការអង្កេតមួយរបស់អង្គភាពចារកម្មសេដ្ឋកិច្ច (Economist Intelligence Unit) ក្នុងឆ្នាំ ២០០៨ បានរាយការណ៍ថា មានថ្នាក់ដឹកនាំក្រុមហ៊ុនលើសកលលោកជាង ៤០% គិតថា វាជាការសំខាន់ ដែលក្រុមហ៊ុនរបស់ពួកគេត្រូវបញ្ចូលនិរន្តរភាពទៅក្នុងសកម្មភាពធុរកិច្ចរបស់ពួកគេ។ អង្គការ សមាគមកម្មករនិយោជិត ក៏បានខិតខំលើកកម្ពស់ឲ្យមានការអនុវត្តក្នុងកន្លែងធ្វើការដែលកាន់តែមាននិរន្តរភាពផងដែរ។

តាមរយៈយុទ្ធនាការផ្តល់ព័ត៌មានដល់សាធារណជនទូទៅ គម្រោងភាពជាដៃគូនិងសម្ព័ន្ធភាពបៃតង អង្គការមិនមែនរដ្ឋាភិបាល សុទ្ធតែបំពេញតួនាទីសំខាន់ ក្នុងការកៀងគរការគាំទ្ររបស់សាធារណជនទូទៅដល់ការងារអភិរក្ស។ ក្រុមរៀបចំយុទ្ធនាការ តាមរយៈគេហទំព័រ ដូចជា Avaaz ដែលមានសមាជិក ៤៤ លាននាក់ ក្នុង ១៩៤ ប្រទេស បានជួយបង្កើនការយល់ដឹងអំពីបរិស្ថានតាមរយៈគំនិតផ្តួចផ្តើមនានា ដូចជា យុទ្ធនាការហាមឃាត់ការប្រើប្រាស់ថ្នាំកសិកម្មដែលសម្លាប់ឃ្មុំ រយៈពេល ២ ឆ្នាំ ជាដើម។

## ការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុទាមទារឲ្យមានការប្រើប្រាស់វិធីសាស្រ្តរៀនសូត្រចម្រុះមុខបញ្ចូលគ្នា

ការអប់រំបង្កើនភាពធន់របស់មនុស្សចំពោះហានិភ័យពាក់ព័ន្ធនឹងអាកាសធាតុ។ ការអប់រំក៏លើកទឹកចិត្តមនុស្សឲ្យផ្តល់ការគាំទ្រ និងចូលរួមក្នុងសកម្មភាពកាត់បន្ថយផលប៉ះពាល់ទាំងនេះផងដែរ។ ការពង្រីកលទ្ធភាពទទួលបានការអប់រំអំពីការទប់ទល់នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ មានប្រសិទ្ធភាពជាងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ដូចជា ជញ្ជាំងសមុទ្ទ និងប្រព័ន្ធធារាសាស្រ្ត ជាដើម។

> “ប្រសិនបើវឌ្ឍនភាពនៃការអប់រំនៅទ្រឹង នោះករណីមរណភាពពាក់ព័ន្ធ នឹងគ្រោះមហន្តរាយនាពេលអនាគត នឹងកើនឡើង ២០% ក្នុងមួយទសវត្សរ៍។”

ការអប់រំក្មេងស្រីកាត់បន្ថយករណីមរណភាព ពាក់ព័ន្ធនឹងគ្រោះមហន្តរាយ។ ការព្យាករបង្ហាញថា ប្រសិនបើវឌ្ឍនភាពនៃការអប់រំនៅទ្រឹងនោះករណីមរណភាពពាក់ព័ន្ធនឹងគ្រោះមហន្តរាយនាពេលអនាគត នឹងកើនឡើង ២០% ក្នុងមួយទសវត្សរ៍។ សហគមន៍ដែលងាយរងគ្រោះជាងគេ ដោយសារតែព្រឹត្តិការណ៍ពាក់ព័ន្ធនឹងអាកាសធាតុ ជាទូទៅ គឺជាសហគមន៍ ដែលស្ថិតក្នុងប្រទេស ដែលលកម្រិតវប្បធម៌មានកម្រិតទាប និងពុំមានសមភាព។

ការអប់រំអាចជួយសហគមន៍ឲ្យត្រៀមរៀបចំខ្លួន និងបន្សាំខ្លួនទៅនឹងគ្រោះមហន្តរាយ ពាក់ព័ន្ធនឹងអាកាសធាតុ។ ការសិក្សាមួយលើប្រទេសគុយបា សាធារណរដ្ឋដូមីនិច និងហៃទី បានរកឃើញថា កង្វះការអប់រំ និងអត្រាអក្ខរកម្មទាប រារាំងមនុស្សមិនឲ្យយល់ពីសញ្ញាព្រមានពីគ្រោះមហន្តរាយ។ ក្នុងប្រទេសហ្វីលីពីន សហគមន៍មូលដ្ឋានបានធ្វើការងារជាមួយនឹងមន្ត្រីអប់រំ និងដៃគូផ្សេងទៀត ដើម្បីបង្ហាត់បង្រៀនមនុស្សវ័យក្មេងអំពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ដែលជួយកសាងនូវភាពធន់របស់សហគមន៍។

# វិបុលភាព




@GEMReport #SDG4All bitly.com/sdg4all

# វិបុលភាព៖ សេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន

សេដ្ឋកិច្ចរបស់ពិភពលោក ចាំបាច់ត្រូវតែមាននិរន្តរភាពខាងបរិស្ថាន និងមានបរិយាប័ន្ន ប្រសិនបើគេចង់ឲ្យការអនុវត្តរបៀបវារៈឆ្នាំ ២០៣០ ទទួលបានជោគជ័យ។ ការអប់រំមានតួនាទីយ៉ាងសំខាន់ ដើម្បីធ្វើឲ្យមានការផ្លាស់ប្ដូរបែបនេះ។

ការអប់រំ និងការរៀនសូត្រពេញមួយជីវិត គឺជាអ្វីដែលចាំបាច់ត្រូវមាន ដើម្បីធ្វើឲ្យការផលិត និងការប្រើប្រាស់មាននិរន្តរភាព ផ្ដត់ផ្ដង់ជំនាញសម្រាប់បង្កើតឧស្សាហកម្មបៃតង និងតម្រង់ទិសការអប់រំថ្នាក់ឧត្ដមសិក្សា និងការស្រាវជ្រាវឆ្ពោះទៅរកនវានុវត្តន៍បៃតង។ ការអប់រំ និងការរៀនសូត្រពេញមួយជីវិតក៏មានតួនាទីសំខាន់ ក្នុងការធ្វើឲ្យមានការផ្លាស់ប្ដូរក្នុងវិស័យសេដ្ឋកិច្ចសំខាន់ៗ ដូចជា វិស័យកសិកម្ម ជាដើម ដែលជាវិស័យពឹងអាស្រ័យដោយប្រទេស និងគ្រួសារអ្នកមានផង និងអ្នកក្រផង។

ទន្ទឹមពេលដែលសេដ្ឋកិច្ចត្រូវតែមានចីរភាព សេដ្ឋកិច្ចក៏ត្រូវតែមានបរិយាប័ន្នជាងមុន និងកាត់បន្ថយវិសមភាពផងដែរ។ ការអប់រំដែលមានគុណភាពខ្ពស់ អាចរួមចំណែកសម្រេចគោលបំណងទាំងនេះបាន។ កម្លាំងពលកម្មដែលទទួលបានការអប់រំខ្ពស់ គឺជាកត្តាសំខាន់ចាំបាច់ ដើម្បីធ្វើឲ្យកំណើនសេដ្ឋកិច្ចមានបរិយាប័ន្ន ផ្ដោតលើសុខុមាលភាពរបស់មនុស្ស។ ការអប់រំកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើនឱកាសរកការងារសមរម្យបានធ្វើ និងទទួលបានចំណូលគ្រប់គ្រាន់ ក៏ដូចជាជួយបំបិទគម្លាតប្រាក់ឈ្នួល ដែលកើតឡើងដោយសារតែយេនឌ័រ ស្ថានភាពសង្គមសេដ្ឋកិច្ច និងមូលដ្ឋានផ្សេងទៀតនៃការរើសអើងផងដែរ។

## ការធ្វើឲ្យឧស្សាហកម្មមានពណ៌បៃតងនឹងបង្កើនតម្រូវការជំនាញ

ការអភិវឌ្ឍប្រកបដោយចីរភាព និងការអភិវឌ្ឍបៃតង មានន័យថាជាការបង្កើតឧស្សាហកម្មបៃតង និងធ្វើឲ្យឧស្សាហកម្មដែលមានស្រាប់ "មានភាពបៃតង"។ ឧស្សាហកម្មបៃតងកំពុងផ្ដល់ការងារដល់កម្មករនិយោជិតជាច្រើននាក់រួចទៅហើយ ហើយគេរំពឹងថាឧស្សាហកម្មប្រភេទនេះនឹងមានការរីកចម្រើនខ្លាំង ក្នុងបណ្ដាប្រទេសដែលមានចំណូលទាប។ ឧទាហរណ៍ ជិតពាក់កណ្ដាលនៃថាមពលអគ្គិសនី ដែលផលិតសរុបចន្លោះពីឆ្នាំ ២០១៥ ដល់ ២០៤០ មានប្រភពពីថាមពលកកើតឡើងវិញ ហើយបន្តមានការកើនឡើង ជាពិសេសក្នុងប្រទេសចិន ឥណ្ឌា អាមេរិចឡាទីន និងអាហ្វ្រិច។

ការបង្កើតឧស្សាហកម្មបៃតង ពឹងអាស្រ័យលើបុគ្គលិកដែលមានជំនាញកម្រិតខ្ពស់ ទទួលបានការអប់រំថ្នាក់ឧត្ដមសិក្សា និងការបណ្ដុះបណ្ដាលជាក់លាក់។ ដោយឡែកការធ្វើឲ្យឧស្សាហកម្មមានស្រាប់មានពណ៌បៃតង ទាមទារឲ្យមានការបន្តផ្ដល់ការអប់រំ និងការបណ្ដុះបណ្ដាលដល់កម្មករនិយោជិតដែលមានជំនាញកម្រិតទាប និងមធ្យម ដោយជារឿយៗ ក្នុងទម្រង់ជាការបណ្ដុះបណ្ដាលនៅនឹងកន្លែងធ្វើការផ្ទាល់។ អ្នកតាក់តែងគោលនយោបាយ និងអ្នកអប់រំ ជួបការលំបាកក្នុងការកំណត់ថាតើត្រូវបង្រៀនជំនាញណាខ្លះ នៅពេលដែលសេដ្ឋកិច្ចឆ្លងកាត់ការផ្លាស់ប្ដូរយ៉ាងឆាប់រហ័សបែបនេះ។

និរន្តរភាព និងកំណើនបៃតង តម្រូវឲ្យមានការបង្កើនការវិនិយោគឲ្យបានច្រើនលើការស្រាវជ្រាវ និងការអភិវឌ្ឍ។ ដើម្បីឲ្យប្រព័ន្ធអប់រំឧត្ដមសិក្សាអាចផ្ដល់ចំណេះដឹង និងជំនាញឯកទេសដល់មនុស្សគ្រប់ចំនួន គេចាំបាច់ត្រូវរៀបចំនូវកម្មវិធីសិក្សាចម្រុះ និងជាក់លាក់ រួមនឹងកម្មវិធីសិក្សាបែបសហការគ្នាចម្រុះវិស័យ។ ទីភ្នាក់ងារថាមពលអន្តរជាតិធ្វើការប៉ាន់ប្រមាណថា រដ្ឋាភិបាលចាំបាច់ត្រូវបង្កើនការងារស្រាវជ្រាវ និងអភិវឌ្ឍន៍វិស័យថាមពល ឲ្យបានរហូតដល់ ៥ ដង រៀងរាល់ឆ្នាំ ដើម្បីឲ្យមានការផ្លាស់ទៅរកថាមពលដែលបញ្ចេញជាតិកាបូនទាប។

## ការអប់រំអាចជួយធ្វើឲ្យមានការផ្លាស់ប្ដូរក្នុងវិស័យកសិកម្ម

វិស័យកសិកម្មទូទាំងពិភពលោកកំពុងជួបប្រទះនឹងបញ្ហាប្រឈម ដែលមិនធ្លាប់កើតឡើងកន្លងមក ចាប់ពីឆ្នាំ ២០១៥ ដល់ ២០៣០។ វិស័យនេះ គឺជាវិស័យមួយ ក្នុងចំណោមវិស័យនានារបស់សេដ្ឋកិច្ច ដែលទទួលរងផលប៉ះពាល់ផ្ទាល់ជាងគេ ដោយសារការរិចរឹលនៃបរិស្ថាន ហើយក៏ជាវិស័យ ដែលទទួលខុសត្រូវលើការបំភាយឧស្ម័នផ្ទះកញ្ចក់មួយភាគបីផងដែរ។ ក្នុងពេលជាមួយគ្នា កំណើនចំនួនប្រជាជន តម្រូវឲ្យមានការបង្កើនផលិតកម្មអាហារដ៏ច្រើន ប៉ុន្តែតាមបែបផែនដែលមាននិរន្តរភាព ក៏ដូចជាការបែងចែកផ្គត់ផ្គង់អាហារឲ្យកាន់តែមានសមធម៌ជាងមុន។

> “ កម្មវិធីអក្ខរកម្ម និងកម្មវិធីផ្សព្វផ្សាយកសិកម្ម អាចជួយឲ្យកសិករ បង្កើនផលិតភាព រហូតដល់ ១២%។ ”

ការអប់រំ គឺជាកត្តាសំខាន់ ដើម្បីឲ្យផលិតកម្មអាហារមាននិរន្តរភាព។ ការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា ផ្តល់ឲ្យសិស្សដែលមានបំណងចង់ក្លាយជាកសិករនូវជំនាញជាមូលដ្ឋាន ក៏ដូចជាចំណេះដឹងសំខាន់ៗ អំពីបញ្ហាប្រឈមពាក់ព័ន្ធនឹងនិរន្តរភាពក្នុងវិស័យកសិកម្ម។ គោលនយោបាយស្តីពីជំនាញ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ អាចភ្ជាប់គម្លាតរវាងកសិករ និងបច្ចេកវិទ្យាថ្មីៗ។ កម្មវិធីអក្ខរកម្ម និងកម្មវិធីផ្សព្វផ្សាយកសិកម្ម អាចជួយឲ្យកសិករបង្កើនផលិតភាព។ ការស្រាវជ្រាវកសិកម្ម ដែលផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងការអប់រំកម្រិតឧត្តមសិក្សា ជួយនាំឲ្យមាននវានុវត្តន៍ ដែលជាកត្តានាំឲ្យមាននិរន្តរភាពមានការកើនឡើង។ បើទោះជាបែបនេះក៏ដោយ ប្រទេស និងអ្នកផ្តល់ជំនួយជាច្រើនបែរជាលែងវិនិយោគ ឬកាត់បន្ថយការវិនិយោគលើការស្រាវជ្រាវបែបនេះទៅវិញ។ចំណុចគួរឲ្យកត់សម្គាល់ភាគរយនៃការចំណាយលើប្រទេសអាហ្វ្រិចសាប់សាហារ៉ាគិតជាភាគរយនៃចំណាយជាសកលលើការស្រាវជ្រាវជាសាធារណៈលើវិស័យកសិកម្ម មានការថយចុះពី ១០% ក្នុងឆ្នាំ ១៩៦០ មក ៦% ក្នុងឆ្នាំ ២០០៩។

## ការអប់រំ និងការរៀនសូត្រពេញមួយជីវិត រួមចំណែកនាំឲ្យមានកំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែង

ការកើនឡើងនូវចំនួនអ្នកដែលទទួលបានការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា រួមចំណែកនាំឲ្យមានកំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែង។ កម្រិតដំបូងៗនៃការទទួលបានការអប់រំរបស់ប្រជាពលរដ្ឋ នៅអាស៊ីបូព៌ា និងអាហ្វ្រិចសាប់សាហារ៉ា អាចពន្យល់បានពាក់កណ្តាលនៃមូលហេតុដែលនាំឲ្យមានភាពខុសប្លែកគ្នានៃអត្រាកំណើនរវាងក្រុមប្រទេសទាំងពីរ ចន្លោះពីឆ្នាំ ១៩៦៥ និង ២០១០។

ការអប់រំដែលមានគុណភាពល្អ និងកម្មករនិយោជិតដែលមានជំនាញកម្រិតខ្ពស់ ជម្រុញឲ្យផលិតភាពមានការកើនឡើង និងឲ្យមានការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ។ភាពខុសប្លែកគ្នាខាងគុណភាពនៃប្រព័ន្ធអប់រំជួយពន្យល់ពី“ភាពអច្ឆរិយៈ”នៃកំណើនសេដ្ឋកិច្ចរបស់បណ្តាប្រទេសនៅអាស៊ីបូព៌ា និង “ទសវត្សរ៍នៃការខាតបង់” នៅអាមេរិចឡាទីន។ ដើម្បីឲ្យប្រទេសនានាមានការរីកចម្រើន ការវិនិយោគលើការអប់រំកម្រិតមធ្យមសិក្សា និងឧត្តមសិក្សាប្រកបដោយគុណភាពគឺជាអ្វីដែលត្រូវធ្វើខាងតែបាន ជាពិសេស នៅប្រទេសអាហ្វ្រិចសាប់សាហារ៉ា ដែលអត្រារួមនៃការសិក្សានៅកម្រិតឧត្តមសិក្សាមានត្រឹមតែ ៨% ប៉ុណ្ណោះ ក្នុងឆ្នាំ ២០១៤។

> “ ត្រឹមឆ្នាំ ២០២០ ពិភពលោកអាចមានកម្មករនិយោជិតដែលមានកម្រិតវប្បធម៌ឧត្តមសិក្សាត្រឹមតែ ៤០ លាននាក់ប៉ុណ្ណោះ ដែលនេះជាចំនួនមួយតិចតួចខ្លាំង បើធៀបជាមួយនឹងតម្រូវការ។ ”

ប្រសិនបើការអប់រំនៅតែបន្តបំពេញតួនាទីជម្រុញកំណើននិងការអភិវឌ្ឍ ការអប់រំត្រូវតាមឲ្យទាន់ល្បឿននៃការ ផ្លាស់ប្តូរយ៉ាងឆាប់រហ័សក្នុងពិភពការងារ។ បច្ចេកវិទ្យាមិនត្រឹមតែបង្កើនតម្រូវការ កម្មករនិយោជិតដែលមានជំនាញកម្រិតខ្ពស់ប៉ុណ្ណោះទេប៉ុន្តែក៏បានកាត់បន្ថយតម្រូវការសម្រាប់ការងារជំនាញកម្រិតមធ្យមដូចជាស្មៀន ភ្នាក់ងារលក់ និងការីម៉ាស៊ីន ជាដើម ដែលការងារទាំងអស់នេះងាយស្រួលធ្វើជាងដោយប្រើប្រាស់ម៉ាស៊ីន។ ការផ្លាស់ប្តូរបែបនេះ អាចមានផលប៉ះពាល់ដល់មនុស្សរាប់លាននាក់ នាពេលអនាគត។ ក្នុងឆ្នាំ ២០១៥ ក្នុងចំណោមការងារសរុប មានតិចជាងពីរភាគបីបន្តិចដែលជាការងារប្រើប្រាស់ជំនាញកម្រិតមធ្យម។

ភស្តុតាងនានាបង្ហាញថា ប្រព័ន្ធអប់រំភាគច្រើន តាមមិនទាន់តម្រូវការទីផ្សារឡើយ។ ត្រឹមឆ្នាំ ២០២០ ពិភពលោកអាចមានកម្មករនិយោជិតដែលមានកម្រិតវប្បធម៌ឧត្តមសិក្សាត្រឹមតែ ៤០ លាននាក់ប៉ុណ្ណោះ ដែលនេះជាចំនួនមួយតិចតួចខ្លាំង បើធៀបជាមួយនឹងតម្រូវការ ហើយមានកម្មករនិយោជិតដែលមានកម្រិតវប្បធម៌ទាបជាងនេះដល់ទៅ៩៥លាននាក់ដែលជាចំនួនមួយច្រើនពេក ធៀបជាមួយនឹងតម្រូវការ។

ជំនាញ និងសមត្ថភាព ដែលផ្តល់ដោយការអប់រំចំណេះទូទៅគ្រប់ជ្រុងជ្រោយ ដូចជា ជំនាញគិតល្អិតល្អន់ ដោះស្រាយបញ្ហា ការងារក្រុមនិងការងារគម្រោងនិងជំនាញអក្ខរកម្មប្រាស្រ័យទាក់ទងនិងជំនាញធ្វើបទឧទ្ទេសនាម-ទំនងជានៅតែជាជំនាញនិងសមត្ថភាពដែលមានតម្លៃក្នុងទីផ្សារការងារ។ ដូច្នេះ ការរៀនចេះជំនាញមូលដ្ឋាន និងជំនាញដែលអាចយកទៅប្រើប្រាស់បានច្រើនកាលៈទេសៈ មានសារៈសំខាន់យ៉ាងខ្លាំង សម្រាប់ការងារនាពេលអនាគត។ បញ្ហាប្រឈមសម្រាប់ប្រព័ន្ធអប់រំ គឺថាតើត្រូវផ្តល់ជំនាញ និងសមត្ថភាពទាំងនេះឲ្យមានប្រសិទ្ធភាពខ្ពស់បំផុត ដោយរបៀបណា។

## ការអប់រំអាចគាំទ្រឲ្យមានបរិយាប័ន្នសង្គម

ការអប់រំ មានសារៈសំខាន់ ដើម្បីធានាយ៉ាងណាឲ្យកំណើនសេដ្ឋកិច្ចគឺជាកំណើនដែលមាននិរន្តរភាព និងមិនទុកអ្នកណាម្នាក់ចោល។ ការអប់រំជំរុញកំណើន បង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋដែលមានជីវភាពក្រីក្រជាងគេ និងប្រសិនបើមានការបែងចែកប្រកបដោយសមធម៌ ការអប់រំក៏អាចកាត់បន្ថយវិសមភាពផងដែរ។ ប្រសិនបើរដ្ឋចំនួន ១០ ដែលទើបចូលជាសមាជិករបស់សហភាពអឺរ៉ុបកាលពីពេលថ្មីៗនេះ អាចសម្រេចតាមចំណុចដៅ ២០២០ ពាក់ព័ន្ធនឹងការកាត់បន្ថយការឆាប់បោះបង់ចោលការសិក្សា និងបង្កើនការចូលរៀននៅថ្នាក់ឧត្តមសិក្សា នោះចំនួនអ្នកដែលងាយធ្លាក់ចូលទៅក្នុងភាពក្រីក្រអាចមានការថយចុះចំនួន ៣,៧ លាននាក់។

ប៉ុន្តែ ការបង្កើនការបណ្តុះបណ្តាល និងជំនាញ មិនមែនសុទ្ធតែនាំឲ្យមានការថយចុះនូវវិសមភាពសង្គមនោះទេ។ ទន្ទឹមគ្នានឹងកិច្ចខិតខំប្រឹងប្រែងពង្រីកការអប់រំប្រកបដោយសមធម៌ រដ្ឋាភិបាលចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់លើគោលនយោបាយសង្គមដែលធ្វើការបែងចែកភាគផលសារជាថ្មី ដើម្បីផ្លាស់ប្តូរនិន្នាការដែលកំពុងធ្វើឲ្យវិសមភាពចំណូលក្នុងប្រទេសមានការកើនឡើង។

## ការអប់រំធ្វើឲ្យលទ្ធផលក្នុងទីផ្សារការងារកាន់តែមានលក្ខណៈល្អប្រសើរ

អត្រាអ្នកគ្មានការងារធ្វើ កាន់តែមានកម្រិតទាប ក្នុងចំណោមអ្នកដែលមានកម្រិតវប្បធម៌កាន់តែខ្ពស់ ជាពិសេស ក្នុងប្រទេសអ្នកមាន។ ក្នុងប្រទេសដែលជាសមាជិកអង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) មានមនុស្សពេញវ័យអាយុចន្លោះពី ២៥ ដល់ ៦៤ ឆ្នាំ ដែលមានកម្រិតវប្បធម៌តិចជាងមធ្យមសិក្សាទុតិយភាព ត្រឹមតែ ៥៥% ប៉ុណ្ណោះ ដែលមានការងារធ្វើ ក្នុងឆ្នាំ ២០១៣ បើធៀបជាមួយនឹងតួលេខ៧៣%សម្រាប់អ្នកដែលមានកម្រិតវប្បធម៌មធ្យមសិក្សាទុតិយភូមិឬកម្រិតវប្បធម៌មិនមែនឧត្តមសិក្សានិង៨៣%សម្រាប់អ្នកដែលមានកម្រិតវប្បធម៌ឧត្តមសិក្សា។ ក្នុងប្រទេសក្រីក្រ ទំនាក់ទំនងបែបនេះ ជារឿយៗ មានកម្រិតខ្សោយ ក្នុងចំណោមយុវជនដែលមានន័យថាតម្រូវការកម្លាំងពលកម្មជំនាញមានកម្រិតទាប ហើយប្រព័ន្ធអប់រំពុំបានបំពាក់បំប៉នសិស្សនូវជំនាញសម្រាប់ឆ្លើយតបចំពោះទីផ្សារការងារឡើយ។

ការកាត់បន្ថយវិសមភាពនៃការអប់រំ អាចបង្កើនលទ្ធភាពទទួលបានការងារសមរម្យ សម្រាប់ក្រុមដែលជួបការលំបាក។ ការវិភាគដែលធ្វើឡើងសម្រាប់របាយការណ៍ GEM ២០១៦ នេះ មានន័យថាប្រសិនបើកម្មករនិយោជិតមកពីក្រុមសង្គមមានប្រៀប និងចាញ់ប្រៀប ទទួលបានការអប់រំដូចគ្នា ពេលនោះគម្លាតនៃភាពក្រីក្ររបស់អ្នកមានការងារធ្វើអាចថយចុះបាន ៣៩%។

ការអប់រំមានទំនាក់ទំនងយ៉ាងច្បាស់លាស់ជាមួយនឹងប្រាក់ចំណូល។ក្នុងប្រទេសចំនួន១៣៩អត្រានៃការទទួលបានផលមកវិញពីការរៀនសូត្របន្ថែមមួយឆ្នាំគឺ ៩,៧%។ អត្រានៃការទទួលបានផលមកវិញបែបនេះ មានកម្រិតខ្ពស់បំផុតក្នុងប្រទេសក្រីក្រ ដែលខ្វះកម្មករនិយោជិតមានជំនាញ។ ប៉ុន្តែ ការធានាយ៉ាងណាឲ្យសិស្សទទួលបានប្រយោជន៍ច្រើនបំផុតពីកម្រិតវប្បធម៌កាន់តែខ្ពស់ ទាមទារឲ្យការវិនិយោគលើការអប់រំដើរទន្ទឹមគ្នានឹងការអនុវត្តគោលនយោបាយសេដ្ឋកិច្ច ដែលបង្កើនតម្រូវការកម្លាំងពលកម្មជំនាញ។

**រូបភាពទី២ :**

**នៅពេលដែលកម្រិតវប្បធម៌កាន់តែមានការកើនឡើង អត្រានៃភាពក្រីក្ររបស់អ្នកមានការងារធ្វើកាន់តែមានការថយចុះ**

ភាពក្រីក្ររបស់អ្នកមានការងារធ្វើ (ក្រោម ៥០% នៃកម្រិតមេដ្យាននៃចំណូលប្រចាំសប្តាហ៍) តាមកម្រិតវប្បធម៌ ក្នុងប្រទេសដែលមានចំណូលទាប និងមធ្យមចំនួន ១២




*កម្រិតវប្បធម៌ត្រូវបានដកចេញ ដោយសារតែការសង្កេតមានចំនួនតិច

សម្គាល់៖ សំណាកគំរូនេះ គឺសម្រាប់តំបន់ប្រជុំជន។ សំណាកគំរូនេះគ្របដណ្តប់តែលើកម្មករនិយោជិតធ្វើការពេញម៉ោង (យ៉ាងហោចណាស់ ៣០ ម៉ោង ក្នុងមួយសប្តាហ៍) អាយុពី ១៥ ដល់ ៦៤ ឆ្នាំតែប៉ុណ្ណោះ។

ប្រភព៖ ការគណនារបស់ក្រុមរៀបចំរបាយការណ៍ GEM ផ្អែកតាមទិន្នន័យដែលបានពីការអង្កេតវាស់វែងជំនាញ STEP របស់ធនាគារពិភពលោក (២០១២-២០១៣)

ខណៈពេលដែលកំណើនបៃតងផ្តល់នូវឱកាសជាច្រើនសម្រាប់ពង្រីកចំនួនការងារ ការបាត់បង់ការងារទៅវិញ គឺជាអ្វីដែលមិនអាចចៀសរួច នៅពេលដែលឧស្សាហកម្មដែលពុំមាននិរន្តរភាពខាងបរិស្ថានត្រូវបិទទ្វារ។ ចាំបាច់ត្រូវតែមានគោលនយោបាយពង្រីកការរៀនសូត្រពេញមួយជីវិត ដើម្បីជម្រុញលើកកម្ពស់កម្មវិធីអប់រំ និងបណ្តុះបណ្តាល ដែលផ្តល់លទ្ធភាពឲ្យកម្មករនិយោជិតដែលអត់ការងារធ្វើ អាចចាប់យកការងារថ្មីៗ។



បុរសម្នាក់ឈរក្នុងចំការដំឡូងមី ដែលដាំដោយប្រើប្រាស់បច្ចេកទេសល្អជាងមុន នៅក្នុងខេត្តប៊ិកូកូ នៃសាធារណរដ្ឋអាហ្វ្រិចកណ្តាល

ថតដោយ ៖ Riccardo Gangale/FAO




@GEMReport #SDG4All bitly.com/sdg4all

# មនុស្ស៖ ការអភិវឌ្ឍសង្គមបែបបរិយាប័ន្ន

ការអភិវឌ្ឍសង្គម នាំឲ្យមានការលើកកម្ពស់សុខុមាលភាពមនុស្ស និងសមភាព និងជាអ្វីដែលត្រូវកើតមានទន្ទឹមគ្នានឹងប្រជាធិបតេយ្យ និងយុត្តិធម៌។ ការអប់រំ គឺជាកត្តាដ៏មានឥទ្ធិពលដែលនាំឲ្យមានការអភិវឌ្ឍសង្គម និងជាចំណុចមួយដ៏សំខាន់នៃការអភិវឌ្ឍសង្គម។ ការអប់រំ មានសារៈសំខាន់ ដើម្បីធានាយ៉ាងណាឲ្យមនុស្សអាចរស់នៅដោយមានសុខភាពល្អ និងធ្វើឲ្យជីវិតកូនៗរបស់ពួកគេកាន់តែមានលក្ខណៈល្អប្រសើរ។ ការអប់រំអាចបង្កើនសមភាពយេនឌ័រ តាមរយៈការផ្តល់ភាពអង់អាចដល់ក្រុមដែលងាយរងគ្រោះដែលភាគច្រើនជាក្មេងស្រី និងស្ត្រី។

ការអប់រំមានទំនាក់ទំនងទៅវិញទៅមកជាមួយនឹងវិស័យផ្សេងទៀត ដូចដែលសុខភាព អាហារូបត្ថម្ភ ទឹក និងប្រភពថាមពលមានសារៈសំខាន់ចំពោះការអប់រំដែរ។ សុខភាពរបស់កុមារជាកត្តាកំណត់ពីសមត្ថភាពរបស់ពួកគេក្នុងការរៀនសូត្រ។ គេអាចប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសុខភាពដើម្បីផ្តល់ការអប់រំ ហើយគ្រូដែលមានសុខភាពល្អ គឺសំខាន់មិនអាចអត់បាន ដើម្បីឲ្យវិស័យអប់រំដំណើរការបានល្អ។

ចុងក្រោយ គេចាំបាច់ត្រូវប្រើប្រាស់វិធីសាស្ត្រអភិវឌ្ឍន៍មនុស្សដែលក្តោបរួមលើគ្រប់ទិដ្ឋភាពទាំងអស់ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនៃភាពក្រីក្រ ដែលមានលក្ខណៈចម្រុះវិស័យ។

## ការអភិវឌ្ឍសង្គមបែបបរិយាប័ន្ន មានសារៈសំខាន់ ដើម្បីឲ្យអនាគតមាននិរន្តរភាពសម្រាប់យើងទាំងអស់គ្នា

ការអភិវឌ្ឍសង្គមប្រកបដោយបរិយាប័ន្ន ទាមទារឲ្យមានការផ្តល់សេវាសំខាន់ៗ ដូចជា សេវាអប់រំ សុខភាព ទឹក អនាម័យ ថាមពល លំនៅដ្ឋាន និងសេវាដឹកជញ្ជូនដល់ប្រជាពលរដ្ឋគ្រប់រូប ដែលបច្ចុប្បន្ននេះ នៅមិនទាន់សម្រេចបាននៅឡើយ។ បើទោះបីជាមានការសម្រេចនូវវឌ្ឍនភាពក៏ដោយ សមភាពយេនឌ័រពិតប្រាកដ នៅតែមិនទាន់មាននៅឡើយ ក្នុងប្រទេសភាគច្រើន ឧទាហរណ៍ ស្ត្រីត្រូវធ្វើការងារមិនបានកម្រៃច្រើនជាងបុរសដល់ទៅពីរដង ហើយជារឿយៗ ពួកគេធ្វើការងារក្នុងវិស័យមិនរៀបរយ។

> “ស្ត្រីត្រូវធ្វើការងារ មិនបានកម្រៃច្រើនជាង បុរសដល់ទៅពីរដង។”

ការអភិវឌ្ឍសង្គមបែបបរិយាប័ន្ន ទាមទារឲ្យមានការឆ្លើយតបចំពោះការមិនមានផ្តល់ឱកាស និងការរើសអើងលើស្ត្រី ជនពិការ ជនជាតិដើមភាគតិច ក្រុមជនជាតិភាគតិច និងក្រុមនិយាយភាសាភាគតិច ជនភៀសខ្លួននិងជនភាសឹកក៏ដូចជាក្រុមងាយរងគ្រោះផ្សេងទៀត។ដើម្បីធ្វើការផ្លាស់ប្តូរបទដ្ឋានដែលមានលក្ខណៈរើសអើងនិងផ្តល់ភាពអង់អាចដល់ស្ត្រី និងបុរស គេអាចធ្វើការកែលំអការអប់រំ និងចំណេះដឹងដែលផ្តល់តាមរយៈការអប់រំបន្ថែមទៀត ដើម្បីជះឥទ្ធិពលលើគុណតម្លៃ និងឥរិយាបថនានា។

ក្រុមជាច្រើនមានឱកាសតិចតួចក្នុងការទទួលបានការអប់រំប្រកបដោយគុណភាព ដូចជា ក្រុមភាគតិចខាងពូជសាសន៍ ជាតិពន្ធុ និងភាសា ជនពិការ កសិករចិញ្ចឹមសត្វពាហនៈ អ្នករស់នៅតំបន់ក្រីក្រ កុមារផ្ទុកមេរោគអេដស៍ កុមារ “ដែលមិនបានចុះអត្រានុកូលដ្ឋានត្រឹមត្រូវ” និងកុមារកំព្រា។ ភាពខុសប្លែកគ្នាខាងចំណូល ទីតាំង ជាតិពន្ធុ និងយេនឌ័រ នាំឲ្យមានការបាត់បង់ឱកាសទទួលបានការអប់រំតាមបែបផែនខុសៗគ្នាដែរ ក្នុងប្រទេសមួយ។ ភាពក្រីក្រ គឺជាឧបសគ្គធំបំផុត ចំពោះការអប់រំ។ ក្នុងចំណោមអ្នកដែលមានអាយុពី ២០ ដល់ ២៤ ឆ្នាំ ក្នុងប្រទេសចំណូលទាប និងមធ្យមចំនួន ១០១ អ្នកដែលក្រីក្រជាងគេទទួលបានការអប់រំតិចជាងអ្នកដែលមានជីវភាពធូរធាជាងគេជាមធ្យម ៥ ឆ្នាំ។ គម្លាតបែបនេះគឺ ២,៦ ឆ្នាំ រវាងអ្នករស់នៅទីក្រុង និងជនបទ និង ១,១ ឆ្នាំ រវាងស្ត្រី និងបុរស។

កត្តាទាំងនេះក៏តែងត្រួតគ្នាផងដែរ។ឧទាហរណ៍ស្ត្រីដែលមានប្រវត្តិជួបការលំបាកដោយសារតែភាពក្រីក្រជាតិពន្ធុឬទីកន្លែងដែលខ្លួនរស់នៅ ត្រូវជួបនឹងស្ថានភាពអន់ឆ្ងាយជាងបុរស ដែលមានប្រវត្តិដូចគ្នានេះ។ ក្នុងប្រទេសភាគច្រើន ស្ត្រីក្រីក្ររស់នៅទីជនបទតិចជាងពាក់កណ្តាល មានជំនាញអក្ខរកម្មត្រឹមកម្រិតមូលដ្ឋានប៉ុណ្ណោះ។ ក្នុងប្រទេសមួយចំនួន ដូចជា អាហ្គាហ្វនីស្ថាន បេនីន អេត្យូពី ហ្គីនី ប៉ាគីស្ថាននិងស៊ូដង់ខាងត្បូងជាដើមដែលមានគម្លាតឃ្លាតគ្នាខ្លាំងមែនទែនស្ត្រីវ័យក្មេងដែលមានជីវភាពក្រីក្រជាងគេ បានរៀនត្រឹមក្រោមមួយឆ្នាំប៉ុណ្ណោះ។

## ការអប់រំធ្វើឲ្យលទ្ធផលនៃការអភិវឌ្ឍសង្គមកាន់តែប្រសើរជាងមុន

ការអប់រំអាចធ្វើឲ្យលទ្ធផលនៃការអភិវឌ្ឍសង្គមកាន់តែប្រសើរជាងមុន នៅតាមវិស័យជាច្រើន ជាពិសេស សុខភាព និងមុខមាត់របស់ស្ត្រី។ ការអប់រំផ្តល់នូវជំនាញ និងចំណេះដឹងជាក់លាក់អំពីសុខភាព និងអាហារូបត្ថម្ភ ធ្វើឲ្យមានការផ្លាស់ប្តូរឥរិយាបថ ដែលនាំឲ្យស្ថានភាពសុខភាពកាន់តែប្រសើរជាងមុន។ ក្នុងប្រទេសឥណ្ឌា ឥណ្ឌូនេស៊ី ប៉ាពួហ្គីណេថ្មី និងសាធារណរដ្ឋតង់ហ្សានី អ្នកជំងឺក្រីក្រដែលទទួលបានការអប់រំទាប ទទួលបានសេវាតែពីវេជ្ជបណ្ឌិតដែលមិនសូវមានសមត្ថភាពប៉ុណ្ណោះ។

អន្តរាគមន៍តាមសាលារៀនដូចជាយុទ្ធនាការផ្តល់អាហារនិងយុទ្ធនាការសុខភាពជាដើមអាចមានឥទ្ធិពលភ្លាមៗលើសុខភាព។ ការផ្តល់អាហារតាមសាលារៀនអាចបង្កើនវត្តមានរបស់សិស្សផងដែរ។ នៅតំបន់ជនបទភាគខាងជើងនៃប្រទេសប៊ើគីណាហ្វាសូ ការផ្តល់អាហារថ្ងៃត្រង់ប្រចាំថ្ងៃនៅសាលារៀន និងការផ្តល់អាហារឲ្យសិស្សបានយកទៅផ្ទះវិញ បានបង្កើនអត្រាចូលរៀនរបស់សិស្សស្រីពី ៥ ទៅ ៦ ភាគរយចំណុច ក្រោយពេលដែលយុទ្ធនាការនេះអនុវត្តបានមួយឆ្នាំ។

អន្តរាគមន៍តាមសាលារៀន អាចផ្តល់ព័ត៌មានអំពីសុខភាព និងនាំឲ្យមានការផ្លាស់ប្តូរឥរិយាបថ។ អន្តរាគមន៍ជាច្រើនដែលផ្តោតលើទឹកស្អាត និងអនាម័យ តាមសាលារៀន ធ្វើឲ្យសុខភាព សេដ្ឋកិច្ច និងសមធម៌យេនឌ័រមានការកើនឡើង។ ក្នុងប្រទេសហ្វាំងឡង់ អាហារដែលផ្តល់នៅតាមសាលារៀន ត្រូវបានគេចាត់ទុកថាជាការវិនិយោគលើការរៀនសូត្រនិងជាវិធីមួយដើម្បីបង្រៀនពីទម្លាប់ហូបចុកដែលនៅជាប់ជាមួយនឹងសិស្សបានយូរអង្វែង ក៏ដូចជាបង្កើនការយល់ដឹងអំពីជម្រើសអាហារ។

> “គេប៉ាន់ប្រមាណថា ការអប់រំបន្ថែម ៤ ឆ្នាំ ក្នុងសាលារៀន នៅប្រទេសនីហ្សេរីយ៉ា អាចកាត់បន្ថយអត្រាសាយកូនបានមួយនាក់សម្រាប់ក្មេងស្រីម្នាក់។”

ទាំងបុគ្គល ទាំងសង្គម សុទ្ធតែអាចទទួលបានប្រយោជន៍ នៅពេលដែលក្មេងស្រី និងស្ត្រី បានទទួលការអប់រំដែលមានគុណភាពល្អជាងមុន។ ការអប់រំពង្រីកឱកាសការងាររបស់ស្ត្រី។ ជំនាញអក្ខរកម្មជួយឲ្យស្ត្រីទទួលបានព័ត៌មានអំពីសិទ្ធិសង្គម និងសិទ្ធិស្របច្បាប់ ក៏ដូចជាសេវាសុខុមាលភាព។ ការអប់រំអាចបង្កើនការចូលរួមក្នុងវិស័យនយោបាយរបស់ស្ត្រី តាមរយៈការផ្តល់នូវជំនាញ ដែលផ្តល់លទ្ធភាពឲ្យពួកគេអាចចូលរួម ក្នុងដំណើរការប្រជាធិបតេយ្យបាន។ ការអប់រំដែលមានកម្រិតទាប គឺជាកត្តាហានិភ័យដ៏សំខាន់មួយ ដែលនាំឲ្យមានអំពើហិង្សាដៃគូស្និទ្ធស្នាល។

ម្តាយដែលទទួលបានការអប់រំកាន់តែច្រើន កាន់តែអាចចិញ្ចឹមកូនបានល្អ និងរក្សាកូនឲ្យនៅតែមានសុខភាពល្អ។ ការអប់រំរបស់ម្តាយក៏មានឥទ្ធិពលតជំនាន់ផងដែរ ពោលគឺអាចផ្លាស់ប្តូរអាទិភាពក្នុងគ្រួសារ និងបទដ្ឋានសង្គម។ គេប៉ាន់ប្រមាណថា ការអប់រំបន្ថែម ៤ឆ្នាំក្នុងសាលារៀននៅប្រទេសនីហ្សេរីយ៉ាអាចកាត់បន្ថយអត្រាសាយកូនបានមួយនាក់សម្រាប់ក្មេងស្រីម្នាក់។ការអប់រំរយៈពេលខ្លីដែលផ្តល់ការគាំទ្រដល់ម្តាយដែលមានកូនតូច អាចមានឥទ្ធិពលធំធេងមកលើសុខភាព និងអាហារូបត្ថម្ភរបស់ពួកគេ។ ការអប់រំក្រៅប្រព័ន្ធចំគោលដៅ អាចមានប្រសិទ្ធភាព ក្នុងការជួយឲ្យស្ត្រីរៀបចំផែនការសម្រាប់ការមានកូនរបស់ពួកគេ។

ការអប់រំអាចកាត់បន្ថយអត្រាមរណភាពមាតា។ ការបង្កើនការអប់រំដល់ស្ត្រីពី ០ ដល់ ១ ឆ្នាំ អាចបង្ការមរណភាពមាតាបាន ១៧៤ ករណី ក្នុង ១០០០០០ កំណើត។

**រូបភាពទី៣ :**

**មានការសម្រេចបាននូវវឌ្ឍនភាពជាច្រើន ក្នុងការលើកកម្ពស់ការអប់រំថ្នាក់មូលដ្ឋាន និងលទ្ធផលខាងសុខភាព ក៏ដូចជាការផ្តល់នូវសេវាជាមូលដ្ឋានសំខាន់ៗ ប៉ុន្តែបញ្ហាប្រឈមធំៗនៅតែមាន។ ការរីកចម្រើនខាងការទទួលបានសេវាជាមូលដ្ឋាន និងលទ្ធផលខាងសុខភាព និងការអប់រំ រវាងឆ្នាំ ២០០០ និងឆ្នាំចុងក្រោយ**




សម្គាល់៖ "ឆ្នាំចុងក្រោយ" គឺឆ្នាំ ២០១២ សម្រាប់ការទទួលបានឥន្ធនៈមិនមែនជាប្រភេទឥន្ធនៈរឹងទៅប្រើប្រាស់ និងការមានអគ្គិសនីប្រើប្រាស់។ ឆ្នាំ ២០១៤ សម្រាប់អត្រារួមនៃការចុះឈ្មោះចូលរៀនថ្មី រហូតដល់ថ្នាក់ចុងក្រោយនៃកម្រិតបឋមសិក្សា និង ២០១៥ សម្រាប់អត្រាមរណភាពកុមារអាយុក្រោម ៥ ឆ្នាំ និងការមានទឹកស្អាត និងបរិក្ខារអនាម័យប្រើប្រាស់។
ប្រភព៖ មូលដ្ឋានទិន្នន័យរបស់ UIS និងធនាគារពិភពលោក (២០១៦)

## ការអភិវឌ្ឍសង្គមមានឥទ្ធិពលលើការអប់រំ

ដូចគ្នានឹងការដែលការអប់រំមានឥទ្ធិពល ជាវិជ្ជមានលើការអភិវឌ្ឍសង្គម ការអភិវឌ្ឍសង្គមក៏មានឥទ្ធិពលលើការអប់រំផងដែរ ទាំងវិជ្ជមាន ទាំងអវិជ្ជមាន ប្រសិនបើការអភិវឌ្ឍសង្គមកើតឡើង មិនតាមបែបបរិយាប័ន្ន។ សុខភាព និងអាហារូបត្ថម្ភគឺជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធអប់រំ។ សុខភាព និងអាហារូបត្ថម្ភ ជាលក្ខខណ្ឌកំណត់ពីសមត្ថភាពរបស់កុមារដើម្បីអាចទៅសាលារៀននិងទទួលបានការរៀនសូត្រ ក៏ដូចជាលទ្ធភាពរបស់គ្រួសារ ដើម្បីផ្តល់ការគាំទ្រដល់ពួកគេ។ ក្នុងប្រទេសកេនយ៉ា ក្មេងស្រីដែលបានទទួលថ្នាំទម្លាក់ព្រូន អាចមានលទ្ធភាពជាប់ប្រលងបញ្ចប់បឋមសិក្សាថ្នាក់ជាតិច្រើនជាងក្មេងស្រីដែលមិនបានទទួលដល់ទៅ២៥%។ ជីវភាពរស់នៅនៅវ័យកុមារតូច ក៏មានសារៈសំខាន់សម្រាប់ការរៀនសូត្រផងដែរ។ ការទទួលបានសេវាថែទាំសុខភាពដែលមានគុណភាពល្អ សម្រាប់គ្រូ អាចកាត់បន្ថយអត្រាអវត្តមាន និងអត្រាឈប់របស់គ្រូបង្រៀនផងដែរ។

ការទទួលបានទឹកស្អាត អនាម័យ និងថាមពល មានឥទ្ធិពលជាវិជ្ជមានលើការអប់រំ។ ក្នុងប្រទេសហ្គាណា ការកាត់បន្ថយរយៈពេលទៅដងទឹកពាក់កណ្តាល ធ្វើឲ្យវត្តមានរបស់សិស្សស្រីក្នុងសាលារៀនមានការកើនឡើង ជាពិសេស នៅតាមតំបន់ជនបទ។ នៅតំបន់ជនបទនៃប្រទេសពេរូ ចំនួនគ្រួសារ ដែលមានអគ្គិសនីប្រើប្រាស់ កើនឡើងពី ៧,៧% ក្នុងឆ្នាំ ១៩៩៣ ដល់ ៧០% ក្នុងឆ្នាំ ២០១៣ ធ្វើឲ្យរយៈពេលសិក្សារបស់កុមារកើនឡើង ៩៣ នាទី ក្នុងមួយថ្ងៃ។

## ចាំបាច់ត្រូវមានអន្តរាគមន៍សង្គម និងអប់រំបញ្ចូលគ្នា

វឌ្ឍនភាព ដែលសម្រេចបានខាងយុគភាពយេនឌ័រក្នុងការអប់រំ មិនមែនមានន័យថាជាការសម្រេចបាននូវសមភាពយេនឌ័រ ក្នុងលក្ខណៈជាប្រព័ន្ធឡើយ។ ឧទាហរណ៍ នៅតាមបណ្តាប្រទេសនៅអាស៊ី ដូចជា ប្រទេសជប៉ុន និងសាធារណរដ្ឋកូរ៉េ ជាដើម ស្របពេលដែលការអប់រំរបស់ស្ត្រីមានការកើនឡើង ការចូលរួមរបស់កម្លាំងពលកម្មជាស្ត្រីនៅមានកម្រិតនៅឡើយ បើទោះបីជាមានតម្រូវការកម្លាំងពលកម្មដែលមានការអប់រំខ្ពស់ ដោយសារតែកម្លាំងពលកម្មដែលមានស្រាប់កាន់តែមានវ័យចាស់ជរាក៏ដោយ។ ស្រដៀងគ្នានេះដែរ ការផ្លាស់ប្តូរឥរិយាបថសុខភាពពាក់ព័ន្ធនឹងសុខភាពមិនអាចមាននិរន្តរភាពបាន ដែលដោយអន្តរាគមន៍ខាងអប់រំតែឯងឡើយ។

និន្នាការទាំងនេះគូសបញ្ជាក់ពីភាពចាំបាច់ ដែលត្រូវមានអន្តរាគមន៍ និងគោលនយោបាយទូលំទូលាយ ដែលបញ្ចូលការអប់រំជាមួយនឹងសកម្មភាពនានា ដូចជា ការផ្លាស់ប្តូរច្បាប់ ឬគោលនយោបាយកម្លាំងពលកម្មជាដើម។ កម្មវិធីគាំពារសង្គម ដែលមានបំណងកាត់បន្ថយហានិភ័យ និងភាពងាយរងគ្រោះ ដូចជា របបសោធននិវត្តន៍ ការផ្ទេរសាច់ប្រាក់ និងមីក្រូហិរញ្ញវត្ថុ ជាដើម អាចនាំមកនូវលទ្ធផលជាច្រើន ចាប់ពីកាត់បន្ថយភាពក្រីក្រ រហូតដល់ការបង្កើនលទ្ធភាពទទួលបានការអប់រំ។ ឧទាហរណ៍ គោលនយោបាយគ្រួសារមេត្រី និងការរៀបចំកន្លែងធ្វើការដែលមានភាពបត់បែន អាចលើកទឹកចិត្តឲ្យស្ត្រីនៅតែបន្តចូលរួមក្នុងកម្លាំងពលកម្មបន្តទៀត។

ការឆ្លើយតបចំពោះភាពលំអៀងយេនឌ័រ ដែលចាក់ឫសគល់យ៉ាងជ្រៅ តាមរយៈកម្មវិធីនានា ដែលនាំបុរស និងស្ត្រី ឲ្យមកជុំគ្នា អាចជាវិធានការដែលមានប្រសិទ្ធភាព។ ក្នុងប្រទេសប្រេស៊ីល កម្មវិធី H មានបញ្ចូលវគ្គអប់រំក្រុម រៀបចំយុទ្ធនាការដឹកនាំដោយយុវជននិងសកម្មភាព ដើម្បីធ្វើការផ្លាស់ប្តូរផ្នត់គំនិតយេនឌ័រ ក្នុងចំណោមបុរសវ័យក្មេង។ កម្មវិធីនេះត្រូវបានគេយកទៅអនុវត្តតាមក្នុងប្រទេសជាង ២០។



Selina Akter និស្សិតឆ្មបឆ្នាំទី ២ ដើរតួជាម្តាយ ពេលដែលនិស្សិតហ្វឹកហាត់ជំនាញថែទាំក្រោយសម្រាលនៅវិទ្យាស្ថានថែទាំវេជ្ជសាស្ត្រ Dinajpur ក្នុងប្រទេសបង់ក្លាដេស។
រូបថត៖ Nicolas Axelrod/Ruom




@GEMReport #SDG4All bitly.com/sdg4all

# សន្តិភាព៖ ការចូលរួមក្នុងវិស័យនយោបាយ សន្តិភាព និងការទទួលបានយុត្តិធម៌

អំពើហិង្សានិងជម្លោះប្រដាប់អាវុធដែលបន្តកើតឡើងឥតឈប់ឈរបង្កអន្តរាយដល់សុវត្ថិភាព និងសុខុមាលភាពរបស់បុគ្គលម្នាក់ៗ។ ការទប់ស្កាត់អំពើហិង្សា និងការសម្រេចឲ្យបាននូវសន្តិភាពប្រកបដោយនិរន្តរភាព ទាមទារឲ្យមានស្ថាប័នដែលតំណាងឲ្យប្រជាពលរដ្ឋតាមបែបប្រជាធិបតេយ្យពិតប្រាកដ និងប្រព័ន្ធយុត្តិធម៌ដែលដំណើរការបានល្អ។ការអប់រំគឺជាធាតុផ្សំមួយដ៏សំខាន់នៃការចូលរួមក្នុងវិស័យនយោបាយ បរិយាប័ន្ន ការតស៊ូមតិ និងលទ្ធិប្រជាធិបតេយ្យ។ ខណៈពេលដែលការអប់រំអាចរួមចំណែកនាំឲ្យមានជម្លោះកើតឡើង វាក៏អាចកាត់បន្ថយ ឬលុបបំបាត់ជម្លោះផងដែរ។ ការអប់រំអាចបំពេញតួនាទីសំខាន់ ក្នុងការកសាងសន្តិភាព និងជួយដោះស្រាយផលវិបាកដែលកើតឡើង ដោយសារតែការមិនយកចិត្តទុកដាក់ចំពោះការអប់រំ។ គំនិតផ្តួចផ្តើមអប់រំ ជាពិសេស គំនិតផ្តួចផ្តើមដឹកនាំដោយអង្គការសង្គមស៊ីវិល អាចជួយឲ្យប្រជាពលរដ្ឋដែលមិនសូវមានឱកាស ទទួលបានយុត្តិធម៌។

## ការអប់រំ និងអក្ខរកម្ម ធ្វើឲ្យនយោបាយកាន់តែមានបង្គលក្ខណៈឲ្យមានការចូលរួម

ការអប់រំបង្កើនចំណេះដឹងអំពីអ្នកដឹកនាំនយោបាយសំខាន់ៗ និងអំពីដំណើរការនៃប្រព័ន្ធនយោបាយ។ បុគ្គលម្នាក់ៗត្រូវការព័ត៌មាន និងជំនាញដើម្បីចុះឈ្មោះបោះឆ្នោត យល់ពីអ្វីដែលជាចំណុចសំខាន់ និងចាប់អារម្មណ៍ចំពោះលទ្ធផលនៃការបោះឆ្នោត។នៅភាគខាងលិចនៃប្រទេសកេនយ៉ា កម្មវិធីអាហារូបករណ៍ ដែលផ្តោតលើក្មេងស្រីមកពីក្រុមជនជាតិភាគតិចដែលមិនសូវមានឱកាសចូលរួមក្នុងវិស័យនយោបាយ នាំឲ្យមានការកើនឡើងនូវការចូលរៀននៅថ្នាក់មធ្យមសិក្សា និងបានបង្កើនចំណេះដឹងនយោបាយរបស់ពួកគេ។ ក្នុងប្រទេសប៉ាគីស្ថាន យុទ្ធនាការបង្កើនការយល់ដឹងរបស់អ្នកបោះឆ្នោត មុនការបោះឆ្នោតឆ្នាំ ២០០៨ បានបង្កើនលទ្ធភាពទៅបោះឆ្នោតរបស់ស្ត្រីចំនួន ១២ ភាគរយចំណុច។ក្នុងប្រទេសនីហ្សេរីយ៉ា យុទ្ធនាការប្រឆាំងអំពើហិង្សាមុនការបោះឆ្នោតឆ្នាំ២០០៧ បានកាត់បន្ថយការសម្លុតគំរាម និងនាំឲ្យចំនួនអ្នកដែលចេញទៅបោះឆ្នោតកើនឡើងជាងមុន ១០%។

ការអប់រំពីតតែល្អក៏អាចជួយឲ្យមនុស្សចេះគិតគូរបានកាន់តែល្អិតល្អន់ និងចូលរួមក្នុងកិច្ចការនយោបាយ និងអាចបង្កើនភាពជាតំណាងរបស់ក្រុមដែលមិនសូវមានឱកាស។ សិស្សនឹងកាន់តែចង់ចូលរួមក្នុងកិច្ចការនយោបាយ នៅពេលដែលពួកគេទទួលបានការអប់រំពលរដ្ឋវិជ្ជាដែលមានការរៀបចំបានល្អ និងទទួលបានបរិយាកាសរៀនសូត្របើកចំហ ដែលគាំទ្រឲ្យមានការពិភាក្សាពីប្រធានបទដែលមានលក្ខណៈចម្រូងចម្រាស់ និងដែលផ្តល់ឱកាសឲ្យសិស្សអាចស្តាប់ និងសម្តែងការយល់ឃើញផ្សេងៗគ្នា។ ការសិក្សាលើប្រទេសចំនួន ៣៥ បានបង្ហាញថាភាពបើកចំហក្នុងការពិភាក្សាក្នុងថ្នាក់រៀនបង្កើនការយកចិត្តទុកដាក់ចង់ចូលរួមក្នុងកិច្ចការនយោបាយ។ ក្នុងប្រទេសអ៊ីស្រាអែល និងអ៊ីតាលី បរិយាកាសថ្នាក់រៀនដែលបើកចំហឲ្យមានការចូលរួម បានជួយឲ្យសិស្សកាន់តែចូលរួមក្នុងសកម្មភាពពលរដ្ឋ និងសកម្មភាពនយោបាយ។

ការអប់រំពីតតែល្អ និងការចូលរួមរបស់ស្ត្រី ក្នុងស្ថាប័នធ្វើសេចក្តីសម្រេចចិត្តនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន មានទំនាក់ទំនងយ៉ាងជិតស្និទជាមួយគ្នា។ ការកើនឡើងនូវភាពជាតំណាងរបស់ស្ត្រីក្នុងវិស័យនយោបាយ និងការកាន់មុខតំណែងសាធារណៈ អាចកាត់បន្ថយគម្លាតយេនឌ័រក្នុងវិស័យអប់រំ តាមរយៈការបង្ហាញនូវគំរូភាពជាវិជ្ជមានដល់ស្ត្រី និងបង្កើនបំណងប្រាថ្នាចង់ទទួលបានការអប់រំរបស់ពួកគេ។ ក្នុងរដ្ឋធំៗជាងគេចំនួន ១៦ របស់ប្រទេសឥណ្ឌា ការបង្កើនចំនួនស្ត្រី ដែលចូលរួមក្នុងកិច្ចការនយោបាយនៅតាមស្រុកចំនួន ១០% នាំឲ្យអត្រាបញ្ចប់ការអប់រំបឋមសិក្សាជិត ៦% ដែលមានឥទ្ធិពលធំធេងមកលើការអប់រំរបស់ក្មេងស្រី។

> “ចន្លោះពីឆ្នាំ ១៨៧០ ដល់ ២០០០ ពាក់កណ្តាលនៃការផ្លាស់ប្តូររបបទៅរករបបប្រជាធិបតេយ្យ កើតឡើងស្របពេលនឹងមានការកើនឡើងនូវកម្រិតអក្ខរកម្ម”

ការអប់រំធ្វើឲ្យប្រជាពលរដ្ឋដែលកើតទុក្ខមិនសុខចិត្តលើកឡើងពីក្តីបារម្ភរបស់ពួកគេ តាមរយៈចលនាស៊ីវិលអហិង្សា ដូចជា ការតវ៉ា ការធ្វើពហិការ កូដកម្ម ការប្រមូលផ្តុំគ្នា ការធ្វើបាតុកម្មនយោបាយ ការមិនចូលរួមសហការក្នុងសង្គម និងការតបតជាដើម។ ក្នុងប្រទេសចំនួន ១០៦ ក្នុងរយៈពេល ៥៥ ឆ្នាំកន្លងមកនេះ ក្រុមជាតិពន្ធុដែលទទួលបានការអប់រំបានច្រើន ច្រើនចូលរួមក្នុងការតវ៉ាដោយអហិង្សា។

ការទទួលបានការអប់រំប្រកបដោយគុណភាព ទូលំទូលាយ និងប្រកបដោយសមធម៌ ជួយរក្សានិរន្តរភាពនៃការអនុវត្ត និងស្ថាប័នប្រជាធិបតេយ្យ។ ចន្លោះពីឆ្នាំ ១៨៧០ ដល់ ២០០០ ពាក់កណ្តាលនៃការផ្លាស់ប្តូររបបទៅរករបបប្រជាធិបតេយ្យ កើតឡើងស្របពេលនឹងមានការកើនឡើងនូវកម្រិតអក្ខរកម្ម។

## ការអប់រំ និងជម្លោះ៖ ទំនាក់ទំនងដ៏ស្មុគស្មាញ

ភាពក្រីក្រ ភាពគ្មានការងារធ្វើ និងភាពអស់សង្ឃឹម ដែលកើតឡើងដោយសារការខ្វះការអប់រំដែលល្អ អាចជាកត្តាដែលក្រុមឧទ្ទាមប្រដាប់អាវុធប្រើប្រាស់ ដើម្បីជ្រើសរើសកម្លាំងរបស់ខ្លួន។ ក្នុងប្រទេសសៀរ៉ាលីអូន មនុស្សវ័យក្មេងដែលមិនបានទទួលការអប់រំងាយនឹងចូលរួមជាមួយនឹងក្រុមឧទ្ទាមច្រើនជាងអ្នកដែលមានការអប់រំយ៉ាងហោចណាស់មធ្យមសិក្សា ដល់ទៅ ៩ ដង។ វិសមភាពក្នុងវិស័យអប់រំ ធ្វើឲ្យបញ្ហានេះកាន់តែរីកធំជាងនេះទៅទៀត។ ទិន្នន័យពីប្រទេសចំនួន ១០០ ក្នុងរយៈពេល ៥០ ឆ្នាំ បានរកឃើញថា ប្រទេសដែលមានគម្លាតការអប់រំកាន់តែធំ កាន់តែងាយធ្លាក់ចូលទៅក្នុងស្ថានភាពជម្លោះ។ ទោះជាយ៉ាងណាក៏ដោយ ការអប់រំខ្ពស់ក៏មិនមែនជាដំណោះស្រាយនោះដែរ៖ នៅពេលដែលកម្រិតនៃការអប់រំមានការកើនឡើង ប៉ុន្តែទីផ្សារការងារនៅទ្រឹង នោះការខកចិត្តអាចឡើងកម្តៅរឹតតែខ្លាំងដែរ។

សាលារៀន ដែលបណ្តុះបុរេវិនិច្ឆ័យ ការមិនយល់អធ្យាស្រ័យ និងការបង្វៃប្រវត្តិសាស្ត្រ អាចជាមូលដ្ឋានបណ្តុះអំពើហិង្សា។ ក្នុងបណ្តាប្រទេសជាច្រើន មានការរកឃើញថា កម្មវិធីសិក្សា និងឯកសាររៀនសូត្រ បានពង្រឹងបន្ថែមនូវផ្នត់គំនិត និងធ្វើឲ្យការកើតទុក្ខមិនសុខចិត្តខាងនយោបាយ និងសង្គមរឹតតែមានការកើនឡើង។

> "ទិន្នន័យពីប្រទេសចំនួន ១០០ ក្នុងរយៈពេល ៥០ ឆ្នាំ បានរកឃើញថា ប្រទេសដែលមានគម្លាតការអប់រំកាន់តែធំ កាន់តែងាយធ្លាក់ចូលទៅក្នុងស្ថានភាពជម្លោះ។"

ក្នុងប្រទេសរ៉ាវ៉ាន់ដា ការពិនិត្យឡើងវិញលើគោលនយោបាយ និងកម្មវិធីអប់រំ ចាប់ពីឆ្នាំ ១៩៦២ ដល់ ១៩៩៤ បានរកឃើញថា ខ្លឹមសារនៃគោលនយោបាយ និងកម្មវិធីអប់រំទាំងនេះ បានរួមចំណែកធ្វើឲ្យមានការបែងចែក និងការមាក់ងាយដល់ក្រុម Hutu និង Tutsi ដោយចាត់ទុកក្រុមទាំងពីរនេះថាជាក្រុមខុសពីគេ។ ភាសា ដែលគេប្រើក្នុងការអប់រំក៏អាចជាប្រភពដែលនាំឲ្យមានការកើនឡើងនូវការថ្នាំងថ្នាក់គ្នាផងដែរ។

**រូបភាពទី៤ :**

**ស្ថានភាពនៃការអប់រំរបស់កុមារដែលជាជនភៀសខ្លួន មានការប្រែប្រួលខុសគ្នាឆ្ងាយ**

អត្រាសិក្សានៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា នៅតាមជំរុំជនភៀសខ្លួនមួយចំនួន តាមប្រទេសមួយចំនួន ឆ្នាំ ២០១៤




ប្រភព៖ ការវិភាគរបស់ក្រុមរៀបចំរបាយការណ៍ GEM (២០១៦) ផ្អែកតាមទិន្នន័យ UNHCR ឆ្នាំ ២០១៤

ជម្លោះប្រដាប់អាវុធ គឺជាឧបសគ្គមួយ ក្នុងចំណោមឧបសគ្គធំៗជាងគេ ដែលរារាំងដល់ការសម្រេចវឌ្ឍនភាពក្នុងវិស័យអប់រំ។ ក្នុងប្រទេសដែលរងផលប៉ះពាល់ដោយសារជម្លោះ មានកុមារដល់វ័យចូលរៀននៅបឋមសិក្សាចំនួន ២១,៥ លាននាក់ (ស្មើនឹង ៣៥% នៃកុមារសរុប) និងក្មេងជំទង់ដែលដល់វ័យចូលរៀននៅមធ្យមសិក្សាបឋមភូមិចំនួន ១៥ លាននាក់ (២៥%) ត្រូវនៅក្រៅសាលា។ ក្នុងសាធារណរដ្ឋអារ៉ាប់ស៊ីរី មានកុមារជាងកន្លះលាននាក់ដែលនៅក្រៅសាលាបឋមសិក្សា ក្នុងឆ្នាំ ២០១៣។ ជារឿយៗ សាលារៀនត្រូវបានគេប្រើប្រាស់ សម្រាប់គោលបំណងយោធា។ គ្រូត្រូវប្រឈមនឹងគ្រោះថ្នាក់៖ ក្នុងប្រទេសកូឡុំប៊ីមានគ្រូចំនួន១៤០នាក់ត្រូវបានគេសម្លាប់ចន្លោះពីឆ្នាំ២០០៩ ដល់ ២០១៣។ ការចាប់បង្ខំកុមារឲ្យចូលក្នុងក្រុមប្រដាប់អាវុធនៅតែកើតមានជាទូទៅ។

ជនភៀសខ្លួន គឺជាបញ្ហាប្រឈមដ៏ធំមួយ សម្រាប់ប្រព័ន្ធអប់រំ។ កុមារ និងក្មេងជំទង់ដែលជាជនភៀសខ្លួន ងាយនឹងបោះបង់ចោលការសិក្សាជាងកុមារ និងក្មេងជំទង់ ដែលមិនមែនជាជនភៀសខ្លួនដល់ទៅ ៥ ដង។ នៅតាមជំរុំជនភៀសខ្លួនមួយចំនួន ផលធៀបសិស្ស/គ្រូមានកម្រិតខ្ពស់រហូតដល់៧០៖១ហើយគ្រូបង្រៀនជាច្រើននាក់មិនមែនជាគ្រូដែលមានសមត្ថភាពនោះទេ។

ការអប់រំអាចជួយកាត់បន្ថយភាពខុសប្លែកគ្នារវាងក្រុមជាតិពន្ធុ និងក្រុមសាសនានានា។ ប៉ុន្តែ នៅតាមកន្លែងដែលសាលារៀនពុំធ្វើការផ្លាស់ប្តូរកម្មវិធីសិក្សាឬរបៀបបែងចែកក្រុមក្នុងសាលារៀនវារឹតតែបណ្តុះឲ្យមានឥរិយាបថរើសអើងថែមទៀត។ក្នុងប្រទេសបូស្នៀ

និងហេហ្សេហ្គោវីណា សាលារៀនត្រូវបានបែងចែកទៅតាមក្រុមជាតិពន្ធុ និងក្រុមភាសា ចាប់តាំងពីការបញ្ចប់សង្គ្រាមក្នុងឆ្នាំ ១៩៩៦ មកម្ល៉េះ។ ខ្លឹមសារក្នុងកម្មវិធីសិក្សា អាចជួយ ឬបង្កគ្រោះថ្នាក់ដល់ទំនាក់ទំនងរវាងក្រុម និងក្រុម ក្រោយពេលដែលមានជម្លោះកើតមានឡើង។ ជោគជ័យនៃកំណែទម្រង់កម្មវិធីសិក្សាណាក៏ដោយសុទ្ធតែត្រូវការគ្រូដែលមានទឹកចិត្ត ចូលរួមសកម្ម និងបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ។

ការអប់រំសន្តិភាព ក្នុងប្រព័ន្ធក្តី ក្រៅប្រព័ន្ធក្តី ដែលមានការរៀបចំបានល្អ អាចកាត់បន្ថយចរឹកកាចសាហាវ ចូលចិត្តរុគគួនគេ និងការចូលរួមក្នុងជម្លោះហិង្សារបស់សិស្ស។ គេចាំបាច់ត្រូវបញ្ចូលការអប់រំ ទៅក្នុងរបៀបវារៈកសាងសន្តិភាពអន្តរជាតិ ប៉ុន្តែផ្ទុយទៅវិញ គេច្រើនតែផ្តល់អាទិភាពដល់បញ្ហាសន្តិសុខទៅវិញ។ ក្នុងកិច្ចព្រមព្រៀងសន្តិភាពដែលអាចរកបានពេញលេញជាសាធារណៈចំនួន ៣៧ ដែលចុះចន្លោះពីឆ្នាំ ១៩៨៩ ដល់ ២០០៥ មានកិច្ចព្រមព្រៀងចំនួន ១១ មិនបាននិយាយពីការអប់រំទាល់តែសោះ។

## ការអប់រំអាចមានសារៈសំខាន់ក្នុងការកសាងនូវប្រព័ន្ធយុត្តិធម៌មួយដែលដំណើរការបានល្អ

ប្រព័ន្ធយុត្តិធម៌ ដែលដំណើរការបានល្អ មានសារៈសំខាន់ ដើម្បីធានាឲ្យសង្គមមួយមានសុខសន្តិភាពយូរអង្វែង។ ប៉ុន្តែប្រជាពលរដ្ឋជាច្រើននាក់នៅខ្វះជំនាញដើម្បីអាចប្រើប្រាស់ប្រព័ន្ធយុត្តិធម៌ដែលមានលក្ខណៈស្មុគស្មាញ។ក្នុងឆ្នាំ២០១១បើតាមលទ្ធផលនៃការអង្កេតលើអ្នកប្រើប្រាស់ប្រព័ន្ធតុលាការ ក្នុងសាធារណរដ្ឋម៉ាសេដូនៀ ដែលជាផ្នែកមួយនៃអតីតយូហ្គោស្លាវី ក្នុងចំណោមអ្នកដែលរៀនបានត្រឹមបឋមសិក្សា មានត្រឹមតែ ៣២% ប៉ុណ្ណោះ ដែលបានដឹងច្បាស់ ឬបានដឹងខ្លះពីប្រព័ន្ធយុត្តិធម៌ និងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ បើធៀបជាមួយនឹង ៧៧% សម្រាប់អ្នកដែលមានការអប់រំកម្រិតឧត្តមសិក្សា។ កម្មវិធីអប់រំតាមសហគមន៍ អាចជួយបង្កើនការយល់ដឹងពីសិទ្ធិស្របច្បាប់ ជាពិសេស ដល់ក្រុមដែលមិនសូវមានឱកាស។

ការកសាងសមត្ថភាពមន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់គឺជាកិច្ចការដ៏សំខាន់។ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពមិនគ្រប់គ្រាន់ អាចធ្វើឲ្យប្រព័ន្ធយុត្តិធម៌ដើរថយក្រោយ និងនាំឲ្យមានការពន្យារពេល ការប្រមូលភស្តុតាងមិនត្រឹមត្រូវឬមិនគ្រប់គ្រាន់ កង្វះការអនុវត្តច្បាប់ និងមានការរំលោភបំពានជាដើម។ ក្នុងប្រទេសហៃទី ប៉ូលីសជាតិបានប្រែក្លាយខ្លួនពីស្ថាប័នសាធារណៈដែលទទួលបានការជឿទុកចិត្តតិចជាងគេ ទៅជាស្ថាប័នដែលទទួលបានការជឿទុកចិត្តច្រើនជាងគេ ក្នុងរយៈពេល ៥ ឆ្នាំ តាមរយៈកម្មវិធីបណ្តុះបណ្តាលប៉ូលីសចូលថ្មីដែលផ្តល់ដោយអង្គការសហប្រជាជាតិ ក្នុងរយៈពេល ៧ ខែ។



កុមារមើលតាមបង្អួចបន្ទប់រៀន នៅសាលាបឋមសិក្សា Yerwa ក្នុងខេត្ត Maiduguri នៃរដ្ឋ Borno ដែលរងការបំផ្លាញ ក្នុងកំឡុងពេលមានការវាយប្រហារពីពួក Boko Haram ក្នុងឆ្នាំ ២០១០ និង ២០១៣។ សាលារៀននេះ ដែលបង្កើតឡើងក្នុងឆ្នាំ ១៩១៥ គឺជាសាលាបឋមសិក្សាដំបូងបង្អស់ នៅភាគឥសាន របស់ប្រទេសនីហ្សេរីយ៉ា។
រូបថត៖ Bede Sheppard/Human Rights Watch

# ទីកន្លែង




@GEMReport #SDG4All bitly.com/sdg4all

# ទីកន្លែង៖ ទីក្រុង និងកន្លែងតាំងទីលំនៅរបស់មនុស្ស

នគរូបនីយកម្ម (ការពង្រីកទីក្រុង) គឺជានិន្នាការមួយ ក្នុងចំណោមនិន្នាការប្រជាសាស្ត្រសំខាន់ៗនាពេលបច្ចុប្បន្ននេះ - ជាងពាក់កណ្តាលនៃប្រជាជនក្នុងពិភពលោករស់នៅតាមទីក្រុង និងតំបន់ប្រជុំជន ហើយកំណើនចំនួនប្រជាជនក្នុងទីក្រុងដែលគេព្យាករថានឹងមានច្រើនជាងគេ រហូតដល់ឆ្នាំ ២០៥០ នឹងកើតឡើង នៅតាមទីក្រុងដែលមានចំណូលទាប។ របាយការណ៍ GEM នេះពិនិត្យថា តើទីក្រុង និងនគរូបនីយកម្ម មានផលប៉ះពាល់យ៉ាងដូចម្តេចខ្លះមកលើការអប់រំ និងថាតើការអប់រំមានឥទ្ធិពលយ៉ាងដូចម្តេចខ្លះលើបញ្ហាដែលកើតមានក្នុងទីក្រុង។

វិសាលភាព និងល្បឿននៃការផ្លាស់ប្តូរក្នុងទីក្រុង ទាមទារជាចាំបាច់នូវអភិបាលកិច្ចល្អ ភាពបត់បែន និងនវានុវត្តន៍។ ការអប់រំគួរបញ្ចូលទៅក្នុងការរៀបចំផែនការទីក្រុង ដើម្បីឲ្យមានការបំពេញតម្រូវការ និងសិទ្ធិក្នុងការទទួលបានការអប់រំ នៅពេលដែលចំនួនប្រជាជនក្នុងទីក្រុងមានការប្រែប្រួល។ ប៉ុន្តែ វិស័យអប់រំហាក់បីដូចជាមិនត្រូវបានបញ្ចូលទៅក្នុងការពិភាក្សាសំខាន់ៗអំពីការអភិវឌ្ឍទីក្រុងឡើយ។ អ្នកធ្វើការពាក់ព័ន្ធនឹងវិស័យអប់រំ និងថ្នាក់ដឹកនាំទីក្រុង ត្រូវធ្វើការតស៊ូមតិ និងបង្ហាញពីភាពជាអ្នកដឹកនាំឲ្យបានរឹងមាំ ប្រសិនបើគេចង់ឲ្យការអប់រំត្រូវបានគេបញ្ចូលទៅក្នុងការពិភាក្សាអំពីអនាគតរបស់ទីក្រុង។

## ទីក្រុងមានផលប៉ះពាល់លើការរៀបចំផែនការអប់រំ

ក្នុងសកលលោកទាំងមូល ប្រហែលជាពាក់កណ្តាលនៃកំណើនប្រជាជនក្នុងក្នុងទីក្រុង គឺកើតឡើងដោយសារកំណើនប្រជាជនតាមធម្មតា និងពាក់កណ្តាលទៀត គឺការធ្វើចំណាកស្រុកពីតំបន់ជនបទ។ ការកើនឡើងនូវចំនួនប្រជាជនបែបនេះ ធ្វើឲ្យតម្រូវការការអប់រំកម្រិតមូលដ្ឋាន ការរៀនសូត្រពេញមួយជីវិត ការអភិវឌ្ឍជំនាញ និងគ្រូ ក៏មានការកើនឡើងផងដែរ។ លើសពីនេះ គេក៏ចាំបាច់ត្រូវលើកកម្ពស់ការចេះរស់នៅជាមួយគ្នាក្នុងសង្គម និងការអធ្យាស្រ័យដល់ភាពខុសប្លែកគ្នាខាងវប្បធម៌ តាមរយៈការអប់រំ ដូចជា សម្រាប់អ្នកតាំងទីលំនៅក្នុងតំបន់ក្រីក្រ ជនចំណាកស្រុក និងជនភៀសខ្លួន ជាដើម។

ជាងមួយភាគបីនៃអ្នករស់នៅទីក្រុង ក្នុងបណ្តាប្រទេសដែលមានចំណូលទាប គឺជាអ្នករស់នៅតំបន់ក្រីក្រ ឬតំបន់មិនរៀបរយចំកណ្តាលក្រុង ឬនៅជាយក្រុង។ ស្ថានភាពនៅតាមតំបន់ក្រីក្រមានការប្រែប្រួល ខុសគ្នាឆ្ងាយប៉ុន្តែ នៅក្នុងតំបន់ក្រីក្រជាច្រើនការទទួលបានសេវាមូលដ្ឋាន ដូចជា សេវាអប់រំ ជាដើម នៅមានកម្រិតទាប។ ទិន្នន័យដែលប្រមូលបានពីតំបន់តាំងទីលំនៅរបស់ប្រជាពលរដ្ឋក្រីក្រចំនួន ១៣០ កន្លែង មកពីក្រុង និងតំបន់ប្រជុំជនចំនួន ១២ ក្នុងប្រទេសអ៊ូហ្គាន់ដា បានរកឃើញថា ខណៈពេលដែលនៅតាមតំបន់តាំងទីលំនៅភាគច្រើន មានសាលារៀន អ្នកតបសំណួរបានលើកឡើងពីភាពចាំបាច់ ក្នុងការបង្កើនចំនួនសាលារៀនសាធារណៈ ដែលងាយឲ្យកុមារបានចូលរៀន។

> “ត្រឹមចុងឆ្នាំ ២០១៤ ក្នុងចំណោមជនភៀសខ្លួន ១០ នាក់ មាន ៦ នាក់ រស់នៅតំបន់ប្រជុំជន។ ជាងពាក់កណ្តាលនៃជនភៀសខ្លួនក្នុងពិភពលោក មានអាយុក្រោម ១៨ ឆ្នាំ។”

ជនចំណាកស្រុក ដែលធ្វើដំណើរទៅទីក្រុង ដើម្បីស្វែងរកការងារធ្វើ ជួបប្រទះនឹងបញ្ហាប្រឈមនានា ដូចជា ការរើសអើង ឧបសគ្គខាងភាសា ការពុំមានការងារធ្វើ និងការរើសអើង ក្នុងសេដ្ឋកិច្ចមិនរៀបរយ។ ការឆ្លើយតបចំពោះបញ្ហាទាំងនេះ ទាមទារឲ្យមានការផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍជំនាញ។

ប្រព័ន្ធអប់រំក្នុងទីក្រុងដែលទទួលយកកុមារនិងយុវជនដែលបង្ខំចិត្តចាកចេញពីផ្ទះសម្បែងរបស់ពួកគេ ចាំបាច់ត្រូវសម្របខ្លួន ដើម្បីគាំទ្រដល់ការធ្វើសមាហរណកម្មពួកគេក្នុងរយៈពេលវែង - ជាពិសេស ខណៈពេលដែលវិបត្តិជនភៀសខ្លួនជាសកលកំពុងតែស្ថិតក្នុងសភាពធ្ងន់ធ្ងរទៅៗ។ ត្រឹមចុងឆ្នាំ ២០១៤ ក្នុងចំណោមជនភៀសខ្លួន ១០ នាក់ មាន ៦ នាក់ រស់នៅតំបន់ប្រជុំជន។ ជាងពាក់កណ្តាលនៃជនភៀសខ្លួនក្នុងពិភពលោក មានអាយុក្រោម ១៨ ឆ្នាំ។ ក្នុងប្រទេសតួកគី កុមារដែលជាជនភៀសខ្លួនជនជាតិស៊ីរីរស់នៅតាមជំរុំ ៨៥% បានទៅរៀន ប៉ុន្តែកុមារដែលជាជនភៀសខ្លួនរស់នៅក្នុងទីក្រុងវិញ បានទៅរៀនត្រឹមតែ ៣០% ប៉ុណ្ណោះ។

ប្រេវ៉ាឡង់នៃសាលារៀនឯកជន ជាពិសេស នៅតាមទីក្រុងធំៗ និងតំបន់ជាយក្រុង ត្រូវបានគេមិនសូវយកចិត្តទុកដាក់ ឬមិនយកមកបញ្ចូលក្នុងការពិភាក្សាអំពីការអប់រំសាធារណៈតែម្តង។ សាលារៀនឯកជន ដែលកាន់តែមានចំនួនច្រើនឡើងនៅតំបន់ជាយក្រុង

ភាគច្រើនជាសាលារៀនមិនរៀបរយ ហើយជារឿយៗ មិនត្រូវបានបញ្ចូលក្នុងស្ថិតិផ្លូវការឡើយ ហើយមិនត្រូវបានគេអើពើឡើយ។ ជំរឿនសាលារៀនឯកជនឆ្នាំ ២០១០/១១ ក្នុងរដ្ឋ Lagos ប្រទេសនីហ្សេរីយ៉ា បានរកឃើញថា មានសិស្សអាយុចូលរៀនសាលាមត្តេយ្យជាង ៨៥% និងសិស្សអាយុចូលរៀនសាលាបឋមសិក្សា ៦០% បានចុះឈ្មោះចូលរៀន ក្នុងសាលារៀនឯកជន។

## ការអប់រំមានឥទ្ធិពលខាងសេដ្ឋកិច្ច សង្គម និងបរិស្ថានមកលើទីក្រុង ...

ការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា ដែលមានគុណភាពល្អ និងអត្រាចុះឈ្មោះចូលរៀនខ្ពស់ នៅកម្រិតឧត្តមសិក្សា គឺជាមូលដ្ឋានគ្រឹះ សម្រាប់លើកកម្ពស់នវានុវត្តន៍ និងបង្កើនផលិតភាពក្នុងសេដ្ឋកិច្ចពុទ្ធិ (knowledge economies)។ ទីក្រុងទាក់ទាញធនធានមនុស្ស និងការវិនិយោគផ្ទាល់ពីបរទេស ដោយសារតែទីក្រុងបំពេញតួនាទីជាមជ្ឈមណ្ឌលប្រមូលផ្តុំការអប់រំកម្រិតឧត្តមសិក្សា ជំនាញ ទេពកោសល្យ ចំណេះដឹង និងនវានុវត្តន៍។ ទីក្រុងធំៗ ដូចជា ទីក្រុងសៀងហៃ ប្រទេសចិន ជាដើម ទាក់ទាញមនុស្សដែលមានទេពកោសល្យក្នុងមុខជំនាញជាច្រើនអាចទទួលបានប្រយោជន៍ពីនិស្សិតដែលបញ្ចប់ការសិក្សាជាង១០០០០០នាក់និងបានបង្កើនទ្វេដងនូវភាគរយនៃកម្លាំងពលកម្មដែលបញ្ចប់ការសិក្សាថ្នាក់មហាវិទ្យាល័យ តែក្នុងរយៈពេលមួយទសវត្សរ៍ប៉ុណ្ណោះ។ បើតាមរបាយការណ៍ផ្សេងៗ សកលវិទ្យាល័យ Standford គឺជាសកលវិទ្យាល័យដែលមានឥទ្ធិពលធំធេងលើសេដ្ឋកិច្ចសកលលោកទាំងមូល៖ មានក្រុមហ៊ុនចំនួន ១៨០០០ ត្រូវបានបង្កើតឡើងដោយអតីតនិស្សិតដែលបញ្ចប់ការសិក្សាពីសកលវិទ្យាល័យនេះ ដែលស្ថិតនៅតំបន់ទីក្រុងនៃរដ្ឋកាលីហ្វរនីយ៉ា។

ការងារក្នុងវិស័យមិនរៀបរយ គឺជាប្រភពចម្បងនៃការងារ និងប្រាក់ចំណូល ក្នុងប្រទេសដែលមានចំណូលទាប ជាពិសេស នៅក្នុងទីក្រុង និងជាវិស័យដ៏សំខាន់ដែលបំពេញគម្លាតការងារ ក្នុងប្រទេសដែលមានចំណូលខ្ពស់ ក្នុងកំឡុងពេលមានវិបត្តិសេដ្ឋកិច្ច។ ការទទួលស្គាល់ និងការបញ្ចូលការងារក្នុងវិស័យមិនរៀបរយ ទៅក្នុងសេដ្ឋកិច្ចទីក្រុង គឺមានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីធានានូវវិបុលភាព និងបរិយាប័ន្នសង្គម តាមទីក្រុង។

ការអប់រំក៏មានឥទ្ធិពលជាវិជ្ជមានមកលើសង្គមផងដែរ ជាពិសេស ក្នុងការកាត់បន្ថយចំនួនបទល្មើស។ ក្នុងប្រទេសអង់គ្លេស និងវេលស៍ (ចក្រភពអង់គ្លេស) ការបន្ថែមរយៈពេលសម្រាប់ការអប់រំដែលតម្រូវដោយច្បាប់ នាំឲ្យមានការថយចុះយ៉ាងច្រើននូវចំនួនបទល្មើស និងអំពើហិង្សា។ នៅសហរដ្ឋអាមេរិច ការវិនិយោគលើការអប់រំកុមារតូចមានផលប៉ះពាល់រយៈពេលវែងលើការកាត់បន្ថយចំនួនបទល្មើស ដែលប្រព្រឹត្តដោយមនុស្សពេញវ័យ។

ការអប់រំអាចបង្កើនការយល់ដឹងអំពីបញ្ហាប្រឈមខាងបរិស្ថាន និងការទទួលខុសត្រូវក្នុងទីក្រុង។ ឧបករណ៍អប់រំមានតួនាទីយ៉ាងសំខាន់ ក្នុងការលើកទឹកចិត្តឲ្យប្រជាពលរដ្ឋជាច្រើននាក់ប្រើប្រាស់រថយន្តក្រុងសាធារណៈ និងប្រើប្រាស់កង់ជាមធ្យោបាយធ្វើដំណើរ។ នៅរដ្ឋ Lagos ប្រទេសនីហ្សេរីយ៉ា កម្មវិធីអប់រំផ្សព្វផ្សាយទូលំទូលាយអំពីប្រព័ន្ធរថយន្តក្រុងសាធារណៈថ្មី បានជួយកាត់បន្ថយការពន្យារពេលការដាក់ឲ្យអនុវត្តនូវប្រព័ន្ធថ្មីនេះ។ ក្នុងប្រទេស ដែលប្រជាពលរដ្ឋនិយមប្រើប្រាស់កង់ជាមធ្យោបាយធ្វើដំណើរក្នុងទីក្រុង ដូចជា ប្រទេសដាណឺម៉ាក អាល្លឺម៉ង់ និងហុល្លង់ ជាដើម ការអប់រំត្រូវបានបញ្ចូលទៅក្នុងវិធីសាស្ត្របណ្តុះបណ្តាលចម្រុះ ដើម្បីឲ្យកុមារអាចទទួលបានការបណ្តុះបណ្តាលបែបនេះតាំងពីពេលដែលពួកគេនៅតូចៗឡើងទៅ។

## ...ប៉ុន្តែ ក៏អាចចូលរួមចំណែកនាំឲ្យមានវិសមភាពនៅតំបន់ទីក្រុងផងដែរ

ដើម្បីធានាយ៉ាងណាឲ្យការអប់រំមិនធ្វើឲ្យកាន់តែមានការបែងចែកវណ្ណៈក្នុងសង្គម រដ្ឋាភិបាលចាំបាច់ត្រូវថ្លឹងថ្លែងសកម្មភាពពាក់ព័ន្ធនឹងការអប់រំ ដែលអាចបង្កើនភាពប្រកួតប្រជែងរបស់ទីក្រុង ជាមួយនឹងសកម្មភាព ដែលលើកកម្ពស់បរិយាប័ន្នសង្គម។

វិសមភាពនៃការអប់រំមានកម្រិតខ្ពស់រវាងក្រុមមួយ និងក្រុមមួយទៀត ក្នុងតំបន់ទីក្រុង និងរវាងតំបន់ជនបទ និងតំបន់ទីក្រុង។ អត្ថប្រយោជន៍ ដែលគេអាចទទួលបានពីការរស់នៅក្នុងតំបន់ទីក្រុង អាចត្រូវបានរាំងស្ទះ ដោយសារតែការពុំមានគោលនយោបាយ ដែលផ្តោតការយកចិត្តទុកដាក់លើបញ្ហាអសមធម៌។ គោលនយោបាយ និងការអនុវត្ត ដែលមានចរិតរើសអើង ដូចជា ការបែងចែកពុំមានសមធម៌នូវគ្រូដែលមានសមត្ថភាព ក៏អាចធ្វើឲ្យបញ្ហាវិសមភាពកាន់តែរីកធំផងដែរ។ ក្នុងទីក្រុង Concepcion នៃប្រទេសឈីលី គេរកឃើញភាពខុសប្លែកគ្នាយ៉ាងច្រើន ពាក់ព័ន្ធនឹងការបែងចែកសាលារៀន ដែលមានគុណភាពល្អ។

**រូបភាពទី៥ :**

**គម្លាតរវាងតំបន់ជនបទ និងតំបន់ទីក្រុង កើតមាននៅតាមប្រទេសកំពុងអភិវឌ្ឍ ហើយប្រទេសទាំងនេះក៏មានគម្លាតខ្ពស់រវាងប្រជាជនក្រុមមួយ និងក្រុមមួយទៀត ក្នុងទីក្រុងផងដែរ**

គម្លាតតាមទីតាំង (ជនបទ-ទីក្រុង) និងទ្រព្យធន (បញ្ចភាគក្រោមគេ និងលើគេ) នៃអត្រាបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិ




ប្រភព៖ ការវិភាគរបស់ក្រុមរៀបចំរបាយការណ៍ GEM (២០១៦) ដោយប្រើប្រាស់ការអង្កេតប្រជាសាស្ត្រ និងសុខភាព ការអង្កេតដោយប្រើប្រាស់ចង្កោមសូចនាករចម្រុះ និងការអង្កេតគ្រួសារទូទាំងប្រទេស

សាលារៀនឯកជន ដែលជារឿយៗត្រូវបានបង្កើតឡើងដោយសារតែការផ្តល់សេវារបស់រដ្ឋាភិបាលមានកម្រិតខ្សោយ អាចជួយកាត់បន្ថយវិសមភាពផង និងអាចធ្វើឲ្យវិសមភាពមានការកើនឡើងផង។ការមានសាលារៀនច្រើនសម្រាប់ជ្រើសរើស ដែលអាចឲ្យឪពុកម្តាយធ្វើការ ជ្រើសរើសរវាងសាលារៀនរដ្ឋ សាលារៀនឯកជន សាលារៀនដែលផ្តល់កន្លែងស្នាក់នៅដល់សិស្ស និងសាលារៀន មិនមែនជារបស់រដ្ឋផ្សេងទៀត គឺជាមូលហេតុផង និងជាផលវិបាកនៃការបែងចែកប្រជាសាស្ត្រផង។

វិសមភាពក្នុងវិស័យអប់រំ អាចកើតឡើងដោយសារតវិយាបថអវិជ្ជមាន។គ្រូតែងតែបង្ហាញពីឥរិយាបថ រើសអើងចំពោះកុមារចំណាកស្រុក និងកុមារជនជាតិភាគតិច ដែលនេះជាកត្តា ដែលអាចរួមចំណែកឲ្យក្រុមទាំងនេះត្រូវបាត់បង់ឱកាសក្នុងសង្គម។ ក្នុងទីក្រុងសៀងហៃ គ្រូថ្នាក់ទីមួយ ច្រើនតែរាយការណ៍ថា សិស្សចំណាកស្រុកទទួលបានពិន្ទុក្រោមមធ្យមភាគខាងភាសា សូម្បីតែក្រោយពេលគិតបញ្ចូលលក្ខណៈផ្សេងៗនៃសាវតាររបស់ពួកគេរួចក៏ដោយ។ការអប់រំក៏អាចបង្កឲ្យមានការផាត់ក្រុមណាមួយចេញពីសង្គមផងដែរ ប្រសិនបើមានអំពើហិង្សាកើតឡើងក្នុងសាលារៀនដែលផ្តល់ការអប់រំដល់ក្រុមដែលជួបការលំបាក។

វិសមភាពនៃការអប់រំមានកម្រិតខ្ពស់រវាងក្រុមមួយ និងក្រុមមួយទៀត ក្នុងតំបន់ទីក្រុង និងរវាងតំបន់ជនបទ និងតំបន់ទីក្រុង។ អត្ថប្រយោជន៍ ដែលគេអាចទទួលបានពីការរស់នៅក្នុងតំបន់ទីក្រុង អាចត្រូវបានរាំងស្ទះ ដោយសារតែការពុំមានគោលនយោបាយ ដែលផ្តោតការយកចិត្តទុកដាក់លើបញ្ហាអសមធម៌។គោលនយោបាយ និងការអនុវត្តដែលមានចរិតរើសអើង ដូចជា ការបែងចែកពុំមានសមធម៌នូវគ្រូដែលមានសមត្ថភាព ក៏អាចធ្វើឲ្យបញ្ហាវិសមភាពកាន់តែរីកធំផងដែរ។ ក្នុងទីក្រុង Concepcion នៃប្រទេសឈីលី គេរកឃើញភាពខុសប្លែកគ្នាយ៉ាងច្រើន ពាក់ព័ន្ធនឹងការបែងចែកសាលារៀន ដែលមានគុណភាពល្អ។

សាលារៀនឯកជន ដែលជារឿយៗ ត្រូវបានបង្កើតឡើង ដោយសារតែការផ្តល់សេវារបស់រដ្ឋាភិបាលមានកម្រិតខ្សោយ អាចជួយកាត់បន្ថយវិសមភាពផង និងអាចធ្វើឲ្យវិសមភាពមានការកើនឡើងផង។ ការមានសាលារៀនច្រើនសម្រាប់ជ្រើសរើស ដែលអាចឲ្យឪពុកម្តាយធ្វើការជ្រើសរើសរវាងសាលារៀនរដ្ឋ សាលារៀនឯកជន សាលារៀនដែលផ្តល់កន្លែងស្នាក់នៅដល់សិស្ស និងសាលារៀនមិនមែនជារបស់រដ្ឋផ្សេងទៀត គឺជាមូលហេតុផង និងជាផលវិបាកនៃការបែងចែកប្រជាសាស្ត្រផង។

វិសមភាពក្នុងវិស័យអប់រំ អាចកើតឡើងដោយសារតវិយាបថអវិជ្ជមាន។ គ្រូតែងតែបង្ហាញពីឥរិយាបថរើសអើងចំពោះកុមារចំណាកស្រុក និងកុមារជនជាតិភាគតិច ដែលនេះជាកត្តាដែលអាចរួមចំណែកឲ្យក្រុមទាំងនេះត្រូវបាត់បង់ឱកាសក្នុងសង្គម។ ក្នុងទីក្រុងសៀងហៃ គ្រូថ្នាក់ទីមួយ ច្រើនតែរាយការណ៍ថា សិស្សចំណាកស្រុកទទួលបានពិន្ទុក្រោមមធ្យមភាគខាងភាសា សូម្បីតែក្រោយពេលគិតបញ្ចូលលក្ខណៈផ្សេងៗនៃសាវតាររបស់ពួកគេរួចក៏ដោយ។ ការអប់រំក៏អាចបង្កឲ្យមានការផាត់ក្រុមណាមួយចេញពីសង្គមផងដែរ ប្រសិនបើមានអំពើហិង្សាកើតឡើងក្នុងសាលារៀនដែលផ្តល់ការអប់រំដល់ក្រុមដែលជួបការលំបាក។

ការបែងចែកទៅតាមជាតិពន្ធុ វណ្ណៈសង្គម ឬពូជសាសន៍ តែងកើតមានក្នុងការអប់រំ ដែលផ្តល់តាមទីក្រុងនានា នៅសហរដ្ឋអាមេរិចក្នុងទីក្រុងជាច្រើននៅអឺរ៉ុប និងនៅតាមប្រទេសដែលធ្លាប់មានបញ្ហាខាងពូជសាសន៍ ដូចជា អាហ្វ្រិចខាងត្បូង ជាដើម។ ការបែងចែកក្នុងវិស័យអប់រំ រឹតតែមានកម្រិតខ្ពស់ថែមទៀត ក្នុងតំបន់ទីក្រុងដែលបច្ចេកវិទ្យាមានការរីកចម្រើនខ្ពស់ ប្រើប្រាស់ចំណេះដឹងជាគោល។ ក្នុង ៩០% នៃតំបន់ទីក្រុងធំៗជាងគេចំនួន ៣០ នៅសហរដ្ឋអាមេរិច ការបែងចែកសិស្សទៅតាមគ្រួសារដែលមានចំណូលខ្ពស់ និងទាប រឹតតែមានការកើនឡើងខ្ពស់ជាងមុន។ ការស្រាវជ្រាវពីទីក្រុងធំៗចំនួន ១៣ នៅអឺរ៉ុប បង្ហាញថា ការបែងចែកទៅតាមឋានៈសង្គម

សេដ្ឋកិច្ច និងតាមទីកន្លែងរស់នៅ រឹតតែមានការកើនឡើង នៅពេលដែលប្រជាជនដែលមានការអប់រំខ្ពស់បំពេញតួនាទីសំខាន់ ក្នុងការជម្រុញកំណើនឧស្សាហកម្មដែលប្រើប្រាស់ចំណេះដឹងជាគោល។

## ការអប់រំ និងការរៀនសូត្រពេញមួយជីវិត អាចមានឥទ្ធិពលលើការរៀបចំផែនការទីក្រុង និងជួយឲ្យមានការផ្លាស់ប្តូរក្នុងទីក្រុង

ការអប់រំអាចមានឥទ្ធិពលលើការរៀបចំផែនការទីក្រុង ប្រសិនបើការអប់រំគឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីរៀបចំផែនការទីក្រុង។ ក្នុងទីក្រុងប៉ៃឡាំង មានការដាក់ឲ្យអនុវត្តនូវគម្រោងគ្រប់គ្រងសហគមន៍ ដើម្បីបង្កើតនូវ "ទីក្រុងដែលមនុស្សអាចរស់នៅប្រកបដោយភាពសុខដុមរមនាជាមួយគ្នាក្នុងសង្គម" តាមរយៈការរៀបចំនូវសកម្មភាពផ្សេងទៀត និងការផ្តល់នូវឱកាសអប់រំ និងការងារ។

ការសម្រេចសក្តានុពលនេះតម្រូវឲ្យមានការកែលំអការបណ្តុះបណ្តាលអន្តរជំនាញ ដើម្បីផ្តល់លទ្ធភាពឲ្យអ្នករៀបចំផែនការទីក្រុងបំពេញការងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ដោយមានការសហការរវាងជំនាញ និងវិស័យនានា ក្នុងគោលបំណងលើកកម្ពស់ឲ្យបរិយាកាសរស់នៅកាន់តែមាននិរន្តរភាព។ ក្នុងប្រទេសភាគច្រើន សាលារៀន និងកម្មវិធីបណ្តុះបណ្តាលអំពីការរៀបចំផែនការទីក្រុងនៅមានចំនួនតិចតួចនៅឡើយ។ ប្រទេសឥណ្ឌាមានអ្នករៀបចំផែនការទីក្រុង ១ នាក់ សម្រាប់ប្រជាជនក្នុងទីក្រុង ១០០០០០ នាក់ បើធៀបជាមួយនឹង ១ នាក់ សម្រាប់ប្រជាជន ៥០០០ នាក់ នៅប្រទេសកាណាដា និងសហរដ្ឋអាមេរិច។ វិធីសាស្ត្ររៀបចំផែនការទីក្រុងដែលបង្កលក្ខណៈឲ្យមានការចូលរួម ដែលទទួលស្គាល់ពីតម្រូវការរបស់ក្រុមដែលជួបការលំបាកធ្វើឲ្យការរៀបចំផែនការទីក្រុង និងការធ្វើសេចក្តីសម្រេចចិត្តកាន់តែមានលក្ខណៈល្អប្រសើរ។ បណ្តាញអ្នករស់នៅតំបន់ក្រីក្រអន្តរជាតិ (Shack/Slum Dwellers International) បានជួយសមាជិកសហគមន៍ ឲ្យចេះចងក្រងឯកសារពីបញ្ហាវិសមភាពដែលកើតមានឡើង និងធ្វើការទាមទារសេវាពីរដ្ឋាភិបាលក្នុងមូលដ្ឋានរបស់ពួកគេ។ ក្នុងភាពជាដៃគូជាមួយនឹងសមាគមសាលាផែនការនៅអាហ្វ្រិច បណ្តាញនេះបានចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីបង្កើនភាពឆ្លើយតបនៃការរៀបចំផែនការទីក្រុង ជាពិសេស ពាក់ព័ន្ធជាមួយនឹងការតាំងទីលំនៅមិនរៀបរយ។

> "ប្រទេសឥណ្ឌាមានអ្នករៀបចំផែនការទីក្រុង ១ នាក់ សម្រាប់ប្រជាជនក្នុងទីក្រុង ១០០០០០ នាក់ បើធៀបជាមួយនឹង ១ នាក់ សម្រាប់ប្រជាជន ៥០០០ នាក់ នៅប្រទេសកាណាដា និងសហរដ្ឋអាមេរិច"

ថ្នាក់ដឹកនាំទីក្រុងដែលទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយអាចប្រើប្រាស់ការអប់រំនិងការរៀនសូត្រពេញមួយជីវិតដើម្បីធ្វើឲ្យទីក្រុងមានការផ្លាស់ប្តូរ។ ក្នុងទីក្រុង Medellin ប្រទេសកូឡុំប៊ី អភិបាលក្រុងនេះបានជួយកែប្រែទីក្រុងនេះ ពីទីក្រុងមួយដែលមានអំពើហិង្សាជាងគេក្នុងពិភពលោក ទៅជាទីក្រុងដែលមាននវានុវត្តន៍ជាងគេ តាមរយៈការអនុវត្តយុទ្ធសាស្ត្រដែលធ្វើឲ្យមានការផ្លាស់ប្តូរក្នុងសង្គមតាមរយៈការអប់រំ។ នៅពេលដែលទីក្រុងកាន់តែមានតួនាទីសំខាន់ ការបង្កើនស្វ័យភាពរបស់ទីក្រុង និងការផ្តោតការយកចិត្តទុកដាក់លើយុទ្ធសាស្ត្រអប់រំ គឺជាគន្លឹះ ដើម្បីធ្វើឲ្យទីក្រុងមាននិរន្តរភាព និងបរិយាប័ន្ន។



តំបន់ Favelas ក្នុងទីក្រុង Rio de Janeiro ដែលត្រូវបានបង្កើតឡើងនៅពេលដែលប្រជាជនជាច្រើននាក់ផ្លាស់ពីតំបន់ជនបទមកទីក្រុងក្នុងប្រទេសប្រេស៊ីល។
រូបថត៖ Anna Spysz/GEM Report




@GEMReport #SDG4All bitly.com/sdg4all

# ភាពជាដៃគូ៖ លក្ខខណ្ឌ ដែលផ្តល់លទ្ធភាពឲ្យមានការសម្រេចគោលដៅ SDG ទី ៤ និងគោលដៅ SDG ផ្សេងទៀត

របៀបវារៈឆ្នាំ ២០៣០ ចាត់ទុកបញ្ហាប្រឈមខាងសង្គម សេដ្ឋកិច្ច និងបរិស្ថានបច្ចុប្បន្ននេះ ថាជាបញ្ហា ដែលមិនអាចបែងចែកពីគ្នាបាន ដែលទាមទារឲ្យមានការឆ្លើយតបបែបក្តោបរួមជាអន្តរវិស័យ។ គោលដៅ SDG ទី ១៧ រៀបរាប់ពីមធ្យោបាយ ដើម្បីសម្រេចគោលដៅ SDG នានា និងអំពាវនាវឲ្យមានការពង្រឹងឡើងវិញនូវភាពជាដៃគូជាសកល។ ចំណុចដៅនៃគោលដៅនេះរំលេចឲ្យឃើញពីភាពចាំបាច់ ដើម្បីឲ្យមានកិច្ចសហប្រតិបត្តិការជាមួយគ្នា ដើម្បីធានាឲ្យមានការផ្តល់ថវិកាឲ្យបានគ្រប់គ្រាន់ បង្កើនភាពស៊ីសង្វាក់គ្នាខាងគោលនយោបាយ និងកសាងនូវភាពជាដៃគូក្នុងរវាងអ្នកពាក់ព័ន្ធនានា ។ល។

## ហិរញ្ញប្បទាន

ក្រុមរៀបចំរបាយការណ៍ពិនិត្យតាមដានការអប់រំទូទាំងសកលលោកនេះ ប៉ាន់ប្រមាណឃើញថា ត្រឹមឆ្នាំ ២០៣០ ចំណាយប្រចាំឆ្នាំសរុប ដើម្បីធានាយ៉ាងណាឲ្យកុមារ និងក្មេងជំទង់គ្រប់រូប ក្នុងប្រទេសដែលមានចំណូលទាប និងប្រទេសដែលមានចំណូលមធ្យមកម្រិតទាប អាចទទួលបានការអប់រំប្រកបដោយគុណភាព ចាប់ពីកម្រិតមត្តេយ្យសិក្សា រហូតដល់កម្រិតមធ្យមសិក្សាទុតិយភូមិ មានការកើនឡើងពី ១៤៩ ពាន់លានដុល្លារ រហូតដល់ ៣៤០ ពាន់លានដុល្លារ។ គណៈកម្មការអន្តរជាតិទទួលបន្ទុកការងារផ្តល់ហិរញ្ញប្បទានដល់ឱកាសទទួលបានការអប់រំជាសកល បានធ្វើការប្រកាសក្នុងកិច្ចប្រជុំកំពូលស្តីពីការអប់រំសម្រាប់ការអភិវឌ្ឍក្នុងទីក្រុងអូស្លូ កាលពីខែ កក្កដា ឆ្នាំ ២០១៥ បានអំពាវនាវឲ្យមានការរៀបចំកិច្ចព្រមព្រៀងថ្មីមួយស្តីពីការអប់រំ ដោយបានដាក់ចេញនូវវិធានការជាក់លាក់ ដើម្បីកៀងគរមូលនិធិក្នុងប្រទេស និងដើម្បីបំពេញកង្វះថវិកា។

ក្របខ័ណ្ឌសកម្មភាពអប់រំឆ្នាំ ២០៣០ ដាក់ចេញនូវចំណុចដៅចំនួន ២ សម្រាប់ការផ្តល់ហិរញ្ញប្បទានដល់វិស័យអប់រំពីប្រភពថវិកាក្នុងស្រុក៖ ៤% ទៅ ៦% នៃផលិតផលសរុបក្នុងស្រុក និងពី ១៥% ដល់ ២០% នៃចំណាយសាធារណៈ។ ការកៀងគរធនធានក្នុងស្រុកបន្ថែមទៀតគឺមានសារៈសំខាន់យ៉ាងខ្លាំង។ ក្នុងប្រទេសចំណូលទាបប្រហែលជាពាក់កណ្តាល អត្រាពន្ធគឺស្ថិតនៅក្រោម ១៥% នៃ GDP បើធៀបជាមួយនឹង ១៨%ក្នុងប្រទេសដែលមានសេដ្ឋកិច្ចទើបរីកចម្រើន និង ២៦%ក្នុងប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើនខ្លាំង។ការបង្កើនអត្រាពន្ធ នៅតាមប្រទេសក្រីក្រ ទាមទារឲ្យមានកិច្ចខិតខំប្រឹងប្រែងក្នុងស្រុកផង និងកិច្ចខិតខំប្រឹងប្រែងកម្រិតសកលផង។ ការអប់រំអាចកែលំអឥរិយាបថរបស់អ្នកបង់ពន្ធ និងបង្កើនភាពអនុលោមតាមច្បាប់។ អត្រាអក្ខរកម្មទាបមានទំនាក់ទំនងជាមួយនឹងការថមថយចំណូលពន្ធក្នុងប្រទេសចំនួន ១២៣ ដែលត្រូវបានសិក្សាជាមួយនឹងទិន្នន័យពីឆ្នាំ ១៩៩៦ ដល់ ២០១០។ អ្នកដែលគេចវេសពីការបង់ពន្ធ ភាគច្រើន ជាក្រុមអ្នកដែលមានកម្រិតវប្បធម៌ខ្ពស់ ប៉ុន្តែការអប់រំក៏មានទំនាក់ទំនងជាមួយនឹងឥរិយាបថជាវិជ្ជមានពាក់ព័ន្ធនឹងពន្ធផងដែរ។ នៅអាមេរិចឡាទីនប្រទេសចំនួន ៩ បានបញ្ចូលការអប់រំអំពីពន្ធទៅក្នុងកម្មវិធីសិក្សារបស់ខ្លួន តាមរយៈការខិតខំប្រឹងប្រែងរួមគ្នារវាងក្រសួងអប់រំ និងអាជ្ញាធរទទួលបន្ទុកប្រមូលពន្ធ។

> “ប្រទេសដែលមានចំណូលទាបខាតបង់ចំណូលពន្ធប្រមាណជា ១០០ ពាន់លានដុល្លារក្នុងមួយឆ្នាំ ដោយសារតែការគេចវេសមិនបង់ពន្ធរបស់ក្រុមហ៊ុនពហុជាតិ។”

ការដោះស្រាយបញ្ហាគេចវេសមិនបង់ពន្ធ ក៏ជាការទទួលខុសត្រូវកម្រិតសកលផងដែរ។ ការប៉ាន់ប្រមាណកាលពីពេលថ្មីៗនេះ បង្ហាញថា ប្រទេសដែលមានចំណូលទាបខាតបង់ចំណូលពន្ធប្រមាណជា ១០០ ពាន់លានដុល្លារក្នុងមួយឆ្នាំ ដោយសារតែការគេចវេសមិនបង់ពន្ធរបស់ក្រុមហ៊ុនពហុជាតិ ដោយសារការវិនិយោគនៅក្រៅប្រទេស។ ចាំបាច់ត្រូវមានការចាត់វិធានការដែលមានការសម្របសម្រួលបានល្អក្នុងប្រទេស និងជាអន្តរជាតិ ជុំវិញការលើកទឹកចិត្តផ្នែកពន្ធ សន្ធិសញ្ញាស្តីពីពន្ធ និងការសម្រេចចិត្តដែលមានលក្ខណៈទុច្ចរិតរបស់ក្រុមហ៊ុនពាក់ព័ន្ធនឹងពន្ធ ដើម្បីជួយឲ្យប្រទេសដែលមានចំណូលទាបអាចស្តារមកវិញនូវការបាត់បង់ចំណូលពន្ធរបស់ខ្លួន។

ប្រទេសជាច្រើនអាចធ្វើការវិភាជន៍ថវិកាចំណាយរបស់ខ្លួនឡើងវិញ ដើម្បីផ្តល់ប្រយោជន៍ដល់វិស័យអប់រំ។ វិធីពីរយ៉ាង សម្រាប់ផ្តល់អាទិភាពដល់ចំណាយសម្រាប់វិស័យអប់រំ រួមមាន ការដកឧបត្ថម្ភពីឥន្ធនៈហ្វូស៊ីល និងយកចំណូលនេះមកប្រើប្រាស់សម្រាប់វិស័យអប់រំ។ ក្នុងប្រទេសឥណ្ឌូនេស៊ី ចំណាយសាធារណៈលើវិស័យអប់រំបានកើនឡើងជាង ៦០% ចន្លោះពីឆ្នាំ ២០០៥ ដល់ ២០០៩ ដោយសារតែកំណែទម្រង់ឧបត្ថម្ភធនឥន្ធនៈបែបនេះ។

ប៉ុន្តែបើទោះបីជាគេសន្មត់ថាការកៀងគរចំណូលក្នុងស្រុកមានការកើនឡើងក៏ដោយថវិកាសម្រាប់វិស័យអប់រំនៅខ្វះ៣៩ពាន់លានដុល្លារជារៀងរាល់ឆ្នាំ។ ជំនួយអន្តរជាតិនៅតែបន្តជាការចាំបាច់ សម្រាប់ប្រទេសដែលមានចំណូលទាបជាច្រើន។ ទោះជាយ៉ាងណាក៏ដោយ ទំហំជំនួយសម្រាប់វិស័យអប់រំមានការថយចុះប្រហែលជា ៦០០ លានដុល្លារ ពីឆ្នាំ ២០១៣ ដល់ ២០១៤។ ក្នុងបរិបទនេះ មានជម្រើសចំនួន ៣ ដែលមានសក្តានុពល៖ វិភាជន៍ថវិកាបន្ថែម សម្រាប់វិស័យអប់រំ តាមរយៈយន្តការពហុភាគី, ប្រើប្រាស់ថវិកាជំនួយបន្ថែមសម្រាប់កសាងសមត្ថភាពរបស់អាជ្ញាធរជាតិ ដើម្បីបង្កើនការកៀងគរធនធានក្នុងប្រទេស និងផ្តល់ថវិកាជំនួយឲ្យចំគោលដៅប្រទេស និងកម្រិតនៃការអប់រំដែលកំពុងត្រូវការជំនួយជាងគេ។ មានចំណុចជាច្រើនសម្រាប់ធ្វើការកែលំអបន្ថែមទៀត៖ បើទោះបីជាការវិនិយោគលើការអប់រំកុមារតូចផ្តល់នូវអត្ថប្រយោជន៍ជាច្រើនយ៉ាងណាក៏ដោយ ការគាំពារ និងអប់រំកុមារតូចទទួលបានថវិកាជំនួយផ្ទាល់ត្រឹមតែ ១០៦ លានដុល្លារប៉ុណ្ណោះ ក្នុងឆ្នាំ ២០១៤ ពោលគឺតិចជាង ៣% នៃថវិកាជំនួយសម្រាប់ការអប់រំក្រោយមធ្យមសិក្សា។

## ភាពស៊ីសង្វាក់គ្នាខាងគោលនយោបាយ

ការប្រើប្រាស់អភិក្រមតាមវិស័យ គឺមិនគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហាប្រឈមនៃការអភិវឌ្ឍប្រកបដោយចីរភាពដែលទាមទារឲ្យមានការប្រើប្រាស់អភិក្រមពហុវិស័យនោះទេ។ របៀបវារៈ SDG ទាំងមូល ត្រូវការអភិក្រមដែលមានចរិតអន្តរវិស័យ។ ក្នុងវិស័យអប់រំអន្តរាគមន៍ពហុវិស័យ រួមមាន ការអនុវត្តគំនិតផ្តួចផ្តើមពហុវិស័យ ដែលផ្តោតលើការផ្តល់អាហារតាមសាលារៀន និងសុខភាពសិក្សា ការអភិវឌ្ឍកុមារតូច និងការបណ្តុះបណ្តាលជំនាញចិញ្ចឹមជីវិត។

នៅថ្នាក់ជាតិ កិច្ចខិតខំប្រឹងប្រែងដែលទទួលបានជោគជ័យក្នុងការកែលំអការរៀបចំផែនការពហុវិស័យ ឆ្លុះបញ្ចាំងឲ្យឃើញពីសារៈសំខាន់នៃឆន្ទៈនយោបាយ ការគាំទ្រស្ថាប័ន សមត្ថភាពគ្រប់គ្រាន់ និងទិន្នន័យគ្រប់ជ្រុងជ្រោយ។ ក្នុងប្រទេសនីហ្សេរីយ៉ា មូលនិធិដោះបំណុលត្រូវបានប្រើប្រាស់ ដើម្បីគាំទ្រឲ្យមានការផ្តល់សេវាអប់រំ សុខភាព ទឹក និងអនាម័យ ដល់មូលដ្ឋានផ្ទាល់នូវ ដែលជាការគាំទ្រដល់ការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ ផែនការអភិវឌ្ឍន៍ជាតិ របស់ប្រទេសកូឡុំប៊ីចាត់ទុកការអប់រំ សន្តិភាព និងសមធម៌ ជាអាទិភាពរបស់ប្រធានាធិបតី។ ផែនការនេះមានគោលបំណងធ្វើឲ្យប្រទេសកូឡុំប៊ីក្លាយជាប្រទេសដែលមានកម្រិតអប់រំខ្ពស់ជាងគេ នៅអាមេរិចឡាទីន ត្រឹមឆ្នាំ ២០២៥។

**រូបភាពទី៦ :**

**ជំនួយសម្រាប់ការអប់រំកម្រិតមូលដ្ឋានពុំបានផ្សារភ្ជាប់ជាមួយនឹងតម្រូវការឡើយ**

ជំនួយសរុបសម្រាប់ការអប់រំកម្រិតមូលដ្ឋាន សម្រាប់កុមារដល់អាយុចូលរៀននៅបឋមសិក្សាមួយនាក់(២០១៤) និងអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា (២០០៨-២០១៤)




ប្រភព៖ ការវិភាគរបស់ក្រុមរៀបចំរបាយការណ៍ GEM ផ្អែកតាមប្រព័ន្ធរាយការណ៍របស់ក្រុមប្រទេសផ្តល់ឥណទានដែលជាសមាជិករបស់ OECD (២០១៦), មូលដ្ឋានទិន្នន័យវិសមភាពអប់រំពិភពលោក

ជាធម្មតា ស្ថាប័ននានារបស់រដ្ឋាភិបាលច្រើនផ្តោតការ យកចិត្តទុកដាក់លើការតាក់តែង និងការអនុវត្តគោលនយោបាយក្នុងវិស័យរៀងៗខ្លួនរបស់ពួកគេ ដែលធ្វើឲ្យប៉ះពាល់ដល់ការសម្របសម្រួល និងការសហការគ្នា។ ផែនការជាតិ ដែលមានការតាក់តែងបានល្អ ហើយដែលផ្សារភ្ជាប់ ទំនាក់ទំនងជាមួយនឹងផែនការផ្តល់ហិរញ្ញប្បទាន ដល់វិស័យអប់រំដែលមានគុណភាពល្អ ក៏ដូចជាជាមួយនឹងប្រព័ន្ធផែនការ និងហិរញ្ញប្បទានបែបវិមជ្ឈការ និងដែលនាំឲ្យមានការធ្វើសមាហរណកម្មពហុវិស័យបានល្អប្រសើរ គឺជាអ្វីដែលមិនសូវជាកើតមាននៅតាមប្រទេសក្រីក្រភាគច្រើនឡើយ។

ទីភ្នាក់ងារផ្តល់ជំនួយនានាជួបប្រទះនឹងបញ្ហាប្រឈមចំនួនពីរ ក្នុងការអនុវត្តកម្មវិធី ឲ្យស្របតាមតម្រូវការនៃការរៀបចំផែនការបែបពហុវិស័យ ដើម្បីសម្រេចគោលដៅ SDG៖ ទីភ្នាក់ងារទាំងនេះអាចពុំមានចក្ខុវិស័យដែលមានលក្ខណៈស៊ីសង្វាក់គ្នា ជុំវិញអភិក្រមដែលទីភ្នាក់ងារទាំងនេះប្រើប្រាស់ សម្រាប់អនុវត្តការងារអភិវឌ្ឍន៍របស់ខ្លួន ហើយទីភ្នាក់ងារទាំងនេះជួបការលំបាកក្នុងការសម្របសម្រួលការ

អនុវត្តកម្មវិធីដែលមានលក្ខណៈពហុវិស័យ។ ជំនួយមិនត្រូវបានគេវិភាគជន៍ក្នុងចំនួនគ្រប់គ្រាន់ ទៅតាមតម្រូវការរបស់ប្រទេសឡើយ។ ក្នុងប្រទេសលីបេរី និងម៉ៅរីតានី មានកុមារប្រហែលជាពាក់កណ្ដាល ដែលរៀនចប់បឋមសិក្សា ប៉ុន្តែប្រទេសលីបេរីទទួលបានថវិកាជំនួយសម្រាប់ការអប់រំកម្រិតមូលដ្ឋាន សម្រាប់កុមារដល់អាយុចូលរៀនម្នាក់ ច្រើនជាងប្រទេសម៉ៅរីតានី ដល់ទៅ ១០ ដង។

## ភាពជាដៃគូ

អាជ្ញាធររដ្ឋនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ សង្គមស៊ីវិល អ្នកសិក្សាស្រាវជ្រាវ សហគមន៍វិទ្យាសាស្ត្រ វិស័យឯកជន និងអង្គការដែលមានការចូលរួមពីអ្នកពាក់ព័ន្ធចម្រុះនៅថ្នាក់សកល គឺជាដៃគូមួយចំនួន ដែលអាចជួយអនុវត្តរបៀបវារៈសកល ដូចជា គោលដៅ SDGs នេះជាដើម។ ភាពជាដៃគូរវាងសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធចម្រុះ មានតួនាទីសំខាន់ ក្នុងការផ្ដល់ហិរញ្ញប្បទាន អនុវត្ត និងធានាឲ្យមានគណនេយ្យភាពទ្វេទិស សម្រាប់របៀបវារៈថ្មីនេះ ដែលត្រូវមានអនុវត្តក្រោមការដឹកនាំរបស់រដ្ឋាភិបាលថ្នាក់ជាតិ។

ការកើនឡើងនូវសកម្មភាពរបស់សង្គមស៊ីវិល គឺជាសមិទ្ធផលចម្បងមួយនៃរបៀបវារៈអប់រំ សម្រាប់ទាំងអស់គ្នា។ ប៉ុន្តែ មានការលំបាកមួយចំនួនក្នុងការរៀបចំភាពជាដៃគូសង្គមស៊ីវិលឲ្យបានល្អ។ តើអង្គការនានា ដែលពឹងអាស្រ័យខ្លាំងលើមូលនិធិពីអ្នកផ្ដល់ជំនួយ អាចរក្សាសម្លេងឯករាជ្យរបស់ខ្លួន? បញ្ហាប្រឈមមួយទៀត គឺមានតួអង្គច្រើនពេក ដែលជ្រកក្រោមឆ័ត្រសង្គមស៊ីវិល។

សកម្មភាព និងហិរញ្ញប្បទាន ដែលវិស័យឯកជនអាចចូលរួម ដើម្បីសម្រេចគោលដៅ SDGs គឺជាមូលហេតុដែលនាំឲ្យគេមានសុទិដ្ឋិនិយម។ ប៉ុន្តែខណៈពេលដែលមានមនុស្សមួយចំនួនសាទរថាការកើនឡើងនូវការចូលរួមរបស់វិស័យឯកជន ថានឹងនាំមកនូវធនធានហិរញ្ញប្បទាន ភាពបត់បែន នវានុវត្តន៍ និងធ្វើឲ្យលទ្ធផលនៃការរៀនសូត្រកាន់តែមានលក្ខណៈល្អប្រសើរ អ្នកដែលមានមន្ទិលសង្ស័យមើលឃើញពីសក្ដានុពលនៃការកើនឡើងនូវសិមភាព និងធ្វើឲ្យការអប់រំទទួលរងឥទ្ធិពលមិនល្អពីទីផ្សារ។

> “ស្ថាប័នសម្របសម្រួល និងផ្ដល់ហិរញ្ញប្បទានមានតួនាទីសំខាន់ សម្រាប់ជោគជ័យនៃរបៀបវារៈ SDG។”

ស្ថាប័នសម្របសម្រួល និងផ្ដល់ហិរញ្ញប្បទានមានតួនាទីសំខាន់។ យន្តការសម្របសម្រួលការងារអប់រំនៅកម្រិតសកល មាន ដូចជា គណៈកម្មាធិការដឹកនាំការងារអប់រំនៃគោលដៅ SDG ឆ្នាំ ២០៣០, កិច្ចប្រជុំសកលស្ដីពីការអប់រំ, កិច្ចប្រជុំថ្នាក់តំបន់ និងបណ្ដាញអង្គការមិនមែនរដ្ឋាភិបាលនានា។ គណៈកម្មាធិការដឹកនាំនេះគឺជាយន្តការចម្បង ដើម្បីផ្ដល់ការគាំទ្រដល់ប្រទេសនានា ពិនិត្យលើវឌ្ឍនភាពដែលសម្រេចបាន និងលើកទឹកចិត្តឲ្យមានការសម្របសម្រួលសកម្មភាពដែលអនុវត្តដោយដៃគូនានា។ ភាពជាដៃគូសកលសម្រាប់ការអប់រំ ដែលជាភាពជាដៃគូចម្បងមានការចូលរួមពីអ្នកពាក់ព័ន្ធចម្រុះក្នុងវិស័យអប់រំ អាចរៀនសូត្រពីភាពជាដៃគូក្នុងវិស័យសុខាភិបាល ដូចជា មូលនិធិសកលសម្រាប់ប្រយុទ្ធនឹងជំងឺរបេង ជំងឺអេដស៍ និងជំងឺគ្រុនចាញ់ និងសម្ព័ន្ធ GAVI ដែលបានប្រមែប្រមូលធនធានថវិកាបានយ៉ាងច្រើន។ មូលនិធិការអប់រំមិនអាចរង់ចាំយូរ (Education Cannot Wait Fund) ដែលជាមូលនិធិមួយថ្មី មានគោលបំណងរៃអង្គាសប្រាក់សម្រាប់ផ្ដល់សេវាអប់រំឲ្យចំគោលដៅលើអ្នកដែលរងផលប៉ះពាល់ ដោយសារជម្លោះ គ្រោះមហន្តរាយធម្មជាតិ និងការផ្ទុះជំងឺនានា។

# ការព្យាករ៖ តើការពង្រីកការអប់រំនឹងមានឥទ្ធិពលអ្វីខ្លះដល់លទ្ធផលនៃការអភិវឌ្ឍ?

## ការព្យាករពីការសម្រេចលទ្ធផលនៃការអប់រំរហូតដល់ឆ្នាំ ២០៣០ និងឆ្នាំក្រោយៗទៀត

របាយការណ៍ GEM ឆ្នាំ ២០១៦ នេះ ធ្វើការព្យាករពីលទ្ធភាពក្នុងសម្រេចឲ្យបាន នូវសកលកម្មនៃការបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សា ត្រឹមឆ្នាំ ២០៣០ ដោយប្រើប្រាស់សំណុំទិន្នន័យដែលមានភាពជាតំណាងជាសកល និងវិធីសាស្ត្រដែលមានលក្ខណៈស្មុគស្មាញ។ សារដែលទទួលបានពីការវិភាគនេះមានលក្ខណៈមុតស្រួច៖ ពិភពលោកនឹងមានភាពយឺតយ៉ាវរហូតដល់ ៥០ ឆ្នាំ ក្នុងការសម្រេចសក្ខានុពលនៃការអប់រំជសកល។ បើនិន្នាការបច្ចុប្បន្ននៅតែបន្តមានសកលកម្មនៃការបញ្ចប់ការសិក្សា កម្រិតបឋមសិក្សានឹងត្រូវសម្រេចនៅឆ្នាំ២០៤២,សកលកម្មនៃការបញ្ចប់ការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងឆ្នាំ ២០៥៩ និងសកលកម្មនៃការបញ្ចប់ការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងឆ្នាំ ២០៨៤។ ប្រទេសក្រីក្រជាងគេនឹងសម្រេចសកលកម្មនៃការអប់រំកម្រិតបឋមិក្សាយឺតជាងប្រទេសមានធនធានជាងគេ ដល់ទៅជាង ១០០ឆ្នាំ។សេចក្តីសន្និដ្ឋានដែលគេអាចទាញចេញពីចំណុចនេះគឺ ក្នុងប្រទេសចំណូលទាប ក៏ដូចជាប្រទេសចំណូលមធ្យម សេណារីយ៉ូ SDG ទាមទារឲ្យមានការងាកចេញដែលមិនធ្លាប់មានពីនិន្នការកន្លងមក ប្រសិនបើគេចង់សម្រេចទៅតាមចំណុចដៅ ៤.១។

## ការព្យាករមានឥទ្ធិពលលើលទ្ធផលនៃការអភិវឌ្ឍ

ខណៈពេលដែលការព្យាករនេះបង្ហាញថា គេប្រហែលជាមិនអាចសម្រេចបាននូវចំណុចដៅអប់រំក្នុង SDG សូម្បីតែវឌ្ឍនភាពតិចតួចបំផុតក៏អាចធ្វើឲ្យមានភាពខុសប្លែកគ្នាធំធេងដល់មនុស្សជំនាន់ក្រោយដែរ។ ដើម្បីយល់ថាតើការពង្រីកការអប់រំរួមចំណែកអ្វីខ្លះដល់ការសម្រេច SDGs ផ្សេងទៀតរបាយការណ៍GEMនេះធ្វើការវិភាគថាតើការអប់រំអាចជួយសង្គ្រោះជីវិតដោយរបៀបណា (តាមរយៈការកាត់បន្ថយមរណភាពទារក និងកុមារ និងបង្កើនអាយុកាលរំពឹងទុករបស់មនុស្សពេញវ័យ) រំដោះមនុស្សនិងប្រទេសចេញពីភាពក្រីក្រ (តាមរយៈការបង្កើនកំណើនសេដ្ឋកិច្ចជារួមរបស់ប្រទេសនិងកាត់បន្ថយភាពក្រីក្រតោកយ៉ាក) និងកាត់បន្ថយភាពងាយទទួលរងគ្រោះមហន្តរាយ។

ការសម្រេចនូវសកលកម្មនៃ ការបញ្ចប់ការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិត្រឹមឆ្នាំ ២០៣០ នឹងកាត់បន្ថយអត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំនៅអាហ្វ្រិចសាប់សាហារ៉ា

**រូបភាពទី៧ :**

**បើនិន្នាការកន្លងមកនៅតែបន្តទៀត សូម្បីតែសកលកម្មនៃការបញ្ចប់ការអប់រំកម្រិតបឋមសិក្សាក្នុងប្រទេសចំណូលទាប និងចំណូលមធ្យមក៏មិនអាចសម្រេចបានត្រឹមឆ្នាំ ២០៣០ នោះដែរ**

អត្រានៃការសម្រេចការអប់រំដែលត្រូវបានព្យាករសម្រាប់កុមារអាយុពី១៥ដល់១៩ឆ្នាំ បែងចែកតាមកម្រិតនៃការអប់រំ និងក្រុមចំណូលតាមប្រទេស ២០១០-២០៨០




ប្រភព៖ Barakat (2016)

ពី ៦៨ មកនៅ ៥៤ ករណី ក្នុង ១០០០ កំណើតរស់ ត្រឹមឆ្នាំ ២០៣០ និងពី ៥១ មកនៅ ៣៨ ករណី ក្នុង ១០០០ កំណើតរស់ ត្រឹមឆ្នាំ ២០៥០។ ដោយសារតែសុខភាពរបស់កុមារអាចទទួលបានប្រយោជន៍ពីសកម្មភាពនៅកម្រិតសហគមន៍ និងការផ្សព្វផ្សាយពីការអនុវត្ត និងឥរិយាបថដែលនាំមកនូវសុខភាពល្អ មរណភាពកុមារអាចមានការថយចុះច្រើនជាងការប៉ាន់ប្រមាណទាំងនេះទៅទៀត។

ការអប់រំអាចបង្កើនចំណូលក្នុងប្រជាជនម្នាក់ តាមរយៈការបង្កើនផលិតភាពការងារ និងពន្លឿនការអភិវឌ្ឍ និងការប្រើប្រាស់បច្ចេកវិទ្យា។ នៅតាមប្រទេសដែលមានចំណូលទាប សកលកម្មការបញ្ចប់ការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិនឹងបង្កើនចំណូលក្នុងប្រជាជនម្នាក់ ៧៥% ត្រឹមឆ្នាំ ២០៥០។ បើទោះបីជាការសម្រេចចំណុច ៤.១ នៃ SDG ក៏មិនគ្រប់គ្រាន់ ដើម្បីលុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរត្រឹមឆ្នាំ ២០៣០ វាអាចសន្សំពេលលុបបំបាត់ភាពក្រីក្របាន ១០ ឆ្នាំ។

ការអប់រំអាចជួយកាត់បន្ថយករណីស្លាប់ពាក់ព័ន្ធនឹងគ្រោះមហន្តរាយ ដោយសារតែអ្នកដែលមានការអប់រំ មានការយល់ដឹងច្រើនពីហានិភ័យ មានការត្រៀមរៀបចំ និងការឆ្លើយតបសមស្របកម្រិតខ្ពស់ និងទទួលរងការបាត់បង់តិចតួច នៅពេលដែលមានគ្រោះមហន្តរាយកើតមានឡើង។ ប្រសិនបើមានការសម្រេចនូវសកលកម្មនៃការអប់រំកម្រិតមធ្យមសិក្សាត្រឹមឆ្នាំ ២០៣០ នោះត្រឹមឆ្នាំ ២០៤០-២០៥០ នឹងមានករណីស្លាប់ពាក់ព័ន្ធនឹងគ្រោះមហន្តរាយតិចជាងមុនពី ១០០០០ ដល់ ២០០០០ ករណីក្នុងមួយទសវត្សរ៍ បើធៀបនឹងករណីស្លាប់ ២៥០០០០ ករណី ចន្លោះពីឆ្នាំ ២០០០ ដល់ ២០១០ ប្រសិនបើភាពញឹកញាប់នៃគ្រោះមហន្តរាយនៅតែបន្តនៅថេរដូចបច្ចុប្បន្ន។ សកលកម្មនៃការអប់រំកម្រិតមធ្យមសិក្សាមានឥទ្ធិពលយ៉ាងខ្លាំងមកលើការស្លាប់ពាក់ព័ន្ធនឹងគ្រោះមហន្តរាយ នៅអាស៊ី ដោយសារតែអាស៊ីជាតំបន់ដែលមានប្រជាជនច្រើនជាងគេ ហើយក្រុមងាយរងគ្រោះភាគច្រើនរស់នៅតាមតំបន់ឆ្នេរ។

# ការអប់រំ និងនិរន្តរភាព៖ អ្វីដែលយើងដឹង និងអ្វីដែលយើងចាំបាច់ត្រូវធ្វើ

ផ្នែកមុននេះបានបង្ហាញពីទំនាក់ទំនងជាច្រើនរវាងការអប់រំ និងការអភិវឌ្ឍប្រកបដោយចីរភាព។ ផ្នែកនេះបង្ហាញថា ការបញ្ចប់ការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សាផ្តល់នូវប្រយោជន៍យ៉ាងច្រើន មិនត្រឹមតែដល់បុគ្គលម្នាក់ៗប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដល់ក្រុមគ្រួសារសហគមន៍និងកន្លែងធ្វើការរបស់ពួកគេទៀតផង។បុរសនិងស្ត្រីដែលមានកម្រិតវប្បធម៌កាន់តែខ្ពស់មានការយល់ដឹងកាន់តែច្រើនពីបរិស្ថាន កាន់តែអាចទ្រាំធន់ទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ កាន់តែមានផលិតភាពនិងរកចំណូលបានច្រើន និងកាន់តែអាចរស់នៅប្រកបដោយសុខភាពល្អចូលរួមក្នុងសកម្មភាពនយោបាយនិងចេះគ្រប់គ្រងជីវិតរបស់ខ្លួន។អត្ថប្រយោជន៍នៃការអប់រំក្មេងស្រីនិងស្ត្រី មានច្រើនអនេក និងបន្សល់ទុកច្រើនជំនាន់។

> “ដើម្បីឲ្យការអប់រំមានឥទ្ធិពលធ្វើឲ្យមានការផ្លាស់ប្តូរការគាំទ្រដល់របៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាពថ្មី “ការអប់រំតាមបែបធម្មតា” គឺមិនគ្រប់គ្រាន់ឡើយ។”

គេមានការព្រួយបារម្ភក្រៃលែងការវិវឌ្ឍនៃស្ថានភាព ក្នុងសកលលោកទាំងមូលធ្វើឲ្យប្រយោជន៍ដែលបានពីការអប់រំមានការផ្លាស់ប្តូរ។ ឧទាហរណ៍សេដ្ឋកិច្ចរបស់ពិភពលោកបានបង្កើតនូវទ្រព្យសម្បត្តិជាច្រើនសម្រាប់មនុស្សមួយចំនួន ប៉ុន្តែក៏បានទុកមនុស្សជាច្រើនចោលផងដែរ ធ្វើឲ្យជីវិត និងជីវភាពរស់នៅរបស់ពួកគេងាយរងគ្រោះនៅពេលមានវិបត្តសេដ្ឋកិច្ចកើតឡើង និងធ្វើឲ្យពួកគេបន្តស្ថិតក្នុងភាពក្រីក្រ។ វដ្តនៃឌីនភាពសេដ្ឋកិច្ចធ្វើឲ្យបញ្ហាអសន្តិសុខ និងជម្លោះនយោបាយកាន់តែធ្ងន់ធ្ងរ បង្ខំឲ្យមនុស្សរាប់លាននាក់ត្រូវភៀសខ្លួន។ ការធ្វើចំណាកស្រុកដោយសារតែគ្រោះមហន្តរាយធម្មជាតិ និងការប្រែប្រួលអាកាសធាតុ ធ្វើឲ្យអន្តរាយដល់កិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសមួយដើម្បីធានាយ៉ាងណាឲ្យមនុស្សវ័យក្មេងទាំងអស់ទទួលបានការអប់រំយ៉ាងហោចណាស់១២ឆ្នាំក៏ដូចជាផ្តល់នូវឱកាសឲ្យបានគ្រប់គ្រាន់ សម្រាប់រៀនសូត្រពេញមួយជីវិត។

ដើម្បីឲ្យការអប់រំមានឥទ្ធិពលធ្វើឲ្យមានការផ្លាស់ប្តូរការគាំទ្រដល់របៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាពថ្មី“ការអប់រំតាមបែបធម្មតា” គឺមិនគ្រប់គ្រាន់ឡើយ។ ការរៀនសូត្រគួរជម្រុញឲ្យមានការគិតពិចារណា ដែលគិតពីទំនាក់ទំនងជាមួយអ្នកដទៃ មានលក្ខណៈក្តោបរួមយល់ចិត្តអ្នកដទៃ ចេះរំពឹងពីអ្វីដែលនឹងកើតមានឡើង និងមានលក្ខណៈជាប្រព័ន្ធ។ សាលារៀនគួរជាកន្លែងផ្តល់គំរូ ដែលបណ្តុះគំនិតអំពីចីរភាព - ពោលគឺជាកន្លែងដែលមានលក្ខណៈបរិយាប័ន្ន ប្រជាធិបតេយ្យ នាំមកនូវសុខភាពល្អ និងជាកន្លែងដែលបញ្ចេញនិងស្រូបកាបូនស្មើគ្នា ដែលទាំងអស់នេះដាក់ចេញនូវមូលដ្ឋាន ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

**អនុសាសន៍គោលនយោបាយខាងក្រោមបង្ហាញពីរបៀបដែលប្រព័ន្ធអប់រំអាចរួមចំណែកកាន់តែមានប្រសិទ្ធភាព ចំពោះការអភិវឌ្ឍប្រកបដោយចីរភាព។**

- ផ្តល់ការគាំទ្រដល់ការសហការ និងការធ្វើសកម្មភាពផ្ដួបកម្លាំងគ្នារវាងគ្រប់វិស័យ និងគ្រប់ដៃគូទាំងអស់។ ដោយសារតែដែលមានលក្ខណៈជាប្រព័ន្ធតម្រូវឲ្យមានការចូលរួមពីតួអង្គចម្រុះ ដែលមានទស្សនវិស័យផ្សេងៗគ្នា ចាំបាច់ត្រូវពង្រឹងកិច្ចខិតខំប្រឹងប្រែង ដើម្បីជម្រុញឲ្យមានការចូលរួមពីគ្រប់ដៃគូទាំងអស់ ដូចជា ក្រសួង អ្នកជំនាញខាងអប់រំ និងសង្គមស៊ីវិល នៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ និងរវាងវិស័យនានា។

- រដ្ឋាភិបាលចាំបាច់ត្រូវចាត់ទុកការអប់រំ និងការបណ្តុះបណ្តាលក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ថាជាគន្លឹះ នៃកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេ ដើម្បីដោះស្រាយបញ្ហាដែលមានចរិតអន្តរវិស័យ។ ការអប់រំអាចជាឧបករណ៍ដ៏មានសារៈសំខាន់ សម្រាប់កសាងសមត្ថភាពក្នុងគ្រប់វិស័យទាំងអស់។ ចំណុចដៅជាច្រើននៃគោលដៅ SDG ត្រូវការនូវជំនាញ និងឯកទេស ដែលផ្តល់ដោយប្រព័ន្ធអប់រំ។

- ការអប់រំអាចកាត់បន្ថយវិសមភាពចំណូល ប៉ុន្តែមិនអាចកាត់បន្ថយវិសមភាពចំណូលដោយខ្លួនឯងនោះទេ។ ការពង្រីកលទ្ធភាពរបស់ក្រុមដែលមានឱកាសតិចតួច ឲ្យទទួលបានការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សាប្រកបដោយគុណភាព នឹងជួយធានាឲ្យប្រជាពលរដ្ឋទទួលបានចំណូលសមរម្យ និងកាត់បន្ថយបាននូវវិសមភាព។ ការផ្លាស់ប្តូរបទដ្ឋានទីផ្សារការងារ និងបច្ចេកវិទ្យា មិនគួរក្លាយជាការដាក់ទណ្ឌកម្មដល់កម្មករ ដោយកាត់បន្ថយភាពជាប់លាប់នៃការងាររបស់ពួកគេ ជាពិសេស ក្នុងវិស័យមិនរៀបរយនោះទេ។

- ប្រព័ន្ធអប់រំត្រូវការការផ្តល់ហិរញ្ញប្បទានឲ្យបានច្រើនជាងមុន ក្នុងទម្រង់ដែលគេអាចព្យាករដឹងមុន ដើម្បី (ក) ធ្វើសកលកម្មការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា (ខ) បង្កើនចំនួនគ្រូដែលមានសមត្ថភាព មានចំណេះដឹង និងមានទឹកចិត្តធ្វើការងារ (គ) ផ្តល់ការអប់រំប្រកបដោយគុណភាពដល់ក្រុមប្រជាជនដែលបាត់បង់ឱកាស និង (ឃ) ត្រៀមទប់ទល់នឹងផលវិបាកនៃការប្រែប្រួលអាកាសធាតុ និងលទ្ធភាពកើតឡើងនូវជម្លោះអូសបន្លាយពេលយូរ។

## បង្កើនសមធម៌

- សកលកម្មការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា ជាពិសេស សម្រាប់ក្មេងស្រី មានសារៈសំខាន់ ដើម្បីលើកកម្ពស់ស្វ័យភាព និងការធ្វើសេចក្តីសម្រេចចិត្តរបស់ស្ត្រី។ ការសម្រេចចំណុចដៅនេះទាមទារឲ្យមានការទប់កំណើនប្រជាជន ផ្លាស់ប្តូរបទដ្ឋានសង្គម និងការអនុវត្តឆ្លងជំនាន់ និងកាត់បន្ថយការដាក់បន្ទុកមកលើភពផែនដី។

- គោលនយោបាយអប់រំ ដែលផ្តោតគោលដៅលើក្រុមជនជាតិភាគតិច ជនភៀសខ្លួន និងជនបាត់បង់ទីលំនៅក្នុងប្រទេស គួរដាក់អាទិភាពលើភាសាសម្រាប់បង្រៀនដែលមានលក្ខណៈសមស្រប និងធានាឲ្យមានការប្រើប្រាស់កម្មវិធីសិក្សា និងឯកសារសិក្សាដែលមិនលំអៀង។ ការបង្កើនក្រុមគ្រូដែលមានសមត្ថភាពស្ទាត់ជំនាញខាងភាសា ដែលប្រើប្រាស់ក្នុងការបង្រៀន មានសារៈសំខាន់ សម្រាប់ប្រទេសដែលមានក្រុមជនជាតិភាគតិច និងក្រុមចំណាកស្រុកក្នុងភាគរយមួយខ្ពស់។

- ការរៀបចំផែនការទីក្រុងចាំបាច់ត្រូវបញ្ចូលការរៀបចំផែនការអប់រំ ហើយមិនត្រូវទុកតំបន់ជនបទចោលឡើយ។ ការរៀបចំផែនការអប់រំ រួមនឹងសេវាជាមូលដ្ឋានផ្សេងទៀត សម្រាប់អ្នកដែលរស់នៅក្នុងតំបន់ក្រីក្រ គឺជាការងារដ៏មានសារៈសំខាន់។ គួរមានការបែងចែកសេវាសាធារណៈ និងគ្រូបង្រៀនដែលមានគុណភាព ប្រកបដោយសមធម៌ ហើយសាលារផនគួរជាកន្លែងដែលមានសុវត្ថិភាព និងពុំមានអំពើហិង្សា។ តំបន់ជនបទ ដែលប្រជាជនចេះតែមានចំនួនតិចទៅៗ និងការច្របាច់បញ្ចូលសាលារៀននៅតាមតំបន់ជនបទបញ្ចូលគ្នា ទាមទារឲ្យមានការយកចិត្តទុកដាក់នៅពេលរៀបចំផែនការ និងការចូលរួមពីសហគមន៍។

## ការផ្លាស់ប្តូរការយកចិត្តទុកដាក់នៃវិស័យអប់រំ

- ក្នុងការរៀបចំគោលនយោបាយជំនាញ ប្រព័ន្ធអប់រំគួរធ្វើការពិចារណាលើតម្រូវការរយៈពេលមធ្យមផង និងរយៈពេលវែងផង ក៏ដូចជាលើភាពពាក់ព័ន្ធនៃកំណើនប្រកបដោយចីរភាព។ ចាំបាច់ត្រូវមានការបង្រៀនជំនាញបៃតងដល់សិស្ស និងផ្តល់ឲ្យកម្មករនយោជិតនូវឱកាសទទួលបានការបណ្តុះបណ្តាលឡើងវិញ និងបង្កើនជំនាញរបស់ពួកគេ ក៏ដូចជាធ្វើការផ្លាស់ប្តូរកម្មវិធី

សិក្សាកម្រិតមធ្យមសិក្សា និងឧត្តមសិក្សា។ ការបង្កើនកិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុន និងឧស្សាហកម្ម នឹងបង្កើនភាពឆ្លើយតប ក៏ដូចជាគុណភាពនៃការបង្រៀន។

- កម្មវិធីអប់រំដែលផ្តោតលើកាតព្វកិច្ចរបស់ប្រជាពលរដ្ឋ សន្តិភាព និងចីរភាព អាចជាកត្តាសំខាន់ ដើម្បីសម្រេចវឌ្ឍនភាពនៃគោលដៅ SDG។ ប្រសិនបើអនុវត្តប្រកបដោយប្រសិទ្ធភាព កម្មវិធីទាំងនេះអាចជានាឲ្យប្រព័ន្ធយុត្តិធម៌កាន់តែមានសមធម៌ កសាងសមត្ថភាពមន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់ លើកកម្ពស់សង្គមដែលកាត់បន្ថយអំពើហិង្សានិងកាន់តែមានលក្ខណៈស្ថាបនា បង្កើនការយល់ដឹងពីទំនាក់ទំនងរវាងវប្បធម៌ សេដ្ឋកិច្ច និងបរិស្ថាន និងផ្តល់អាទិភាពដល់សកម្មភាព ដែលផ្តល់នូវភាពល្អប្រសើរដល់មនុស្សជំនាន់ក្រោយ។

# បញ្ហាប្រឈមជុំវិញការពិនិត្យតាមដានការអប់រំ ក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

គោលដៅ SDG ទី ៤ រួមនឹងចំណុចដៅចំនួន ១០ នៃគោលដៅនេះ គឺមហិច្ឆតាមួយដែលត្រូវសម្រេចឲ្យបានក្នុងរយៈពេល ១៥ ឆ្នាំទៀត និងមានវិសាលភាពលើសពីកិច្ចព្រមព្រៀងអប់រំជាសកល ដែលធ្លាប់មានកន្លងមក។ របាយការណ៍ GEM នេះ បង្ហាញពីបញ្ហាប្រឈមជុំវិញការពិនិត្យតាមដានវឌ្ឍនភាពនៃការអប់រំ ក្នុងរបៀបវារៈឆ្នាំ ២០៣០ នេះ។ របាយការណ៍នេះធ្វើការវិភាគគ្រប់ចំណុចដៅទាំងអស់នៃគោលដៅ SDG ទី ៤ ដោយចំណុចដៅមួយចំនួនមិនត្រូវបានរៀបចំបានល្អឡើយ និងធ្វើការពិភាក្សាពីបញ្ហាប្រឈមបច្ចេកទេសក្នុងការពិនិត្យតាមដានសូចនាករពាក់ព័ន្ធ។ របាយការណ៍នេះក៏ពិនិត្យលើកិច្ចខិតខំប្រឹងប្រែង ដើម្បីបង្កើតនូវឧបករណ៍វាស់វែងដែលមានសុពលភាពអាចជឿទុកចិត្តបាន និងអាចឲ្យគេប្រៀបធៀបលទ្ធផលបានផងដែរ។

របាយការណ៍ GEM សួរសំណួរថាតើការពិនិត្យតាមដានការអប់រំទូទាំងសកលលោកទាំងមូល ត្រូវផ្តោតលើអាទិភាពអ្វីខ្លះ ហើយតើប្រទេស និងអង្គការស្ថាប័នណាខ្លះត្រូវប្រើប្រាស់ធនធានរបស់ខ្លួនឲ្យចំគោលដៅ។ របាយការណ៍នេះធ្វើការពិនិត្យផងដែរលើបរិបទស្ថាប័ន បរិបទនយោបាយ និងបរិបទបច្ចេកទេស សម្រាប់វាស់វែងសូចនាករទាំងនេះ។

## តួនាទីនៃរបាយការណ៍ GEM

របាយការណ៍ GEM មានតួនាទីជួយឲ្យសហគមន៍អន្តរជាតិធ្វើការស្វែងយល់ថាតើពិភពលោកទាំងមូលបានសម្រេចវឌ្ឍនភាពជុំវិញការអប់រំ និងការរៀនសូត្រពេញមួយជីវិតដែរឬទេ ហើយបើមានការសម្រេចវឌ្ឍនភាពមែន តើសម្រេចបានប៉ុណ្ណា។ ខណៈពេលដែលមានការយល់ឃើញថា របាយការណ៍ពិនិត្យតាមដានជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នា បានសម្រេចតួនាទីរបស់ខ្លួន បរិបទទូទៅមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ហើយការពង្រីកវិសាលភាពសម្រាប់របៀបវារៈ ២០៣០ នាំមកនូវបញ្ហាប្រឈមថ្មីៗបន្ថែមទៀត។

> “របាយការណ៍ GEM មានតួនាទីជួយឲ្យសហគមន៍អន្តរជាតិធ្វើការស្វែងយល់ថាតើពិភពលោកទាំងមូលបានសម្រេចវឌ្ឍនភាពជុំវិញការអប់រំ និងការរៀនសូត្រពេញមួយជីវិតដែរឬទេ ហើយបើមានការសម្រេចវឌ្ឍនភាពមែន តើសម្រេចបានប៉ុណ្ណា។”

សូចនាករពិនិត្យតាមដានមួយសំណុំត្រូវបានរៀបចំឡើង (ប្រអប់ទី ១) បើទោះបីជាបច្ចុប្បន្ននេះគេនៅ កំពុងគិតគូរពីវិធីសាស្ត្រសម្រាប់វាស់វែងសូចនាករជាច្រើន ក្នុងចំណោមសូចនាករទាំងនេះក៏ដោយ។ សូចនាករជាច្រើនគ្របដណ្តប់បានតែមួយផ្នែកនៃទស្សនទានក្នុងចំណុចដៅនីមួយៗតែប៉ុណ្ណោះ។ គេក៏គួររិះរកវិធីសាស្ត្រជាជម្រើសផ្សេងទៀត សម្រាប់ធ្វើការវាស់វែង និងពិនិត្យតាមដានចំណុចដៅ នៅថ្នាក់ជាតិ និងថ្នាក់តំបន់។

ក្នុងឆ្នាំខាងមុខៗនេះ របាយការណ៍ GEM នឹងពិនិត្យក្នុងលក្ខណៈគ្រប់ជ្រុងជ្រោយលើវឌ្ឍនភាពដែលសម្រេចបានក្នុងការងារអប់រំក្នុងសកលលោកទាំងមូល ដោយប្រើប្រាស់សូចនាករដែលមាន ដោយធ្វើការចោទសំណួរពីសារៈប្រយោជន៍នៃសូចនាករទាំងនោះ ធ្វើការឆ្លុះបញ្ចាំងពីគុណភាពនៃប្រភពទិន្នន័យ បង្ហាញពីវិធីសាស្ត្រថ្មីៗសម្រាប់ពិនិត្យលើភស្តុតាង និងជម្រុញឲ្យមានការកែលំអបន្ថែមទៀត។

## ប្រអប់ទី១

### ចំណុចដៅ និងក្របខ័ណ្ឌសូចនាករសកល/តាមប្រធានបទដែលស្នើឡើងសម្រាប់គោលដៅ SDG ទី ៤ ស្តីពីការអប់រំ

**គោលដៅទី ៤៖** ធានានូវការអប់រំប្រកបដោយគុណភាព បរិយាប័ន្ន និងសមធម៌ និងលើកកម្ពស់ឱកាសរៀនសូត្រសម្រាប់ទាំងអស់គ្នា

**សូចនាករ ៤.១៖** ត្រឹមឆ្នាំ ២០៣០ ធានាយ៉ាងណាឲ្យក្មេងស្រី និងក្មេងប្រុសគ្រប់រូបបញ្ចប់ការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សាប្រកបដោយសមធម៌ និងគុណភាពដោយមិនគិតថ្លៃ ដែលនាំឲ្យការសម្រេចលទ្ធផលនៃការរៀនសូត្រពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព

១. ភាគរយនៃកុមារ និងមនុស្សវ័យក្មេង៖ (ក) រៀនថ្នាក់ទី ២/៣ (ខ) នៅចុងកម្រិតអប់រំបឋមសិក្សា និង (គ) នៅចុងកម្រិតអប់រំមធ្យមសិក្សាបឋមភូមិ ដែលសម្រេចបាននូវភាពស្ទាត់ជំនាញយ៉ាងហោចណាស់ត្រឹមកម្រិតអប្បបរមាខាង (i) អំណាន និង (ii) គណិតវិទ្យា បែងចែកតាមភេទ។ [សូចនាករសកល ៤.១.១]

២. ការវាយតម្លៃលើការរៀនសូត្រដែលមានលក្ខណៈតំណាងនៅថ្នាក់ជាតិ (i) នៅកម្រិតបឋមសិក្សា (ii) នៅចុងកម្រិតបឋមសិក្សា និង (iii) នៅចុងកម្រិតមធ្យមសិក្សាបឋមភូមិ

៣. អត្រារួមនៃការសិក្សារហូតដល់ថ្នាក់ចុងក្រោយ (បឋមសិក្សា មធ្យមសិក្សាបឋមភូមិ)

៤. អត្រាបញ្ចប់ការសិក្សា (បឋមសិក្សា មធ្យមសិក្សាបឋមភូមិ មធ្យមសិក្សាទុតិយភូមិ)

៥. អត្រាកុមារក្រៅសាលា (បឋមសិក្សា មធ្យមសិក្សាបឋមភូមិ មធ្យមសិក្សាទុតិយភូមិ)

៦. ភាគរយកុមារលើសអាយុសិក្សាសម្រាប់ថ្នាក់ដែលពួកគេកំពុងរៀន (បឋមសិក្សា មធ្យមសិក្សាបឋមភូមិ)

៧. ចំនួនឆ្នាំនៃការអប់រំបឋមសិក្សា និងមធ្យមសិក្សា (i) មិនគិតថ្លៃ និង (ii) ដែលតម្រូវដោយច្បាប់ ដែលបានធានាក្នុងក្របខ័ណ្ឌច្បាប់

**ចំណុចដៅ ៤.២៖** ត្រឹមឆ្នាំ ២០៣០ ធានាយ៉ាងណាឲ្យក្មេងស្រី និងក្មេងប្រុសទាំងអស់ទទួលបានការអភិវឌ្ឍ និងការគាំពារកុមារតូច ក៏ដូចជាការអប់រំកម្រិតមត្តេយ្យសិក្សាប្រកបដោយគុណភាព ដើម្បីឲ្យពួកគេអាចត្រៀមខ្លួនរួចរាល់ សម្រាប់ការអប់រំកម្រិតបឋមសិក្សា។

៨. ភាគរយនៃកុមារអាយុក្រោម ៥ ឆ្នាំ ដែលមានកម្រិតអភិវឌ្ឍន៍សមស្រប ខាងសុខភាព ការរៀនសូត្រ និងសុខុមាលភាពចិត្តសង្គម បែងចែកតាមភេទ [សូចនាករសកល ៤.២.១]

៩. ភាគរយនៃកុមារអាយុក្រោម ៥ ឆ្នាំ ដែលទទួលបានបរិយាកាសភ្ញោច និងរៀនសូត្រជាវិជ្ជមាន

១០. អត្រានៃការចូលរួមរៀនសូត្រក្នុងបរិយាកាសដែលមានការរៀបចំត្រឹមត្រូវ (មួយឆ្នាំមុនពេលអាយុចូលរៀននៅបឋមសិក្សាជាផ្លូវការ) បែងចែកតាមភេទ [សូចនាករសកល ៤.២.២]

១១. អត្រារួមនៃការសិក្សាកម្រិតមត្តេយ្យសិក្សា

១២. ចំនួនឆ្នាំនៃការអប់រំកម្រិតមត្តេយ្យសិក្សា (i) មិនគិតថ្លៃ និង (ii) ដែលតម្រូវដោយច្បាប់ ដែលបានធានាក្នុងក្របខ័ណ្ឌច្បាប់

**ចំណុចដៅ ៤.៣៖** ត្រឹមឆ្នាំ ២០៣០ ធានាយ៉ាងណាឲ្យស្ត្រី និងបុរសទាំងអស់មានលទ្ធភាពដូចៗគ្នា ដើម្បីទទួលបានការអប់រំបច្ចេកទេស ការអប់រំវិជ្ជាជីវៈ និងការអប់រំមកម្រិតឧត្តមសិក្សាដែលមានតម្លៃសមរម្យ និងមានគុណភាព រួមទាំងការអប់រំនៅតាមសកលវិទ្យាល័យផង

១៣. អត្រារួមនៃនៃការសិក្សា សម្រាប់កម្រិតឧត្តមសិក្សា

១៤. អត្រាចូលរួមក្នុងកម្មវិធីអប់រំបច្ចេកទេស និងវិជ្ជាជីវៈ (១៥ ដល់ ២៤ ឆ្នាំ)

១៥. អត្រាចូលរួមរបស់យុវជន និងមនុស្សពេញវ័យ ក្នុងការអប់រំបណ្តុះបណ្តាលក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ក្នុងរយៈពេល ១២ ខែ កន្លងទៅ បែងចែកតាមភេទ [សូចនាករសកល ៤.៣.១]

**ចំណុចដៅ ៤.៤៖** ត្រឹមឆ្នាំ ២០៣០ បង្កើនចំនួនយុវជន និងមនុស្សពេញវ័យ ដែលមានជំនាញពាក់ព័ន្ធ រាប់បញ្ចូលទាំងជំនាញបច្ចេកទេស និងវិជ្ជាជីវៈផង សម្រាប់ធ្វើការងារ ទទួលបានការងារសមរម្យ និងសហគ្រិនភាព

១៦.១ ភាគរយនៃយុវជន និងមនុស្សពេញវ័យ ដែលមានភាពស្ទាត់ជំនាញខាងជំនាញឌីជីថលយ៉ាងហោចណាស់ត្រឹមកម្រិតអប្បបរមា

១៦.២ ភាគរយនៃយុវជន និងមនុស្សពេញវ័យ ដែលមានជំនាញព័ត៌មាន និងសារគមនាគមន៍ (ICT) បែងចែកតាមប្រភេទជំនាញ [សូចនាករសកល ៤.៤.១]

១៧. អត្រាសម្រេចបានការអប់រំរបស់យុវជន/មនុស្សពេញវ័យ បែងចែកតាមក្រុមអាយុ ស្ថានភាពនៃសកម្មភាពសេដ្ឋកិច្ច កម្រិតវប្បធម៌ និងការតម្រង់ទិសកម្មវិធី

**ចំណុចដៅ ៤.៥៖** ត្រឹមឆ្នាំ ២០៣០ លុបបំបាត់គម្លាតយេនឌ័រក្នុងវិស័យអប់រំ និងធានាឲ្យមានការទទួលបានការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈប្រកបដោយសមភាព សម្រាប់ក្រុមដែលងាយរងគ្រោះ រាប់បញ្ចូលទាំងជនពិការ ជនជាតិដើមភាគតិច និងកុមារស្ថិតក្នុងស្ថានភាពងាយរងគ្រោះផង

សូចនាករយុតភាព (ស្រី/ប្រុស ជនបទ/ប្រជុំជន បញ្ចភាគខាងក្រោមគេ/ខាងលើគេ និងស្ថានភាពផ្សេងទៀត ដូចជា ស្ថានភាពពិការភាព ជនជាតិដើមភាគតិច និងក្រុមដែលរងផលប៉ះពាល់ដោយសារជម្លោះ ទៅតាមទិន្នន័យដែលមាន) សម្រាប់គ្រប់សូចនាករអប់រំទាំងអស់ក្នុងបញ្ជីនេះ ដែលអាចបែងចែកទៅតាមស្ថានភាពបែបនេះបាន [សូចនាករសកល ៤.៥.១]

១៨. ភាគរយនៃសិស្សកម្រិតបឋមសិក្សា ដែលភាសាទីមួយ ឬភាសាកំណើត គឺដូចគ្នានឹងភាសាបង្រៀនពួកគេ

១៩. កម្រិតដែលគោលនយោបាយដែលប្រើប្រាស់រូបមន្តច្បាស់លាស់ជាគោលធ្វើការវិភាជន៍ធនធានអប់រំដល់ក្រុមដែលជួបការលំបាក

## ប្រអប់ទី២

២០. ចំណាយអប់រំសម្រាប់សិស្សម្នាក់ បែងចែកទៅតាមកម្រិតវប្បធម៌ និងប្រភពហិរញ្ញប្បទាន
២១. ភាគរយនៃជំនួយសម្រាប់វិស័យអប់រំសរុប ដែលបែងចែកទៅឲ្យប្រទេសដែលមានចំណូលទាប

ចំណុចដៅ ៤.៦ ត្រឹមឆ្នាំ ២០៣០ ធានាថា យុវជនគ្រប់រូប និងមនុស្សពេញវ័យមួយភាគធំ ទាំងប្រុស ទាំងស្រី នឹងមានចំណេះដឹងអក្ខរកម្ម និងលេខនពន្ធ
២២. ភាគរយនៃប្រជាជនក្នុងក្រុមអាយុណាមួយ ដែលសម្រេចបាននូវភាពស្ទាត់ជំនាញយ៉ាងហោចណាស់នៅកម្រិតកំណត់មួយខាង (ក) អក្ខរកម្ម និង (ខ) ជំនាញលេខនពន្ធវិជ្ជាជីវៈ បែងចែកតាមភេទ [សូចនាករសកល ៤.៦.១]
២៣. អត្រាអក្ខរកម្មយុវជន/មនុស្សពេញវ័យ
២៤. អត្រាចូលរួមរបស់យុវជន/មនុស្សពេញវ័យក្នុងកម្មវិធីអក្ខរកម្ម

ចំណុចដៅ ៤.៧៖ ត្រឹមឆ្នាំ ២០៣០ ធានាយ៉ាងណាឲ្យអ្នករៀនសូត្រគ្រប់រូបទទួលបានចំណេះដឹង និងបំណិន ដែលចាំបាច់ ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព តាមរយៈជាអាទ៌ ការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងរបៀបផែននៃការរស់នៅប្រកបដោយចីរភាព សិទ្ធិមនុស្ស សមភាពយេនឌ័រ ការលើកកម្ពស់វប្បធម៌សន្តិភាពនិងអហិង្សា ភាពជាពលរដ្ឋសកល និងការផ្តល់តម្លៃដល់វប្បធម៌ផ្សេងៗគ្នា និងដល់ការរួមចំណែករបស់វប្បធម៌ក្នុងការសម្រេចនូវការអភិវឌ្ឍប្រកបដោយចីរភាព
២៥. វិសាលភាព ដែល (i) ការអប់រំពលរដ្ឋសកល និង (ii) ការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព រួមនឹងសមភាពយេនឌ័រ និងសិទ្ធិមនុស្ស ត្រូវបានបញ្ជ្រាបនៅគ្រប់កម្រិតទាំងអស់ ក្នុង (ក)គោលនយោបាយអប់រំជាតិ (ខ) កម្មវិធីសិក្សា (គ) ការអប់រំគ្រូនិង (ឃ) ការវាយតម្លៃសិស្ស [សូចនាករសកល ៤.៧.១]
២៦. ភាគរយនៃសិស្សបែងចែកតាមក្រុមអាយុ (ឬកម្រិតវប្បធម៌) ដែលបង្ហាញពីការយល់ដឹងគ្រប់គ្រាន់អំពីបញ្ហានានា ដែលពាក់ព័ន្ធនឹងភាពជាពលរដ្ឋសកល និងនិរន្តរភាព
២៧. ភាគរយនៃសិស្សអាយុ ១៥ ឆ្នាំ ដែលបង្ហាញពីភាពស្ទាត់ជំនាញខាងចំណេះដឹងអំពីវិទ្យាសាស្ត្របរិស្ថាន និងដែនដីវិទ្យា
២៨. ភាគរយនៃសាលារៀន ដែលផ្តល់ការអប់រំបំណិនជីវិតអំពីមេរោគអេដស៍ និងការអប់រំរឿងភេទ
២៩. វិសាលភាពនៃការអនុវត្តក្របខ័ណ្ឌកម្មវិធីពិភពលោកអប់រំស្តីពីសិទ្ធិមនុស្សនៅទូទាំងប្រទេស (ទៅតាមសេចក្តីសម្រេចលេខ ៥៩/១១៣ នៃមហាសន្និបាតសហប្រជាជាតិ)

ចំណុចដៅ ៤.ក៖ កសាង និងកែលំអសម្ភាររូបវ័ន្តអប់រំដែលគិតគូរពីកុមារ ពិការភាព និងយេនឌ័រ និងផ្តល់នូវបរិយាកាសអប់រំអហិង្សា បរិយាប័ន្ន និងមានប្រសិទ្ធភាពសម្រាប់ទាំងអស់គ្នា
៣០-៣២ ភាគរយនៃសាលារៀន ដែលមាន៖ (ក) អគ្គិសនី (ខ) អ៊ីនធឺណិតសម្រាប់គោលបំណងគរុកោសល្យ (គ) កុំព្យូទ័រសម្រាប់គោលបំណងគរុកោសល្យ (ឃ) ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារដែលកែសម្រួលសម្រាប់សិស្សពិការ (ង) ទឹកស្អាតសម្រាប់ផឹក (ច) សម្ភាររូបវ័ន្តអនាម័យបែងចែកតាមភេទ និង (ឆ) សម្ភាររូបវ័ន្តសម្រាប់លាងសំអាតដៃ (ទៅតាមនិយមន័យសូចនាករទឹកស្អាត និងអនាម័យ (WASH)) [សូចនាករសកល ៤.ក.១]
៣៣. ភាគរយនៃសិស្សដែលទទួលរងការសម្លុតគំរាម ការដាក់ទណ្ឌកម្មរាងកាយ ការបៀតបៀន អំពើហិង្សា ការរើសអើងភេទ និងការរំលោភបំពាន
៣៤. ចំនួននៃការវាយប្រហារលើសិស្ស បុគ្គលិក និងគ្រឹះស្ថាន

ចំណុចដៅ ៤.ខ៖ ត្រឹមឆ្នាំ ២០២០ ពង្រីកជាសកលនូវចំនួនអាហារូបករណ៍ ដែលមានសម្រាប់ប្រទេសកំពុងអភិវឌ្ឍ ជាពិសេស នៅតាមប្រទេសដែលមានការអភិវឌ្ឍតិចតួច រដ្ឋកំពុងអភិវឌ្ឍជាកោះតូចៗ និងប្រទេសអាហ្វ្រិច ដើម្បីឲ្យសិស្សអាចចូលរៀននៅកម្រិតឧត្តមសិក្សា រាប់បញ្ចូលទាំងការបណ្តុះបណ្តាលវិជ្ជាជីវៈ កម្មវិធីបណ្តុះបណ្តាលខាងបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ កម្មវិធីបច្ចេកទេស វិស្វកម្ម និងវិទ្យាសាស្ត្រ ក្នុងប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍផ្សេងទៀត
៣៥. ចំនួនអាហារូបករណ៍ថ្នាក់ឧត្តមសិក្សាដែលត្រូវបានផ្តល់ បែងចែកទៅតាមប្រទេសទទួលផល
៣៦. ទំហំលំហូរជំនួយអភិវឌ្ឍន៍ផ្លូវការ សម្រាប់អាហារូបករណ៍ បែងចែកតាមវិស័យ និងប្រភេទនៃការសិក្សា [សូចនាករសកល ៤.ខ.១]

ចំណុចដៅ ៤.គ៖ ត្រឹមឆ្នាំ ២០៣០ បង្កើនឲ្យបានច្រើននូវការផ្គត់ផ្គង់គ្រូដែលមានសមត្ថភាព ដូចជា តាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិសម្រាប់ការបណ្តុះបណ្តាលគ្រូ ក្នុងប្រទេសកំពុងអភិវឌ្ឍ ជាពិសេស ប្រទេសដែលមានការអភិវឌ្ឍតិចតួច និងរដ្ឋកំពុងអភិវឌ្ឍជាកោះតូចៗ
៣៧. ភាគរយនៃគ្រូដែលមានសមត្ថភាព ទៅតាមស្តង់ដាជាតិ បែងចែកតាមកម្រិតនៃការអប់រំ និងប្រភេទគ្រឹះស្ថាន
៣៨. ផលធៀបសិស្ស/គ្រូដែលមានសមត្ថភាព បែងចែកទៅតាមកម្រិតអប់រំ
៣៩. ភាគរយគ្រូនៅ (ក) កម្រិតមត្តេយ្យសិក្សា (ខ) បឋមសិក្សា (គ) មធ្យមសិក្សាបឋមភូមិ និង (ឃ) មធ្យមសិក្សាទុតិយភូមិ ដែលបានទទួលការបណ្តុះបណ្តាលដំបូង (ដូចជា ការបណ្តុះបណ្តាលគរុកោលសល្យ ជាដើម) និងវិក្រិតការយ៉ាងហោចណាស់ត្រឹមកម្រិតអប្បបរមា ដែលតម្រូវឲ្យមានសម្រាប់ការបង្រៀនតាមកម្រិត ក្នុងប្រទេស [សូចនាករសកល ៤.គ.១]
៤០. ផលធៀបសិស្ស/គ្រូដែលបានទទួលការបណ្តុះបណ្តាល បែងចែកទៅតាមកម្រិតអប់រំ
៤១. ប្រាក់បៀវត្សរ៍គ្រូជាមធ្យម ធៀបនឹងអាជីពផ្សេងទៀត ដែលត្រូវការគុណវឌ្ឍិអប់រំក្នុងកម្រិតប្រហាក់ប្រហែលគ្នា
៤២. អត្រាឈប់របស់គ្រូ បែងចែកទៅតាមកម្រិតអប់រំ
៤៣. ភាគរយគ្រូដែលទទួលបានការបណ្តុះបណ្តាលវិក្រឹតការ ក្នុងរយៈពេល ១២ ខែចុងក្រោយ បែងចែកទៅតាមប្រភេទនៃការបណ្តុះបណ្តាល

ប្រភព៖ UNESCO (2016) សេចក្តីប្រកាស និងក្របខ័ណ្ឌសកម្មភាពអ៊ីងឈ័នសម្រាប់ការអប់រំឆ្នាំ ២០៣០៖ ឆ្ពោះទៅរកការអប់រំ និងការរៀនសូត្រពេញមួយជីវិតប្រកបដោយគុណភាព បរិយាប័ន្ន និងសមធម៌ សម្រាប់ទាំងអស់គ្នា ទីក្រុងប៉ារីស យូណេស្កូ។

# ការអប់រំបឋមសិក្សា និងមធ្យមសិក្សា

Sustainable Development Goal 4.1

## គោលដៅ ៤.១

ចំណុចដៅ ៤.១ ចាត់ទុកសកលកម្មនៃការបញ្ចប់ការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា ថាជាមាគ៌ា ឆ្ពោះទៅរកការរៀនសូត្រ ដែលឆ្លើយតប និងមានប្រសិទ្ធភាព។ វឌ្ឍនភាពក្នុងការឈានទៅសម្រេចចំណុចដៅនេះ ត្រូវបានចាត់ទុកថាជាការវាស់វែងដ៏សំខាន់ មួយលើការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល និងសហគមន៍អន្តរជាតិ ក្នុងការឈានទៅសម្រេចគោលដៅ SDGs។ អ្នករិះគន់ចំណុចដៅនេះ ជឿថា ការសម្រុកមុខព្រួញឈានទៅសម្រេចសកលកម្មនៃការបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិ ធ្វើឲ្យមានការងាកចេញ ពីអាទិភាពនៃការអប់រំថ្នាក់មូលដ្ឋានសម្រាប់ទាំងអស់គ្នាដែលត្រូវការពេលយ៉ាងហោចណាស់ ៩ ឆ្នាំ។

### ការទទួលបានសេវាអប់រំ ការចូលរួមរៀនសូត្រ និងការបញ្ចប់ការសិក្សា

ចាំបាច់ត្រូវមានការពិនិត្យតាមដានការទទួលបានសេវាអប់រំឲ្យបានល្អិតល្អន់ ក្នុងរបៀបវារៈថ្មីនេះ។ ខណៈពេលដែលរបៀបវារៈនេះមានគោលបំណងសម្រេចឲ្យបាននូវការអប់រំរយៈពេល ១២ ឆ្នាំ សម្រាប់ក្រុមសិស្សបច្ចុប្បន្ន ត្រឹមឆ្នាំ ២០៣០ គេមិនគួរភ្លេចទេថា មានកុមារចំនួន ២៥ លាន នាក់ ដែលមិនទាំងបានចាប់ផ្តើមចូលរៀននៅបឋមសិក្សានៅឡើយផង។ ជិត ៣០% នៃកុមារមកពីគ្រួសារក្រីក្រជាងគេ ក្នុងប្រទេសដែលមានចំណូលទាប មិនដែលបានចូលរៀនឡើយ។

ចំណុចដៅ ៤.១ ផ្តោតលើការចូលរៀននៅកម្រិតបឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងជាលើកទីមួយហើយ ដែលផ្តោតលើការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ។ ក្នុងឆ្នាំ ២០១៤ មាន ៩១% នៃកុមារដល់វ័យចូលរៀននៅបឋមសិក្សា ៨៤% នៃក្មេងជំទង់ដែលដល់វ័យចូលរៀននៅមធ្យមសិក្សាបឋមភូមិ និង ៦៣% នៃយុវជនដល់វ័យចូលរៀននៅមធ្យមសិក្សាទុតិយភូមិ កំពុងរៀនសូត្រក្នុងសាលារៀន។ តួលេខប៉ាន់ប្រមាណទាំងនេះបង្ហាញថា សរុបមានមនុស្ស ២៦៣ លាននាក់ ដែលស្ថិតនៅក្រៅសាលា៖ ក្នុងនោះមានអ្នកដែលវ័យចូលរៀននៅបឋមសិក្សា ៦១ លាននាក់ អ្នកដែលដល់វ័យចូលរៀននៅមធ្យមសិក្សាបឋមភូមិ ៦០ លាននាក់ និងអ្នកដែលដល់វ័យចូលរៀននៅមធ្យមសិក្សាទុតិយភូមិ ១៤២ លាននាក់។

**រូបភាពទី ៨៖**

ក្នុងចំណោមប្រទេសដែលមានចំណូលទាប និងមធ្យម ៩០ មានប្រទេសតែ ២ ប៉ុណ្ណោះ ដែលមានប្រជាជនវ័យក្មេងជាងគេទទួលបានការអប់រំយ៉ាងហោចណាស់ ១២ ឆ្នាំ
ចំនួនឆ្នាំនៃការអប់រំដែលបានទទួល ក្នុងចំណោមអ្នកដែលមានអាយុពី ២០ ដល់ ២៤ ឆ្នាំ បែងចែកតាមទ្រព្យធន ក្នុងប្រទេសមួយចំនួន ចន្លោះពីឆ្នាំ ២០០៨ ដល់ ២០១៤




ប្រភព៖ ការវិភាគរបស់ក្រុមរៀបចំរបាយការណ៍ GEM ដោយប្រើប្រាស់ការអង្កេតគ្រួសារ

របៀបវារៈថ្មីនេះគឺជាការបោះជំហានទៅមុខដ៏សំខាន់មួយ ក្នុងការផ្តោតការយកចិត្តទុកដាក់លើការបញ្ចប់ការសិក្សា ជាជាងលើការសិក្សា។ ចន្លោះពីឆ្នាំ ២០០៨ ដល់ ២០១៤ អត្រាបញ្ចប់ការសិក្សាកម្រិតបឋមសិក្សាគឺ ៩២% ក្នុងប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ ៨៤% ក្នុងប្រទេសដែលមានចំណូលមធ្យមកម្រិតទាប និង ៥១% ក្នុងប្រទេសដែលមានចំណូលទាប ដោយក្នុងប្រទេសដែលមានចំណូលទាប អត្រាបញ្ចប់ការសិក្សាកម្រិតបឋមសិក្សារបស់ក្មេងស្រីមកពីគ្រួសារក្រីក្របំផុតគឺត្រឹមតែ ២៥% ប៉ុណ្ណោះ។ អត្រាបញ្ចប់ការសិក្សាកម្រិតមធ្យមទុតិយភូមិគឺ៨៤%ក្នុងប្រទេសដែលមានចំណូលខ្ពស់៤៣%ក្នុងប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់៣៨%ក្នុងប្រទេសដែលមានចំណូលមធ្យមកម្រិតទាប និង ១៤% ក្នុងប្រទេសដែលមានចំណូលទាប។ សូម្បីតែអ្នកដែលមានជីវភាពធូរធាបំផុត ក្នុងប្រទេសដែលមានចំណូលខ្ពស់ ក៏មិនអាចសម្រេចបាននូវការបញ្ចប់ការសិក្សាកម្រិតសកលដល់ ៩៣% ដែរ។ ក្នុងប្រទេសដែលមានចំណូលទាប មានក្មេងស្រីក្រីក្រជាងគេត្រឹមតែ ១% ប៉ុណ្ណោះ ដែលបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិ។

> “ក្នុងចំណោមប្រទេសចំនួន ១៩០ ដែលមានទិន្នន័យអំពីការអប់រំដែលតម្រូវដោយច្បាប់ មាន ២៣% តម្រូវឲ្យមានការអប់រំតម្រូវដោយច្បាប់តិចជាង ៩ ឆ្នាំ។”

## ការអប់រំដែលតម្រូវដោយច្បាប់ និងផ្តល់ដោយមិនគិតថ្លៃ

សូចនាករមួយ ក្នុងចំណោមសូចនាករតាមប្រធានបទនានា គឺចំនួនឆ្នាំនៃការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា ដែល (i) មិនគិតថ្លៃ និង (ii) តម្រូវដោយច្បាប់ ដូចដែលត្រូវបានធានា ក្នុងក្របខ័ណ្ឌច្បាប់។ ក្នុងចំណោមប្រទេសចំនួន ១៩០ ដែលមានទិន្នន័យអំពីការអប់រំដែលតម្រូវដោយច្បាប់ មានប្រទេសចំនួន ៤៤ (២៣%)តម្រូវឲ្យមានការអប់រំតម្រូវដោយច្បាប់តិចជាង ៩ ឆ្នាំ។

មេដ្យាននៃចំនួនឆ្នាំគឺ ១០ ឆ្នាំ សម្រាប់ការអប់រំតម្រូវដោយច្បាប់ ១២ ឆ្នាំ សម្រាប់ការអប់រំមិនគិតថ្លៃ។ ប៉ុន្តែ ទស្សនទាននៃការអប់រំដោយមិនគិតថ្លៃ នាំឲ្យមានបញ្ហាពាក់ព័ន្ធនឹងការវាស់វែងវឌ្ឍនភាព ក្នុងការសម្រេចចំណុចដៅនេះ៖ បើទោះបីជានៅតាមកន្លែងដែលមានលុបចោលថ្លៃសេវាក៏ដោយ ចំណាយជាច្រើនសម្រាប់ការអប់រំ អាចដាក់បន្ទុកលើគ្រួសារ។ ភាគរយនៃចំណាយសរុបលើការអប់រំ ដែលត្រូវរ៉ាប់រងដោយគ្រួសារនៅកម្រិតនីមួយៗ គឺជាសូចនាករបង្ហាញពីកម្រិតដែលការអប់រំត្រូវបានផ្តល់ដោយមិនគិតថ្លៃ។

## គុណភាព

ក្របខ័ណ្ឌពិនិត្យតាមដានដែលស្នើឡើងនេះមិនបានផ្តោតការយកចិត្តទុកដាក់លើគុណភាពឡើយ លើកលែងតែសូចនាករ ពាក់ព័ន្ធនឹងលទ្ធផលនៃការរៀនសូត្រ និងសមធម៌។

ដោយប្រើប្រាស់ក្របខ័ណ្ឌនេះសម្រាប់តម្រង់ទិសការពិភាក្សាពីគុណភាព មានបញ្ហាចំនួនពីរត្រូវបានជ្រើសរើស៖ ធាតុចូល និងដំណើរការពាក់ព័ន្ធនឹងបន្ទប់រៀន។ ការមាន និងការប្រើប្រាស់សៀវភៅសិក្សា គឺជាធាតុផ្សំដ៏សំខាន់នៃគុណភាព តែទោះជាយ៉ាងនេះក្តី ការចូលដល់សាលារៀន និងការសង្កេតមើលបន្ទប់រៀន បង្ហាញថា ទិន្នន័យផ្លូវការអំពីសាលារៀន និងបន្ទប់រៀន គឺមិនអាចជឿទុកចិត្តបានឡើយ។ ក្នុងប្រទេសឆាដ សិស្សដែលរៀនមុខវិជ្ជាអំណាន និងគណិតវិទ្យានៅថ្នាក់ទី ២ និងទី ៦ ប្រហែលជា ៩០% ត្រូវចែករំលែកសៀវភៅសិក្សា ជាមួយនឹងសិស្សយ៉ាងហោចណាស់ ២ នាក់ផ្សេងទៀត។

គេមានការលំបាកក្នុងការជម្រុញឲ្យមានការប្រើប្រាស់ការសង្កេតតាមថ្នាក់ ដើម្បីធ្វើការប្រៀបធៀបប្រព័ន្ធអប់រំមួយ និងប្រព័ន្ធអប់រំមួយទៀត។ ទោះជាយ៉ាងណាក៏ដោយ ឧបករណ៍ពិនិត្យតាមដានដែលមានលក្ខណៈស៊ីសង្វាក់គ្នា អាចឲ្យអ្នកតាក់តែងគោលនយោបាយផ្តោតការយកចិត្តទុកដាក់លើបញ្ហាសំខាន់ៗជុំវិញការបង្រៀន និងគរុកោសល្យ។ ការអង្កេតលើថ្នាក់រៀនចំនួន ១៥០០០ ក្នុងប្រទេសប្រេស៊ីល កូឡុំប៊ី ហុងឌុយរ៉ាស់ ចាម៉ែកា និងពេរូ បង្ហាញថា គ្រូចំណាយពេល ៦០-៦៥% របស់ខ្លួនលើការបង្រៀន ពោលគឺទាបជាង ៨៥% ដែលគួរមាន។ ជាការសំខាន់ណាស់ ដែលគេត្រូវបន្តស្វែងរកឧបករណ៍ដែលងាយស្រួលយកមកប្រើប្រាស់ ប៉ុន្តែនៅតែអាចជឿទុកចិត្តបានមានប្រសិទ្ធភាពខាងចំណាយ និងងាយស្រួលប្រើប្រាស់ក្នុងទ្រង់ទ្រាយធំ។

## លទ្ធផលនៃការរៀនសូត្រ

ដើម្បីធ្វើឲ្យលទ្ធផលនៃការរៀនសូត្រកាន់តែមានលក្ខណៈល្អប្រសើរ ជាការសំខាន់ណាស់ ដែលត្រូវមានចំណុចដៅ ដើម្បីបង្ហាញថាតើមានការសម្រេចបាននូវវឌ្ឍនភាពដែរឬទេ។ ប៉ុន្តែ មានការចោទជាសំណួរអំពីថាតើមាន “លទ្ធផលរៀនសូត្រអ្វីខ្លះដែលពាក់ព័ន្ធ និងមានប្រសិទ្ធភាព” តើត្រូវធ្វើការវាស់វែងលទ្ធផលទាំងនេះដោយរបៀបណា និងតើត្រូវយកលទ្ធផលរកឃើញទាំងនេះទៅប្រើប្រាស់យ៉ាងដូចម្តេច។

ការវាស់វែងសូចនាករសកលដែលស្មើឡើង ដែលផ្តោតលើបំណិនអំណាន និងគណិតវិទ្យា ទាមទារឲ្យមានការឯកភាពគ្នាលើខ្លឹមសារនៃលទ្ធផលនៃការរៀនសូត្រដែលត្រូវវាយតម្លៃ ស្តង់ដាគុណភាពដែលត្រូវបំពេញ និងចំណុចដៅសម្រាប់វាយការណ៍ដែលត្រូវប្រើប្រាស់។

## វាស់វែងលទ្ធផលនៃការរៀនសូត្រ៖ ការកំណត់ខ្លឹមសារ

ដើម្បីកំណត់ពីកម្រិតស្ទាត់ជំនាញកម្រិតអប្បបរមា តាមមុខវិជ្ជាផ្សេងៗ ដូចជា អំណាន និងគណិតវិទ្យា ជាដើម ចាំបាច់ត្រូវមានការកំណត់ប៉ារ៉ាម៉ែត្រគោល សម្រាប់វាយតម្លៃ។ តើមានអ្វីកើតឡើង នៅពេលដែលគេចាំបាច់ត្រូវរកឲ្យឃើញនូវចំណុចរួមគ្នារវាងកម្មវិធីសិក្សាផ្សេងៗគ្នា? តើគេរំពឹងថាសិស្សនឹងរៀនចេះចំណេះដឹងថ្មីៗអ្វីខ្លះ ក្នុងកម្មវិធីសិក្សា? តើសំណួរអ្វីខ្លះបង្ហាញថាសិស្សម្នាក់បានឈានដល់កម្រិតស្ទាត់ជំនាញអ្វីមួយ? តើគេធ្វើការកំណត់ពីកម្រិតស្ទាត់ជំនាញដោយរបៀបណា?

មានបញ្ហាចម្រូងចម្រាស់ចំនួនពីរ។ទីមួយ ពុំមានការយល់ស្របគ្នាលើការវាយតម្លៃអំណាន និងគណិតវិទ្យាថ្នាក់ដំបូងឡើយដោយសារមូលហេតុនយោបាយ និងមូលហេតុបច្ចេកទេស។ ទោះជាយ៉ាងណាក៏ដោយ ការវាយតម្លៃនេះបានទាក់ទាញការយកចិត្តទុកដាក់លើបញ្ហាប្រឈមធំៗ ដែលកំពុងកើតមានជាក់ស្តែង។ ក្នុងប្រទេសម៉ាឡាវី ក្នុងឆ្នាំ ២០១២ មានសិស្សថ្នាក់ទី ២ ចំនួន ៩០% អាចមិនដាច់សូម្បីតែពាក្យមួយម៉ាត់ ជាភាសា Chichewa ហើយមានកុមារជិត ៤០% នៅតែមិនចេះអាន រហូតដល់ថ្នាក់ទី ៤។

ទីពីរ សូចនាករសកលសម្រាប់ភាពស្ទាត់ជំនាញខាងអំណាននិងលេខនពន្ធមិនបានរាប់បញ្ចូលអ្នកនៅក្រៅសាលាឡើយ។នៅតំបន់ជនបទនៃប្រទេសប៉ាគីស្ថាន សិស្សរៀនថ្នាក់ទៅ ១០ ៨៩% ចេះអានរឿងនិទានថ្នាក់ទី ២ ជាភាសា Urdu, Sindhi ឬ Pashto ប៉ុន្តែក្នុងចំណោមកុមារអាយុ ១៤ ឆ្នាំទាំងអស់ មានតែ ៦៤% ប៉ុណ្ណោះ ដែលអានរឿននិទានបែបនេះបាន។

## ឧបករណ៍សម្រាប់វាស់វែងលទ្ធផលនៃការរៀនសូត្រ៖ ការធានាគុណភាពនៃការវាយតម្លៃ

សូចនាករតាមប្រធានបទមួយ ធ្វើការវាស់វែងថាតើប្រទេសមួយបានធ្វើការវាយតម្លៃលើការរៀនសូត្រ ដែលមានលក្ខណៈតំណាងឲ្យប្រទេសទាំងមូល ក្នុងកំឡុងពេលដែលសិស្សកំពុងរៀនកម្រិតបឋមសិក្សា នៅចុងបញ្ចប់ថ្នាក់បឋមសិក្សា និងនៅចុងបញ្ចប់ថ្នាក់មធ្យមសិក្សាបឋមភូមិដែរឬទេ។ ចាំបាច់ត្រូវមានស្តង់ដាច្បាស់លាស់ សម្រាប់ធ្វើការវាយតម្លៃ ក៏ដូចជាយន្តការរឹងមាំ ដើម្បីធានាយ៉ាងណាឲ្យការវាយតម្លៃអាចបំពេញបានស្តង់ដាទាំងនេះ។

គុណភាពនៃការវាយតម្លៃមានធាតុផ្សំពាក់ព័ន្ធចំនួនពីរ៖ (ក) ចាំបាច់ត្រូវមានបរិបទស្ថាប័នដែលមានលក្ខណៈអំណោយផល ដើម្បីធានាបាននូវនិរន្តរភាព និងទំនាក់ទំនងឲ្យបានរឹងមាំ ជាមួយនឹងប្រព័ន្ធអប់រំ និង (ខ) ការវាយតម្លៃដែលអាចតំណាងឲ្យប្រទេសទាំងមូលគួរមានសុពលភាព និងអាចជឿទុកចិត្តបាន សម្រាប់ផ្តល់នូវព័ត៌មានពាក់ព័ន្ធដល់អ្នកតាក់តែងគោលនយោបាយ និងសាធារណជនទូទៅ។ការវាយតម្លៃដែលអាចតំណាងឲ្យប្រទេសទាំងមូល ក៏ត្រូវមានទិសដៅស្របគ្នាជាមួយនឹងគោលដៅអប់រំ និងគោលបំណងនៃការរៀនសូត្ររបស់សិស្ស ក៏ដូចជាជាមួយនឹងឱកាសអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូផងដែរ។

សំណួរ ពាក់ព័ន្ធជាមួយនឹងថាតើត្រូវធ្វើយ៉ាងណា ដើម្បីឲ្យការវាយតម្លៃមួយមានលក្ខណៈសមស្របទៅតាមគោលបំណងនៃការពិនិត្យតាមដាន ធ្វើឲ្យមានបញ្ហាចំនួនពីរ។ ទីមួយ លក្ខខណ្ឌតម្រូវបច្ចេកទេស ដែលមានលក្ខណៈតឹងរ៉ឹងពេក អាចធ្វើឲ្យប្រទេសជាច្រើនពុំមានសមត្ថភាពដល់កម្រិតដែលចាំបាច់ និងនាំឲ្យមានអ្នកផ្តល់សេវាតែមួយក្រុមតូចជាអ្នកធ្វើការវាយតម្លៃភាគច្រើន ដែលធ្វើឲ្យប៉ះពាល់ដល់ភាពឆ្លើយតប និងការប្រើប្រាស់លទ្ធផលដែលបានពីការវាយតម្លៃទាំងនេះ របស់ប្រទេសនានា។ ទីពីរ គួរមានការវិភាជន៍ធនធានសម្រាប់បង្កើនសមត្ថភាពរបស់ប្រទេស ដើម្បីធ្វើការវាយតម្លៃលើការរៀនសូត្រឲ្យបានត្រឹមត្រូវ ឲ្យកាន់តែមានប្រសិទ្ធភាពជាងមុន។

## ការវាស់វែងលទ្ធផលនៃការរៀនសូត្រ៖ ការរាយការណ៍ពីលទ្ធផល ដែលបានពីការវាយតម្លៃផ្សេងគ្នា

ការវាស់វែងលទ្ធផលនៃការរៀនសូត្រនៅកម្រិតសកល តម្រូវឲ្យមានការឯកភាពគ្នាលើចំណុចដៅនៃការរាយការណ៍ និងចំណុចដៅនៃការកំណត់លទ្ធផល ទៅតាមកម្រិត (ឬអាយុ) និងមុខវិជ្ជា។ នេះតម្រូវឲ្យមានការរៀបចំសំណួរតេស្តសម្រាប់ការវាយតម្លៃប្រភេទផ្សេងៗគ្នា ដែលអាចភ្ជាប់ទំនាក់ទំនងជាមួយគ្នា តាមរយៈការវិភាគលើកម្រិតនៃការលំបាករបស់ការវាយតម្លៃទាំងនោះ។ តែទោះជាយ៉ាងណាក៏ដោយ ការភ្ជាប់ទំនាក់ទំនងសំណួរតេស្តមិនមែនត្រឹមតែជាបញ្ហាបច្ចេកទេសប៉ុណ្ណោះទេ វាក៏ពាក់ព័ន្ធជាមួយនឹងគោលបំណងដែលគេចង់សម្រេចឲ្យបានចេញពីសូចនាករផងដែរ។

សូចនាករលទ្ធផលនៃការរៀនសូត្រ ដែលអាចឲ្យគេប្រៀបធៀបបានជាលក្ខណៈសកល មិនត្រឹមតែមានគោលបំណងសម្រាប់ធ្វើការពិនិត្យតាមដានជាសកលប៉ុណ្ណោះទេ ប៉ុន្តែក៏បំពេញទៅតាមតម្រូវការរបស់ប្រទេសផងដែរ។ សម្ព័ន្ធសកលសម្រាប់ពិនិត្យតាមដានការរៀនសូត្រ (Global Alliance to Monitor Learning) អាចជួយបំពេញកិច្ចខិតខំប្រឹងប្រែងនេះបាន។




# ការអប់រំកុមារតូច

## គោលដៅ ៤.២

ចំណុចដៅ ៤.១ គូសបញ្ជាក់សារជាថ្មីពីការផ្តោតការយកចិត្តទុកដាក់របស់សហគមន៍អន្តរជាតិលើការធានាយ៉ាងណាឲ្យកុមារគ្រប់រូបមានមូលដ្ឋានគ្រឹះរឹងមាំ តាមរយៈការគាំពារ និងការអប់រំកុមារតូច។ ការពិនិត្យតាមដានចំណុចដៅនេះមានបញ្ហាប្រឈមចំនួន ៣៖ (ក) នៅមិនទាន់មានព័ត៌មានគ្រប់គ្រាន់នៅឡើយថាតើមានកុមារប៉ុន្មាននាក់ ដែលទទួលបានប្រយោជន៍ពីការអប់រំកម្រិតមត្តេយ្យសិក្សាយ៉ាងហោចណាស់មួយឆ្នាំ (ខ) សូចនាករដែលស្នើឡើងមិនបានក្តោបលើទស្សនទានគុណភាពនៃការផ្តល់សេវានិង (គ) ខណៈពេលដែលចំណុចដៅនេះផ្តោតលើការអភិវឌ្ឍកុមារតូច ដែលហួសពីការគាំពារ និងការអប់រំ លទ្ធភាពបង្កើតយន្តការពិនិត្យតាមដានការអភិវឌ្ឍកុមារតូច គឺមិនមានភាពប្រាកដប្រជាឡើយ។

“ការអប់រំកម្រិតមត្តេយ្យសិក្សា គឺជាការអប់រំដែលច្បាប់តម្រូវ ក្នុងប្រទេសចំនួន ៤៩ និងជាការអប់រំដែលផ្តល់ដោយមិនគិតថ្លៃ និងតម្រូវដោយច្បាប់យ៉ាងហោចណាស់ឲ្យបានមួយឆ្នាំក្នុងប្រទេសចំនួន ៣៦។”

### លទ្ធភាពទទួលបានសេវា និងការចូលរួម

ការប្រៀបធៀបអត្រានៃការចូលរួមរវាងប្រទេសមួយ និងប្រទេសមួយសម្រាប់ការអប់រំកម្រិតមត្តេយ្យសិក្សា គឺពិបាកជាងសម្រាប់កម្រិតបឋមសិក្សា និងមធ្យមសិក្សា។ ក្រុមអាយុចូលរៀននៅមត្តេយ្យសិក្សា និងអាយុចាប់ផ្តើមចូលរៀន មិនសូវជាមានស្តង់ដាត្រឹមត្រូវ ដូចកម្រិតផ្សេងទៀតឡើយ៖ ការអប់រំកម្រិតមត្តេយ្យសិក្សា គឺជាការអប់រំដែលច្បាប់តម្រូវ ក្នុងប្រទេសចំនួន ៤៩ និងជាការអប់រំដែលផ្តល់ដោយមិនគិតថ្លៃ និងតម្រូវដោយច្បាប់យ៉ាងហោចណាស់ឲ្យបានមួយឆ្នាំក្នុងប្រទេសចំនួន ៣៦។

ក្នុងសកលលោកទាំងមូល មានកុមារដែលមានអាយុក្រោមអាយុចូលរៀនបឋមសិក្សាមួយឆ្នាំ ប្រហែល ៦៧% បានចុះឈ្មោះចូលរៀនថ្នាក់មត្តេយ្យសិក្សា ឬបឋមសិក្សា។ តួលេខប៉ាន់ស្មាននេះគឺកៀកទៅនឹងតួលេខប៉ាន់ស្មានចេញពីការអង្កេតតាមគ្រួសារអំពីការធ្លាប់រៀនថ្នាក់មត្តេយ្យសិក្សារបស់សិស្សថ្នាក់ទីមួយ ប៉ុន្តែមិនមែនចេះដូចគ្នារហូតទៅនឹងការអង្កេតនេះឡើយ។ ការអង្កេតនេះក៏ធ្វើការតាមដានកម្រិតនៃការចូលរៀន បែងចែកទៅតាមទ្រព្យធនរបស់គ្រួសារផងដែរ។ ក្នុងចំណោមកុមារអាយុពី ៣ ដល់ ៤ ឆ្នាំ ក្នុងប្រទេសដែលមានចំណូលទាប ទៅមធ្យម កុមារក្នុងគ្រួសារដែលមានជីវភាពធូរធាជាងគេមានលទ្ធភាពទទួលបានការអប់រំកុមារតូច ច្រើនជាងកុមារដែលក្រីក្រជាងគេ ដល់ទៅ ៦ ដង។

### គុណភាព

ចំណុចដៅនេះផ្តោតលើការផ្តល់ការអប់រំប្រកបដោយគុណភាព។ គុណភាពសំដៅលើកម្រិតដែលបរិបទក្នុងសាលារៀន និងថ្នាក់រៀន (រាប់បញ្ចូលទាំងអគារ និងដំណើរការបង្រៀនផង) និងប្រព័ន្ធទាំងមូល ផ្តល់ការគាំទ្រដល់ការអភិវឌ្ឍទាំងមូលរបស់កុមារ ជាពិសេស កុមារដែលងាយនឹងទទួលរងការផាត់ចេញពីសង្គម។ ខណៈពេលដែលប្រទេសនានាចាំបាច់ត្រូវកំណត់គោលដៅ និងស្តង់ដាគុណភាពដោយខ្លួនឯង មានឧបករណ៍ ដែលគេអាចប្រើប្រាស់សម្រាប់ពិនិត្យតាមដានគុណភាពនៃការផ្តល់ការអប់រំកុមារតូច តាមបែបប្រហាក់ប្រហែលគ្នានេះដែរ បើទោះបីជាឧបករណ៍ទាំងនេះបានជម្រុញឲ្យមានការជជែកវែកញែកគោលនយោបាយក៏ដោយ។ ក្នុងចំណោមប្រទេសដែលមានចំណូលទាប និងមធ្យមចំនួន ២១ ក្នុងការសិក្សាពិនិត្យលើគោលនយោបាយអប់រំកុមារតូច ដែលធ្វើឡើងដោយធនាគារពិភពលោក មានប្រទេសចំនួន ១៣ បានដាក់ចេញនូវស្តង់ដាគោលសម្រាប់ផលធៀបសិស្សគ្រូ ប៉ុន្តែមានប្រទេសតែ ៨ ប៉ុណ្ណោះ ដែលពង្រឹងការអនុវត្តស្តង់ដាទាំងនេះ។

## លទ្ធផលនៃការអភិវឌ្ឍកុមារ

ចំណុចដៅ ៤.២ ផ្តោតលើការធានាថា កុមារបានចាប់ផ្តើមការសិក្សាក្នុងប្រព័ន្ធទៅតាមកម្រិតនៃការអភិវឌ្ឍរបស់ពួកគេ និង "ត្រៀមខ្លួនរួចរាល់ដើម្បីចូលរៀន នៅសាលាបឋមសិក្សា"។ ទស្សនៈក្តោបរួមបែបនេះគឺជាការងាកចេញ ពីទស្សនៈនៃការអភិវឌ្ឍកុមារ ដែលប្រើប្រាស់តែសូចនាករពាក់ព័ន្ធនឹងសុខភាព។ ការសម្រេចចិត្តពីរបៀបដែល ល្អបំផុតសម្រាប់ធ្វើការវាស់វែង ការអភិវឌ្ឍរបស់កុមារ គឺជាការសម្រេចចិត្តដ៏ស្មុគស្មាញ។ គេចាំបាច់ត្រូវធ្វើការតាមដានការអភិវឌ្ឍធម្មតា ក្នុងវប្បធម៌ផ្សេងៗគ្នា និងបង្កើតវិធីសាស្ត្រសម្រាប់ធ្វើការវាស់វែង ដោយប្រើប្រាស់លទ្ធផលរកឃើញទាំងនេះ ធ្វើជាគោល។




**រូបភាពទី៩ :**
ទិន្នន័យអំពីការចូលរួមក្នុងកម្មវិធីគាំពារ និងអប់រំកុមារតូច កម្មវិធីមានលក្ខណៈខុសគ្នារវាងគ្រួសារមួយ និងគ្រួសារមួយទៀត និងរវាងសាលារៀនមួយ និងសាលារៀនមួយទៀត
អត្រាពិតនៃការសិក្សាសម្រាប់កម្រិតមត្តេយ្យសិក្សាដែលបានកែសម្រួល ក្នុងឆ្នាំចុងក្រោយនៃមត្តេយ្យសិក្សា ២០១៤ និងភាគរយនៃសិស្សរៀនថ្នាក់ទីមួយនៃបឋមសិក្សា ដែលបានចូលរួមទទួលការអប់រំកម្រិតមត្តេយ្យសិក្សានៅឆ្នាំមុន តាមប្រទេសមួយឆ្នាំ ពីឆ្នាំ ២០១០ ដល់ ២០១៥

ប្រភព៖ មូលដ្ឋានទិន្នន័យ UIS សម្រាប់អត្រាពិតនៃការសិក្សាដែលត្រូវបានកែសម្រួល, MICS សម្រាប់របាយការណ៍ចុងក្រោយ និងលទ្ធផលរកឃើញសំខាន់ៗនៃភាគរយសិស្សនៅថ្នាក់ទីមួយនៃបឋមសិក្សា ដែលបានចូលរៀននៅមត្តេយ្យមសិក្សា កាលពីឆ្នាំសិក្សាមុន

ការវាស់វែង ដែលមានបច្ចុប្បន្ននេះមានវិសាលភាព គ្របដណ្តប់ខ្ពស់ជាងគេ គឺសន្ទស្សន៍អភិវឌ្ឍន៍កុមារតូចរបស់យូនីសេហ្វ (ដែលហៅកាត់ថា ECDI)។ ក្នុងប្រទេសចំនួន ៥៦ ដែលភាគច្រើន ជាប្រទេសដែលមានចំណូលទាប និងមធ្យម ចន្លោះពីឆ្នាំ ២០១០ ដល់ ២០១៥ មានការរកឃើញថា មានកុមារអាយុ ៣ ឆ្នាំ ៧០% និងកុមារអាយុ ៤ ឆ្នាំ ៨០% ដែលមានការអភិវឌ្ឍស្របតាមអាយុរបស់ពួកគេ។ សន្ទស្សន៍នេះមានសមាសភាគចំនួន ៤ ប៉ុន្តែវងឥទ្ធិពលជាងគេពីសមាសភាគមួយនោះគឺចំណេះដឹងអក្សរ និងលេខនព្វន្ធ ដែលត្រូវបានគេរិះគន់ថាឆ្លុះបញ្ចាំងពីបទដ្ឋាននៃការអប់រំកុមារតូច ជាជាងសមត្ថភាពស្រូបយកចំណេះដឹងរបស់កុមារ។

កត្តាសំខាន់មួយ ដែលជួយឲ្យកុមារអាចសម្រេចសក្តានុពលរបស់ពួកគេ គឺបរិយាកាសក្នុងផ្ទះ ដែលផ្តល់ឱកាសឲ្យកុមារអាចធ្វើការប្រាស្រ័យទាក់ទង និងឯកសាររៀនសូត្រនានា។ សមាជិកគ្រួសារជាមនុស្សពេញវ័យក្នុងប្រទេសអ៊ុយក្រែន បានជម្រុញឲ្យមានកុមារអាយុពី ៣ ទៅ ៤ ឆ្នាំ ចូលរួមក្នុងសកម្មភាពយ៉ាងហោចណាស់ចំនួន ៤ បើធៀបជាមួយនឹងកុមារត្រឹមតែ ៤០% ក្នុងប្រទេសហ្គាណា។ ក្នុងប្រទេសចំនួន ៥៤ ដែលភាគច្រើនជាប្រទេសដែលមានចំណូលទាប និងមធ្យម ពីឆ្នាំ ២០១០ ដល់ ២០១៥ មានគ្រួសារចំនួន ១៩% មានសៀវភៅកុមារយ៉ាងហោចណាស់ចំនួន ៣ ក្បាល និង ៧,៥% មានសៀវភៅយ៉ាងហោចណាស់ ១០ ក្បាល។ ក្នុងចំណោមគ្រួសារក្រីក្រជាងគេ ២០% មានគ្រួសារតិចជាង ១% ដែលមានសៀវភៅយ៉ាងហោចណាស់ ១០ ក្បាល។

Sustainable Development Goal 4.3

គោលដៅ ៤.៣

# ការអប់រំបច្ចេកទេស ការអប់រំវិជ្ជាជីវៈ ការអប់រំឧត្តមសិក្សា និងការអប់រំមនុស្សពេញវ័យ

ចំណុចដៅ ៤.៣ ផ្តើមបញ្ចូលការអប់រំបច្ចេកទេស វិជ្ជាជីវៈ និងឧត្តមសិក្សា ទៅក្នុងរបៀបវារៈជាសកល។ ការអប់រំទាំងនេះត្រូវបានចាត់ទុកថាជាផ្នែកនៃការអប់រំសម្រាប់ទាំងអស់គ្នា ប៉ុន្តែត្រឹមតែជាការគាំទ្រដល់គោលដៅផ្សេងទៀតតែប៉ុណ្ណោះ។

សូចនាករសកលសម្រាប់ចំណុចដៅនេះ - ភាគរយនៃយុវជន និងមនុស្សពេញវ័យ ដែលចូលរួមក្នុងការអប់រំ ឬការបណ្តុះបណ្តាលក្នុងប្រព័ន្ធ ឬក្រៅប្រព័ន្ធ ក្នុងរយៈពេល ១២ ខែកន្លងទៅ - ក៏ក្តោបលើការអប់រំមនុស្សពេញវ័យផងដែរ។ ដូច្នេះ របាយការណ៍ GEM នេះក្តោបតែលើការអប់រំបច្ចេកទេស-វិជ្ជាជីវៈ ឧត្តមសិក្សា និងការអប់រំមនុស្សពេញវ័យ ក្រោមចំណុចដៅ ៤.៣ ចេញពីជ្រុងទស្សនទានទាំង ៣ ដែលជាមូលដ្ឋានកំណត់ចំណុចដៅនេះប៉ុណ្ណោះ នោះគឺ៖ ការទទួលបានសេវា ភាពសមស្របនៃតម្លៃ និងគុណភាព។

## ការអប់រំ និងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (ដែលហៅកាត់ថា TVET) ត្រូវផ្តល់នៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាល កន្លែងធ្វើការ ឬផ្តល់ព្រមគ្នានៅកន្លែងទាំងពីរនេះ។ ដោយសារតែក្របខ័ណ្ឌគោលនយោបាយ ការរៀបចំស្ថាប័ន និងរបៀបរៀបចំ មានលក្ខណៈចម្រុះផ្សេងៗពីគ្នា ប្រព័ន្ធស្ថិតិជាតិអាចក្តោបបានរូបភាពតែមួយជ្រុងប៉ុណ្ណោះ ដែលធ្វើឲ្យគេមានការពិបាកក្នុងការប្រៀបធៀបការផ្តល់សេវាអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ រវាងប្រទេសមួយ និងប្រទេសមួយទៀត។

> “ការវិភាគថ្មីពីប្រទេសចំនួន ១២ បង្ហាញថា មានយុវជនប្រមាណជា ២០% បានចូលរួមក្នុងកម្មវិធីនៅតាមកន្លែងធ្វើការ។”

យន្តការពិនិត្យតាមដានបច្ចុប្បន្ន ផ្តោតការយកចិត្តទុកដាក់លើការចូលរៀនតាមគ្រឹះស្ថាននានា ជាពិសេសគ្រឹះស្ថានដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ។ ការផ្តោតបែបនេះធ្វើឲ្យវិសាលភាពនៃការពិនិត្យតាមដានចំណុចដៅនេះកាន់តែរួមតូច។ ការបញ្ចូលការអប់រំបណ្តុះបណ្តាលនៅកន្លែងធ្វើការតម្រូវឲ្យមានការប្រមូលទិន្នន័យពីអង្កេតលើកម្លាំងពលកម្ម ការអង្កេតសហគ្រាស ឬការអង្កេតគ្រួសារ ដែលចាំបាច់ត្រូវធ្វើការសម្របសម្រួលនិយមន័យ និងកម្រងសំណួរជាមួយគ្នាឲ្យបានជិតស្និទ។ ការវិភាគលើរបាយការណ៍ GEM មកពីប្រទេសចំនួន ១២ បង្ហាញថា បង្ហាញថា មានយុវជនប្រមាណជា ២០% បានចូលរួមក្នុងកម្មវិធីនៅតាមកន្លែងធ្វើការ។

សំណួរ ពាក់ព័ន្ធនឹងភាពសមស្របនៃតម្លៃ គួរផ្តោតលើកម្រិតដែលគោលនយោបាយរបស់រដ្ឋាភិបាលជួយដោះស្រាយបញ្ហាវិសមភាពក្នុងការទទួលបានសេវា TVET។ ដោយសារតែលក្ខណៈចម្រុះផ្សេងៗគ្នានៃអ្នកផ្តល់សេវា របៀបបង់ថ្លៃ គោលនយោបាយសាធារណៈ និងបរិបទជាតិ សូចនាករតែមួយទំនងជាមិនអាចរៀបរាប់ពីលក្ខណៈសមស្របនៃតម្លៃនោះទេ។វិធីសាស្ត្រមួយ ដែលគេអាចប្រើប្រាស់បាន គឺការពិនិត្យលើចំណូលរបស់គ្រឹះស្ថាន ដែលត្រូវរ៉ាប់រងដោយសិស្ស ធៀបជាមួយនឹងទំហំនៃការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីរដ្ឋាភិបាល ដែលសិស្សទទួលបាន។

វិធីសាស្ត្រមួយ សម្រាប់ធ្វើការវាយតម្លៃគុណភាពរបស់សេវា TVET គឺត្រូវផ្តោតលើថាតើមានការបញ្ចូលស្តង់ដាដែលអាចជឿទុកចិត្តបាន ទៅក្នុងក្របខ័ណ្ឌគុណវឌ្ឍិជាតិដែរឬទេ។ មានប្រទេសយ៉ាងហោចណាស់ចំនួន ១៤០ ដែលមានក្របខ័ណ្ឌបែបនេះ។ ក្របខ័ណ្ឌទាំងនេះមានប្រសិទ្ធភាពខុសៗគ្នា ប៉ុន្តែអាចជួយឲ្យអ្នកសិក្សា អ្នកផ្តល់សេវា និងនិយោជកអាចផ្តោតលើលទ្ធផល ជាជាងលើរបៀបដែលអ្នកសិក្សាទទួលបានគុណវឌ្ឍិ។

## ការអប់រំកម្រិតឧត្តមសិក្សា

ការអប់រំកម្រិតឧត្តមសិក្សា មានចាប់ពីវគ្គខ្លី រហូតដល់កម្មវិធីបរិញ្ញាបត្រ កម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ ន ិងកម្មវិធីថ្នាក់បណ្ឌិត។ គ្រឹះស្ថានមានទំហំ ចំណាយ វគ្គសិក្សា នីតិវិធី និងគុណភាព ខុសគ្នាឆ្ងាយ។ សំណួរជុំវិញបញ្ហាសមធម៌ ចាំបាច់ត្រូវធ្វើការពិចារណាលើឧបសគ្គ ដែលមាននៅតាមដំណាក់កាលផ្សេងៗ ចាប់ពីការទទួលបានសេវា រហូតដល់ការបញ្ចប់ការសិក្សា។ ការចុះឈ្មោះចូលរៀនជា

សកល នៅកម្រិតឧត្តមសិក្សា មានការកើនឡើងទ្វេដងពី ១០០ លាននាក់ ក្នុងឆ្នាំ ២០០០ រហូតដល់ ២០៧ លាននាក់ ក្នុងឆ្នាំ ២០១៤ ប៉ុន្តែគម្លាតក្នុងប្រទេសមួយ និងរវាងប្រទេសមួយ និងប្រទេសមួយទៀត មានទំហំធំ។ ក្នុងប្រទេសហ្វីលីពីន ក្នុងឆ្នាំ ២០១៣ ក្នុងចំណោមមនុស្សអាយុពី ២៥ ដល់ ២៩ ឆ្នាំ ដែលមានជីវភាពធូរធាជាងគេ មាន ៥២% ដែលបានរៀនចប់ការអប់រំកម្រិតឧត្តមសិក្សាយ៉ាងហោចណាស់រយៈពេល ៤ ឆ្នាំ ខណៈពេលក្នុងចំណោមអ្នកដែលមានជីវភាពក្រីក្រជាងគេ តួលេខនេះមានត្រឹមតែ ១% ប៉ុណ្ណោះ។

ភាពសមស្របនៃតម្លៃ សម្រាប់ការអប់រំកម្រិតឧត្តមសិក្សា គឺអាស្រ័យទៅតាមទំនាក់ទំនងរវាងចំណាយ និងចំណូល។ គេអាចធ្វើការប្រៀបធៀបចំណាយសរុបជាមួយនឹងកម្រិតចំណូលមធ្យមរបស់គ្រួសារដោយប្រើប្រាស់ទិន្នន័យដែលបានពីការអង្កេតគ្រួសារ។ស្របពេលដែលការប្រៀបធៀបបែបនេះផ្តល់នូវព័ត៌មានដែលមានប្រយោជន៍ វាមិនបានបង្ហាញថាតើមានមនុស្សវ័យក្មេងប៉ុន្មាននាក់ ដែលពុំមានលទ្ធភាពបង់ថ្លៃសិក្សានៅកម្រិតឧត្តមសិក្សាឡើយ។ ការវាស់វែងមួយ ដែលគេអាចធ្វើបាន គឺត្រូវប្រៀបធៀបបន្ទុកហិរញ្ញវត្ថុដែលគ្រួសារត្រូវរ៉ាប់រង ជាមួយនឹងជំនួយហិរញ្ញវត្ថុ ដែលរដ្ឋាភិបាលផ្តល់ដល់គ្រួសារ។ ជោគជ័យ ក្នុងការផ្តោតគោលដៅលើអ្នកដែលមានត្រូវការការអប់រំប្រភេទនេះជាងគេ ក៏គួរពិនិត្យតាមដានផងដែរ។

**រូបភាពទី ១០៖**

**មានភាពខុសប្លែកគ្នាច្រើនខាងការទទួលបានការអប់រំកម្រិតឧត្តមសិក្សា រវាងអ្នកក្រ និងអ្នកមាន**

ភាគរយនៃមនុស្សអាយុពី ២៥ ដល់ ២៩ ឆ្នាំ ដែលបានបញ្ចប់ការអប់រំកម្រិតឧត្តមសិក្សាយ៉ាងហោចណាស់ ៤ ឆ្នាំ បែងចែកតាមទ្រព្យធន តាមប្រទេសមួយចំនួន ចន្លោះពីឆ្នាំ ២០០៨ ដល់ ២០១៤




ប្រភព៖ ការវិភាគរបស់ក្រុមការងាររៀបចំរបាយការណ៍ GEM ដោយប្រើប្រាស់ទិន្នន័យដែលបានពីការអង្កេតគ្រួសារ

ភាពខុសប្លែកគ្នានៃរចនាសម្ព័ន្ធគោលនយោបាយ និងធនធានរបស់ជាតិ នៃបេសកកម្មរបស់សកលវិទ្យាល័យ បង្កជាឧបសគ្គធំធេង ចំពោះការវាស់វែងគុណភាពនៃការអប់រំកម្រិតឧត្តមសិក្សាទូទាំងសកលលោកប្រកបដោយអត្ថន័យ។ ការដាក់ចំណាត់ថ្នាក់សកលវិទ្យាល័យ ទាក់ទាញចំណាប់អារម្មណ៍ ដោយសារតែចំណាត់ថ្នាក់ទាំងនេះងាយស្រួលយល់ ប៉ុន្តែការដាក់ចំណាត់ថ្នាក់បែបនេះគឺធ្វើឡើងផ្អែកទៅតាមការស្រាវជ្រាវ ជាជាងផ្អែកទៅតាមគុណភាពនៃការបង្រៀន ឬការរៀនសូត្ររបស់សិស្ស។

## ការអប់រំមនុស្សពេញវ័យ

ឱកាសរបស់មនុស្សពេញវ័យក្នុងការទទួលបានការរៀនសូត្រ ការអប់រំ និងការបណ្តុះបណ្តាល គឺជាយុទ្ធសាស្ត្រមួយ ដើម្បីសម្រេចចំណុចដៅ ៤.៣ នេះបើតាមការលើកឡើងក្នុងក្របខ័ណ្ឌសកម្មភាពសម្រាប់ការអប់រំឆ្នាំ ២០៣០។ ការអប់រំមនុស្សពេញវ័យអាចជាការអប់រំក្នុងប្រព័ន្ធ (តាមគ្រឹះស្ថាន) ក្រៅប្រព័ន្ធ ឬក្រៅផ្លូវការ។

ដោយសារតែការផ្តល់ការអប់រំដល់មនុស្សពេញវ័យមានលក្ខណៈចម្រុះ ការពិនិត្យតាមដានលើការចូលរួមទទួលសេវានេះ មានការលំបាកជាពិសេស។ ខណៈពេលមានព័ត៌មានមួយចំនួនអំពីមនុស្សពេញវ័យ ដែលទទួលបានការអប់រំក្នុងប្រព័ន្ធ ព័ត៌មាននេះបង្ហាញតែផ្នែកតូចមួយនៃរូបភាពទាំងមូលប៉ុណ្ណោះ។ ក្នុងប្រទេសចំនួន ២៨ ដែលជាសមាជិករបស់សហភាពអឺរ៉ុប មានមនុស្សពេញវ័យប្រហែលជា ៦% បានចូលរួមក្នុងការអប់រំក្នុងប្រព័ន្ធ និង ៣៧% ចូលរួមក្នុងការអប់រំក្រៅប្រព័ន្ធ ក្នុងឆ្នាំ ២០១១ នេះបើតាមការអង្កេតមួយ ដែលផ្តល់ជាមេរៀនសម្រាប់រៀបចំបង្កើតឧបករណ៍វាស់វែងការចូលរួមទទួលការអប់រំរបស់មនុស្សពេញវ័យ ក្នុងសកលលោកទាំងមូល។

គេមានការលំបាកក្នុងការវាយតម្លៃលើភាពសមស្របនៃតម្លៃ មិនត្រឹមតែដោយសារមានការផ្តល់ហិរញ្ញប្បទានពីប្រភពឯកជនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដោយសារតែកង្វះព័ត៌មានទៀតផង សូម្បីតែព័ត៌មានអំពីហិរញ្ញប្បទានពីប្រភពសាធារណៈ។ ក្នុងចំណោមប្រទេសចំនួន ៦ មានប្រទេសមិនដល់មួយផង ដែលចំណាយលើពី ០,៣% នៃ GDP របស់ខ្លួនលើការអប់រំមនុស្សពេញវ័យ។ ជារួម គេត្រូវការព័ត៌មានស្តីពីចំណាយសាធារណៈបន្ថែមទៀត ដើម្បីយល់ថាតើមានការផ្តោតការយកចិត្តទុកដាក់យ៉ាងដូចម្តេចខ្លះ ក្នុងការផ្តល់សេវាដល់ក្រុមដែលត្រូវការការអប់រំប្រភេទនេះជាងគេ។

ការពិនិត្យតាមដានការអប់រំមនុស្សពេញវ័យ រួមទាំងគុណភាពនៃការអប់រំប្រភេទនេះផង គឺជាការងារមួយដែលពិបាក។ របាយការណ៍សកលស្តីពីការរៀនសូត្រ និងការអប់រំមនុស្សពេញវ័យទី ៣ សន្និដ្ឋានថា គ្រប់តំបន់ទាំងអស់ក្នុងពិភពលោកសុទ្ធតែមានបញ្ហាពាក់ព័ន្ធនឹងទិន្នន័យ ដែលធ្វើឲ្យគេមិនអាចដឹងពីផលជះដែលបានពីការអប់រំមនុស្សពេញវ័យ។ របាយការណ៍នេះអំពាវនាវឲ្យប្រទេសនានាធ្វើការរៀបចំប្រព័ន្ធ សម្រាប់ដោះស្រាយឧបសគ្គនានា ដែលកំពុងធ្វើឲ្យរាំងស្ទះដល់ការប្រមូលទិន្នន័យ សម្រាប់ធ្វើការពិនិត្យតាមដាន និងវាយតម្លៃ។

# ជំនាញសម្រាប់ការងារ

## គោលដៅ ៤.៤

ចំណុចដៅ ៤.៤ លើកឡើងនូវសំណួរសំខាន់ៗចំនួន ៣៖ តើមានជំនាញ “សម្រាប់ការងារ ដើម្បីបានការងារសមរម្យធ្វើ និងសម្រាប់សហគ្រិនភាព” អ្វីខ្លះ ដែលមានភាពពាក់ព័ន្ធជាពិសេសទៅនឹងការពិនិត្យតាមដានជាសកល ក្នុងបរិបទផ្សេងៗពីគ្នា? តើគេទទួលបានជំនាញទាំងនេះ តាមរយៈការអប់រំ និងការបណ្តុះបណ្តាល ឬតាមរយៈមធ្យោបាយផ្សេងទៀត? តើរង្វាស់ដែលមាន ជារង្វាស់ដែលមានសុពលភាព និងអាចអនុវត្តទៅបាន ដោយអស់ចំណាយទាប ដែរឬទេ?

ភាពមិនប្រាកដប្រជាជុំវិញសំណួរទាំងនេះ ត្រូវបានឆ្លុះបញ្ចាំង ក្នុងសូចនាករដែលត្រូវបានស្នើឡើង។ សូចនាករមួយ គឺអត្រានៃការទទួលបានការអប់រំ របស់មនុស្សពេញវ័យ ដែលមិនមែនជារង្វាស់ជំនាញឡើយ។ សូចនាករមួយទៀត គឺជំនាញផ្នែកបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍(ICT)និងជំនាញចំណេះដឹងឌីជីថលដែលងាយនឹងធ្វើឲ្យរបៀបវារៈទាំងមូលកាន់តែមានវិសាលភាពតូចជាងមុនប៉ុន្តែសូចនាករនេះក៏ជាការប៉ុនប៉ងផ្តោតការយកចិត្តទុកដាក់លើជំនាញជាក់លាក់ ដែលអាចវាស់វែងផងដែរ។

> “នៅសហភាពអឺរ៉ុប មនុស្សពេញវ័យ ៤៤% ប្រើប្រាស់រូបមន្តពីជគណិតងាយៗ ក្នុងតារាងទិន្នន័យ ក្នុងឆ្នាំ ២០១៤។”

### ជំនាញស្រូបយកចំណេះដឹង

ជំនាញចំណេះដឹងជាមូលដ្ឋាន រួមមាន ចំណេះដឹងអក្សរ (អក្ខរកម្ម) និងលេខនព្វន្ត។ ការវិភាគថ្មីៗ ដែលធ្វើឡើង សម្រាប់របាយការណ៍ GEM នេះ បង្ហាញថា ជំនាញអក្ខរកម្មកម្រិតខ្ពស់ធ្វើឲ្យលទ្ធភាពបានការងារសមរម្យធ្វើកើនឡើងពិតទ្វេដង។

ជំនាញ ICT មានសារៈសំខាន់យ៉ាងខ្លាំង ចំពោះជីវិត និងការងារប្រចាំថ្ងៃ។ ក្នុងឆ្នាំ ២០១៤ នៅសហភាពអឺរ៉ុប មនុស្សពេញវ័យ ៤៤% ប្រើប្រាស់រូបមន្តពីជគណិតងាយៗ ក្នុងតារាងទិន្នន័យ ពោលគឺចាប់ពី ១៦% ក្នុងប្រទេសរ៉ូម៉ានី ដល់ ៦៣% ក្នុងប្រទេសហ្វាំងឡង់។ ជំនាញចំណេះដឹងឌីជីថល គឺជារង្វាស់មួយល្អជាង ដោយសារតែគេអាចធ្វើការវាយតម្លៃជំនាញទាំងនេះដោយផ្ទាល់បាន។ នៅសាធារណរដ្ឋឆេក ក្នុងឆ្នាំ ២០១៣ សិស្សរៀនថ្នាក់ទី ៨ ចំនួន ៨៥% ចេះប្រើប្រាស់កុំព្យូទ័រ ដើម្បីធ្វើការងារផ្សេងៗ បើធៀបជាមួយនឹង ១៣% នៅប្រទេសថៃ និង ៩%ក្នុងប្រទេសតួគី។ ឧបករណ៍កម្រិតសកល ចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់លើការផ្លាស់ប្តូរដ៏ឆាប់រហ័សនៃបច្ចេកវិទ្យាក្នុងរយៈពេលមួយ និងជាពិសេស ភាពលំអៀងខាងវប្បធម៌ ក្នុងសំណួរ ដែលគេកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ននេះ។

### ជំនាញមិនពាក់ព័ន្ធនឹងការស្រូបយកចំណេះដឹង...

មានការចាប់អារម្មណ៍កាន់តែខ្លាំងឡើងលើជំនាញ ដែលគេជឿថាមិនសូវពាក់ព័ន្ធនឹងដំណើរការស្រូបយកចំណេះដឹង បើទោះបីជាក្នុងការអនុវត្តជាក់ស្តែង ជំនាញដែលត្រូវបានគេផ្តល់តម្លៃឲ្យខ្ពស់បំផុតនៅកន្លែងធ្វើការងារជាច្រើន ដូចជា ជំនាញច្នៃប្រឌិត ការគិតពិចារណាល្អិតល្អន់ ការដោះស្រាយបញ្ហា និងការសហការគ្នា ជាដើម មិនសូវជាត្រូវបានគេរាប់បញ្ចូលក៏ដោយ។

ពុំមានភស្តុតាងគ្រប់គ្រាន់បង្ហាញពីកម្រិត ដែលជំនាញមិនពាក់ព័ន្ធនឹងចំណេះដឹង ដូចជា ភាពអត់ធ្មត់ ការចេះគ្រប់គ្រងខ្លួនឯង ឬជំនាញសង្គមនិងអារម្មណ៍ ជាដើម អាចព្យាករបានល្អបំផុតពីលទ្ធផលជាវិជ្ជមានពាក់ព័ន្ធនឹងការងារនោះឡើយ។ កម្រិតខ្ពស់បំផុតនៃជំនាញទាំងនេះ ច្រើនអាស្រ័យទៅតាមបរិបទការងារ។

ការបង្កើតឧបករណ៍វាស់វែង ដើម្បីឲ្យគេអាចធ្វើការប្រៀបធៀបជំនាញមិនពាក់ព័ន្ធនឹងចំណេះដឹងរវាងប្រទេសមួយ និងប្រទេសមួយទៀត គឺជាការពិបាក។ របាយការណ៍ GEM នេះ ផ្តល់អនុសាសន៍ឲ្យគេចៀសវាងធ្វើការវាស់វែងក្នុងទ្រង់ទ្រាយធំ សម្រាប់គោលបំណងពិនិត្យតាមដានជាសកល និងអំពាវនាវឲ្យមានការយកចិត្តទុកដាក់លើការស្រាវជ្រាវ ដែលអាចវាស់វែងការទទួលបានជំនាញទាំងនេះ និងឥទ្ធិពលនៃជំនាញទាំងនេះនៅកន្លែងធ្វើការ។

### ... និងការប្រើប្រាស់ជំនាញទាំងនេះបញ្ចូលគ្នា សម្រាប់ពិភពការងារ

មានឧទាហរណ៍ចំនួនពីរ ដែលបង្ហាញពីភាពពាក់ព័ន្ធនៃការបញ្ចូលជំនាញស្រូបយកចំណេះដឹង និងជំនាញមិនពាក់ព័ន្ធនឹងចំណេះដឹង ចំពោះពិភពការងារ នោះគឺចំណេះដឹងហិរញ្ញវត្ថុ និងជំនាញសហគ្រិនភាព។ ការប៉ុនប៉ងបង្កើតឧបករណ៍វាស់វែងចំណេះដឹងហិរញ្ញវត្ថុ មានការរីកចម្រើនយ៉ាងច្រើន ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ បើតាមនិយមន័យមួយបែប ក្នុងចំណោមមនុស្សពេញវ័យសរុបក្នុងពិភពលោកទាំងមូល មាន ៣៣% មានចំណេះដឹងផ្នែកហិរញ្ញវត្ថុ ពោលគឺចាប់ពី ១៣% ក្នុងប្រទេសយេមែន រហូតដល់ ៧១% ក្នុងប្រទេសណរវេ៉។ ការវាយតម្លៃលើជំនាញសហគ្រិនភាព ដែលនៅដំណាក់កាលស្រាវជ្រាវនៅឡើយ លើកឡើងនូវសំណួរអំពីប្រធានបទដែលត្រូវបញ្ចូលក្នុងកម្មវិធីសិក្សា។

# សមធម៌

## គោលដៅ ៤.៥

បំណងប្រាថ្នា “មិនទុកអ្នកណាម្នាក់ចោល” បានជ្រួតជ្រាបក្នុងរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ ២០៣០ ទាំងមូល ហើយគេរំពឹងថា នឹងបង្កើនតម្រូវការឲ្យមានការពិនិត្យតាមដាន និងការរាយការណ៍ពីបញ្ហាវិសមភាព ដែលកំពុងកើតមានឡើងក្នុងសកលលោកទាំងមូល។ របាយការណ៍ GEM នេះផ្ដោតការយកចិត្តទុកដាក់លើបញ្ហាធំៗចំនួន ៣៖ តើមានវិធីសាស្ត្រសមស្របអ្វីខ្លះ ដើម្បីធ្វើការវាស់វែងវិសមភាព និងការវិវឌ្ឍនៃបញ្ហាវិសមភាព តើត្រូវធ្វើការប្រមូលព័ត៌មាន ដើម្បីកំណត់ថាបុគ្គលណាម្នាក់ជាសមាជិករបស់ក្រុមងាយរងគ្រោះដោយរបៀបណា និងថាតើគេអាចវាស់វែងសមធម៌ក្នុងការអប់រំ លើសពីយុគភាពទៅទៀត ដោយរបៀបណា។

## ការវាស់វែងវិសមភាព

មានកត្តាធំៗចំនួន ៣ ដែលធ្វើឲ្យគេពិបាកវាស់វែងវិសមភាពក្នុងវិស័យអប់រំ។ ទីមួយ គេអាចពិនិត្យលើបញ្ហាវិសមភាព ផ្អែកទៅតាមសូចនាករជាច្រើន ដូចជា សូចនាករពាក់ព័ន្ធនឹងការទទួលបានសេវា ឬការរៀនសូត្រ ជាដើម។ ទីពីរ គេអាចប្រើប្រាស់ការវាស់វែងវិសមភាព ដើម្បីពិនិត្យមើលថាតើសូចនាករអប់រំមួយបានក្ដោបលើប្រជាជនទាំងអស់ដែរឬទេ ជាពិសេស អ្នកដែលមានប្រៀប និងអ្នកដែលជួបការលំបាក។ ការវាស់វែងផ្សេងៗពីគ្នា អាចធ្វើឲ្យគេទាញចេញនូវសេចក្ដីសន្និដ្ឋានអំពីកម្រិតនៃវិសមភាព និងការប្រែប្រួលបញ្ហាវិសមភាពក្នុងរយៈពេលមួយ ផ្សេងៗគ្នាដែរ។ ទីបី អ្នកតាក់តែងគោលនយោបាយចាំបាច់ត្រូវដឹងថាតើសូចនាករមួយមានការប្រែប្រួលទៅតាមលក្ខណៈរបស់វា ដូចជា ទ្រព្យធន ជាដើម យ៉ាងដូចម្ដេចខ្លះ ប៉ុន្តែជារឿយៗ គេមានការលំបាកក្នុងការប្រៀបធៀបលក្ខណៈទាំងនេះរវាងប្រទេសមួយ និងប្រទេសមួយទៀតណាស់។

> “ក្នុងប្រទេសដែលមានចំណូលទាប រៀងរាល់យុវជនមកពីគ្រួសារដែលមានជីវភាពធូរធាជាងគេ ១០០ នាក់ ដែលបានបញ្ចប់ការសិក្សានៅកម្រិតបឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ មានយុវជនមកពីគ្រួសារក្រីក្រជាងគេត្រឹមតែ ៣៦ នាក់ប៉ុណ្ណោះ ដែលបានរៀនចប់បឋមសិក្សា ១៩ នាក់ រៀនចប់មធ្យមសិក្សាបឋមភូមិ និង ៧ នាក់ រៀនចប់មធ្យមសិក្សាទុតិយភូមិ។”

ក្រុមអ្នកជំនាញអន្តរស្ថាប័ន ដែលទទួលខុសត្រូវលើការរៀបចំសូចនាករ SDG បានលើកស្នើឲ្យមានការប្រើប្រាស់សន្ទស្សន៍យុគភាព (parity index) ជារង្វាស់ សម្រាប់វាស់វែងវិសមភាពក្នុងការអប់រំក្នុងសកលលោកទាំងមូល។ រង្វាស់នេះ ជារង្វាស់ងាយស្រួលផ្ដល់ព័ត៌មានបំផុត ដល់មនុស្សទូទៅ ហើយកន្លងមក គឺជារង្វាស់ដែលមានប្រសិទ្ធភាពសម្រាប់រៀបរាប់ពីបញ្ហាអយុគភាពយេនឌ័រ ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ។ ក្នុងចំណោមលក្ខណៈផ្សេងៗ ដែលគេអាចយករង្វាស់នេះទៅប្រើប្រាស់ អយុគភាពខាងទ្រព្យធនមានលក្ខណៈធ្ងន់ធ្ងរជាងគេ។ ក្នុងប្រទេសចំណូលមធ្យមកម្រិតខ្ពស់ សន្ទស្សន៍យុគភាពទ្រព្យធនសម្រាប់អត្រានៃការបញ្ចប់ការសិក្សាគឺ ០,៩០ សម្រាប់បឋមសិក្សា ០,៧១ សម្រាប់មធ្យមសិក្សាបឋមភូមិ និង ០,៤៤ សម្រាប់មធ្យមសិក្សាទុតិយភូមិ។ ក្នុងប្រទេសដែលមានចំណូលទាប សន្ទស្សន៍យុគភាពទ្រព្យធនគឺ ០,៣៦ សម្រាប់បឋមសិក្សា ០,១៩ សម្រាប់មធ្យមសិក្សាបឋមភូមិ និង ០,០៧ សម្រាប់មធ្យមសិក្សាទុតិយភូមិ។

ការបង្កើតក្រុមអន្តរស្ថាប័នទទួលបន្ទុករៀបចំសូចនាករវាស់វែងវិសមភាពក្នុងការអប់រំ គឺជាជំហានមួយក្នុងទិសដៅត្រឹមត្រូវ ដោយសារតែក្រុមនេះអាចបង្កលក្ខណៈឲ្យគេធ្វើការវិភាគប្រកបដោយសង្គតភាពលើទិន្នន័យដែលបានពីការអង្កេត និងធ្វើការប្រមូលផ្ដុំប្រភពទិន្នន័យដែលមិនត្រូវបានគេប្រើប្រាស់កន្លងមក។ វឌ្ឍនភាពនៃការសម្របសម្រួលនៅកម្រិតសកល ចាំបាច់ត្រូវតែបម្លែងជាវឌ្ឍនភាពដូចគ្នានៅកម្រិតប្រទេស។

## យេនឌ័រ

មានការសម្រេចបានយុគភាពទូទាំងសកលលោកក្នុងឆ្នាំ ២០១៤ សម្រាប់ការអប់រំកម្រិតបឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ បើទោះបីជាមានក្នុងចំណោមប្រទេសទាំងអស់ មានប្រទេសត្រឹមតែ ៦៤% ប៉ុណ្ណោះ ដែលសម្រេចបានយុគភាពនៅកម្រិតបឋមសិក្សា ៤៦% នៅកម្រិតមធ្យមសិក្សាបឋមភូមិ និង ២៣% នៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ លើសពីនេះ ការបង្ហាញ

ពីអគ្រាមធ្យម មិនបង្ហាញឲ្យឃើញពីបញ្ហាអយុត្តិភាពក្នុងប្រទេស និងបញ្ហាអយុត្តិភាពរវាងក្រុមមួយ និងក្រុមមួយទៀតឡើយ។ ប្រទេសអាហ្វ្រិចសាប់សាហារ៉ា រាយការណ៍ពីយុត្តិភាពយេនឌ័ររបស់អ្នកដែលបានបញ្ចប់ការអប់រំបឋមសិក្សា ក្នុងចំណោមអ្នកដែលមានជីវភាពធូរធាជាងគេ ២០% ខណៈពេលដែលក្នុងចំណោមអ្នកដែលមានជីវភាពក្រីក្រជាងគេ ២០% វិញ រៀងរាល់ក្មេងប្រុស ១០០ នាក់ មានក្មេងស្រីតែ ៨៣ នាក់ប៉ុណ្ណោះ ដែលបានរៀនចប់បឋមសិក្សា។ អយុត្តិភាពនេះមានការកើនឡើងបន្ថែមទៀត៖ រៀងរាល់ក្មេងប្រុស ១០០ នាក់ មានក្មេងស្រីតែ ៧៣ នាក់ប៉ុណ្ណោះ ដែលបានរៀនចប់មធ្យមសិក្សាបឋមភូមិ និង ៤០ នាក់ រៀនចប់មធ្យមសិក្សាទុតិយភូមិ។

ការប្រើប្រាស់សន្ទស្សន៍យុត្តិភាព ដើម្បីពិនិត្យតាមដានទិដ្ឋភាពយេនឌ័រក្នុងចំណុចដៅ ៤.៥ ផ្តោតលើសពីអត្រាសិក្សាទៅទៀត ដោយគ្របដណ្តប់លើគ្រប់សូចនាករអប់រំទាំងអស់ រាប់បញ្ចូលទាំងលទ្ធផលនៃការរៀនសូត្រផង។ ខណៈពេលដែលនេះជាចំណុចវិជ្ជមាន សន្ទស្សន៍នេះផ្តោតតែលើផ្នែកមួយ ក្នុងចំណោមផ្នែកនានាជាច្រើននៃសមភាពយេនឌ័រ ក្នុងការអប់រំតែប៉ុណ្ណោះ។ ដើម្បីឲ្យការពិនិត្យតាមដានសមភាពយេនឌ័រក្នុងការអប់រំកាន់តែមានលក្ខណៈល្អប្រសើរជាងមុនគេជាចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់លើការប្រមូលទិន្នន័យឲ្យបានកាន់តែគ្រប់ជ្រុងជ្រោយថែមទៀតលើទិដ្ឋភាពយេនឌ័រក្នុងកម្មវិធីសិក្សា សៀវភៅសិក្សា ការវាយតម្លៃ និងការអប់រំគ្រូ ហើយចាំបាច់ត្រូវតែមានការសហការគ្នាបន្ថែមទៀតរវាងអ្នកដែលធ្វើការងារពាក់ព័ន្ធនឹងសូចនាករសមភាពយេនឌ័រក្នុងការអប់រំ និងសូចនាករសមភាពយេនឌ័រនៅកម្រិតទូលំទូលាយជាងនេះ។

**តារាងទី ២**

**សន្ទស្សន៍យុត្តិភាពយេនឌ័រ បែងចែកតាមក្រុមចំណូលតាមតំបន់ និងប្រទេស ឆ្នាំ ២០១៤**

| | ការអប់រំកម្រិតបឋមសិក្សា | | ការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ | | ការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ | |
|---|---|---|---|---|---|---|
| | សន្ទស្សន៍យុត្តិភាព យេនឌ័រ | ប្រទេសដែលមានយុត្តិភាព (%) | សន្ទស្សន៍យុត្តិភាពយេនឌ័រ | ប្រទេសដែលមានយុត្តិភាព (%) | សន្ទស្សន៍យុត្តិភាពយេនឌ័រ | ប្រទេសដែលមានយុត្តិភាព (%) |
| ពិភពលោកទាំងមូល | 0.99 | 64 | 0.99 | 46 | 0.98 | 23 |
| ចំណូលទាប | 0.93 | 31 | 0.86 | 9 | 0.74 | 5 |
| ចំណូលមធ្យមកម្រិតទាប | 1.02 | 52 | 1.02 | 33 | 0.93 | 17 |
| ចំណូលមធ្យមកម្រិតខ្ពស់ | 0.97 | 68 | 1.00 | 60 | 1.06 | 22 |
| ចំណូលខ្ពស់ | 1.00 | 83 | 0.99 | 59 | 1.01 | 37 |
| តំបន់ខៅខាស៊ុស និងអាស៊ីភាគកណ្តាល | 0.99 | 100 | 0.99 | 83 | 0.98 | 29 |
| អាស៊ីបូព៌ា និងអាស៊ីអាគ្នេយ៍ | 0.99 | 93 | 1.01 | 57 | 1.01 | 37 |
| អឺរ៉ុប និងអាមេរិចភាគខាងជើង | 1.00 | 86 | 0.99 | 67 | 1.01 | 31 |
| អាមេរិចឡាទីន និងការ៉ាប៊ៀន | 0.98 | 48 | 1.03 | 39 | 1.13 | 19 |
| អាហ្វ្រិចខាងជើង និងអាស៊ីភាគខាងលិច | 0.95 | 56 | 0.93 | 46 | 0.96 | 33 |
| ប៉ាស៊ីហ្វិច | 0.97 | 67 | 0.95 | 44 | 0.94 | 0 |
| អាស៊ីភាគខាងត្បូង | 1.06 | 29 | 1.04 | 25 | 0.94 | 38 |
| ធូរធាជាងគេ | 0.93 | 38 | 0.88 | 19 | 0.82 | 6 |

សម្គាល់៖ រាល់តម្លៃទាំងអស់ដែលបង្ហាញនេះគឺជាតម្លៃមធ្យម។

ប្រភព៖ មូលដ្ឋានទិន្នន័យរបស់ UIS

**រូបភាពទី ១១៖**
**យុគភាពយេនឌ័រមានកម្រិតខ្ពស់ក្នុងចំណោមអ្នកដែលមានជីវភាពក្រីក្រជាងគេ**
សន្ទស្សន៍យុគភាពយេនឌ័រ សម្រាប់សូចនាករអប់រំមួយចំនួន ដោយភ្ជាប់ទំនាក់ទំនងជាមួយនឹងទ្រព្យធន បែងចែកតាមតំបន់ ២០០៨-២០១៤




សម្គាល់៖ តម្លៃសម្រាប់អាស៊ីបូព៌ា និងអាស៊ីអាគ្នេយ៍ និងសម្រាប់អាហ្វ្រិចភាគខាងជើង និងអាស៊ីភាគខាងលិច សំដៅតែលើប្រទេសដែលមានចំណូលពីទាបទៅមធ្យមប៉ុណ្ណោះ
ប្រភព៖ ការវិភាគរបស់ក្រុមរៀបចំរបាយការណ៍ GEM (២០១៦) ផ្អែកតាមទិន្នន័យដែលបានពីការអង្កេតតាមគ្រួសារ

## ពិការភាព

ការកំណត់ពីវិវឌ្ឍនភាពជុំវិញសមភាពនៃការទទួលបានការអប់រំរបស់ជនពិការ ទាមទារឲ្យមានការវាស់វែងពិការភាព ដែលអាចឲ្យគេប្រៀបធៀបជាលក្ខណៈអន្តរជាតិ ប៉ុន្តែពិការភាពមានច្រើនទម្រង់។ បើតាមការវាស់វែងមួយបែប ក្នុងឆ្នាំ ២០១០ ក្នុងចំណោមប្រព័ន្ធអប់រំចំនួន ៣០ នៅអឺរ៉ុប ៣,៧% នៃកុមារដែលទទួលបានការអប់រំដែលតម្រូវតាមច្បាប់ ត្រូវបានចាត់ទុកថាជាកុមារដែលមានតម្រូវការអប់រំពិសេស។ យូនីសេហ្វ និងក្រុមវ៉ាស៊ីងតោនដែលទទួលបន្ទុកស្ថិតិពិការភាព កំពុងដឹកនាំកិច្ចខិតខំប្រឹងប្រែង ដើម្បីបង្កើតនូវរង្វាស់ពិការភាពដែលគេងាយស្រួលយកទៅប្រើប្រាស់។ អ្វីដែលសំខាន់ផងដែរគឺត្រូវពិនិត្យតាមដានថាតើអ្នកផ្តល់ការអប់រំបានរៀបចំខ្លួនបានល្អដែរឬទេ និងថាតើហេដ្ឋារចនាសម្ព័ន្ធសាលារៀនត្រូវបានកែសម្រួលបានល្អ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកសិក្សាដែលជាជនពិការ។

## ភាសា

ការបន្តមិនអើពើលើការអប់រំពហុភាសា ដោយយកភាសាកំណើតជាគោល អាចជាមូលហេតុ ដែលនាំឲ្យមានគម្លាតគ្នាដ៏ធំនៃលទ្ធផលនៃការអប់រំ។ ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីពិនិត្យតាមដានគោលនយោបាយស្តីពីការប្រើប្រាស់ភាសា ក្នុងការអប់រំ។ ដោយប្រើប្រាស់រង្វាស់មួយបែប ក្នុងពិភពលោកទាំងមូល មានប្រជាពលរដ្ឋប្រមាណជា ៤០% ដែលមិនបានទទួលការបង្រៀនដោយប្រើប្រាស់ភាសា ដែលពួកគេនិយាយ ឬយល់។ ការពិនិត្យតាមដានឯកសារគោលនយោបាយនៅថ្នាក់ជាតិ មិនអាចផ្តល់ព័ត៌មានឲ្យដឹងថាតើសិស្សបានទទួលឯកសារបង្រៀន និងរៀនជាភាសាកំណើតរបស់ពួកគេ ថាតើគ្រូបានទទួលការត្រៀមខ្លួន ឬមានការអនុវត្តគោលនយោបាយផ្លូវការនៅនឹងមូលដ្ឋានផ្ទាល់ ឬអត់នោះទេ។ ក្នុងតំបន់ Mopti នៃប្រទេសម៉ាលី មានសាលាបឋមសិក្សាតែ ១% ប៉ុណ្ណោះ ដែលផ្តល់ការបង្រៀនពីរភាសា ដោយប្រើប្រាស់ភាសាសមស្រប និងដោយគ្រូដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ បើទោះបីជាមានគោលនយោបាយជាតិក៏ដោយ។

## ការធ្វើចំណាកស្រុក និងការបង្ខំឲ្យចាកចេញពីទីលំនៅ

បើទោះបីជាគេជួបបញ្ហាក្នុងការបំពេញទៅតាមតម្រូវការរបស់ជនចំណាកស្រុកនៅជនបទ ដែលតែងផ្លាស់ទៅនៅតាមតំបន់ក្រីក្រ ឬតំបន់ជាយក្រុង ដែលមានសាលារៀនសាធារណៈក្នុងចំនួនតិចតួចក៏ដោយ ជាទូទៅ ការធ្វើចំណាកស្រុកទៅកាន់តំបន់ប្រជុំជនតែងបង្កលក្ខណៈងាយស្រួលឲ្យគេអាចទទួលបានសេវាសាធារណៈ។ ក្នុងករណីអ្នកធ្វើចំណាកស្រុកឆ្លងប្រទេសវិញ បញ្ហាប្រឈម ដែលអ្នកតាក់តែងគោលនយោបាយតែងប្រឈមគឺថាសិស្សទាំងនេះច្រើនប្រមូលផ្តុំ នៅតាមសាលារៀនក្នុងតំបន់ជួបការលំបាក។

> “ក្នុងពិភពលោកទាំងមូល ៥០% នៃជនភៀសខ្លួន ដែលដល់អាយុចូលរៀននៅបឋមសិក្សា និង ៧៥% នៃជនភៀសខ្លួន ដែលដល់អាយុចូលរៀននៅមធ្យមសិក្សា កំពុងនៅក្រៅសាលា។”

បញ្ហាប្រឈមធំជាងគេ គឺពាក់ព័ន្ធជាមួយនឹងអ្នកដែលត្រូវបានគេបង្ខំឲ្យចាកចេញពីលំនៅដ្ឋាន។ ប្រជាពលរដ្ឋដែលគ្មានផ្ទះសម្បែងត្រឹមត្រូវក្នុងប្រទេសរបស់ខ្លួន គឺជាអ្នកដែលគេមើលមិនឃើញ។ ក្នុងជំរុំចំនួន ១៩ ក្នុងចំណោមជំរុំចំនួន ៤២ សម្រាប់អ្នកដែលគ្មានផ្ទះសម្បែង ក្នុងរដ្ឋចំនួន ៦ ក្នុងប្រទេសនីហ្សេរីយ៉ា ក្នុងខែ មិថុនា ឆ្នាំ ២០១៥ កុមារពុំបានទទួលការអប់រំក្នុងប្រព័ន្ធ ឬក្រៅប្រព័ន្ធឡើយ។ ជនភៀសខ្លួន គឺជាក្រុមដែលងាយរងគ្រោះជាងគេ៖ ក្នុងពិភពលោកទាំងមូល ៥០% នៃជនភៀសខ្លួន ដែលដល់អាយុចូលរៀននៅបឋមសិក្សា និង ៧៥% នៃជនភៀសខ្លួន ដែលដល់អាយុចូលរៀននៅមធ្យមសិក្សា កំពុងនៅក្រៅសាលា។ ការពិនិត្យតាមដានលើស្ថានភាពនៃការអប់រំជនចំណាកស្រុក និងជនដែលត្រូវបានបង្ខំឲ្យចាកចេញពីផ្ទះសម្បែងរបស់ខ្លួន គឺជាការងារមួយដ៏ពិបាក។ ចាំបាច់ត្រូវមានការបង្កើនកិច្ចខិតខំប្រឹងប្រែងដែលមានការសម្របសម្រួលបានល្អ ដើម្បីយល់ឲ្យកាន់តែច្បាស់ពីគម្លាតក្នុងការទទួលបានការអប់រំរបស់ពួកគេ។




# អក្ខរកម្ម និងចំណេះដឹងលេខនព្វន្ត

### គោលដៅ ៤.៦

តាមរយៈចំណុចដៅ ៤.៦ សហគមន៍អន្តរជាតិនៅតែបន្តផ្តោតការយកចិត្តទុកដាក់លើអក្ខរកម្មមនុស្សពេញវ័យ ដែលជាផ្នែកមួយនៃគោលដៅអប់រំសម្រាប់ទាំងអស់គ្នាទីបួន និងបានបញ្ចូលនូវគំនិតថ្មីចំនួនពីរ។ ទីមួយ សូចនាករសកលអំពីអក្ខរកម្ម និងចំណេះដឹងលេខនព្វន្ត ត្រូវបានរៀបចំឡើង ដើម្បីសំដៅលើភាពស្ទាត់ជំនាញខាងជំនាញអ្វីមួយ។ ចំណុចនេះពាក់ព័ន្ធជាមួយនឹងទស្សនៈមួយ ដែលចាត់ទុកអក្ខរកម្មថាមិនត្រឹមតែជាជំនាញចំណេះដឹងជាមូលដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែវាក៏សំដៅលើសមត្ថភាពប្រើប្រាស់ជំនាញទាំងនេះ ដើម្បីរួមចំណែកដល់សង្គម សេដ្ឋកិច្ច និងធ្វើឲ្យមានការផ្លាស់ប្តូរនៅកម្រិតបុគ្គលផងដែរ។ ទីពីរ ការលើកឡើងយ៉ាងជាក់ច្បាស់ពីចំណេះដឹងលេខនព្វន្តបែបនេះ ជាការអំពាវនាវឲ្យមានការផ្តោតការយកចិត្តទុកដាក់លើលក្ខណៈលំអិតនៃចំណេះដឹងលេខនព្វន្ត។

## ការចូលរួមក្នុងកម្មវិធីអក្ខរកម្មមនុស្សពេញវ័យ

ការវាស់វែងការចូលរួមរបស់មនុស្សពេញវ័យ ក្នុងកម្មវិធីអក្ខរកម្មក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ គឺជាការងារដែលពិបាក។ របាយការណ៍សកលស្តីពីការរៀនសូត្រ និងការអប់រំមនុស្សពេញវ័យ ចាំបាច់ត្រូវបង្កើតនូវទម្រង់គំរូសម្រាប់រាយការណ៍មួយដែលមានលក្ខណៈស្តង់ដាដែលអាចប្រមូលព័ត៌មានយ៉ាងហោចណាស់ពីការចូលរួមរបស់មនុស្សពេញវ័យក្នុងកម្មវិធីអក្ខរកម្មដែលរៀបចំ ឬគាំទ្រដោយរដ្ឋ។

ការវិភាគថ្មី ដែលធ្វើឡើង សម្រាប់របាយការណ៍ GEM នេះ បានប្រើប្រាស់សំណួរមួយ ដែលគេធ្លាប់ដាក់បញ្ចូលកន្លងមកក្នុងការអង្កេតប្រជាសាស្ត្រ និងសុខភាព។ ការវិភាគនេះបង្ហាញថា ចន្លោះពីឆ្នាំ ២០០៤ ដល់ ២០១១ មានមនុស្សពេញវ័យអាយុពី ១៥ ដល់ ៤៩ ឆ្នាំ តែ ៦% ប៉ុណ្ណោះ ដែលធ្លាប់បានចូលរួមក្នុងកម្មវិធីអក្ខរកម្ម ក្នុងប្រទេសដែលមានចំណូលទាប និងមធ្យមចំនួន ២៩។ មនុស្សពេញវ័យមិនចេះអក្សរភាគច្រើន គឺជាស្ត្រី និងជាអ្នកដែលមានជីវភាពក្រីក្រ ប៉ុន្តែមានមនុស្សពេញវ័យមិនចេះអក្សរជាបុរស និងអ្នកដែលមានជីវភាពរស់នៅជាច្រើននាក់បានចូលរួមក្នុងកម្មវិធីបែបនេះ។

## អក្ខរកម្ម

បើទោះបីជារបៀបវារៈ SDG បានផ្លាស់ទៅផ្តោតការយកចិត្តទុកដាក់លើការវាស់វែងភាពស្ទាត់ជំនាញខាងជំនាញអក្ខរកម្មយ៉ាងណាក៏ដោយ ឧបករណ៍ដែលចាំបាច់សម្រាប់ធ្វើការវាស់វែងភាពស្ទាត់ជំនាញទាំងនេះពុំអាចរកបានឲ្យបានទូលំទូលាយឡើយ ដូច្នេះនៅមានការបន្តរាយការណ៍ពីអត្រាអក្ខរកម្មយុវជន និងមនុស្សពេញវ័យ ដោយប្រើប្រាស់អត្រាអក្ខរកម្មដែលធ្លាប់តែប្រើប្រាស់កន្លងមកដដែល។ ចន្លោះពីឆ្នាំ ២០០៥ ដល់ ២០១៤ មានមនុស្សពេញវ័យប្រមាណជា ៧៥៨ លាននាក់ ឬ ១៥% នៃមនុស្សពេញវ័យក្នុងសកលលោកទាំងមូល នៅខ្វះជំនាញអក្ខរកម្មវិជ្ជាជីវៈ ដែលក្នុងនោះមាន ៦៣% ជាស្ត្រី។

## ភាពស្ទាត់ជំនាញខាងអក្ខរកម្ម និងចំណេះដឹងលេខនព្វន្ធ

ព័ត៌មានអំពីកម្រិតស្ទាត់ជំនាញខាងអក្ខរកម្ម និងចំណេះដឹងលេខនព្វន្ធ ដែលត្រូវបានគេវាយតម្លៃដោយផ្ទាល់ គឺជាព័ត៌មានដែលអាចរកបាន ក្នុងប្រទេសដែលមានចំណូលខ្ពស់ជាច្រើន។ ក្នុងចំណោមអ្នកចូលរួមក្នុងកម្មវិធីវាយតម្លៃអន្តរជាតិលើសមត្ថភាពមនុស្សពេញវ័យ (PIAAC) របស់អង្គការ OECD ១៥% ពុំមានភាពស្ទាត់ជំនាញខាងអក្ខរកម្មជាមូលដ្ឋានទៅតាមស្តង់ដា ដែលតម្រូវឲ្យពួកគេទាញសេចក្តីសន្និដ្ឋានកម្រិតទាបពីអត្ថបទនោះទេ។ អត្រានេះមានចាប់ពីក្រោម ៥% ក្នុងប្រទេសជប៉ុនរហូតដល់ជិត ២៨% ក្នុងប្រទេសអ៊ីតាលី។ ចាំបាច់ត្រូវមានការសហការគ្នាជាអន្តរជាតិ ដើម្បីបង្កលក្ខណៈឲ្យគេអាចធ្វើការវាយតម្លៃលើចំណេះដឹងអក្ខរកម្ម និងលេខនព្វន្ធ ដែលអាចធ្វើការប្រៀបធៀបគ្នាបាន។ ដើម្បីផ្តល់ទិន្នន័យពិនិត្យតាមដានដែលមានប្រយោជន៍ត្រឹមឆ្នាំ ២០៣០ វិធីសាស្ត្រដែលជោគជ័យ គឺត្រូវថ្លឹងថ្លែងសមត្ថភាពរបស់ប្រទេសនានា ក្នុងប្រើប្រាស់ការវាស់វែងដែលមានក្នុងប្រទេសរបស់ខ្លួន និងភាពចាំបាច់ សម្រាប់ធ្វើការវាយតម្លៃដើម្បីបំពេញទៅតាមស្តង់ដាសកល។

**រូបភាពទី ១២៖**

**ការវាយតម្លៃលើអក្ខរកម្មដោយប្រើប្រាស់កម្រិតបន្តបន្ទាប់គ្នា អាចឆ្លុះបញ្ចាំងពីជំនាញរបស់មនុស្សពេញវ័យបានសុក្រិតជាង**

ចំនួនមនុស្សពេញវ័យ បែងចែកទៅតាមកម្រិតស្ទាត់ជំនាញខាងអក្ខរកម្ម ២០១១-២០១៤




សម្គាល់៖ សម្រាប់ប្រទេសដែលមានសញ្ញាផ្កាយ ( * ) ទិន្នន័យ PIAAC សំដៅតែលើតំបន់នីមួយៗតែប៉ុណ្ណោះ៖ ប្រទេសអង់គ្លេស និងអៀរឡង់ភាគខាងជើង សម្រាប់ចក្រភពអង់គ្លេស និង Flanders សម្រាប់ប្រទេសបែលហ្ស៊ិក

ប្រភព៖ OECD (2013; 2016) និងការវិភាគរបស់ក្រុមរៀបចំរបាយការណ៍ GEM ដោយប្រើប្រាស់ទិន្នន័យ STEP របស់ធនាគារពិភពលោក

# ការអភិវឌ្ឍប្រកបដោយចីរភាព និងភាពជាប្រជាពលរដ្ឋសកល

## គោលដៅ ៤.៧

ចំណុចដៅ ៤.៧ ផ្តោតលើទិដ្ឋភាពសង្គម មនុស្ស និងសីលធម៌ នៃការអប់រំ ច្រើនជាងចំណុចដៅផ្សេងទៀត។ ចំណុចដៅនេះភ្ជាប់ទំនាក់ទំនងការអប់រំ ជាមួយនឹងគោលដៅ SDG ដទៃទៀត និងក្តោបលើបំណងប្រាថ្នាដែលចង់ឲ្យមានការផ្លាស់ប្តូរ នៃរបៀបវារៈអភិវឌ្ឍន៍សកលថ្មីនេះ។

របាយការណ៍ GEM នេះ ផ្តោតលើសូចនាករសកលដែលត្រូវបានស្នើឡើង និងធ្វើការពិនិត្យលើរបៀបដែលភាពជាពលរដ្ឋសកល និងការអភិវឌ្ឍប្រកបដោយចីរភាព ត្រូវបានបញ្ចូលទៅក្នុងអន្តរាគមន៍ក្នុងប្រព័ន្ធអប់រំទាំងមូល ក្នុងឯកសារកម្មវិធីសិក្សានានា ដូចជាក្របខ័ណ្ឌកម្មវិធីសិក្សាជាតិ និងសៀវភៅសិក្សាជាដើម និងក្នុងកម្មវិធីអប់រំគ្រូ។

ការកំណត់រកសូចនាករ សម្រាប់ពិនិត្យតាមដានចំណេះដឹង ជំនាញ និងឥរិយាបថ ដែលចាំបាច់ត្រូវមាន ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព គឺជាការងារមួយដ៏សែនពិបាក។ របាយការណ៍នេះពិនិត្យលើគំនិតផ្តួចផ្តើមនានា ដែលគេអាចប្រើប្រាស់ សម្រាប់ពិនិត្យតាមដានលើការទទួលបានចំណេះដឹង និងជំនាញដែលពាក់ព័ន្ធ ក៏ដូចជាលើឥរិយាបថរបស់យុវជន និងមនុស្សពេញវ័យ។

ចំណុចដៅ ៤.៧ មានទំនាក់ទំនងយ៉ាងជិតស្និទជាមួយនឹងក្របខ័ណ្ឌនៃការរៀនសូត្រពេញមួយជីវិត ហើយមិនបានបញ្ជាក់ពីកម្រិតនៃការអប់រំ ឬក្រុមអាយុឡើយ។ គោលដៅ និងសូចនាករតាមប្រធានបទដែលស្នើឡើងនេះ ផ្តោតការយកចិត្តទុកដាក់ជាចម្បងលើកុមារ និងក្មេងជំទង់ ដែលចូលរួមក្នុងការអប់រំក្នុងប្រព័ន្ធ។ ពុំមានសូចនាករតាមប្រធានបទដែលត្រូវបានស្នើឡើងណាមួយលើកឡើងជាក់លាក់ពីមនុស្សពេញវ័យដែលជាអ្នករៀនសូត្រ ក្នុងប្រព័ន្ធអប់រំក្រៅប្រព័ន្ធ និងក្រៅផ្លូវការនោះទេ។

### កម្មវិធីសិក្សា

កម្មវិធីសិក្សា គឺជាមធ្យោបាយដ៏សំខាន់ សម្រាប់ផ្តល់ចំណេះដឹង និងជំនាញ ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព និងភាពជាពលរដ្ឋសកល។ សូចនាករតាមប្រធានបទមួយ បានស្នើឲ្យមានការវាស់វែងការអនុវត្តក្របខ័ណ្ឌកម្មវិធីអប់រំសិទ្ធិមនុស្សពិភពលោក នៅថ្នាក់ជាតិ។ សូចនាករនេះក្តោបលើសមាសភាគមួយចំនួននៃចំណុចដៅ ៤.៧ ដូចជា សិទ្ធិមនុស្ស សេរីភាពជាមូលដ្ឋាន និងការអធ្យាស្រ័យគ្នា ។ល។

សូចនាករតាមប្រធានបទដែលត្រូវបានលើកស្នើមួយទៀត សម្រាប់ចំណុចដៅ ៤.៧ នេះដែរ គឺភាគរយនៃសាលារៀន ដែលផ្តល់ការអប់រំបំណិនជីវិតអំពីមេរោគ/ជំងឺអេដស៍ និងរឿងភេទ ដែលជាការឆ្លើយតបចំពោះសមាសភាគទាំង ៥ នៃចំណុចដៅ ៤.៧ ពោលគឺសិទ្ធិមនុស្ស សមភាពយេនឌ័រ វប្បធម៌សន្តិភាព ភាពអហិង្សា និងចំណេះដឹង និងជំនាញ សម្រាប់លើកកម្ពស់ការអភិវឌ្ឍ និងបែបផែននៃការរស់នៅប្រកបដោយចីរភាព។ ការបញ្ចូលសូចនាករនេះទៅក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ និងការអង្កេតតាមសាលារៀន ត្រូវបានសាកល្បង នៅតាមប្រទេសមួយចំនួន ហើយនឹងផ្តល់លទ្ធភាពឲ្យគេអាចធ្វើការពិនិត្យតាមដានបានកាន់តែប្រសើរនាពេលអនាគត។

> “បីភាគបួននៃប្រទេសចំនួន ៧៨ ផ្តោតការយកចិត្តទុកដាក់ខ្លះលើបញ្ហានៃការអភិវឌ្ឍប្រកបដោយចីរភាព ក្នុងកម្មវិធីសិក្សារបស់ខ្លួន ចន្លោះពីឆ្នាំ ២០០៥ ដល់ ២០១៥។”

ការស្រាវជ្រាវបន្ថែមទៀតអំពីកម្មវិធីសិក្សាតាមមុខវិជ្ជា នឹងជួយឲ្យគេកាន់តែយល់ពីវឌ្ឍនភាពដែលសម្រេចបាន ពាក់ព័ន្ធនឹងចំណុចដៅ ៤.៧ នេះ។ ចាំបាច់ត្រូវមានបញ្ជីដែលមានលក្ខណៈជាប្រព័ន្ធ ដែលបង្ហាញពីក្របខ័ណ្ឌកម្មវិធីសិក្សាជាតិ និងឯកសារដែលពាក់ព័ន្ធនានា។ ការវិភាគលើឯកសារក្របខ័ណ្ឌកម្មវិធីជាង ១១០ ឯកសារ សម្រាប់ការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា ក្នុងប្រទេសចំនួន ៧៨ ដែលធ្វើឡើងសម្រាប់រៀបចំរបាយការណ៍ GEM នេះ បានបង្ហាញថា ចន្លោះពីឆ្នាំ២០០៥ដល់២០១៥មានប្រទេសចំនួនបីភាគបួនផ្តោតការយកចិត្តទុកដាក់ខ្លះលើបញ្ហាអភិវឌ្ឍន៍ប្រកបដោយចីរភាពប៉ុន្តែមានប្រទេស

តិចតួចប៉ុណ្ណោះ ដែលលើកឡើងពីពាក្យពេចន៍ ពាក់ព័ន្ធនឹងភាពជាពលរដ្ឋសកល។ សមភាពយេនឌ័រក៏មិនសូវជាត្រូវបានគេលើកឡើង ឡើងផងដែរ។ មានប្រទេសតិចជាង ១៥% ដែលបានបញ្ចូលពាក្យពេចន៍សំខាន់ៗ ដូចជា ការផ្តល់ភាពអង់អាចយេនឌ័រ យុគភាពយេនឌ័រ ឬការគិតគូរពីយេនឌ័រ និងមានប្រទេសពាក់កណ្តាល ដែលបានលើកឡើងពីពាក្យថាសមភាពយេនឌ័រ។

**រូបភាពទី ១៣៖**

**សិទ្ធិមនុស្ស គឺជាទស្សនទានដែលត្រូវបានលើកឡើងញឹកញាប់ជាងគេ ក្នុងកម្មវិធីសិក្សាជាតិ**

ភាគរយនៃប្រទេស ដែលបានបញ្ចូលពាក្យពេចន៍សំខាន់ៗនីមួយៗក្នុងក្របខ័ណ្ឌកម្មវិធីសិក្សាជាតិរបស់ខ្លួន ២០០៥-២០១៥




សម្គាល់៖ ការវិភាគនេះគឺផ្អែកលើសំណាកគំរូនៃប្រទេសចំនួន ៧៨

ប្រភព៖ IBE (2016)

## សៀវភៅសិក្សា

ភាពជឿនលឿនដែល សម្រេចបានក្នុងពេលថ្មីៗនេះ ជុំវិញការវិភាគលើខ្លឹមសារក្នុងសៀវភៅសិក្សា ផ្តល់នូវក្តីសង្ឃឹម សម្រាប់ការវាស់វែងខ្លឹមសារ ក្នុងកម្មវិធីសិក្សា ។ សម្រាប់របាយការណ៍ GEM នេះ មានការប្រមូលទិន្នន័យចំនួន ៣ ប្រភេទអំពីសៀវភៅសិក្សា ដែលប្រើប្រាស់នៅតាមសាលាមធ្យមសិក្សា សម្រាប់មុខវិជ្ជាប្រវត្តិវិទ្យា ពលរដ្ឋវិជ្ជា សិក្សាសង្គម និងភូមិវិទ្យា។ ការវិភាគបានបង្ហាញថា ចន្លោះពីឆ្នាំ ២០០០ ដល់ ២០១៣ មានសៀវភៅសិក្សាជិត ៥០% បានលើកឡើងពីសិទ្ធិមនុស្ស បើធៀបជាមួយនឹងប្រមាណជា ៥% ចន្លោះពីឆ្នាំ ១៨៩០ ដល់ ១៩១៣។ សម្រាប់អាហ្វ្រិចភាគខាងជើង និងអាស៊ីភាគខាងលិចវិញ មានសៀវភៅសិក្សាជាង ១០% បន្តិចប៉ុណ្ណោះ ដែលបានលើកឡើងពីសិទ្ធិស្ត្រីក្នុងទសវត្សរ៍ចុងក្រោយនេះ។ ការវិភាគនេះបង្ហាញថា គេអាចបង្កើតរង្វាស់ ដែលមានសុពលភាព និងអាចជឿទុកចិត្តបាន ដោយប្រើប្រាស់សៀវភៅសិក្សា។ គួរមានការបង្កើតនូវយន្តការពិនិត្យតាមដានជាប្រចាំមួយ ដើម្បីផ្តល់នូវទិន្នន័យអំពីខ្លឹមសារក្នុងសៀវភៅសិក្សាដែលគេអាចឲ្យគេប្រៀបធៀបជាលក្ខណៈសកលបាន។

## ការអប់រំគ្រូ

គួរមានការត្រៀមរៀបចំគ្រូ ឲ្យបានល្អ ដើម្បីឲ្យពួកគេអាចបង្រៀនប្រធានបទ ដែលពាក់ព័ន្ធជាមួយនឹងការអភិវឌ្ឍ ប្រកបដោយចីរភាព និងភាពជាពលរដ្ឋសកលបាន។ ក្នុងចំណោមប្រទេសចំនួន ៦៦ ដែលត្រូវបានអង្កេត មានតែ ៨% ប៉ុណ្ណោះ ដែលបានបញ្ចូលការអភិវឌ្ឍ ប្រកបដោយចីរភាព ក្នុងការអប់រំគ្រូ ក្នុងឆ្នាំ ២០១៣ ដែលតួលេខនេះកើនឡើងពី ២% ក្នុងឆ្នាំ ២០០៥ មក។ ខ្លឹមសារនៃកម្មវិធីបណ្តុះបណ្តាលគ្រូកម្រនឹងអាចរកបានណាស់ ប៉ុន្តែកន្លងមកមានការប្រមូលព័ត៌មានមួយចំនួន ភាគច្រើននៅ

ថ្នាក់តំបន់។ ចាំបាច់ត្រូវមានការបង្កើនកិច្ចខិតខំប្រឹងប្រែងជាបន្ទាន់ ដើម្បីធ្វើការវាយតម្លៃលើទស្សនទានក្នុងចំណុចដៅ ៤.៧ ដែលពាក់ព័ន្ធជាមួយនឹងការរៀបចំ និងការបណ្ដុះបណ្ដាលគ្រូនេះ។ ការប្រើប្រាស់វិធីសាស្ត្រដាក់លេខកូដតាមស្តង់ដា ក្នុងកម្មវិធីសិក្សារបស់គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូ នឹងអាចឲ្យគេធ្វើការវិភាគលើស័ក្តិសិទ្ធិភាពនៃការអភិវឌ្ឍវិជ្ជាជីវៈ ក្នុងការត្រៀមរៀបចំគ្រូឲ្យចេះឆ្លើយតបចំពោះតម្រូវការផ្សេងៗនៃសហគមន៍សិស្ស។

## សកម្មភាពខាងក្រៅថ្នាក់រៀន

សិស្សទទួលបានការយល់ដឹងពីប្រធានបទនិរន្តរភាព និងភាពជាពលរដ្ឋសកលនេះ មិនត្រឹមតែក្នុងសាលារៀនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងតាមរយៈក្លឹបសិក្សា សមាគមសិស្ស ក្លឹបកីឡា ក្លឹបជជែកពិភាក្សា ក្លឹបសិល្បៈ ក្រុមតន្ត្រី ការងារស្ម័គ្រចិត្ត និងសកម្មភាពផ្សេងទៀតផង។ ការវិភាគ ដែលធ្វើឡើងសម្រាប់របាយការណ៍ GEM នេះ បានរកឃើញថា សកម្មភាពបែបបរិយាប័ន្ន ដែលត្រូវបានរៀបចំត្រឹមត្រូវ ដែលសិស្សគ្រប់គ្នាអាចចូលរួមបាន បានជួយដោះស្រាយជម្លោះដែលបានកើតឡើង ធ្វើឲ្យភាពចុះសម្រុងគ្នាក្នុងសង្គម បង្កើនការយល់ដឹងពីក្របខ័ណ្ឌច្បាប់ និងទស្សនទានពាក់ព័ន្ធនឹងសិទ្ធិមនុស្ស និងបណ្ដុះស្មារតីភាពជាពលរដ្ឋសកល។ ឧបករណ៍ប្រមូលទិន្នន័យដែលមានស្រាប់ មិនបានផ្ដោតការយកចិត្តទុកដាក់គ្រប់គ្រាន់លើគុណភាពនៃបទពិសោធន៍ និងដំណើរការអភិវឌ្ឍ ក្នុងសកម្មភាពទាំងនេះឡើយ។ ការពុំមានស្តង់ដារួមសម្រាប់ធ្វើការវាយការណ៍បែបនេះ បានដាក់កំហិតមិនឲ្យគេអាចទទួលបានទិន្នន័យអាចជឿទុកចិត្តបាន ដែលអាចឲ្យគេធ្វើការប្រៀបធៀបរវាងប្រទេសមួយនិងប្រទេសមួយទៀតនៅកម្រិតសកលលោកបានឡើយ។

## លទ្ធផល

ការពិនិត្យតាមដានបំណងប្រាថ្នាស្នូលនៃចំណុចដៅ ៤.៧ - ការទទួលបានចំណេះដឹង និងជំនាញ ដែលចាំបាច់ សម្រាប់ភាពជាពលរដ្ឋសកល និងការអភិវឌ្ឍប្រកបដោយចីរភាព - មិនមែនជាការងារដែលងាយស្រួលនោះទេ។ ការយល់ដឹងកម្រិតមូលដ្ឋានពីប្រវត្តិសាស្ត្រពិភពលោក ភូមិសាស្ត្រ ស្ថាប័នអន្តរជាតិ និងដំណើរការសកល អាចជាចំណុចចាប់ផ្ដើម ប៉ុន្តែសម្រាប់ការយល់ដឹងបែបនេះ មានការវាយតម្លៃតិចតួចប៉ុណ្ណោះ។ ក្នុងប្រទេសជាច្រើន មានសិស្សតែពីរភាគបីប៉ុណ្ណោះ ដែលដឹងពីសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស។

បញ្ហាប្រឈមធំ គឺពាក់ព័ន្ធជាមួយនឹងភាពតានតឹងរវាងគុណតម្លៃនៅមូលដ្ឋាន និងការបង្កើនការប្ដេជ្ញាចិត្តនៅកម្រិតសកល។ ថ្មីៗនេះ មានការបង្កើតនូវគំនិតផ្ដួចផ្ដើម ដើម្បីកែលំអយន្តការពិនិត្យតាមដាន សម្រាប់ចំណុចដៅ ៤.៧ ពាក់ព័ន្ធជាមួយនឹងក្មេងជំទង់ជាពិសេស សម្រាប់ការអប់រំកម្រិតមធ្យមសិក្សា។ ក្នុងឆ្នាំ ២០១៦ យូណេស្កូ និងសមាគមអន្តរជាតិសម្រាប់វាយតម្លៃលើលទ្ធផលសិក្សាបានចាប់ផ្ដើមសហការគ្នាជាផ្លូវការ ដើម្បីធ្វើការវាស់វែងចំណេះដឹងអំពីភាពជាពលរដ្ឋសកល និងការអភិវឌ្ឍប្រកបដោយចីរភាព។ រង្វាស់ការរៀនសូត្រកម្រិតបឋមសិក្សានៅអាស៊ីអាគ្នេយ៍ ដែលផ្ដោតលើចំណេះដឹងអំពីភាពជាពលរដ្ឋសកលនៅថ្នាក់ទី ៥ មានគោលបំណងធ្វើការវាយតម្លៃប្រៀបធៀប ឲ្យស្របតាមស្ថានភាពនៅមូលដ្ឋាន។




# សម្ភាររូបវ័ន្តសម្រាប់ការអប់រំ និងបរិយាកាសរៀនសូត្រ

## គោលដៅ ៤.ក

ចំណុចដៅ ៤.ក ទទួលស្គាល់ពីគោលការណ៍កុមារមជ្ឈមណ្ឌល ការចូលរួមបែបប្រជាធិបតេយ្យ និងបរិយាប័ន្នភាព ថាជាគោលការណ៍សាលាកុមារមេត្រី។ មិនមែនគ្រប់សមាសធាតុទាំងនេះសុទ្ធតែអាចបញ្ចូលទៅក្នុងការពិនិត្យតាមដានកម្រិតសកលបាននោះទេ ប៉ុន្តែចំណុចបីយ៉ាងដែលគេអាចពិនិត្យតាមដានបាននោះគឺហេដ្ឋារចនាសម្ព័ន្ធសាលារៀន ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ និងអំពើហិង្សា និងការវាយប្រហារតាមសាលារៀន។

> “នៅតាមប្រទេសដែលមានការអភិវឌ្ឍតិចតួច ក្នុងឆ្នាំ ២០១៣ មានសាលារៀនតែ ៥២% ប៉ុណ្ណោះ ដែលមានការផ្គត់ផ្គង់ទឹកគ្រប់គ្រាន់។”

### ហេដ្ឋារចនាសម្ព័ន្ធសាលារៀន

ការកែលំអសម្ភាររូបវ័ន្តផ្គត់ផ្គង់ទឹក និងអនាម័យ នៅតាមគ្រឹះស្ថានអប់រំ អាចមានឥទ្ធិពលជាវិជ្ជមានដល់លទ្ធផលខាងសុខភាព និងការអប់រំ។ តែទោះជាយ៉ាងណាក៏ដោយ ក្នុងឆ្នាំ ២០១៣ មានសាលាបឋមសិក្សាត្រឹមតែ ៧១% ប៉ុណ្ណោះ ដែលមានការផ្គត់ផ្គង់ទឹកស្អាតគ្រប់គ្រាន់ ហើយតួលេខនេះគឺត្រឹមតែ ៥២% ប៉ុណ្ណោះ ក្នុងប្រទេសដែលមានការអភិវឌ្ឍតិចតួចទាំង ៤៩។

នៅពេលដែលសាលារៀនពុំមានសុវត្ថិភាព ផលប៉ះពាល់ដែលបង្កឡើងដោយមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិកាន់តែធ្ងន់ធ្ងរ។ ប្រទេសមួយចំនួនធ្វើការពិនិត្យលើសុវត្ថិភាពសាលារៀនយ៉ាងល្អិតល្អន់ហើយមិនមែនគ្រប់ប្រទេសទាំងអស់សុទ្ធតែអាចធ្វើការពិនិត្យតាមដានល្អិតល្អន់បែបនេះឡើយ។ ឧបករណ៍បែបចូលរួមត្រូវបានរៀបចំឡើង ដើម្បីជួយឲ្យសិស្ស និងសហគមន៍ផ្តល់ព័ត៌មានអំពីសភាពការណ៍ក្នុងសាលារៀនផ្ទាល់។

ជនពិការចាំបាច់ត្រូវជំនះឧបសគ្គរូបវ័ន្ត និងឧបសគ្គសង្គមជាច្រើន ដើម្បីបានទៅដល់សាលារៀន។ គេពិបាកនឹងដឹងថាតើសម្ភាររូបវ័ន្តមានភាពសមស្របសម្រាប់កុមារពិការឬអត់ណាស់ ដោយសារមិនទាន់មានការកំណត់និយមន័យពីសាលារៀនដែលផ្តល់ភាពងាយស្រួលដល់ជនពិការ ហើយជារឿយៗ សមត្ថភាពពិនិត្យតាមដានក៏នៅមានកម្រិត។

### ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) តាមសាលារៀន

មូលដ្ឋាន ដែលគេប្រើប្រាស់ សម្រាប់ពិនិត្យតាមដាន ICT ក្នុងវិស័យអប់រំ គឺផែនការសកម្មភាពទីក្រុងហ្សឺណែវឆ្នាំ ២០០៣ នៃកិច្ចប្រជុំកំពូលពិភពលោកស្តីពីសង្គមព័ត៌មានវិទ្យា ដែលបានដាក់ចេញនូវចំណុចដៅចំនួនពីរ ពាក់ព័ន្ធនឹងការអប់រំ។

ការប្រើប្រាស់ ICT តាមសាលារៀន ទាមទារឲ្យមានភ្ជាប់ចរន្តអគ្គិសនីជាស្រេច។ នៅតាមប្រទេសអាហ្វ្រិចសាប់សាហារ៉ាជាច្រើន កង្វះការផ្គត់ផ្គង់អគ្គិសនី គឺជាកត្តាដែលរាំងស្ទះដល់ការប្រើប្រាស់ ICT។ នៅសាធារណរដ្ឋអាហ្វ្រិចកណ្តាល ពុំមានសាលាបឋមសិក្សា ឬមធ្យមសិក្សាណា ភ្ជាប់ទៅនឹងបណ្តាញផ្គត់ផ្គង់អគ្គិសនីរបស់រដ្ឋឡើយ។ ក្នុងប្រទេសហ្គីនី និងម៉ាដាកាស្កា កុំព្យូទ័រមួយគ្រឿង គឺសម្រាប់សិស្សជាង ៥០០ នាក់ប្រើ។

### អំពើហិង្សា និងការវាយប្រហារនៅតាមសាលារៀន

ទង្វើហិង្សា ឬការគំរាមកំហែងតាមសាលារៀន កើតមានក្នុងបរិវេណសាលារៀនផង និងតាមផ្លូវទៅសាលារៀន តាមផ្ទះ ឬតាមរយៈអ៊ីនធឺណិតផង។ ខណៈពេលដែលជាធម្មតា មានការផ្តោតការយកចិត្តទុកដាក់លើព្រឹត្តិការណ៍ធ្ងន់ធ្ងរ ដូចជា ការបាញ់ប្រហារ ជាដើម អំពើហិង្សាដែលកើតញឹកញាប់ គឺជាអំពើហិង្សា ដែលមានផលប៉ះពាល់អវិជ្ជមានជាងគេមលើការទទួលបានការអប់រំរបស់កុមារ និងក្មេងជំទង់។ អំពើហិង្សាទាំងនេះមិនត្រូវបានគេរាយការណ៍ដល់កម្រិតដែលកើតជាក់ស្តែងឡើយ ដោយសារតែជារឿយៗ អំពើហិង្សាទាំងនេះមានពាក់ព័ន្ធជាមួយនឹងបំរាមក្នុងសង្គមផងដែរ។

“មានកុមារអាយុពី ១៣ ដល់ ១៥ ឆ្នាំ ប្រមាណជា ៤០% ក្នុងប្រទេសចំនួន ៣៧ បានរាយការណ៍ថាធ្លាប់ចូលរួមក្នុងការវាយតប់គ្នា ពីឆ្នាំ ២០០៩ ដល់ ២០១២។”

ការសម្លុតគំរាម គឺជាទម្រង់នៃអំពើហិង្សា ដែលត្រូវបានគេកត់ត្រាទុកក្នុងឯកសារបានទូលំទូលាយជាងគេ ក្នុងសាលារៀន។ ក្នុងរបាយការណ៍ស្តីពីនិន្នាការនៃការសិក្សាមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រជាលក្ខណៈអន្តរជាតិ មានសិស្សថ្នាក់ទី ៨ ចំនួន ៤១% បានរាយការណ៍ថា ធ្លាប់ត្រូវបានគេសម្លុតគំរាមយ៉ាងហោចណាស់មួយដង ក្នុងខែកន្លងទៅ។ អំពើហិង្សាផ្លូវកាយក៏ឧស្សាហ៍កើតមានផងដែរ។ មានកុមារអាយុពី ១៣ ដល់ ១៥ ឆ្នាំ ប្រមាណជា ៤០% ក្នុងប្រទេសចំនួន ៣៧ បានរាយការណ៍ថាធ្លាប់ចូលរួមក្នុងការវាយតប់គ្នា ពីឆ្នាំ ២០០៩ ដល់ ២០១២។ អំពើហិង្សាផ្លូវភេទ គឺជាទម្រង់នៃអំពើហិង្សាដែលនាំឲ្យមានអន្តរាយក្នុងកម្រិតខ្ពស់ តាមសាលារៀន ហើយដែលកម្រិត និងវិសាលភាពរបស់វានៅតែជាអាថ៌កំបាំងនៅឡើយ។ ជារួម ចាំបាច់ត្រូវមានការសម្របសម្រួលដាក់សំណួរឲ្យបានប្រសើរជាងពេលកន្លងមក ក្នុងការអង្កេតអន្តរជាតិនានា ដើម្បីធានាយ៉ាងណាឲ្យការអង្កេតទាំងនេះអាចធ្វើការវាស់វែងនិន្នាការនៃអំពើហិង្សាតាមសាលារៀនក្នុងសកលលោកទាំងមូលឲ្យមានភាពស៊ីសង្វាក់គ្នា។

ការពិនិត្យតាមដានការវាយប្រហារ ពាក់ព័ន្ធនឹងការអប់រំ ក៏ជាការងារមួយដ៏សំខាន់ ដើម្បីធ្វើការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងទាមទារឲ្យជនល្មើសទទួលខុសត្រូវ។ ការយកសាលារៀនប្រើប្រាស់សម្រាប់គោលបំណងយោធា បានកើតឡើងក្នុងប្រទេសចំនួន ២៦ ចន្លោះពីឆ្នាំ ២០០៥ ដល់ ២០១៥។ ពីឆ្នាំ ២០០៩ ដល់ ២០១២ ការវាយប្រហារពាក់ព័ន្ធនឹងការអប់រំចាប់ពី ១០០០ ករណីឡើងទៅក្នុងមួយប្រទេស កើតឡើងក្នុងប្រទេសចំនួន ៦។

# អាហារូបករណ៍

## គោលដៅ ៤.ខ

ចំណុចដៅ ៤.ខ ដែលផ្តោតតែលើប្រទេសមួយចំនួន ហាក់បីដូចជាមិនស៊ីសង្វាក់ជាមួយនឹងរបៀបវារៈសកលឡើយ។ ដូចគ្នានឹងចំណុចដៅផ្សេងទៀតដែរ ចំណុចដៅនេះមានបំណងកាត់បន្ថយវិសមភាពរវាងប្រទេសមួយ និងប្រទេសមួយ ប៉ុន្តែវាអាចបង្កើនវិសមភាពរវាងក្រុមមួយ និងក្រុមមួយទៀត ក្នុងប្រទេសតែមួយទៅវិញ ដោយសារតែអ្នកទទួលបានអាហារូបករណ៍ច្រើនតែជាអ្នកដែលមិនមែនជាក្រុមជួបការលំបាក។លើសពីនេះអ្នកទទួលបានអាហារូបករណ៍ជាច្រើននាក់ពុំបានវិលត្រលប់ទៅប្រទេសរបស់ពួកគេវិញនោះទេ។ នេះអាចមានន័យថា អាហារូបករណ៍ច្រើនតែផ្តល់ការគាំទ្រដល់គ្រឹះស្ថានអប់រំឧត្តមសិក្សារបស់ប្រទេសអ្នកមាន ជាជាងផ្តល់ប្រយោជន៍ដល់ប្រទេសក្រីក្រ។

> “ព័ត៌មានដែលប្រមូលបាន សម្រាប់របាយការណ៍នេះពីកម្មវិធីអាហារូបករណ៍របស់រដ្ឋាភិបាលចំនួន ៥៤ បង្ហាញថា ក្នុងឆ្នាំ ២០១៥ មានការផ្តល់អាហារូបករណ៍ប្រមាណជា ២៥០០០ កន្លែង។”

ការរៀបចំចំណុចដៅ ៤.ខ នៅខ្វះខាតច្រើនចំណុច។ មានការលើកអនុសាសន៍ឲ្យរាប់តែអាហារូបករណ៍ណា ដែលគាំទ្រដល់ការសិក្សាតាមគ្រឹះស្ថានឧត្តមសិក្សាក្នុងប្រទេសផ្សេងពីប្រទេសកំណើតរបស់សិស្ស និងតែអាហារូបករណ៍ដែលមានការឧបត្ថម្ភខ្លះពីរដ្ឋប៉ុណ្ណោះ។

អត្រានៃការផ្លាស់ទៅរៀននៅក្រៅប្រទេស ពោលគឺចំនួននិស្សិតមកពីប្រទេសមួយ ដែលទៅសិក្សានៅក្រៅប្រទេសគិតជាភាគរយនៃចំនួន

**រូបភាពទី ១៤៖**

**សាលាបឋមសិក្សាភាគច្រើនក្នុងប្រទេសក្រីក្រជាងគេមួយចំនួនពុំមានអគ្គិសនីប្រើប្រាស់ឡើយ**

*ភាគរយនៃសាលាបឋមសិក្សា និងមធ្យមសិក្សា ដែលមានអគ្គិសនីប្រើប្រាស់ ២០០៩-២០១៤*




ប្រភព៖ មូលដ្ឋានទិន្នន័យរបស់ UIS

និស្សិតសរុបដែលរៀននៅឧត្តមសិក្សាក្នុងប្រទេសនោះ គឺ ១,៨% សម្រាប់ប្រទេសកំពុងអភិវឌ្ឍ។ ប៉ុន្តែ ក្នុងប្រទេសមួយចំនួន ជាពិសេស តាមប្រទេសដែនកោះតូចៗ ភាគរយនេះគឺខ្ពស់។ នៅ Saint Lucia ក្នុងចំណោមនិស្សិត ១០ នាក់ មាន ៥ នាក់ ទៅរៀននៅក្រៅប្រទេស។

អ្វីដែលគួរឲ្យភ្ញាក់ផ្អើល ពុំមានការសរុបទិន្នន័យអំពីចំនួនអាហារូបករណ៍ក្នុងសកលលោកទាំងមូលឡើយ ចុះទម្រាំសញ្ជាតិ ឬមុខជំនាញសិក្សារបស់អ្នកទទួលអាហារូបករណ៍ទៀតនោះ។ ព័ត៌មាន ដែលប្រមូល សម្រាប់រៀបចំរបាយការណ៍ GEM ពីកម្មវិធីអាហារូបករណ៍របស់រដ្ឋាភិបាលចំនួន ៥៤ បង្ហាញថា ក្នុងឆ្នាំ ២០១៥ មានការផ្តល់អាហារូបករណ៍ចំនួន ២២៥០០ កន្លែង ស្មើនឹង ១% នៃចំនួនសិស្សដែលផ្លាស់ចេញពីប្រទេសចំណូលទាប និងប្រទេសចំណូលមធ្យមកម្រិតទាប។

ចាំបាច់ត្រូវមានយន្តការសកល សម្រាប់ពិនិត្យតាមដានការផ្តល់អាហារូបករណ៍ ដើម្បីរាយការណ៍ពីសូចនាករនានា ដូចជា ចំនួនអាហារូបករណ៍ដែលត្រូវបានផ្តល់ ចំនួនឆ្នាំអាហារូបករណ៍ដែលត្រូវបានផ្តល់ ចំនួនអ្នកទទួលបានអាហារូបករណ៍ដែលបញ្ចប់ការសិក្សារបស់ខ្លួន និងចំនួនអ្នកទទួលបានអាហារូបករណ៍ដែលវិលត្រលប់ទៅប្រទេសកំណើតរបស់ពួកគេវិញ។

ទិន្នន័យអំពីការផ្តល់ជំនួយអាចផ្តល់តែព័ត៌មានខ្លះអំពីកម្មវិធីអាហារូបករណ៍ប៉ុណ្ណោះ។ ក្នុងឆ្នាំ ២០១៤ មានការវិភាជន៍ថវិកាជំនួយចំនួន ២,៨ ពាន់លានដុល្លារ សម្រាប់អាហារូបករណ៍ និងបន្ទុកចំណាយរបស់សិស្ស។ ក្នុងថវិកានេះ ៣៨៦ លានដុល្លារ ត្រូវបានផ្តល់ដល់ប្រទេសដែលមានការអភិវឌ្ឍតិចតួច និងរដ្ឋកំពុងអភិវឌ្ឍនៅតាមដែនកោះតូចៗ។




**រូបភាព ១៥៖**

**ពាក់កណ្តាលនៃជំនួយទាំងអស់សម្រាប់អាហារូបករណ៍ និងបន្ទុកចំណាយលើនិស្សិត គឺប្រមូលផ្តុំក្នុងប្រទេសដែលមានចំណូលមធ្យមចំនួន ១៣**

ការបែងចែកអាហារូបករណ៍ និងបន្ទុកចំណាយរបស់សិស្ស បែងចែកតាមប្រទេសទទួលជំនួយ ២០១៤




ប្រភព៖ ការវិភាគរបស់ក្រុមរៀបចំរបាយការណ៍ GEM (២០១៦) ដោយប្រើប្រាស់ទិន្នន័យរបស់ OECD DAC

# គ្រូ

## គោលដៅ ៤.គ

មានការមិនសប្បាយចិត្តដែលគោលដៅ SDG នេះ ចាត់ទុកគ្រូថាជា “មធ្យោបាយអនុវត្ត” ដែលងាយឲ្យគេប៉ាន់ប្រមាណមិនបានដិតដល់ពីការរួមភាគទាននៃវិជ្ជាជីវៈនេះ ដល់ការផ្តល់ការអប់រំប្រកបដោយគុណភាព និងដល់ការបង្កើតបរិយាកាសរៀនសូត្រដែលមានលក្ខណៈអំណោយផល។ ការរៀបចំចំណុចដៅនេះនៅមានចំណុចខ្សោយនៅឡើយ ដោយមានការកំណត់បញ្ហាសំខាន់ៗពាក់ព័ន្ធនឹងគ្រូតិចតួចប៉ុណ្ណោះ។

របាយការណ៍ GEM ផ្តោតការយកចិត្តទុកដាក់លើការពិនិត្យតាមដានការប្តេជ្ញាចិត្តនៅកម្រិតសកល ដូចដែលបានលើកឡើងក្នុងក្របខ័ណ្ឌសកម្មភាពអប់រំ ២០៣០ ដើម្បី “ធានាថា គ្រូ និងអ្នកអប់រំបានទទួលនូវភាពអង់អាច ត្រូវបានជ្រើសរើសក្នុងចំនួនគ្រប់គ្រាន់ ទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ មានសមត្ថភាពវិជ្ជាជីវៈ មានទឹកចិត្តបម្រើការងារ និងទទួលបានការគាំទ្រ។”

## ការផ្គត់ផ្គង់គ្រូដែលមានសមត្ថភាពឲ្យបានគ្រប់គ្រាន់

ការមានសិស្សច្រើនកកកុញក្នុងថ្នាក់រៀន នៅតែជាបញ្ហាដែលកើតឡើង នៅតាមប្រទេសក្រីក្រជាងគេ ដែ លនេះជាសញ្ញាបង្ហាញពីការផ្គត់ផ្គង់គ្រូមិនបានគ្រប់គ្រាន់។មានបញ្ហាប្រឈមធំៗចំនួនពីរនៅពេលកំណត់ពីកង្វះចំនួនគ្រូ។ទីមួយ ស្ថិតិអំពីចំនួនគ្រូជាមធ្យម លាក់កំបាំងព័ត៌មានអំពីវិសមភាពក្នុងប្រទេសមួយ និងទីពីរ ចំនួនគ្រូមិនអាចកាត់ផ្តាច់ចេញពីគុណភាពបានឡើយ។ ជារឿយៗ អ្នកតាក់តែងគោលនយោបាយធ្វើការឆ្លើយតបចំពោះការកើនឡើងនូវចំនួនសិស្សចុះឈ្មោះចូលរៀន និងការកើនឡើងនូវចំនួនសិស្សក្នុងថ្នាក់ ដោយធ្វើការបន្ទាបស្តង់ដាសម្រាប់ជួលគ្រូ។

មានទិន្នន័យតិចតួចបំផុតអំពីអ្វីដែលចំណុចដៅនេះ សំដៅលើការផ្គត់ផ្គង់គ្រូ “ដែលមានសមត្ថភាព” ដែលគេច្រើនយល់ថាផ្តោតលើគុណវឌ្ឍិអប់រំ។ ក្នុងឆ្នាំ ២០១៤ ជាមធ្យម មានគ្រូ ៨២% ដែលមានគុណវឌ្ឍិកម្រិតអប្បបរមា សម្រាប់បង្រៀនថ្នាក់មត្តេយ្យមសិក្សា ៩៣% សម្រាប់កម្រិតបឋមសិក្សា និង ៨៨% សម្រាប់កម្រិតមធ្យមសិក្សា។

សូចនាករសកល សម្រាប់ចំណុចដៅ ៤.គ - ភាគរយគ្រូដែលបានទទួលការបណ្តុះបណ្តាលកម្រិតអប្បបរមា - មានវិសាលភាពគ្របដណ្តប់ទូលំទូលាយ ប៉ុន្តែនៅខ្វះចំណុចដៅ សម្រាប់ប្រៀបធៀបស្តង់ដាជាតិ។ បើទោះបីជាបែបនេះក៏ដោយ មានភស្តុតាងបង្ហាញយ៉ាងច្បាស់ថា មានគ្រូបង្រៀនជាច្រើននាក់ ដែលមិនបានទទួលការបណ្តុះបណ្តាលកម្រិតអប្បបរមា។ នៅប្រទេសការីបៀន មានគ្រូបឋមសិក្សាតែ ៨៥% ប៉ុណ្ណោះ ដែលទទួលបានការ

**រូបភាពទី ១៦៖**

**មានគ្រូមត្តេយ្យសិក្សាជាងពាក់កណ្តាល និងគ្រូមធ្យមសិក្សាមួយភាគបួន នៅអាហ្វ្រិចសាប់សាហារ៉ា ដែលមិនបានទទួលការបណ្តុះបណ្តាល**

ភាគរយគ្រូដែលបានទទួលការបណ្តុះបណ្តាល បែងចែកតាមកម្រិតនៃការអប់រំ និងតំបន់ ២០១៤




ប្រភព៖ មូលដ្ឋានទិន្នន័យ UIS

បណ្តុះបណ្តាល។ នៅអាហ្វ្រិចភាគខាងជើង និងអាស៊ីភាគខាងលិច មានគ្រូមត្តេយ្យ ៧៣% ដែលទទួលបានការបណ្តុះបណ្តាល។ នៅអាហ្វ្រិចសាប់សាហារ៉ា មានគ្រូមត្តេយ្យតិចជាងពាក់កណ្តាល និងគ្រូមធ្យមសិក្សាទុតិយភូមិបីបភាគបួន ដែលទទួលបានការបណ្តុះបណ្តាល។

ពីឆ្នាំ ២០០២ ដល់ ២០១៤ ជំនួយ សម្រាប់ការងារបណ្តុះបណ្តាលគ្រូ មានការកើនឡើងបីដង រហូតដល់ ២៥១ លានដុល្លារ ស្មើនឹង ២% នៃជំនួយសរុបដែលផ្តល់ផ្ទាល់ទៅឲ្យវិស័យអប់រំ។ ប្រទេសដែលមានការអភិវឌ្ឍតិចតួចបានទទួលជំនួយ ៤១% នៃជំនួយសរុបដែលផ្តល់សម្រាប់ការបណ្តុះបណ្តាលគ្រូ ហើយរដ្ឋកំពុងអភិវឌ្ឍតាមដែនកោះបានទទួល ៧%។

## ការលើកទឹកចិត្តគ្រូ និងការគាំទ្រគ្រូ

ការលើកទឹកចិត្ត និងផ្តល់ការគាំទ្រគ្រូ គឺជាបញ្ហាប្រឈមផ្នែកគោលនយោបាយធំមួយ ដែលត្រូវបានឆ្លុះបញ្ចាំង ក្នុងក្របខ័ណ្ឌសកម្មភាពអប់រំ ២០៣០។ ការប្រមូលព័ត៌មានផ្ទាល់ពីគ្រូ ជុំវិញកត្តានានា ដូចជា ការលើកទឹកចិត្ត និងការពេញចិត្តនឹងការងារ គឺជាការងារដ៏ពិបាក។

របាយការណ៍នេះធ្វើការពិនិត្យលើកត្តាខាងក្រៅ ជាពិសេស កត្តាដែលពាក់ព័ន្ធនឹងគោលនយោបាយរបស់រដ្ឋាភិបាល ដូចជា ការណែនាំនិងការបង្ហាត់បង្ហាញ ការបន្តអភិវឌ្ឍវិជ្ជាជីវៈ លក្ខខណ្ឌការងារ និងការផ្តល់បៀវត្សរ៍ជាដើម។ ការអង្កេតអន្តរជាតិលើការបង្រៀននិងរៀនឆ្នាំ ២០១៣ បានរកឃើញថា គ្រូមធ្យមសិក្សាបឋមភូមិប្រមាណជា ២៥% ដែលមានបទពិសោធន៍ក្រោម ៥ ឆ្នាំ បានលើកឡើងថាពួកគេមានអ្នកបង្ហាត់បង្ហាញផ្ទាល់ម្នាក់ ដែលភាគរយនេះថយចុះមក ៦% ក្នុងប្រទេសឈីលី និង ៩% ក្នុងប្រទេសអ៊ីតាលី។

កញ្ចប់បៀវត្សរ៍ដែលមានលក្ខណៈប្រកួតប្រជែង គឺជាសមាសភាគសំខាន់ចាំបាច់ សម្រាប់ជ្រើសរើស និងបណ្តុះបណ្តាលអ្នកដែលមានសមត្ថភាពបំផុត សម្រាប់អាជីពនេះ។ នៅសាធារណរដ្ឋដូមីនិច គ្រូធម្មតាទទួលបានបៀវត្សរ៍ប្រហែលជា ៧០% នៃបៀវត្សរ៍សម្រាប់អាជីពផ្សេងទៀត ប៉ុន្តែនៅប្រទេសអ៊ូហ្គាយវិញ គ្រូទទួលបានបៀវត្សរ៍ច្រើនជាងអាជីពផ្សេងទៀតវិញ។

ជារួម ដំណើរផ្លូវនៅវែងឆ្ងាយទៀត មុនពេលដែលគេអាចប្រមូលទិន្នន័យដែលអាចជឿទុកចិត្តបានអំពីបៀវត្សរ៍ លក្ខខណ្ឌការងារ និងការបាត់បង់គ្រូ។

# ហិរញ្ញវត្ថុ

## គោលដៅ ៤.៥

របៀបវារៈឆ្នាំ២០៣០មានចំណុចដៅចំនួន៣ដែលពាក់ព័ន្ធជាមួយនឹងមធ្យោបាយអនុវត្តប៉ុន្តែពុំមានចំណុចដៅណាមួយលើកឡើងពីការផ្តល់ហិរញ្ញប្បទានដល់សកម្មភាពអប់រំនោះទេ - បើទោះបីជាការពុំមានការផ្តល់ហិរញ្ញប្បទានប្រកបដោយសមធម៌ និងគ្រប់គ្រាន់ គឺជាមូលហេតុសំខាន់មួយ ដែលនាំឲ្យពិភពលោកមិនអាចសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នា ក្នុងឆ្នាំ ២០១៥។

បើទោះបីជាពុំមានចំណុចដៅខាងការផ្តល់ហិរញ្ញប្បទានយ៉ាងណាក៏ដោយ ទិន្នន័យគ្រប់ជ្រុងជ្រោយ និងអាចរកបានជាប្រចាំអំពីការផ្តល់ហិរញ្ញប្បទានដល់ការអប់រំ គឺជាបុរេលក្ខខណ្ឌ សម្រាប់ការរៀបចំផែនការវិស័យអប់រំប្រកបដោយប្រសិទ្ធភាព និងសម្រាប់ពិនិត្យតាមដានការប្តេជ្ញាចិត្តរបស់គ្រប់ដៃគូទាំងអស់ ដើម្បីសម្រេចរបៀបវារៈអប់រំជាសកល។

## គណនីអប់រំជាតិ

ការជជែកវែកញែកអំពីការផ្តល់ហិរញ្ញប្បទានដល់ការអប់រំ កម្រនឹងពិចារណាលើថាតើប្រភពផ្សេងៗនៃចំណាយលើការអប់រំ ដូចជាចំណាយរបស់រដ្ឋាភិបាល ជំនួយពីដៃគូខាងក្រៅ និងចំណាយរបស់គ្រួសារអាចប្រើប្រាស់បញ្ចូលគ្នារបៀបណា និងមានផលប៉ះពាល់ដល់គ្នាទៅវិញទៅមកយ៉ាងដូចម្តេចខ្លះណាស់។ នៅពេលជួបប្រទះនឹងបញ្ហាប្រឈមស្រដៀងគ្នាបែបនេះ វិស័យសុខាភិបាលបានបង្កើតគណនីសុខាភិបាលថ្នាក់ជាតិ ដើម្បីធ្វើការប្រមូល និងវិភាគលើទិន្នន័យចំណាយសម្រាប់វិស័យសុខាភិបាល។

កាលពីពេលថ្មីៗនេះ មានគម្រោងមួយបានអនុវត្តវិធីសាស្ត្រគណនីអប់រំជាតិ ( NEA ) ក្នុងប្រទេសចំនួន ៨។ ឧទាហរណ៍ រដ្ឋាភិបាលប្រទេសនេប៉ាល់ចំណាយ ៣,៥% នៃ GDP លើវិស័យអប់រំ ពោលគឺទាបជាងប្រទេសវៀតណាម ២,៦ ភាគរយចំណុច។ ប៉ុន្តែ នៅពេលដែលគេរាប់បញ្ចូលប្រភពចំណាយពីគ្រួសារ និងប្រភពផ្សេងទៀត លំដាប់លំដោយរវាងប្រទេសទាំងពីរនេះត្រូវបានផ្លាស់ប្តូរ៖ ប្រទេសនេប៉ាល់វិភាជន៍ថវិកាសម្រាប់វិស័យអប់រំច្រើនជាងប្រទេសវៀតណាម ១,៥ ភាគរយចំណុច។

**តារាងទី ៣៖**
**ចំណាយសាធារណៈសម្រាប់វិស័យអប់រំ បែងចែកតាមក្រុមចំណូលតាមតំបន់ និងប្រទេស ឆ្នាំ ២០១៤**

| | ចំណាយសាធារណៈ សម្រាប់វិស័យអប់រំគិតជា % នៃ GDP | ចំនួនប្រទេស ដែលចំណាយ ក្រោម ៤% នៃ GDP | ចំណាយសាធារណៈ សម្រាប់វិស័យ អប់រំគិតជា % នៃ ចំណាយសាធារណៈ | ចំនួនប្រទេស ដែល ចំណាយ ក្រោម ១៥% នៃ ចំណាយសាធារណៈ | ចំនួនប្រទេស ដែល ចំណាយ ក្រោម ៤% នៃ GDP និងក្រោម ១៥% នៃចំណាយ សាធារណៈ |
|---|---|---|---|---|---|
| ពិភពលោក | 4.6 | 51 | 14.2 | 70 | 35 |
| ចំណូលទាប | 3.9 | 13 | 16.7 | 9 | 9 |
| ចំណូលមធ្យមកម្រិតទាប | 4.1 | 13 | 15.6 | 13 | 10 |
| ចំណូលមធ្យមកម្រិតខ្ពស់ | 4.6 | 9 | 15.7 | 11 | 7 |
| ចំណូលមធ្យម | 4.9 | 16 | 11.9 | 37 | 9 |
| តំបន់ខៅខាស៊ុស និងអាស៊ីភាគកណ្តាល | 2.8 | 4 | 12.9 | 3 | 3 |
| អាស៊ីបូព៌ា និងអាស៊ីអាគ្នេយ៍ | 3.9 | 7 | 15.4 | 6 | 4 |
| អឺរ៉ុប និងអាមេរិចខាងជើង | 5.0 | 7 | 12.1 | 31 | 5 |
| អាមេរិចឡាទីន និងការីបៀន | 4.9 | 7 | 16.1 | 6 | 3 |
| អាហ្វ្រិចខាងជើង និងអាស៊ីខាងលិច | ... | 3 | ... | 5 | 3 |
| ប៉ាស៊ីហ្វិច | ... | 2 | ... | 2 | 1 |
| អាស៊ីខាងត្បូង | 3.8 | 5 | 15.3 | 4 | 4 |
| អាហ្វ្រិចសាប់សាហារ៉ា | 4.3 | 16 | 16.6 | 13 | 12 |

ប្រភព៖ រាល់តម្លៃទាំងអស់ដែលបង្ហាញ គឺជាតម្លៃមេដ្យាន
ប្រភព៖ មូលដ្ឋានទិន្នន័យ UIS

## កែលំអទិន្នន័យហិរញ្ញវត្ថុ

ដើម្បីបង្កើតនូវគណនីអប់រំជាតិដែលមានមូលដ្ឋានរឹងមាំ គេចាំបាច់ត្រូវកែលំអព័ត៌មានអំពីលំហូរចំណាយពីរដ្ឋាភិបាល ដៃគូផ្តល់ជំនួយ និងគ្រួសារ។

## ចំណាយសាធារណៈ

ក្របខ័ណ្ឌសកម្មភាពអប់រំ ២០៣០ លើកស្នើនូវចំណុចដៅចំនួនពីរ ដែលជា “ចំណុចយោងដ៏សំខាន់”៖ វិភាជន៍ថវិកាសម្រាប់វិស័យអប់រំយ៉ាងហោចណាស់ពី ៤% ដល់ ៦% និង/ឬវិភាជន៍ថវិកាចំណាយសម្រាប់វិស័យអប់រំយ៉ាងហោចណាស់ពី ១៥% ដល់ ២០%។ ក្នុងសកលលោកទាំងមូល ប្រទេសនានាចំណាយ ៤,៧% នៃ GDP លើការអប់រំ និងវិភាជន៍ថវិកា ១៤,២% នៃចំណាយសាធារណៈសម្រាប់វិស័យអប់រំ។ ប្រទេសចំនួន ៣៥ ចំណាយតិចជាង ៤% នៃ GDP និងវិភាជន៍ថវិកាក្រោម ១៥% នៃចំណាយសាធារណៈសម្រាប់វិស័យអប់រំ។

**រូបភាពទី ១៧៖**
**ជំនួយដល់វិស័យអប់រំ នៅមិនទាន់បានត្រលប់មករកកម្រិត ២០១០ វិញឡើយ**
ការផ្តល់ជំនួយសរុប សម្រាប់វិស័យអប់រំ ២០០២-២០១៤




ប្រភព៖ ការវិភាគរបស់ក្រុមរៀបចំរបាយការណ៍ GEM ផ្អែកតាមព័ត៌មានក្នុងមូលដ្ឋានទិន្នន័យ OECD CRS

ការវិភាគលើសូចនាករសំខាន់ៗអំពីការផ្តល់ហិរញ្ញប្បទានដល់ការអប់រំសាធារណៈ បានរកឃើញការផ្តល់ព័ត៌មានមិនទៀងទាត់។ មានប្រទេសតែ ៦០% ប៉ុណ្ណោះ ដែលមានទិន្នន័យស្តីពីការចំណាយសរុបសម្រាប់វិស័យអប់រំ គិតជាភាគរយនៃ GDP សម្រាប់ឆ្នាំណាមួយចាប់ពីឆ្នាំ ២០០០ មក។ ដើម្បីធានាឲ្យមានទិន្នន័យល្អប្រសើរអំពីចំណាយសម្រាប់ការអប់រំ ការគ្រប់គ្រងចំណាយសាធារណៈឲ្យបានល្អនៅថ្នាក់ជាតិ មានសារៈសំខាន់យ៉ាងខ្លាំង។

ការពិនិត្យឡើងវិញលើចំណាយសាធារណៈ ត្រូវពង្រីកវិសាលភាព ដើម្បីគ្របដណ្តប់លើបញ្ហាសមធម៌ និងរបៀបដែលចំណាយសាធារណៈត្រូវបានប្រើប្រាស់ សម្រាប់គាំទ្រដល់ក្រុមជួបការលំបាក។ គេអាចធ្វើការប្រៀបធៀបរវាងប្រទេសមួយ និងប្រទេសមួយទៀតបាន ប៉ុន្តែទាមទារឲ្យមានការខិតខំប្រឹងប្រែងច្រើន ដើម្បីដាក់ឲ្យអនុវត្តនូវដំណើរការ ស្វែងរកការឯកភាពគ្នាលើក្របខ័ណ្ឌរួម និងចុះធ្វើការវាយតម្លៃជាក់ស្តែង។ ដើម្បីឲ្យប្រទេសនានាអាចចូលរួមធ្វើការងារនេះ គួរមានការផ្តោតការយកចិត្តទុកដាក់លើការបង្កើតនូវយន្តការពិនិត្យផ្ទៀងផ្ទាត់គ្នាទៅវិញទៅមក ដើម្បីឲ្យគេអាចរៀនសូត្រពីគ្នាទៅវិញទៅមក។

## ចំណាយដែលបានហិរញ្ញប្បទានពីថវិកាជំនួយ

ជំនួយចាំបាច់ត្រូវកើតនឡើងយ៉ាងហោចណាស់៦ដង ទើបអាចបំពេញគម្លាតហិរញ្ញប្បទានប្រចាំឆ្នាំចំនួន ៣៩ ពាន់លានដុល្លារបាន ប៉ុន្តែក្នុងឆ្នាំ ២០១៤ កម្រិតនៃថវិកាជំនួយគឺទាបជាងកម្រិតកំពូលក្នុងឆ្នាំ ២០១០ ចំនួន ៧%។ គេអាចបំពេញគម្លាតនេះបាន ប្រសិនបើអ្នកផ្តល់ជំនួយប្តេជ្ញាវិភាជន៍ថវិកា ០,៧% នៃចំណូលសរុបរបស់ជាតិ (GNI) សម្រាប់ផ្តល់ជំនួយ និងវិភាជន៍ ១០% នៃជំនួយ សម្រាប់ការ

អប់រំកម្រិតមូលដ្ឋាននិងកម្រិតមធ្យមសិក្សា។ចាប់តាំងពីឆ្នាំ២០០៥មកលំហូរជំនួយសរុបមានការឡើងចុះក្នុងរង្វង់ប្រមាណជា ០,៣% នៃចំណូលជាតិរបស់ប្រទេសផ្តល់ជំនួយ។

ប្រទេសក្រីក្រគួរតែជាប្រទេសអាទិភាព ដើម្បីទទួលជំនួយ ប៉ុន្តែប្រទេសដែលមានចំណូលទាប បានទទួលជំនួយត្រឹមតែ ២៨% នៃជំនួយសរុបសម្រាប់ការអប់រំកម្រិតមូលដ្ឋានប៉ុណ្ណោះ ក្នុងឆ្នាំ ២០១៤ ខណៈពេលដែលក្នុងប្រទេសទាំងនេះមានកុមារ ៤៣% ដែលមិនបានបញ្ចប់ការអប់រំកម្រិតបឋមសិក្សា។

គេក៏ចាំបាច់ត្រូវធ្វើការតាមដានកម្រិតនៃជំនួយមនុស្សធម៌ផងដែរ។ ក្នុងឆ្នាំ ២០១៥ វិស័យអប់រំទទួលបានជំនួយប្រមាណជា ១៩៨ លានដុល្លារ ឬក្រោម ១,៩% នៃជំនួយមនុស្សធម៌សរុប។

## ចំណាយគ្រួសារ

ភាគរយនៃចំណាយរបស់គ្រួសារ លើចំណាយសរុបសម្រាប់វិស័យអប់រំ ក្នុងប្រទេសក្រីក្រ ច្រើនមានកម្រិតខ្ពស់ជាងប្រទេសអ្នកមាន។ ការកាត់បន្ថយភាគរយនៃ គឺជាគន្លឹះ សម្រាប់បំពេញទៅតាមចំណុចដៅថ្មីនៃវិស័យអប់រំ ដែលផ្តោតការយកចិត្តទុកដាក់លើសមធម៌។ គេអាចរកបានព័ត៌មានអំពីចំណាយគ្រួសារ នៅតាមប្រទេសភាគច្រើន។ ការវិភាគ ដែលធ្វើឡើងសម្រាប់របាយការណ៍ GEM នេះ បានបង្ហាញថា មានប្រទេសដែលមានចំណូលទាប និងមធ្យមយ៉ាងហោចណាស់ ៩៩ បានដាក់បញ្ចូលសំណួរពាក់ព័ន្ធ ទៅក្នុងការអង្កេតអំពីចំណាយនៅថ្នាក់ជាតិ ចន្លោះពីឆ្នាំ ២០០៨ ដល់ ២០១៤។ ប្រទេសចំនួន ៦៧ បានដាក់បញ្ចូលសំណួរអំពីខ្ទង់ចំណាយនៅកម្រិតបុគ្គល។ ប៉ុន្តែ ទិន្នន័យទាំងនេះកម្រិតនឹងត្រូវបានគេយកមកប្រើប្រាស់ណាស់។ អ្នកតាក់តែងគោលនយោបាយអាចមិនដឹងថាមានទិន្នន័យបែបនេះ និងសារៈសំខាន់នៃទិន្នន័យនេះ ឬសមត្ថភាពរបស់ពួកគេក្នុងការវិភាគ និងទាញសេចក្តីសន្និដ្ឋានពាក់ព័ន្ធពីទិន្នន័យទាំងនេះ នៅមានកម្រិត។

# ប្រព័ន្ធអប់រំ

> “ខណៈពេលដែលគេចង់បានក្របខ័ណ្ឌសកល សម្រាប់ពិនិត្យឡើងវិញលើប្រព័ន្ធ និងគោលនយោបាយអប់រំ ក្នុងការអនុវត្តជាក់ស្តែង អភិក្រមនៅថ្នាក់តំបន់ ឬអនុតំបន់ ងាយស្រួលអនុវត្តជាង។”

គេត្រូវការសូចនាករបែបគុណវិស័យនៃប្រព័ន្ធ និងគោលនយោបាយអប់រំ ដែលត្រូវបានផ្ទៀងផ្ទាត់រួចរាល់ជាច្រើន ដើម្បីគាំទ្រដល់ការពិនិត្យតាមដានរបៀបវារៈអប់រំ ២០៣០ នេះ។ ខណៈពេលដែលគេចង់បានក្របខ័ណ្ឌសកល សម្រាប់ពិនិត្យឡើងវិញលើប្រព័ន្ធ និងគោលនយោបាយអប់រំ ក្នុងការអនុវត្តជាក់ស្តែង អភិក្រមនៅថ្នាក់តំបន់ ឬអនុតំបន់ ងាយស្រួលអនុវត្តជាង។

## ឧបករណ៍សកល សម្រាប់ពិនិត្យតាមដានប្រព័ន្ធអប់រំ

ក្នុងឆ្នាំ ១៩៩៦ ការិយាល័យអប់រំអន្តរជាតិ (IBE) របស់យូណេស្កូ បានបង្កើតនូវកម្រងទិន្នន័យអប់រំពិភពលោក (World Data on Education series)។ ទិន្នន័យនេះ គឺជាប្រភពព័ត៌មានដ៏មានតម្លៃអំពីប្រព័ន្ធអប់រំ នៅកម្រិតសកលលោក ប៉ុន្តែដោយសារតែបញ្ហាធនធាន ការបង្កើតទិន្នន័យនេះត្រូវផ្អាកទៅវិញ ហើយគេមិនទាន់មានផែនការ ដើម្បីធ្វើបច្ចុប្បន្នភាពកម្រងទិន្នន័យនេះ ដែលត្រូវបានគេផ្សព្វផ្សាយចុងក្រោយក្នុងឆ្នាំ ២០១១ ឡើយ។

ទោះជាយ៉ាងណាក៏ដោយ យូណេស្កូមានមូលដ្ឋានទិន្នន័យកម្រិតសកលផ្សេងទៀត អំពីប្រព័ន្ធអប់រំ ដែលពាក់ព័ន្ធជាមួយនឹងប្រព័ន្ធអប់រំ ឬប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ដែលតម្រូវដោយច្បាប់ និងដែលផ្តល់ដោយមិនគិតថ្លៃ។

ការពិនិត្យស៊ីជម្រៅបន្ថែមទៀតលើគោលនយោបាយ អាចធ្វើឡើងដោយប្រើប្រាស់ប្រព័ន្ធសម្រាប់លទ្ធផលអប់រំកាន់តែប្រសើរ (SABER) របស់ធនាគារពិភពលោកដែលត្រូវបានប្រកាសដាក់ឲ្យអនុវត្តក្នុងឆ្នាំ២០១១។ប្រព័ន្ធនេះពិនិត្យលើទិដ្ឋភាពចំនួន១៣នៃប្រព័ន្ធអប់រំជាតិ។ ដើម្បីប្រើប្រាស់ប្រព័ន្ធនេះជាឧបករណ៍សម្រាប់ធ្វើការពិនិត្យតាមដាននៅកម្រិតសកល មានបញ្ហាយ៉ាងហោចណាស់ចំនួន ២ ដែលគេចាំបាច់ត្រូវដោះស្រាយ៖ ការឯកភាពគ្នាលើវិសាលភាព ការគ្របដណ្តប់ និងភាពទៀងទាត់នៃការពិនិត្យឡើងវិញ និងការបង្កើនភាពជាម្ចាស់របស់ប្រទេស។

## ឧបករណ៍ថ្នាក់តំបន់ សម្រាប់ពិនិត្យតាមដានប្រព័ន្ធអប់រំ

ការពិនិត្យតាមដានអាចធ្វើបានល្អបំផុត នៅថ្នាក់តំបន់ជាជាងនៅថ្នាក់សកល។ សមាជិករបស់អង្គការថ្នាក់តំបន់ ច្រើនធ្វើការផ្លោះប្តូរព័ត៌មានអំពីប្រព័ន្ធអប់រំរបស់ពួកគេដោយស្ម័គ្រចិត្ត។ មានឧទាហរណ៍លេចធ្លោរចំនួន ៣។ បណ្តាញ Eurydice អំពីប្រព័ន្ធ និងគោលនយោបាយអប់រំនៅអឺរ៉ុប ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៨០ បានពង្រីកខ្លួនក្លាយជាបណ្តាញនៃអង្គការជាតិចំនួន ៤០ ក្នុងប្រទេសចំនួន ៣៦។ កម្មវិធីសូចនាករនៃប្រព័ន្ធអប់រំ (INES) របស់ OECD ត្រូវបានដាក់ឲ្យអនុវត្តក្នុងឆ្នាំ ១៩៩២។ ក្នុងឆ្នាំ ២០០៩ បណ្តាញមួយក្នុងចំណោមបណ្តាញទាំង ៣ នៃកម្មវិធីនេះ បានក្លាយខ្លួនជាបណ្តាញ INES សម្រាប់សូចនាករកម្រិតប្រព័ន្ធ (ដែលហៅថា NESLI)។ អង្គការនៃរដ្ឋអាយប៊ើរ៉ូអាមេរិច (Organization of Ibero-American States) មានយុទ្ធសាស្ត្រអប់រំមួយ និងអង្គភាពឯកទេសមួយ ដែលមានតួនាទីធ្វើការពិនិត្យឡើងវិញលើសូចនាករ ដែលសូចនាករមួយចំនួន គឺជាសូចនាករពាក់ព័ន្ធនឹងប្រព័ន្ធ។

របាយការណ៍ GEM នេះ បានលើកជាទល្លីករណ៍ឲ្យមានការពិនិត្យតាមដានសូចនាករប្រព័ន្ធអប់រំ ដើម្បីសម្របសម្រួលកិច្ចពិគ្រោះយោបល់ និងលើកទឹកចិត្តរដ្ឋាភិបាលឲ្យរៀនសូត្រពីគ្នាទៅវិញទៅមក នៅថ្នាក់តំបន់។

# ការអប់រំ ក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពផ្សេងទៀត

របៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ ២០៣០ មិនត្រឹមតែទទួលស្គាល់ពីសារៈសំខាន់នៃការមានគោលដៅអប់រំដោយឡែកប៉ុណ្ណោះទេ ថែមទាំងភាពចាំបាច់ ដើម្បីសម្រេចគោលដៅផ្សេងទៀត តាមរយៈការអប់រំផងដែរ។ ក្នុងចំណោមគោលដៅ SDGs ផ្សេងទៀត ក្រៅពីគោលដៅ SDG ទី ៤ ក៏មានសូចនាករ ដែលលើកឡើងពីការអប់រំដោយផ្ទាល់ និងដោយប្រយោលផងដែរ។

“ការអប់រំត្រូវបានលើកឡើងផ្ទាល់ក្នុងសូចនាករសកល សម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពចំនួន ៥ ក្រៅពីគោលដៅ SDG ទី ៕”

## ការលើកឡើងផ្ទាល់ពីការអប់រំ

ការអប់រំត្រូវបានលើកឡើងផ្ទាល់ក្នុងសូចនាករសកលចំនួន ៥ ខាងក្រៅគោលដៅ SDG ទី ៤ ដូចជា សូចនាករស្តីពីការចំណាយរបស់រដ្ឋាភិបាលលើវិស័យអប់រំកិច្ចគាំពារសុខភាព និងសង្គម, សូចនាករស្តីពីការប្រើប្រាស់វិស័យអប់រំ ជាមធ្យោបាយដើម្បីសម្រេចសមភាពយេនឌ័រ, សូចនាករស្តីពីយុវជនដែលពុំស្ថិតក្នុងប្រព័ន្ធអប់រំ ពុំមានការងារធ្វើ ឬពុំកំពុងទទួលបានការបណ្តុះបណ្តាល និងសូចនាករស្តីពីការអប់រំភាពជាពលរដ្ឋសកល និងការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។

## ការលើកឡើងដោយប្រយោលពីការអប់រំ

បន្ថែមពីលើសូចនាករពិនិត្យតាមដាន ដែលលើកឡើងជាក់លាក់ពីការអប់រំ របាយការណ៍ GEM នាពេលអនាគត នឹងផ្តោតការយកចិត្តទុកដាក់លើការលើកឡើងដោយប្រយោលពីការអប់រំក្នុងគោលដៅ SDGs ផ្សេងទៀត។ ឧទាហរណ៍ចំនួន ៣ ត្រូវបានលើកឡើង៖ សូចនាករដែលចាត់ទុកការអប់រំ គឺជាកត្តា ដែលពាក់ព័ន្ធជាមួយនឹងលទ្ធផលនៃការអភិវឌ្ឍផ្សេងទៀត។ សូចនាករ ដែលលើកឡើងពីសមត្ថភាពធនធានមនុស្ស ពាក់ព័ន្ធជាមួយនឹងការអប់រំវិជ្ជាជីវៈ និងការអប់រំកម្រិតឧត្តមសិក្សា និងសូចនាករស្តីពីតួនាទីជាសក្តានុពលនៃការអប់រំមនុស្សពេញវ័យ។

ការបែងចែកសូចនាករកម្រិតសកលដែលពាក់ព័ន្ធទាំងនេះ ទៅតាមកម្រិតនៃការអប់រំ នឹងផ្តល់ពន្លឺបន្ថែមទៀតអំពីបញ្ហាវិសមភាពដែលរារាំងមិនឲ្យមានការសម្រេចចំណុចដៅនៃគោលដៅ SDG។ សូចនាករសកល ដែលគេអាចពិនិត្យតាមដានតាមរបៀបនេះ រួមមានសូចនាករពាក់ព័ន្ធនឹងភាពក្រីក្រ បញ្ហាកង្វះអាហារូបត្ថម្ភ ការរៀបអាពាហ៍ពិពាហ៍របស់កុមារ ការទទួលបានសេវាអនាម័យដែលត្រូវបានកែលំអ ការមានអគ្គិសនីប្រើប្រាស់ប្រាស់ ភាពគ្មានការងារធ្វើ ប្រជាពលរដ្ឋដែលរស់នៅតំបន់ក្រីក្រ ការកែច្នៃសំរាមឡើងវិញករណីស្លាប់ដោយសារគ្រោះមហន្តរាយ អំពើហិង្សា និងការចុះសំបុត្រកំណើត។ ឧទាហរណ៍ ក្នុងប្រទេសដែលមានចំណូលទាប និងមធ្យមចំនួន ៥៤ ដែលមានទិន្នន័យ ពីឆ្នាំ ២០០៨ ដល់ ២០១៥ ចំនួនកំណើតជាមធ្យមក្នុងស្ត្រី ១០០០ នាក់ គឺ ១៧៦ កំណើត សម្រាប់ស្ត្រីដែលពុំបានទទួលការអប់រំ ១៤២ កំណើត សម្រាប់ស្ត្រីដែលទទួលបានការអប់រំកម្រិតបឋមសិក្សា ៦១ កំណើត សម្រាប់ស្ត្រីដែលទទួលបានការអប់រំកម្រិតមធ្យមសិក្សា និង ១៣ កំណើត សម្រាប់ស្ត្រី ដែលទទួលបានការអប់រំកម្រិតឧត្តមសិក្សា។

**រូបភាពទី ១៨៖**

**ការអប់រំមានទំនាក់ទំនងជាវិជ្ជមានជាមួយនឹងលទ្ធផលនៃការអភិវឌ្ឍដែលគេចង់បាន**

អត្រាកំណើតរបស់ក្មេងជំទង់ (ចំនួនកំណើតក្នុងចំណោមស្ត្រី ១០០០ នាក់ អាយុពី ១៥ ដល់ ១៩ ឆ្នាំ) ១៩៩៧ ដល់ ២០១៤




ប្រភព៖ ប្រព័ន្ធទិន្នន័យ STATcompiler សម្រាប់ការអង្កេតប្រជាសាស្ត្រ និងសុខភាព (២០១៦)

# អាទិភាពសម្រាប់ពិនិត្យតាមដានការអប់រំ ក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

ការពិនិត្យឡើងវិញលើបញ្ហាប្រឈមជុំវិញការពិនិត្យតាមដានចំណុចដៅនីមួយនៃគោលដៅ SDG ទី ៤ បង្ហាញឲ្យឃើញពីអាទិភាពដែលតម្រូវឲ្យមានការអនុវត្តសកម្មភាពនៅថ្នាក់ជាតិ តំបន់ និងសកល។ សកម្មភាពទាំងនេះមានគោលបំណងធានាយ៉ាងណាឲ្យមានព័ត៌មានគ្រប់គ្រាន់ ដែលគេអាចយកមកធ្វើការប្រៀបធៀបគ្នាបាន ដើម្បីបំផុសឲ្យមានការពិគ្រោះយោបល់គ្នាជាសកលអំពីវឌ្ឍនភាព ក្នុងការឈានទៅសម្រេចគោលដៅ SDG ទី ៤។ ការធ្វើបែបនេះមិនប៉ះពាល់ដល់ការពិនិត្យតាមដានរបស់ប្រទេសនីមួយៗលើវឌ្ឍនភាពដែលប្រទេសទាំងនោះសម្រេចបានក្នុងវិស័យអប់រំ ដែលផ្តោតការយកចិត្តទុកដាក់លើបរិបទជាតិ និងតម្រូវការជាក់លាក់តាមប្រទេសរៀងៗខ្លួននោះទេ។

ក្របខ័ណ្ឌពិនិត្យតាមដានដែលត្រូវបានស្នើឡើងនេះគឺជាវេទិកាមួយ សម្រាប់ឲ្យស្ថាប័នជាតិ និងអន្តរជាតិនានាធ្វើការផ្លាស់ប្តូរព័ត៌មានរវាងគ្នាអំពីបញ្ហាប្រឈមជុំវិញការវាស់វែងវឌ្ឍនភាពដែលសម្រេចបាន។ ក្រុមសហប្រតិបត្តិការបច្ចេកទេសដែលទើបតែនឹងបង្កើតឡើងកាលពីពេលថ្មីៗនេះ ដែលមានតំណាងពីតាមប្រទេសនានាចូលរួម នឹងធ្វើការកែលំអក្របខ័ណ្ឌនេះបន្ថែមទៀត ក៏ដូចជាជួយអនុវត្តក្របខ័ណ្ឌនេះ ក្នុងគោលបំណងជម្រុញឲ្យមានកិច្ចពិគ្រោះយោបល់ជាអន្តរជាតិអំពីការពិនិត្យតាមដានការអប់រំ។

### នៅថ្នាក់ជាតិ៖ កសាងសមត្ថភាពក្នុងវិស័យសំខាន់ៗចំនួន ៦

មានជំហានសំខាន់ៗចំនួន ៦ ត្រូវបានស្នើឡើង ដើម្បីឲ្យប្រទេសនានាអាចសម្រេចនូវវឌ្ឍនភាពឲ្យបានច្រើន ក្នុងរយៈពេលពី ៣ ទៅ ៥ ឆ្នាំទៀត ក្នុងការពង្រឹងការពិនិត្យតាមដាននៅថ្នាក់ជាតិ ហើយក្នុងពេលជាមួយគ្នា អាចរួមចំណែកដល់ការពិនិត្យតាមដានជាសកលលើការអប់រំ។

**សមធម៌** - ចាំបាច់ត្រូវមានកិច្ចសហប្រតិបត្តិការរវាងក្រសួងអប់រំ និងស្ថាប័នស្ថិតិជាតិ ដើម្បីរកឲ្យឃើញនូវគម្លាតរវាងស្ថាប័នទាំងនេះ និងផ្តល់លទ្ធភាពឲ្យមានការប្រើប្រាស់ទិន្នន័យពីច្រើនប្រភព។

**លទ្ធផលនៃការរៀនសូត្រ** - ប្រទេសទាំងឡាយ ចាំបាច់ត្រូវធានាឲ្យមានការវាយតម្លៃការរៀនសូត្រនៅថ្នាក់ជាតិដែលមានលក្ខណៈរឹងមាំ ដោយប្រើប្រាស់សំណាកគំរូជាគោល ដែលគេអាចយកទៅប្រើប្រាស់ សម្រាប់ពិនិត្យតាមដានវឌ្ឍនភាពជុំវិញការរៀនសូត្រក្នុងរយៈពេលមួយបាន។

**គុណភាព** - ប្រទេសទាំងឡាយចាំបាច់ត្រូវពិនិត្យតាមដានកម្មវិធីសិក្សា សៀវភៅសិក្សា និងកម្មវិធីអប់រំគ្រូឲ្យបានល្អិតល្អន់ ដើម្បីធានាឲ្យមានការប្តេជ្ញាចិត្តឲ្យបានគ្រប់គ្រាន់ ដើម្បីសម្រេចគោលបំណង ដែលបានដាក់ចេញក្នុងចំណុចដៅ ៤.៧។

**ការរៀនសូត្រពេញមួយជីវិត** - ប្រទេសទាំងឡាយចាំបាច់ត្រូវពិនិត្យតាមដានតម្រូវការនៃការអប់រំ ឱកាសទទួលបានការអប់រំ និងលទ្ធផលដែលសម្រេចបានរបស់មនុស្សពេញវ័យរបស់ខ្លួន ដែលជាអ្នកដែលត្រូវធ្វើការសម្រេចចិត្តពាក់ព័ន្ធនឹងការអភិវឌ្ឍប្រកបដោយចីរភាព។

**ប្រព័ន្ធ** - អង្គការនៅថ្នាក់តំបន់ផ្តល់ឲ្យប្រទេសនានានូវវេទិកា សម្រាប់ធ្វើការផ្លាស់ប្តូរព័ត៌មានអំពីលក្ខណៈនៃប្រព័ន្ធអប់រំរបស់ពួកគេ ក៏ដូចជារៀនសូត្រពីគ្នាទៅវិញទៅមក។

**ហិរញ្ញប្បទាន** - ប្រទេសទាំងឡាយត្រូវបានលើកទឹកចិត្តឲ្យប្រើប្រាស់អភិក្រមគណនីអប់រំជាតិ ដើម្បីស្វែងយល់ឲ្យបានកាន់តែប្រសើរពីរបៀបចែករំលែកចំណាយសម្រាប់ការអប់រំរវាងរដ្ឋាភិបាល អ្នកផ្តល់ជំនួយ និងគ្រួសារ។

### នៅកម្រិតតំបន់៖ គាំទ្រដល់ការរៀនសូត្រពីគ្នាទៅវិញទៅមក

តាមរយៈការប្រើប្រាស់បណ្តាញនៅថ្នាក់តំបន់ ជាយន្តការរៀនសូត្រពីគ្នាទៅវិញទៅមក ប្រទេសនានាអាចធ្វើការផ្លាស់ប្តូរព័ត៌មានរវាងគ្នានឹងគ្នា ដូចជា អំពីគោលបំណង និងគោលនយោបាយ ដែលប្រទេសទាំងនេះត្រូវអនុវត្ត ដើម្បីដោះស្រាយបញ្ហារបស់ក្រុមជួបការលំបាកក្នុងវិស័យអប់រំ និងវិសាលភាព ដែលប្រទេសទាំងនេះប្រើប្រាស់ការអប់រំ ដើម្បីសម្រេចគោលដៅនៃការអភិវឌ្ឍប្រកបដោយចីរភាព និងការអប់រំភាពជាពលរដ្ឋសកល។

### នៅថ្នាក់តំបន់៖ ជម្រុញឲ្យមានការឯកភាពគ្នាជារួម និងការសម្របសម្រួលគ្នា

ជំហានចំនួន ៣ ត្រូវបានលើកស្នើឡើង ដើម្បីសម្របសម្រួលការប្រើប្រាស់ឧបករណ៍វាស់វែង និងការស្រាវជ្រាវអំពីបញ្ហានៅកម្រិតសកល។ ចាំបាច់ត្រូវមានកម្មវិធីអង្កេតតាមគ្រួសារកម្រិតអន្តរជាតិ ដែលផ្តោតជាពិសេសលើការអប់រំ ដើម្បីបំពេញភាពខ្វះចន្លោះធំៗជាច្រើន។ អភិក្រមសម្រាប់ពិនិត្យតាមដានលទ្ធផលនៃការរៀនសូត្រដែលមានលក្ខណៈស៊ីសង្វាក់គ្នា ក៏ចាំបាច់ត្រូវមានផងដែរ ដោយត្រូវដាក់បញ្ចូលផងដែរនូវក្រមសីលធម៌របស់អ្នកផ្តល់ជំនួយ ដើម្បីបញ្ចៀសមិនឲ្យមានការធ្វើការងារត្រួតគ្នា។ ការបង្កើតនូវបណ្តាញស្រាវជ្រាវដែលផ្តោតលើការវាស់វែងការអប់រំនៅកម្រិតសកល ក៏ជាអ្វីដែលត្រូវបានលើកឡើងជាអនុសាសន៍ផងដែរ ដោយត្រូវមានការផ្តោតការយកចិត្តទុកដាក់ពិសេស លើការកសាងនូវការឯកភាពគ្នាជុំវិញលទ្ធផលអប់រំសំខាន់ៗ។

នៅពេលដែលទិន្នន័យនៃវិស័យអប់រំមានការប្រែប្រួល ចាំបាច់ត្រូវមានការឯកភាពគ្នាលើទស្សនទានជាមូលដ្ឋាន ការវិនិយោគលើប្រព័ន្ធដែលរឹងមាំ និងការសម្របសម្រួល ដើម្បីធានាឲ្យមានភាពងាយស្រួលក្នុងការប្រើប្រាស់ទិន្នន័យដោយចំហ និងប្រកបដោយគណនេយ្យភាព។



ធ្នើរដាក់ស្បែកជើងក្នុងសាលារៀនមួយ
នៅតំបន់ Chittagong ប្រទេសបង់ក្លាដេស
ដែលបង្ហាញពីចំនួនកុមារដែលមករៀន
នៅថ្ងៃនោះ។

រូបថត៖ Ripon Barua/UNESCO





# ការអប់រំសម្រាប់មនុស្ស និងផែនដី៖

## បង្កើតនូវអនាគតប្រកបដោយចីរភាព សម្រាប់ទាំងអស់គ្នា

**របាយការណ៍ក្រោមប្រធានបទ ការអប់រំសម្រាប់មនុស្ស និងផែនដី៖** បង្កើតនូវអនាគតប្រកបដោយចីរភាព សម្រាប់ទាំងអស់គ្នា នេះ ធ្វើការពិនិត្យលើទំនាក់ទំនងដ៏ស្មុគស្មាញរវាងការអប់រំ និងរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ ២០៣០ ថ្មី ដែលគ្របដណ្តប់លើសសរស្តម្ភជាមូលដ្ឋានចំនួន៦គឺភពផែនដីវិបុលភាពមនុស្សសន្តិភាពទីកន្លែងនិងភាពជាដៃគូ។របាយការណ៍នេះក៏បង្ហាញផងដែរថា ការអប់រំនឹងមិនសម្រេចសក្តានុពលពេញលេញរបស់ខ្លួនឡើយ លុះត្រាតែអត្រានៃការចូលរួមទទួលបានការអប់រំមានការកើនឡើងខ្លាំងក្នុងរយៈពេលមួយខ្លី ហើយការអភិវឌ្ឍប្រកបដោយចីរភាព ប្រើប្រាស់ជាត្រីវិស័យ សម្រាប់តម្រង់ទិសកំណែទម្រង់ប្រព័ន្ធអប់រំទាំងមូល។ របាយការណ៍នេះក៏ព្រមាននៃផលប៉ះពាល់ជាអវិជ្ជមានដែលការប្រែប្រួលអាកាសធាតុជម្លោះការប្រើប្រាស់ដែលគ្មាននិរន្តរភាពនិងការកើនឡើងនូវគម្លាតរវាងអ្នកមាននិងអ្នកក្រ មានមកលើការអប់រំផងដែរ។ ចាំបាច់ត្រូវតែមានការផ្លាស់ប្តូរក្នុងទ្រង់ទ្រាយធំ ប្រសិនបើយើងចង់បង្កើតនូវអនាគតប្រកបដោយចីរភាព សម្រាប់ទាំងអស់គ្នា។

របាយការណ៍សង្ខេបនៃរបាយការណ៍ពិនិត្យតាមដានការអប់រំទូទាំងសកលលោក (ដែលហៅកាត់ថារបាយការណ៍GEM) នេះគឺជារបាយការណ៍ដំបូងក្នុងចំណោមរបាយការណ៍ដែលនឹងត្រូវរៀបចំឡើងជាបន្តបន្ទាប់ដើម្បីវាយតម្លៃលើវឌ្ឍនភាពដែលសម្រេចបានក្នុងវិស័យអប់រំក្រោមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពថ្មី។របាយការណ៍GEMនេះផ្តល់នូវអនុសាសន៍ផ្អែកលើភស្តុតាងជាក់ស្តែងអំពីគោលនយោបាយ យុទ្ធសាស្ត្រនិងកម្មវិធីដែលចាំបាច់ត្រូវមានដើម្បីបំពេញទៅតាមចក្ខុវិស័យអប់រំ ២០៣០ ប្រកបដោយមហិច្ឆតា។របាយការណ៍នេះធ្វើការពិភាក្សាពីបញ្ហាប្រឈមក្នុង ការពិនិត្យតាមដានវឌ្ឍនភាពក្នុងការសម្រេចគោលដៅអប់រំសកល និងចំណុចដៅថ្មីៗដើម្បីធានាឲ្យមានការបង្កើនលទ្ធភាពទទួលបានការអប់រំការចូលរួមការបញ្ចប់ការសិក្សា ការរៀនសូត្រ និងការកាត់បន្ថយវិសមភាព។ របាយការណ៍នេះផ្តល់ឲ្យអ្នកអាននូវប្រភពព័ត៌មានដ៏សំខាន់ សម្រាប់លើកឡើងពីគុណតម្លៃ និងសារៈសំខាន់នៃការអប់រំ នៅគ្រប់កម្រិតទាំងអស់នៃការធ្វើសេចក្តីសម្រេចចិត្ត។

របាយការណ៍GEMគឺជាឯកសារបោះពុម្ពផ្សាយដែលមានលក្ខណៈឯករាជ្យដោយប្រើប្រាស់ភស្តុតាងជាគោល សម្រាប់ជាឧបករណ៍ដែលចាំបាច់ ដើម្បីជម្រុញឲ្យមានការពិគ្រោះយោបល់ផ្អែកតាមព័ត៌មានជាក់ស្តែង និងបង្កើនការយល់ដឹងអំពីវឌ្ឍនភាពដែលសម្រេចបាន និងបញ្ហាប្រឈមក្នុងវិស័យអប់រំ។ របាយការណ៍នេះបានធ្វើការវាយតម្លៃលើវឌ្ឍនភាព ដែលសម្រេចបានក្នុងវិស័យអប់រំ ក្នុងប្រមាណជា ២០០ ប្រទេស និងដែនដី ចាប់តាំងពីឆ្នាំ ២០០២ មក។ ដោយប្រើប្រាស់បទពិសោធន៍ទាំងនេះ ក៏ដូចជាតួនាទីភារកិច្ចថ្មីដើម្បីពិនិត្យតាមដានវឌ្ឍនភាពខាងការអប់រំក្នុងគោលដៅ SDG របាយការណ៍ GEM គឺជាធនធានសកលដ៏សំខាន់ សម្រាប់ធ្វើការតាមដានបន្ត និងពិនិត្យឡើងវិញលើដំណើរការនេះ ក្នុងរយៈពេល ១៥ ឆ្នាំបន្ទាប់។



Global Education Monitoring Report

United Nations Educational, Scientific and Cultural Organization

Sustainable Development Goals

4 QUALITY EDUCATION

Sustainable Development Goals